ទស្សនាវដ្ដី

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Review

## Revue de l’Académie Royale du Cambodge

លេខ ៤ ខែ ធ្នូ ឆ្នាំ ២០១២ | Issue 4 December 2012



ជនជាតិភាគតិចនៅភូមិភាគឦសាន

## នាយកការផ្សាយ

បណ្ឌិតសភាចារ្យ ជា លេខ

## និពន្ធនាយក

បណ្ឌិត អ៊ុំ បុណ្ណា

## លេខាធិការ

បណ្ឌិត ជូ ច័ន្ទដារី

បណ្ឌិត ធុយ ចាន់ធួន

បណ្ឌិត សុខ ស៊ីណា

បណ្ឌិត ម៉ុង ស៊ាងឌីម

បណ្ឌិត តាំង ស៊ិន

## ហេរញ្ញិក

បណ្ឌិត អ៊ឹុ ប៉ុម

បេក្ខជនបណ្ឌិត លី សុធីរ័ត្ន

បេក្ខជនបណ្ឌិត គឹម ឌុទ្ធី

បេក្ខជនបណ្ឌិត ហ្វូត រ៉ា

## បច្ចេកទេសកុំព្យូទ័រ

បេក្ខជនបណ្ឌិត សុខ ឧស្សាហ៍

បេក្ខជនបណ្ឌិត លឹម សេងឌី

បេក្ខជនបណ្ឌិត យិន ពោ

បេក្ខជនបណ្ឌិត ធឿន សុត្ថា

## អក្ខរាវិរុទ្ធ

បណ្ឌិត ជួរ គារី

បណ្ឌិត មាឃ បូរ៉ា

បេក្ខជនបណ្ឌិត ប៉ាង ចាន់ថា

បេក្ខជនបណ្ឌិត ឃិន យ៉ង់

## ទីប្រឹក្សា

បណ្ឌិតសភាចារ្យ ខ្លូត ធីតា

បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ

បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

បណ្ឌិតសភាចារ្យ សំ សោភាន់

បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន

បណ្ឌិតសភាចារ្យ អ៊ីុង ច័ន

បណ្ឌិតសភាចារ្យ សោម សុមុនី

## គណៈកម្មការត្រួតពិនិត្យ

បណ្ឌិត ច័ន្ទ សំណព្វ

បណ្ឌិត នេត បារ៉ុម

បណ្ឌិត សុខ ទូច

បណ្ឌិត សាម្ញ អូហ្សាណូ

បណ្ឌិត ស៊ុន សូត

បណ្ឌិត នូ ចាន់សុភី

## បោះពុម្ព និង ចែកផ្សាយ

បណ្ឌិត ព្រុំ ទេវី

បេក្ខជនបណ្ឌិត កែវ សុជាតិ

បេក្ខជនបណ្ឌិត ហេង ហុកវេន

បេក្ខជនបណ្ឌិត ជួន សោរិទ្ធី

បេក្ខជនបណ្ឌិត តាំង មុយគា

# រដ្ឋបាលសាធារណៈនៅប្រទេសកម្ពុជា



លោក **អ៊ុំ ប៉ុម**
បេក្ខជនបណ្ឌិត ផ្នែករដ្ឋបាលសាធារណៈ
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

គេតែងកត់សម្គាល់ឃើញជាទូទៅថា រដ្ឋបាលសាធារណៈរបស់ប្រទេសនីមួយៗបានចាប់បដិសន្ធិឡើង អស់រយៈពេលដ៏យូរលង់ជាមួយនឹងប្រវត្តិសាស្ត្ររីកចម្រើនរបស់មនុស្សជាតិ។ ក្នុងដំណើរឆ្លងកាត់ដំណាក់កាលនេះ រដ្ឋបាលសាធារណៈបានដើរតួនាទីយ៉ាងធំធេងក្នុងឋានៈជាដែនសមត្ថកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់របស់រដ្ឋនីមួយៗ។ អាស្រ័យដោយតួនាទីបែបនេះ បានញ៉ាំងឱ្យរដ្ឋបាលសាធារណៈក្លាយទៅជា**ប្រតិបត្តិករ**ដ៏សំខាន់ទៅលើកិច្ចការទាំងឡាយ ដូចជា ការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម ការផ្តល់នូវយុត្តិធម៌ ការការពារកម្មសិទ្ធិប្រជាពលរដ្ឋ ការផ្គត់ផ្គង់សម្ភារៈ ការថែរក្សាធនធាននិងទ្រព្យសម្បត្តិសាធារណៈ ការថែរក្សាបេតិកភណ្ឌ ប្រពៃណីរបស់ជាតិជាដើម។ ក្រៅពីនោះ រដ្ឋបាលសាធារណៈនៅបានរួមចំណែកបង្កើតឡើងជាគោលនយោបាយសមស្របក្នុងការគ្រប់គ្រងប្រទេស ក៏ដូចជាការធ្វើទំនាក់ទំនងជាមួយអន្តរជាតិ។ ប៉ុន្តែដើម្បីសម្រេចបាននូវតួនាទីដូចពោលខាងលើ រដ្ឋបាលសាធារណៈគប្បី ជាយន្តការប្រតិបត្តិប្រកបដោយភាពមោះមុត មានភក្តីភាព មានសីលធម៌វិជ្ជាជីវៈ ព្រមទាំងជាអ្នកបម្រើដ៏ពិតប្រាកដមួយស្របទៅតាមតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ។ ម្យ៉ាងទៀត ព្រមជាមួយនឹងដំណើរប្រព្រឹត្តទៅរបស់ប្រទេសនីមួយៗ គេតែងសង្កេតឃើញនូវរូបភាពរដ្ឋបាលពីរបែបគឺ រដ្ឋបាលសាធារណៈបែបបុរាណ ដែលធ្វើសកម្មភាពអស់រយៈកាលដ៏យូរលង់ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមានលក្ខណៈមិនទាន់សមស្របនិងរដ្ឋបាលសាធារណៈមួយបែបទៀតគឺ រដ្ឋបាលសាធារណៈបែបទំនើប ដែលប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសមស្របឆ្លើយតបបានទៅនឹងចង្វាក់រីកចម្រើនរបស់សង្គម។ អាស្រ័យដោយភាពខុសប្លែកគ្នានៃប្រព័ន្ធគ្រប់គ្រងទាំងពីរបែបនេះបានធ្វើឱ្យរដ្ឋបាលសាធារណៈប្រែក្លាយទៅជាកម្លាំងជំរុញដូចជាឧបសគ្គរាំងស្ទះដល់ដំណើរវិវត្តទៅមុខរបស់ប្រទេសជាតិដែលចាំបាច់ត្រូវតែកែលម្អ។

រដ្ឋបាលសាធារណៈរបស់ប្រទេសនីមួយៗ ក៏មិនមានលក្ខណៈដូចគ្នាទាំងស្រុងដែរ អាស្រ័យដោយភាពខុសប្លែកគ្នានៃរបបនយោបាយ ប្រពៃណីទំនៀមទម្លាប់របស់ប្រទេស ក៏ដូចជាបែបបទរដ្ឋបាលពីខាងក្រៅ (រដ្ឋបាលអាណានិគម) ដែលប្រទេសនោះត្រូវបង្ខំចិត្តទទួលយក។ ទន្ទឹមនឹងនេះ លទ្ធភាពអំណោយផលឬមិនអំណោយផលនៃលក្ខខណ្ឌខាងក្នុងនិងខាងក្រៅរបស់ប្រទេសអាចចាត់ទុកជាបរិយាកាសសង្គមដ៏មានឥទ្ធិពល ទៅលើរដ្ឋបាលសាធារណៈ។ ព្រមជាមួយនោះ ស្មារតីទទួលខុសត្រូវរបស់អ្នកអនុវត្តកិច្ចការសាធារណៈដោយផ្ទាល់ ក៏ជាកត្តាសំខាន់រួមចំណែកធ្វើឱ្យរដ្ឋបាលសាធារណៈអនុវត្តតួនាទីរបស់ខ្លួន ប្រកបដោយជោគជ័យ ឬបរាជ័យផងដែរ។

ទាំងអស់នេះសុទ្ធតែជាបញ្ហាដែលចោទឡើងជារួមក្នុងរដ្ឋបាលសាធារណៈ។ ដោយឡែកប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ១៩៥៣-១៩៧០ ដែលពីមុនមកធ្លាប់បានប្រកាន់យករូបភាពរដ្ឋបាលសាធារណៈបែបរាជាធិបតេយ្យផ្តាច់ការ ហើយក្រោយមកទៀត សម្រេចចិត្តទទួលយកនូវបែបបទរដ្ឋបាលសាធារណៈតាមលំនាំអាណានិគម ដើម្បីបញ្ចៀសប្រទេសឱ្យរួចផុតពីគ្រោះបាត់បង់ទឹកដីក៏មានបញ្ហាប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលបានរៀបរាប់រួចមក ហើយនេះដែរ ដូច្នេះ តើគេអាចកំណត់រដ្ឋបាលសាធារណៈនៅប្រទេសកម្ពុជាក្នុងដំណាក់កាលនោះថា ជារដ្ឋបាលសាធារណៈបែបណា? មានដំណើរប្រព្រឹត្តទៅដូចម្តេចខ្លះ? គេអាចឆ្លើយតបទៅនឹងសំណួរទាំងនេះបានដោយប្រមូលផ្តុំសិក្សាទៅលើរូបភាព រចនាសម្ព័ន្ធ សកម្មភាព កំណែទម្រង់ ព្រមទាំងលទ្ធភាពអនុវត្តជាក់ស្តែងរបស់រដ្ឋបាលសាធារណៈនាពេលនោះក្នុងជំពូកជាបន្តបន្ទាប់របស់និក្ខេបបទ។

## I- សញ្ញាណទូទៅនៃរដ្ឋបាលសាធារណៈ

### ១- និយមន័យ

ដើម្បីយល់បានច្បាស់ពីអ្វីទៅដែលហៅថា រដ្ឋបាលសាធារណៈ គេគប្បីសិក្សាស្វែងយល់អំពីអ្វីដែលហៅថា **រដ្ឋបាល**ជាមុនសិន។

### ១.១- រដ្ឋបាលជាអ្វី?

មានមូលដ្ឋានបង្អែកចំនួនប្រាំដើម្បីអះអាងបញ្ជាក់ថា តើរដ្ឋបាលជាអ្វី?

• ទស្សនៈទូទៅរបស់ខ្មែរៈ តាមទស្សនៈជាទូទៅរបស់ខ្មែរយើង បើគេនិយាយដល់**រដ្ឋបាល** គេតែងផ្តោតអារម្មណ៍គិតដល់កិច្ចការរបស់រដ្ឋឬកិច្ចការគ្រប់គ្រងប្រទេស។

• វចនានុក្រមខ្មែរៈ តាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ពាក្យ រដ្ឋបាល ត្រូវបានពន្យល់ដោយញែកពាក្យនេះ ជាពីរគឺពាក្យ **រដ្ឋ** និងពាក្យ **បាល**។

រដ្ឋៈ ប្រែថា នគរ ប្រទេស ឬ ដែន។

បាលៈ មានន័យថា គ្រប់គ្រង ថែរក្សា ការពារ ប្រទេស។

ដូច្នេះរដ្ឋបាលមានន័យថា គ្រប់គ្រងថែរក្សា ការពារប្រទេសឬនគរ។

• និយមន័យអង្គការ **យូអិនឌីភី (UNDP) ៖** បើតាមនិយមន័យផ្តល់ឱ្យដោយអង្គការនេះ រដ្ឋបាល គឺជាយន្តការដែលប្រមូលផ្តុំគ្នារួមទាំងគោលនយោបាយ លិខិត បទដ្ឋាន នីតិវិធី ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ អង្គការចាត់តាំង បុគ្គលិក... ហើយយន្តការនេះមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងការងារទាំងឡាយរបស់រដ្ឋាភិបាលដោយធ្វើទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយរដ្ឋ សង្គម និងបរិស្ថានខាងក្រៅដទៃទៀត។

• សៀវភៅលោក **ឯក ឆេងហួត៖** បើតាមសៀវភៅស្តីពីនីតិមូលដ្ឋានស្វយ័តរបស់លោក ឯក ឆេងហួត បោះពុម្ពឆ្នាំ២០០៣ ត្រង់ទំព័រទី៦ បានផ្តល់និយមន័យឱ្យពាក្យ រដ្ឋបាលថា ជារបៀបចាត់ចែងការងារបម្រើបុគ្គលឬសមូហភាពណាមួយដើម្បីសម្របសម្រួលឋានានុក្រមការងារនោះ ជូនបុគ្គល ឬ សមូហភាពដែលខ្លួនកំពុងស្ថិតនៅ។

• វចនានុក្រមរដ្ឋបាលសាធារណៈ គេអាចឃើញមាននិយមន័យរដ្ឋបាលមួយបែបទៀត ដែលផ្តល់ឱ្យដោយវចនានុក្រមរដ្ឋបាលសាធារណៈ ចងក្រងឡើងដោយលោក ឆេនដ៍ល័រ (Chandler) និងលោក ប្លាណូ (Plano) បោះពុម្ព ឆ្នាំ១៩៩៨ ត្រង់ទំព័រទី៣ បានលើកឡើងយ៉ាងដូច្នេះថា រដ្ឋបាល គឺជាដំណើរនៃការអនុវត្តនូវសេចក្តីសម្រេចនិងគោលនយោបាយ។

សរុបមក បើផ្អែកលើមូលដ្ឋានទស្សនៈនិងការពន្យល់ទាំងប្រាំខាងលើ រដ្ឋបាលមានន័យថា ជាអង្គភាព សកម្មភាព ដំណើរការនិងជាយន្តការដែលប្រមូលផ្តុំគ្នាទាំងគោលនយោបាយ លិខិតបទដ្ឋាន នីតិវិធី ប្រព័ន្ធ រចនាសម្ព័ន្ធ អង្គការចាត់តាំងបុគ្គលិក... ដើម្បីអនុវត្តសេចក្តីសម្រេច និង គោលនយោបាយរបស់អង្គភាពឬរដ្ឋាភិបាល ប្រកបដោយការទទួលខុសត្រូវដោយផ្តើមចេញពីរបៀបចាត់ចែងការងារ សម្របសម្រួលឋានានុក្រម ការងារបម្រើចំពោះបុគ្គលឬសមូហភាពណាមួយ ដោយធ្វើទំនាក់ទំនងជាមួយភ្នាក់ងារនានានៅក្នុងរដ្ឋឬបរិស្ថានខាងក្រៅផ្សេងទៀត។

### ១.២- រដ្ឋបាលសាធារណៈជាអ្វី?

ដើម្បីយល់បានឱ្យស៊ីជម្រៅទៅលើអ្វីដែលហៅថារដ្ឋបាលសាធារណៈ គេគប្បីសិក្សាស្វែងយល់ជាបន្តទៀត ទៅលើទស្សនៈរបស់លោក ឆេនដ៍ល័រ (Chandler) លោក ប្លាណូ (Plano) លោក រូសែលល៍ (Russell) លោកសា-ហ្វ្រីតស៍ (Shafritz) និងលោក អូវែន អ៊ីហ៊ូគជីស (Owen E.Hughes)។

#### ១.២.១- និយមន័យរបស់លោក ឆេនដ៍ល័រ (Chandler) និងលោក ប្លាណូ (Plano)

លោកទាំងពីរបានផ្តល់នូវទស្សនៈរួចម្តងមកហើយអំពីថាតើរដ្ឋបាលជាអ្វី។ នៅក្នុងស្នាដៃរបស់លោកដដែល ត្រង់ទំព័រទី២៩ លោកបានផ្តល់នូវទស្សនៈជាបន្តទៀតអំពីអ្វីទៅដែលហៅថា រដ្ឋបាលសាធារណៈ ដោយសង្កត់ធ្ងន់ថា រដ្ឋ-បាលសាធារណៈ គឺជាដំណើរនៃការគ្រប់គ្រងនិងសម្របសម្រួលនូវធនធាននិងបុគ្គលិកដើម្បីបង្កើត អនុវត្ត និង គ្រប់គ្រងនូវរាល់សេចក្តីសម្រេចនៅក្នុងគោលនយោបាយសាធារណៈ (Public administration is the process by which public resources and personel are organized coordinated to formatted, implement and manage public policy decision)។

#### ១.២.២- និយមន័យរបស់លោក រូសែលល៍ (Russell) និង លោក សាហ្វ្រីតស៍ (Shafritz)

លោកទាំងពីរបានផ្តល់និយមន័យស្តីពីរដ្ឋបាលសាធារណៈដែលលោកគិតថាគ្រប់ភាគីទាំងអស់អាចទទួលយកបាន ដោយលោកផ្អែកទៅលើនិយមន័យបួនប្រភេទខុសៗគ្នាគឺ និយមន័យផ្នែកនយោបាយច្បាប់គ្រប់គ្រងនិងវិជ្ជាជីវៈ។ តើនិយមន័យទាំងបួននេះមានខ្លឹមសារយ៉ាងណាខ្លះ?

*** និយមន័យនយោបាយ៖**

ផ្អែកលើនយោបាយ រដ្ឋបាលសាធារណៈ គឺជា៖

- អ្វីដែលរដ្ឋាភិបាលធ្វើ

-ដំណាក់កាលមួយក្នុងខួបនៃការបង្កើតគោលនយោ- បាយសាធារណៈ

- ការអនុវត្តមានលក្ខណៈជារួមដែលបុគ្គលតែម្នាក់ឯងមិនអាចអនុវត្តបានល្អ។

*** និយមន័យច្បាប់៖** រដ្ឋបាលសាធារណៈគឺជា៖

- ការអនុវត្តច្បាប់

- បទបញ្ញាឬជាការសម្របសម្រួល

- សកម្មភាពរបស់អ្នកគ្រប់គ្រងឬព្រះរាជាក្នុងការផ្តល់ឬប្រទានអ្វីមួយដល់ប្រជាពលរដ្ឋ។

*** និយមន័យគ្រប់គ្រង៖** គឺជាសិល្បៈ តែមិនមែនវិទ្យាសាស្ត្រទេ។

*** និយមន័យវិជ្ជាជីវៈ**

បើតាមនិយមន័យនេះ រដ្ឋបាលសាធារណៈជាទីលានសិក្សាមួយដែលសិក្សាអំពីសិល្បៈនិងវិទ្យាសាស្ត្រគ្រប់គ្រង សម្រាប់យកទៅអនុវត្តនៅក្នុងផ្នែកសាធារណៈ។

**១.២.៣- និយមន័យរបស់ អូវែន អ៊ី ហ៊ូគជីស (Owen E. Hughes)**

ក្នុងស្នាដៃរបស់លោកស្តីពីរដ្ឋបាលសាធារណៈ ដែលនិពន្ធក្នុងឆ្នាំ១៩៩៨ ត្រង់ទំព័រទី៦ លោកបានពន្យល់ពីរដ្ឋបាលសាធារណៈក្នុងឃ្លាដ៏ខ្លីនិងសាមញ្ញបែបនេះថា រដ្ឋបាលសាធារណៈផ្តោតទៅលើអ្វីដែលជាដំណើរការនីតិវិធីនិងភាពសមហេតុផល។ ដូច្នេះបើតាមទស្សនៈរបស់លោក អូវែន អ៊ី ហ៊ូគជីស រដ្ឋបាលសាធារណៈ គឺជាដំណើរការប្រកបដោយនីតិវិធីនិងភាពសមហេតុផល។

## ២- ភាពខុសគ្នារវាងរដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន

រដ្ឋបាលសាធារណៈមានលក្ខណៈពិសេសសម្រាប់សម្គាល់នូវភាពខុសប្លែកគ្នា ជាមួយនឹងរដ្ឋបាលឯកជន។ លោក សាហ្វ្រីតស៍ (Shafritz)និងលោក ហៃដ៍ (Hyde) បានអះអាងថា មានភាពខុសប្លែកគ្នាជាចម្បងត្រង់ភាគីដែលត្រូវផ្តល់សេវា ពោលគឺរដ្ឋបាលដែលតំណាងរដ្ឋបាលសាធារណៈបម្រើផលប្រយោជន៍សាធារណៈ រីឯរដ្ឋបាលឯកជនបម្រើផលប្រយោជន៍ឯកជន។ លោកទាំងពីរបានគូសបញ្ជាក់បន្ថែមទៀតថា ដោយសារភាពខុសគ្នានេះបានបង្កើតឱ្យមានជាបញ្ហា ព្រោះភាគីទាំងពីរពុំបានស្វែងយល់ពីគ្នាឱ្យបានល្អិតល្អន់។ ទាក់ទងទៅនឹងចំណុចខុសគ្នានេះដែរ លោក អាលីសុន ក្នុងសៀវភៅជីខេយបែនឆ្នាំ២០០៤ (T.Keban, 2004) បានលើកឡើងក្នុងទ្រឹស្តីរបស់លោកស្តីពី រដ្ឋបាលសាធារណៈថាមានចំណុចខុសប្លែកគ្នាដល់ទៅ១៥ចំណុច ពោលគឺរដ្ឋបាលសាធារណៈ៖

- មិនអាស្រ័យលើទីផ្សារ

- មិនសូវមានស្វ័យភាព

- ទទួលឥទ្ធិពលពីនយោបាយ

- មានលក្ខណៈឯកាធិភាព

- មានផលប៉ះពាល់ទូលំទូលាយ

- ទទួលការវាយតម្លៃពីសាធារណៈ ចំពោះសកម្មភាពរបស់ខ្លួន

- ទទួលក្តីសង្ឃឹមពីសាធារណៈថា យុត្តិធម៌ ការឆ្លើយតប ការទទួលខុសត្រូវនិងភាពស្មោះត្រង់

- មានគោលបំណងនិងការវិនិច្ឆ័យស្មុគស្មាញ មិនសូវច្បាស់លាស់និងពិបាកក្នុងការវាយតម្លៃ

- មន្ត្រីតែងមានចិត្តមិនចង់ផ្ទេរអំណាច ហើយនិងមានគំនាបនយោបាយពីថ្នាក់លើ

- មានលក្ខណៈប្រយ័ត្នប្រយែង មិនមានភាពទន់ភ្លន់ក្នុងការបំពេញការងារនិងជួបប្រទះនូវការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ព្រោះមានការជ្រើសរើស និងតែងតាំងមន្ត្រីថ្មី។

- មានការលំបាកក្នុងការផ្តល់នូវទំនុកចិត្ត ដែលផ្អែកលើការបំពេញការងារ។

- មានមនុស្សប្រកបដោយចរិតលក្ខណៈខុសៗគ្នា បំពេញការងារនិងការប្តេជ្ញាចិត្តទាបចំពោះស្ថាប័នឬអង្គភាពរបស់ខ្លួន

- មិនមានគោលដៅស្វែងរកចំណេញ

-គិតពីប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធដែរ តែមិនមានលក្ខណៈដាច់ខាត។

- មិនសូវមានយុត្តិធម៌និងការទទួលខុសត្រូវចំពោះសាធារណជន។

## ៣- ប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ

គេអាចមើលឃើញរដ្ឋបាលសាធារណៈនីមួយៗថាមានប្រសិទ្ធភាពឬយ៉ាងណានោះ ដោយផ្អែកទៅលើទ្រឹស្តីលោក ហង់រី ហ្វាយ៉ុល(Henri Fayol) ទ្រឹស្តីស៊ីប៊ែរ ណេទិក (Cybernétique) របស់លោក លុយស៊ាង ម៉ែល (Lucien Mehl) និងទ្រឹស្តីកំណែទម្រង់របស់លោក អេដម៉ាន់ ប៊ើក (Edmund Burke) សម្រាប់ធ្វើជាមូលដ្ឋានដើម្បីត្រិះរិះពិចារណា។

**៣.១- ប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈរបស់លោក ហង់រី ហ្វាយ៉ុល (Henri Fayol)**

ទ្រឹស្តីនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៧ តាម រយៈស្នាដៃស្តីពីរដ្ឋបាលឧស្សាហកម្មនិងទូទៅ (Administration Industrielle et générale)។ តាមការគិតគូររបស់លោក ទ្រឹស្តីនេះអាចយកទៅប្រើប្រាស់បានទាំងក្នុងសហគ្រាសក៏ដូចជារដ្ឋបាលទូទៅ។ ទ្រឹស្តីនេះមានគោលការណ៍ចំនួន១៤គឺ

- ត្រូវមានការបែងចែកការងារជាប្រព័ន្ធ
- ត្រូវមានការកំណត់អំណាច (សមត្ថកិច្ច) ឱ្យបានច្បាស់លាស់
- មានវិន័យម៉ត់ចត់
- ឯកភាពក្នុងការបញ្ជា
- ឯកភាពក្នុងការចាត់ចែងការងារ
- គិតគូរផលប្រយោជន៍ទូទៅធំជាងផលប្រយោជន៍ឯកជន
- មានប្រាក់ខែនិងប្រាក់បំណាច់ផ្សេងៗទៅតាមកម្រិតថ្នាក់នីមួយៗ
- មានឋានានុក្រមត្រឹមត្រូវ
- មានការរៀបចំ និងរបៀបរៀបរយក្នុងការងារ
- មានការបូកសរុបការងារតាមកាលកំណត់ច្បាស់លាស់
- សមធម៌ក្នុងការងារ
- ស្ថិរភាពក្នុងការងារដោយមានលក្ខន្តិកៈគតិយុត្តត្រឹមត្រូវ
- គំនិតផ្តួចផ្តើមពីថ្នាក់លើមកថ្នាក់ក្រោម
- សាមគ្គីភាពបុគ្គលិក ដើម្បីចៀសវាងការឈ្លោះប្រកែកគ្នា ដែលនាំឱ្យខូចប្រយោជន៍អង្គភាព

**៣.២- ទ្រឹស្តីស៊ីប៊ែរណេទិក(Cybernétique) របស់លោក លុយស៊ាង ម៉ែល (Lucien Mehl)** និយាយដោយសាមញ្ញ ស៊ីប៊ែរណេទិក គឺជាសិល្បៈនៃការធ្វើការងារដោយមានប្រសិទ្ធភាព។ តាមទ្រឹស្តីនេះ សកម្មភាពរដ្ឋបាលត្រូវផ្សារភ្ជាប់ទៅនឹងកត្តាសំខាន់បីគឺ

- គោលបំណងដែលបែងចែកចេញជាគោលដៅមួយចំនួន
- សកម្មភាពរួមមានសកម្មភាពនៃអ្នកគិត សកម្មភាពនៃអ្នកដាក់បញ្ជា ត្រួតពិនិត្យ សម្របសម្រួល និង សកម្មភាពនៃអ្នកប្រតិបត្តិការងារឬហៅម្យ៉ាងទៀតថា ជាអ្នកកសាងសមិទ្ធផលដោយផ្ទាល់
- រចនាសម្ព័ន្ធរបស់ស្ថាប័នរដ្ឋបាល ដែលកើតចេញពីគោលបំណងនិងសកម្មភាព។

ក្រៅពីនោះ អ្នកអនុវត្តទ្រឹស្តីនេះត្រូវគិតគូរផងដែរ ពីឥទ្ធិពលវិជ្ជមាននិងអវិជ្ជមាននៃមជ្ឈដ្ឋានខាងក្នុងនិងខាងក្រៅដែលអាចជំរុញឬធ្វើឱ្យរាំងស្ទះដល់ដំណើរប្រព្រឹត្តទៅរបស់ស្ថាប័នរដ្ឋបាលសាធារណៈ។




សញ្ញាព្រួញចុចៗ បង្ហាញពីអ្វីដែលសកម្មភាពរដ្ឋបាលរំខានចំពោះសកម្មភាពរដ្ឋបាល **ទ្រឹស្តីស៊ីប៊ែរណេទិកនៃសកម្មភាពរដ្ឋបាល។**

(ប្រភព៖ វិទ្យាសាស្ត្ររដ្ឋបាលរបស់លោក សាយ បូរី ទំព័រ៦)

**៣.៣- ទ្រឹស្តីកំណែទម្រង់របស់លោក អេដម៉ាន់ ប៊ើក (Ed-mund Burke)**

ចង់ឱ្យរដ្ឋបាលសាធារណៈនីមួយៗប្រព្រឹត្តទៅបាន អ្នកអនុវត្តគប្បីគិតគូរទៅលើបញ្ហាកែទម្រង់ ដើម្បីធ្វើឱ្យប្រព័ន្ធ ឬរចនាសម្ព័ន្ធនៃរដ្ឋបាលសាធារណៈប្រព្រឹត្តទៅបានដោយសមស្របគ្មានឧបសគ្គ ហើយជាចុងក្រោយធ្វើឱ្យរដ្ឋនីមួយៗបន្តឋិតថេរទៅបានដោយគ្មានការដួលរលំ។ លោក អេដម៉ាន់ ប៊ើក ដែលជាអ្នកកែទម្រង់ដ៏ល្បីល្បាញរបស់អង់គ្លេសក្នុងសតវត្សរ៍ទី១៨ បានផ្តួចផ្តើមនូវគោលការណ៍ប្រាំយ៉ាងដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងចលនាកែទម្រង់ពោលគឺ

-កំណែទម្រង់ត្រូវធ្វើឡើងដោយសន្សឹមៗ និង ទន់ភ្លន់

- ការពារឱ្យបាននូវអំពើព្រៃផ្សៃដែលកើតមានឡើង

- រក្សាលំនឹងរបស់រដ្ឋ ដោយមិនធ្វើឱ្យរដ្ឋនោះ ធ្លាក់ចុះ ឬ ដួលរលំ

- កំណែទម្រង់គឺជាការស្រោចស្រង់រដ្ឋឱ្យបន្តស្ថិតស្ថេរទៅបាន

- អ្នកកែទម្រង់ត្រូវមានទឹកចិត្តចង់កែទម្រង់ មានការប្រុងប្រយ័ត្នជាប់ជានិច្ចនិងស្វែងយល់ឱ្យបានច្បាស់ពីចំណុចខ្វះខាតទាំងឡាយដែលត្រូវកែទម្រង់។

## ៤- ប្រភេទនៃរដ្ឋបាលសាធារណៈ

រដ្ឋបាលសាធារណៈមានពីរប្រភេទ៖ រដ្ឋបាលសាធារណៈបែបបុរាណនិងរដ្ឋបាលសាធារណៈបែបទំនើប។

### ៤.១- រដ្ឋបាលសាធារណៈបែបបុរាណ

ទ្រឹស្តីនេះត្រូវបានអនុវត្តតាំងពីដើមសតវត្សរ៍ទី១៩ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ ទើបមានការកែប្រែឆ្ពោះទៅរកទ្រឹស្តីរដ្ឋបាលសាធារណៈបែបទំនើប។ អ្នកទ្រទ្រង់ទ្រឹស្តីនេះ គឺលោក វូដ្រូវ វីលសុន (Woodrow Wilson) និង លោក ហ្វ្រីឌ្រិច វិនស្លូវ ថាយល័រ(Frederick Winslow Taylor) នៅសហរដ្ឋអាម៉េរិក និងលោក ម៉ាក្ស វ៉ឺប៊ែរ (Max Weber) នៅអាល្លឺម៉ង់។ នៅពេលនេះសូមលើកយកទ្រឹស្តីរបស់លោក ម៉ាក្ស វ៉ឺប៊ែរ តែមួយប៉ុណ្ណោះយកមកពិចារណាដោយហេតុថា ទ្រឹស្តីនេះជាទ្រឹស្តីសំខាន់បំផុតនៃរដ្ឋបាលសាធារណៈបែបបុរាណដែលគេនិយមហៅជាទូទៅថា ទ្រឹស្តីការិយាធិបតេយ្យរបស់លោក ម៉ាក្ស វ៉ឺប៊ែរ។ ទ្រឹស្តីនេះផ្អែកលើគោលការណ៍ប្រាំមួយយ៉ាងគឺ

- មានការគ្រប់គ្រងដោយច្បាប់ឬបញ្ញត្តិរដ្ឋបាលមានន័យថា អាជ្ញាធរត្រូវបង្កើតឡើងដោយច្បាប់ និងបទប្បញ្ញត្តិនានា ដែលចេញពីច្បាប់នេះ

- មានការគិតគូរពីការអភិវឌ្ឍការិយាល័យ ដើម្បីបង្កើនទិន្នផលការងារ

- គ្រប់គ្រងដោយច្បាប់ទម្លាប់និងការយល់ដឹង

- មានវិជ្ជាជីវៈច្បាស់លាស់ដែលកើតចេញពីការបណ្តុះបណ្តាលជំនាញ

- ឋានានុក្រមច្បាស់លាស់ ដោយធ្វើយ៉ាងណាឱ្យមានការបែងចែកអំណាចក្នុងការដឹកនាំ

- មានការចងក្រងទុកជាឯកសារ។

### ៤.២- រដ្ឋបាលសាធារណៈបែបទំនើប

រដ្ឋបាលសាធារណៈបែបទំនើប ចាប់ផ្តើមមានឈ្មោះបោះសំឡេងតាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ដោយសាររដ្ឋបាលសាធារណៈបែបបុរាណលែងមានភាពសមស្របតទៅទៀត។ ប្រទេសដែលគិតគូរឱ្យមានរដ្ឋបាលបែបទំនើបមាន ជាអាទិ៍ ចក្រភពអង់គ្លេសនិងសហរដ្ឋអាម៉េរិក។ នៅចក្រភពអង់គ្លេស គេខិតខំកែទម្រង់រដ្ឋបាលសាធារណៈដោយផ្តោតទៅលើ៖ 3Es ពោលគឺ សេដ្ឋកិច្ច (Economy) សមត្ថភាពការងារ (Efficiency) និង ប្រសិទ្ធភាពការងារ (Effe-ctiveness) នៅក្នុងគ្រប់លំដាប់ថ្នាក់នៃរាជរដ្ឋាភិបាលរបស់ចក្រភព។ ចំណែកនៅសហរដ្ឋអាម៉េរិកវិញ ក៏មានការគិតគូរប្រហាក់ប្រហែលគ្នានេះដែរ ប៉ុន្តែរដ្ឋាភិបាលរបស់គេ (រដ្ឋាភិបាលរបស់លោក ប៊ៀល គ្លិនតុន) បានផ្អែកទៅលើគោលការណ៍បួនយ៉ាងគឺ កាត់បន្ថយនូវរបៀបរបបធ្វើការងារស្មុគស្មាញចាត់ទុកអតិថិជនជាធំ ផ្តល់សិទ្ធិដល់និយោជិតឱ្យទទួលបានលទ្ធផល កាត់បន្ថយនូវចំណាយដែលមិនចាំបាច់។ ផ្សារភ្ជាប់ទៅនឹងបញ្ហាដដែលនេះ គេគប្បីពិនិត្យមើល បន្ថែមទៀតទៅលើទ្រឹស្តីរដ្ឋបាលសាធារណៈទំនើបស្តីពី " សេវាសាធារណៈបែបថ្មី" (New Public Service) ដែលបង្កើតឡើងដោយលោក ចេរី ដេនហាដ (J.V. Denhardt) និង អរ ប៊ី ដេនហាដ (R.B. Denhardt) ក្នុងឆ្នាំ២០០៣ ហើយត្រូវបានគេទទួលស្គាល់ថា ជាទ្រឹស្តីបែបទំនើបមួយមានគោលការណ៍អនុវត្ត៧យ៉ាងដូចខាងក្រោម៖

- បម្រើប្រជាពលរដ្ឋ តែមិនបម្រើអតិថិជន

- ចាត់ទុកផលប្រយោជន៍សាធារណៈជាចម្បង

- គិតពីតម្លៃនៃភាពជាពលរដ្ឋជាងសហគ្រិនភាព

- គិតពីយុទ្ធសាស្រ្ត និង មានសកម្មភាពបែបប្រជាធិបតេយ្យ

- ទទួលស្គាល់គណនេយ្យភាពថា មិនមែនជាបញ្ហាដែលងាយស្រួលពេកនោះឡើយ

- បម្រើប្រសើរជាងតម្រង់ទិស

- ឱ្យតម្លៃមនុស្សជាងផលិតផល។

**៥- ចរិតលក្ខណៈនិងតួនាទីរបស់រដ្ឋបាលសាធារណៈ**

**៥.១- ចរិតលក្ខណៈ**

គេអាចបែងចែកចរិតលក្ខណៈរដ្ឋបាលសាធារណៈជាពីរដំណាក់កាលៈ

- **មុននិងដើមសតវត្សរ៍ទី១៩**

គេកំណត់ចរិតលក្ខណៈរបស់រដ្ឋបាលសាធារណៈក្នុងតំណាក់កាលនេះដោយផ្អែកលើៈ

- ភក្ដីភាព

- ការគ្រប់គ្រងមានប្រកាន់បក្សពួក

-ការកើតមានអំពើពុករលួយនិងប្រើប្រាស់ការិយាល័យដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន

- **ចុងសតវត្សរ៍ទី១៩ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៧០ៈ**

តាមការគិតគូររបស់លោក អូវែន អ៊ី ហូគជីស (Owen E.Hughes)ឆ្នាំ១៩៩៨ ចរិតលក្ខណៈក្នុងដំណាក់កាលនេះ ខុសប្លែកគ្នាទាំងស្រុងពីតំណាក់កាលមុនដោយផ្អែកលើៈ

- ការត្រួតពិនិត្យនិងការដឹកនាំរបស់នយោបាយ

- រដ្ឋបាលសាធារណៈ ជាអ្នកអនុវត្តគោលនយោបាយដែលរៀបចំឡើងដោយអ្នកនយោបាយ

- រដ្ឋបាលសាធារណៈផ្អែកលើឋានានុក្រមការិយាធិបតេយ្យច្បាស់លាស់

- មន្ត្រីក្នុងរដ្ឋបាលសាធារណៈធ្វើការរហូតដល់ចូលនិវត្តនិងមានភាពអព្យាក្រឹត។

ផ្អែកលើចំណុចទាំងបួននេះ ធ្វើឱ្យគេគិតពិចារណាមកកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្នដែលផ្ដោតការយកចិត្តទុកដាក់ទៅលើចំណុចបួនជាសំខាន់នោះគឺ

- ទឹកចិត្តបម្រើការងារមោះមុត

- ភក្ដីភាពៈ ក្នុងនាមជាសេនាធិការរបស់រដ្ឋាភិបាលនិងស្ថាប័នរដ្ឋ រដ្ឋបាលសាធារណៈត្រូវមានភក្ដីភាពចំពោះប្រជាពលរដ្ឋ។

- ផ្ដោតលើសេវាៈ រដ្ឋបាលសាធារណៈត្រូវប្រែក្លាយខ្លួនពីអ្នកគ្រប់គ្រងទៅជា «អ្នកផ្ដល់សេវាមានភាពត្រឹមត្រូវក្នុងការបម្រើ ហើយឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ»។

- សីលធម៌និងវិជ្ជាជីវៈ ៖ រដ្ឋបាលសាធារណៈត្រូវបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព។

**៥.២- តួនាទី**

រដ្ឋបាលសាធារណៈមានតួនាទីសំខាន់បំផុតនៅក្នុងរដ្ឋនីមួយៗ។ ជាក់ស្ដែងរដ្ឋបាលសាធារណៈមានតួនាទីជាអ្នកដឹកនាំការប្រតិបត្តិតាមរយៈរដ្ឋាភិបាលនៃប្រទេសនីមួយៗទៅលើកិច្ចការថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ផ្ដល់នូវយុត្តិធម៌សង្គមផ្ដល់នូវសិទ្ធិលើកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ថែរក្សាធនធានធម្មជាតិ ទ្រព្យសម្បត្តិសាធារណៈ ផ្គត់ផ្គង់សម្ភារៈថែរក្សាប្រពៃណីទំនៀមទម្លាប់ បេតិកភណ្ឌជាតិ និង រួមចំណែកជាមួយរដ្ឋាភិបាលដើម្បីបង្កើតឡើងនូវគោលនយោបាយទូទៅក្នុងការគ្រប់គ្រងរដ្ឋ និង ធ្វើទំនាក់ទំនងជាមួយអន្តរជាតិ។ ក្រៅពីនោះ បើពិនិត្យទៅលើគោលការណ៍ទាំងប្រាំពីរយ៉ាងដែលលោក ចេរី ដេនហាដ និង លោក អរ ប៊ី ដេនហាដ បានច្នៃបង្កើតឡើងជាទ្រឹស្ដីរដ្ឋបាលសាធារណៈតាមគំរូថ្មីមួយមានឈ្មោះថា "សេវាសាធារណៈបែបថ្មី" នោះគេអាចសន្និដ្ឋានបានថា រដ្ឋបាលសាធារណៈទំនើបនាពេលនេះមានតួនាទីសំខាន់បីយ៉ាងប៉ុណ្ណោះ ហើយដែលត្រូវបានគេយកចិត្តទុកដាក់ប្រើប្រាស់ជាទូទៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ប្រទេសភាគច្រើននៅលើសកលលោកយើងនេះ ពោលគឺៈ

- រដ្ឋបាលសាធារណៈជាអ្នកបម្រើសេវារបស់ប្រជាពលរដ្ឋទូទៅ

- រដ្ឋបាលសាធារណៈជាអ្នកបម្រើសេវា គ្រប់គ្រងនិងតម្រង់ទិស

- រដ្ឋបាលសាធារណៈជាអ្នកបម្រើសេវាប្រជាពលរដ្ឋប្រកបដោយឆន្ទៈមោះមុត មានភក្ដីភាព និង មានគណ- នេយ្យភាព ឬ និយាយម្យ៉ាងទៀតថា មានស្មារតីទទួលខុស ត្រូវខ្ពស់ក្នុងដែនសមត្ថកិច្ចបំពេញការងាររបស់ខ្លួន។

**៦- ដែនសកម្មភាព**

ជាទូទៅ ដែនសកម្មភាពរដ្ឋបាលសាធារណៈមានលក្ខណៈស្មុគស្មាញ អាស្រ័យដោយការរីកចម្រើននៃតម្រូវការ

ឬបញ្ហាទាំងឡាយដែលមនុស្សភាគច្រើនបានជួបប្រទះ។ គេអាចកំណត់ដែនសកម្មភាពរដ្ឋបាលសាធារណៈរបស់ប្រទេសនីមួយៗ ដោយផ្តោតទៅលើប្រភេទស្ថាប័ននៅរដ្ឋបាលថ្នាក់កណ្តាល។ មានអ្នកជំនាញខាងរដ្ឋបាលសាធារណៈជាច្រើនដូចជាលោក ជេម អែល ផែរី (James L. Perry, ១៩៨៩) លោក នីកូឡាស ហេនរី (Nicolas Henry, ១៩៩៥) លោក សាហ្វ្រីតស៍ (Shafritz) លោក រូសែលល៍ (Russell, ១៩៩៧) និង លោក ធី ខេយ បែន (T. Keban, ២០០៤) បានផ្តល់នូវទស្សនៈខុសៗគ្នាអំពីដែនសកម្មភាពរបស់រដ្ឋបាលសាធារណៈ។ តទៅនេះ គឺជាគោលគំនិតរបស់លោក ធី ខេយ បែន ក្នុងស្នាដៃមួយស្តីពីតម្រូវការជាយុទ្ធសាស្ត្រទាំងប្រាំមួយនៃរដ្ឋបាលសាធារណៈ ដែលក្នុងស្នាដៃនោះ លោកបានចែកដែនសកម្មភាពនៃរដ្ឋបាលសាធារណៈជា៦ផ្នែក មាន៖

+ គោលនយោបាយសាធារណៈទាក់ទងជាសំខាន់ទៅនឹងដំណើរការនៃការកំណត់គោលបំណងនិងមធ្យោបាយដើម្បីសម្រេចគោលបំណងរបស់ស្ថាប័ននីមួយៗ។

+ ស្ថាប័នឬអង្គភាពសាធារណៈទាក់ទងជាសំខាន់ទៅនឹងការបែងចែកភារកិច្ចនៅតាមបណ្តារចនាសម្ព័ន្ធឬផ្នែកទាំងឡាយដើម្បីសម្រេចបាននូវគោលបំណងដែលបាន កំណត់។

+ ការគ្រប់គ្រងទាក់ទងទៅនឹងដំណើរការ ថាតើត្រូវធ្វើដូចម្តេច ដើម្បីឱ្យបណ្តាសកម្មភាពដែលបានគ្រោងទុកអាចអនុវត្ត ទៅបានប្រកបដោយប្រសិទ្ធភាព។

+ សីលធម៌៖ ផ្តល់ជំបូន្មានចំពោះអ្នកបំពេញការងាររដ្ឋបាលនូវអ្វីដែលខុស អ្វីដែលត្រូវ អ្វីដែលអាក្រក់ អ្វីដែលល្អ។

+ បរិស្ថាន គឺជាសកម្មភាពនិងជាលក្ខខណ្ឌនៅជុំវិញ ដែលមានឥទ្ធិពលទៅលើគោលនយោបាយរបស់អង្គភាព ការគ្រប់គ្រងនិងសីលធម៌។

+ ការទទួលខុសត្រូវក្នុងការងារឬគណនេយ្យភាពគឺជាកត្តាសំខាន់ក្នុងរដ្ឋបាលសាធារណៈ។ អ្នកធ្វើការងាររដ្ឋបាល ដែលអាចចាត់ទុកថាមានវិជ្ជាជីវៈនិងសីលធម៌ត្រឹមត្រូវនោះ លុះត្រាតែអ្នកទាំងនោះមានការទទួលខុសត្រូវក្នុងសកម្មភាពរបស់ខ្លួនចំពោះសាធារណប្រយោជន៍។




ប្រភព៖ T. Keban, ២០០៤

ទាំងអស់នេះគឺជាមូលដ្ឋានទ្រឹស្តីនៃរដ្ឋបាលសាធារណៈសម្រាប់ធ្វើជាមូលដ្ឋានបង្អែកចំពោះការសិក្សាស្រាវជ្រាវក្នុងជំពូកក្រោយៗទៀតទាក់ទងទៅនឹងប្រធានបទស្តីពីរដ្ឋបាលសាធារណៈនៅប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ ១៩៥៣-១៩៧០។

## គន្ថនិទ្ទេស

### ១.ភាសាខ្មែរ


១- កៅ មុយថង *រដ្ឋបាលសាធារណៈទំនើប* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ បោះពុម្ពលើកទី១ ឆ្នាំ២០០៧។

២- កៅ មុយថង..កែ វដ្ឋា *ប្រព័ន្ធរដ្ឋបាលកម្ពុជា* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ បោះពុម្ពលើកទី១ ឆ្នាំ២០០៧។

៣- ជួន ណាត *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២* បោះពុម្ព ឆ្នាំ១៩៦៧។

៤- សាយ បូរី *នីតិរដ្ឋបាលទូទៅ* បណ្ណាគារអង្គរ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦។

៥- សាយ បូរី *វិទ្យាសាស្ត្ររដ្ឋបាល* បណ្ណាគារអង្គរ ឆ្នាំ២០០៧។

៦- សយ រាសី *រដ្ឋបាលសាធារណៈ* ឯកសារសម្រាប់បង្រៀន ឆ្នាំ២០១០។

៧- ឯក ឆេងហួត *នីតិមូលដ្ឋានស្វយ័ត* បោះពុម្ព ឆ្នាំ២០០៣។

## ២.ភាសាបរទេស

១- UNDP Practice Note: Public Administration.

២- Chandler & Plano, *Public Administration Dictionary* Edition 1998.

៣- Ebenstein Alan & Ebenstein William, *Great Political Thinker*, sixth edition, 2000.

៤- Perry L. James, *Handbook of Public Administration*, Edition 1989.

៥- Morstein Max, *Elements of Public Administration*, Edition 1996.

៦-T. Keban, *The Six Strategies Needs of Public Administration,* Edition 2004.

# ការលូតលាស់របស់ជ្រូកកូនកាត់ក្នុងស្រុកដោយប្រើស្លឹកមន និងទង ដំឡូងផ្វាស្រស់ជាប្រភពប្រូតេអ៊ីន



លោកស្រី **ហ៊ិន សុទ្ធនា**
បេក្ខជនបណ្ឌិត ផ្នែកវិទ្យាសាស្ត្រកសិកម្ម ឯកទេសៈ វិទ្យាសាស្ត្រសត្វ
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្ដីផ្ដើម

ដំឡូងផ្វាជាដំណាំចំណីសត្វយ៉ាងសំខាន់ ព្រោះថាមើមរបស់វាជាប្រភពថាមពល ចំណែកឯស្លឹកវិញជាប្រភពប្រូតេអ៊ីន ហើយទាំងមើមទាំងស្លឹកអាចត្រូវបានប្រើប្រាស់ក្នុងទម្រង់ស្រស់និងស្ងួតឬផ្អាប់បានទៀតផង(Woolfe, 1992)។

ថ្មីៗនេះ ទងដំឡូងផ្វាស្រស់ត្រូវបានគេបង្ហាញថាអាចផ្ដល់ជាចំណីជ្រូកក្នុងដំណាក់កាលលូតលាស់ និង វគ្គបញ្ចប់នូវកម្រិត២៧%នៃរូបធាតុសោះទឹកនិង៤០% នៃប្រូ-តេអ៊ីនចំណីសរុប(Hoang Nghia Duyet et al., 2003)។ ចំណែកឯដំណាំមនត្រូវបានគេដាំសម្រាប់ធ្វើជាចំណីដង្កូវ-នាងអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ តែការយល់ដឹងមានតិចតួចណាស់ពីតម្លៃនៃសារធាតុចិញ្ចឹមរបស់វាសម្រាប់សត្វក្រពះទោល (Ting Zing et al., 1998)។ «មន»មានសក្ដានុពល ជាចំណីបន្ថែមសម្រាប់សត្វ ដែលអាចប្រើប្រាស់ជាប្រភពប្រូតេអ៊ីន(Rosal, 1997 និង Sanchez, 1999)។ Yao et al., 2001 ស្លឹកមនមានប្រតេអ៊ីន២០,៩ -២១,១% ក្នុងរូបធាតុសោះទឹក NDF ៣៨,៨-៤១,១%។ ចំណែកឯ Ly et al., 2001 បានបញ្ជាក់ថា ស្លឹកមនមានរូបធាតុសោះទឹក ៣១,៨% ប្រូតេអ៊ីន ២២% NDF ២៤,១% ផេះ ១១,៨% សារធាតុសរីរាង្គ ៨១,១% ចំពោះការរំលាយស្លឹកមនរបស់ជ្រូកមានភាពរលាយខ្ពស់ ដូច្នេះវាជាប្រភពប្រូតេអ៊ីនដ៏ប្រសើរសម្រាប់សត្វក្រពះទោល។

## ១-សម្ភារៈនិងវិធីសាស្ត្រស្រាវជ្រាវ

-ជ្រូក៖ ក្នុងការពិសោធយើងជ្រើសរើសយកតែជ្រូកឈ្មោលដែលក្រៀវរួចមានចំនួន២៤ក្បាល ដែលមានទម្ងន់គិតជាមធ្យម២៧,៩គីឡូក្រាមដែលជាពូជកូនកាត់ (Large White X Local)ដែលត្រូវបានបែងចែកជា៨ប្លុក និង មាន ៣ បច្ច័យ ក្នុងមួយបច្ច័យមានជ្រូកចំនួន៣ក្បាលតាមគំរូពិសោធន៍ RCBD (Randomized Completed Block Design)។

- ជញ្ជីង៖ សម្រាប់ថ្លឹងចំណីផ្ដល់ឱ្យសត្វស៊ី និង ចំណីសល់ជារៀងរាល់ថ្ងៃ។

- ទ្រុង៖ បានសាងសង់ឡើងតាមបណ្ដោយថ្ងៃដែលអាចទទួលពន្លឺនិងកម្ដៅថ្ងៃចូលបានគ្រប់គ្រាន់និងមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ។

- រយៈពេលពិសោធន៍៖ ការពិសោធនេះមានរយៈ-ពេល១២០ថ្ងៃ។

- ចំណីនិងការផ្ដល់ចំណី៖ ចំណីដែលយកមកពិសោធនេះមានទងដំឡូងផ្វាស្រស់ ស្លឹកមនស្រស់ ប្រេម៉ិចចុងអង្ករ និង អំបិល។ រូធាតុដើមទាំងនេះត្រូវបានយកទៅវិភាគរករូបធាតុសោះទឹក (DM) និង អាសូត(N) នៅមន្ទីរពិសោធន៍ ចំណីរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វនិងកសិកម្ម។ ចំណីដែលផ្ដល់ឱ្យជ្រូកនោះរួមមាន៖

បច្ច័យទី១៖ ស្លឹកមនស្រស់និងចុងអង្ករ(MLBR)។ ស្លឹកមនស្រស់ត្រូវបានផ្ដល់ឱ្យជ្រូកស៊ី២%នៃទម្ងន់ខ្លួន ហើយត្រូវបានផ្ដល់ឱ្យស៊ីដោយសេរី ប៉ុន្តែត្រូវហាន់ជាបំណែកតូចៗប្រហែលពី០,៥-២សង់ទីម៉ែត្រ មុននិងផ្ដល់ឱ្យជ្រូកស៊ីបន្ទាប់ពីប្រមូលផលភ្លាម។

បច្ច័យទី២៖ ទងដំឡូងផ្វាស្រស់និងចុងអង្ករ(SPV-BR)។ ទងដំឡូងផ្វាស្រស់ត្រូវបានផ្ដល់ឱ្យជ្រូកស៊ី ២% នៃទម្ងន់ខ្លួនហើយការផ្ដល់ឱ្យសត្វស៊ីគឺធ្វើឡើងដូចជាការផ្ដល់ស្លឹកមនដែរ។

បច្ច័យទី៣៖ ស្លឹកមនស្រស់ ទងដំឡូងផ្វាស្រស់និងចុងអង្ករ (MLSPVBR)។ ស្លឹកមននិងទងដំឡូងផ្វាស្រស់គឺផ្ដល់ឱ្យដូចគ្នានឹងបច្ច័យទី១និងទី២ដែរ ប៉ុន្តែចុងអង្ករ គឺយើងផ្ដល់ឱ្យវាស៊ីមានកំណត់ត្រឹមតែ ២%នៃទម្ងន់ខ្លួន ហើយ

ត្រូវផ្តល់ឱ្យសត្វស៊ីមុនការផ្តល់ស្លឹកមន ឬទងដំឡូងផ្វា ឬស្លឹកមនលាយជាមួយទងដំឡូងផ្វា។

តារាងទី១៖ សមាសភាពគីមីរបស់វត្ថុធាតុដើម

| សមាភាពគីមី \ រូបធាតុដើម | រូបធាតុសោះទឹក (DM%) | ប្រូតេអ៊ីន (CP%) | ថាមពល (Kcal/Kg) | ជាតិសរសៃ (CF %) | កាល់ស្យូម (Ca%) | ផូស្វរ (P %) |
|---|---|---|---|---|---|---|
| ស្លឹកមន | ២១,៣២ [a] | ២២,៣៦ [a] | ២៧០០,៧ [f] | ១៦ [b] | ០,៥ [e] | ០,៦ [e] |
| ទងដំឡូងផ្វា | ១១,៦៨ [a] | ២៣,៤១ [a] | ៣៤៤១,៦ [g] | ១៤,៩ [b] | ១,១៥ [c] | ០,៤២ [c] |
| ចុងអង្ករ | ៨៧,៣៤ [a] | ៨,១២ [a] | ៣៧០៤,៥ [d] | ១,៨៨ [b] | ០,២ [d] | ០,៤ [d] |

ប្រភព៖ a : Labor celAgrid, 2008

b : Chhay Ty et al., 2007

c : Hoang Houng Giang et al (2004)

d : NIAH 1995

e : Jayal and Kehar, 1962

f : Makkar and Becker, 1996

g : Dominguez (1992)

## ២- លទ្ធផល

ឆ្លងតាមការពិសោធអស់រយៈពេល១២០ថ្ងៃកន្លងមកទៅលើការលូតលាស់របស់ជ្រូកកូនកាត់ដោយប្រើស្លឹកមននិងទងដំឡូងផ្វាស្រស់ ជាប្រភពប្រូតេអ៊ីន គឺយើងទទួលបានលទ្ធផលដូចខាងក្រោម៖

២.១. បរិមាណចំណីស៊ីចូល

តារាងទី២៖ បរិមាណការស៊ីចំណីចូល(គិតជារូបធា-តុសោះទឹក)

| បច្ច័យ \ ចំណី(ក្រ) | $T_1$ | $T_2$ | $T_3$ | SE | Prob |
|---|---|---|---|---|---|
| ស្លឹកមន | ៤៥២,៥៥ | ០ | ០ | ២,៩៧ | ០,០០០ |
| ទងដំឡូងផ្វា | ០ | ៧៣៧,០១ | ០ | ៧,៣១ | ០,០០០ |
| ស្លឹកមន+ទងដំឡូងផ្វា | ០ | ០ | ៦១៨,០១ | ៤,២២ | ០,០០០ |
| ចុងអង្ករ | ៦៧៤,៩៧ | ៧៨៦,៨៥ | ៧១៦,៩៨ | ៥,៤៩ | ០,០០០ |
| សរុប(DM) | ១១៣៤,១៨ | ១៥៣១,៥៤ | ១៣៤២,១៩ | ១៣,១៥ | ០,០០០ |
| ប្រូតេអ៊ីន | ១៥៦,៩៩ | ២៦០,៥៦ | ១៩៦,៦៩ | ២,៦៥ | ០,០០០ |

តារាងខាងលើបានបង្ហាញឱ្យឃើញថា បរិមាណចំណីស៊ីចូលរបស់បច្ច័យ $T_1$=១១៣៤,១៨ក្រ បច្ច័យ $T_2$ = ១៥៣១,៥៤ក្រ និងបច្ច័យ $T_3$=១៣៤២,១៩ក្រ។ រវាងបច្ច័យទាំងបីនេះយើងសង្កេតឃើញថាបច្ច័យ $T_2$ មានបរិ-មាណចំណីស៊ីចូលខ្ពស់ជាងគេ តែបើយើងប្រៀបធៀបរវាងបច្ច័យ $T_1$ និង $T_3$ វិញឃើញថាបច្ច័យ $T_3$ មានបរិមាណនៃការស៊ីចំណីចូលល្អជាងបច្ច័យ $T_1$ ដោយ (P=0,000)។ Thim sokha(2007) ប្រៀបធៀបកម្រិតប្រូតេអ៊ីនខុសគ្នាដោយប្រើត្រកួនស្រស់លាយជាមួយទងដំឡូងផ្វាស្រស់ក្នុងកម្រិត១០,១២,១៤, និង ១៦ភាគរយដោយក្នុងនោះ ម្សៅមើមដំឡូងមីលាយជាមួយកន្ទក់ឬចុងអង្ករជាចំណីផ្តល់ថាមពល នោះបរិមាណចំណីស៊ីចូលបានត្រឹមតែ ៣៨៤ក្រ, ៦៦៤ក្រ, ៧៣៩ក្រ និង ៦២៥ក្រក្នុងមួយថ្ងៃ គឺវាទាបជាងការពិសោធនេះ។

ដូចនេះយើងឃើញថា ការផ្តល់ទងដំឡូងផ្វាស្រស់លាយជាមួយចុងអង្ករជាចំណីផ្តល់ថាមពល ពិតជាធ្វើឱ្យសត្វស៊ីចំណីចូលបានច្រើនជាងការផ្តល់ស្លឹកមនស្រស់ឬស្លឹកមនលាយជាមួយទងដំឡូងផ្វាស្រស់។

២.២. កំណើនទម្ងន់

ចំពោះលទ្ធផលបានបង្ហាញឱ្យឃើញថា កំណើនទម្ងន់ជាមធ្យមប្រចាំថ្ងៃរបស់បច្ច័យទាំងបីគឺ $T_1$ = ២២៤,៥៦ក្រ/ថ្ងៃ,$T_2$ = ៣៩០,៣៧ក្រ/ថ្ងៃ និង $T_3$ =២៩២,១៥ក្រ/ថ្ងៃ។ ដូចនេះយើងឃើញថា $T_2$ មានកំណើនទម្ងន់ជាមធ្យមប្រចាំថ្ងៃល្អជាងបច្ច័យដទៃទៀត។

# ជំនួយសហរដ្ឋអាមេរិកក្នុងសម័យសង្គមរាស្ត្រនិយម



លោក **តឹក មេង**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ក្រោយសង្គ្រាមលោកលើកទី២ បានបញ្ចប់ទៅនៅឆ្នាំ១៩៤៥ ពិភពលោកបានបែងចែកជាពីរប្លុកគឺ ប្លុកលោកសេរីដែលមានសហរដ្ឋអាម៉េរិកជាអ្នកដឹកនាំ ហើយប្លុកកុម្មុយនីស្តមានសហភាពសូវៀតជាអ្នកដឹកនាំ ហើយមេក្លោងទាំងពីរនេះតែងតែដណ្តើមយកឧត្តមភាពរៀងៗខ្លួន។ ដោយខិតខំពង្រីកនូវលទ្ធិមនោគមវិជ្ជា ដើម្បីទាញយកប្រទេសទាំងឡាយនៅលើពិភពលោកឱ្យដើរតាមលទ្ធិរបស់ខ្លួន។ ដូច្នេះហើយ ទើបសហរដ្ឋអាម៉េរិកចាប់ផ្តើមផ្តល់ជំនួយដល់កម្ពុជាដើម្បីអូសទាញកម្ពុជាឱ្យចូលរួមក្នុងបក្សសម្ព័ន្ធសេអាតូ ហើយជំនួយដែលសហរដ្ឋអាម៉េរិកបានជួយដល់កម្ពុជាមានដូចខាងក្រោមនេះ។

## ១- ជំនួយសេដ្ឋកិច្ចនិងសង្គម

ដោយសេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកជាចម្បងលើវិស័យកសិកម្ម ហើយរហូតមកដល់ទសវត្សរ៍ទី៦០ ផលិតផលកសិកម្មមានការរីកលូតលាស់បានល្អអាចផ្តល់ជាម្ហូបអាហារដល់ប្រជាជនកម្ពុជាគ្រប់គ្រាន់ ហើយសល់អាចនាំចេញទៅក្រៅប្រទេសបានថែមទៀតផង។ នៅក្នុងទសវត្សរ៍ទី៥០ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការឧស្សាហកម្មរបស់ខ្លួនដោយបានផលិត ស៊ីម៉ងត៍ ក្រណាត់ ក្រដាស ក្តារបន្ទះសំបកកង់ឡាន អាហារកំប៉ុង ឈើអារ និង ឧស្សាហកម្មវាយនភណ្ឌ[១]។ ផ្អែកទៅលើគោលបំណងនៃការផ្តល់និងតម្រូវការចាំបាច់របស់សាមីប្រទេស សហរដ្ឋអាម៉េរិកបានលើកគម្រោងកម្មវិធីផ្តល់ជំនួយជាសំខាន់។

### ក- សាធារណការ

ក្នុងក្របខ័ណ្ឌជំនួយរយៈពេល៥ឆ្នាំរបស់សហរដ្ឋអាម៉េរិក (១៩៥៤-១៩៥៩) ទឹកប្រាក់ចំនួន៣៤ ៤៦៦ ៥១៨ដុល្លារនិង៥៤៥ ០០០ ០០០រៀល ត្រូវបានផ្តល់ឱ្យប្រទេសកម្ពុជាក្នុងគោលដៅដើម្បីស្ថាបនានិងកែលម្អផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ ផ្តល់ម៉ាស៊ីនបូមដី។ មួយភាគធំនៃថវិកាសរុបត្រូវបានប្រើប្រាស់ទៅលើការស្ថាបនាផ្លូវថ្នល់និងកែលម្អនូវប្រព័ន្ធគមនាគមន៍ក្នុងប្រទេស[២]។

ជាក់ស្តែង គម្រោងដ៏មានសារៈសំខាន់នោះ មានជាអាទិ៍ គឺការស្ថាបនាផ្លូវថ្នល់ប្រវែង២២៦គីឡូម៉ែត្រ ភ្ជាប់ទីក្រុងភ្នំពេញទៅកាន់កំពង់ផែព្រះសីហនុ ដែលជាច្រកសេដ្ឋកិច្ចដ៏សំខាន់របស់ប្រទេសកម្ពុជាទៅកាន់សមុទ្រទឹកជ្រៅ។ ផ្លូវនេះត្រូវចាក់កៅស៊ូទទឹង៧ម៉ែត្រនិងធ្វើចិញ្ចើមថ្នល់ម្ខាងៗប្រវែង២.៥ម៉ែត្រ ហើយត្រូវចំណាយអស់ថវិកាចំនួន៣២លានដុល្លារ ក្នុងនោះភាគីកម្ពុជាចេញថវិកាជាតិចំនួន៦៥០ ០០០ដុល្លារ គេបានប្រសិទ្ធនាមថា "ផ្លូវមិត្តភាពខ្មែរ-អាម៉េរិកកាំង "ដើម្បីជាការរំឭកឡើងនូវចំណងមិត្តភាពរវាងប្រជាជាតិទាំងពីរ[៣]។

ការស្ថាបនាឡើងវិញនូវប្រព័ន្ធគមនាគមន៍ដែលខូចខាត គឺជាសមិទ្ធផលដ៏មានសារៈសំខាន់ក្នុងកម្មវិធីជំនួយរបស់សហរដ្ឋអាម៉េរិក ចំពោះរាជរដ្ឋាភិបាលកម្ពុជានាសម័យនោះ។ ជាក់ស្តែងមានផ្លូវថ្នល់ប្រវែង១ ២០០គីឡូម៉ែត្រ ស្ពានធំៗចំនួន៦២ស្ពានតូចៗនិងលូចំនួន១៩ ត្រូវបានស្ថាបនាឡើងវិញ។ ដោយឡែកនៅចុងឆ្នាំ១៩៥៩ មានផ្លូវថ្នល់ប្រវែង៨៣គីឡូម៉ែត្រនិងស្ពានមួយទៀត ត្រូវបានស្ថាបនាជាបន្ថែមទៀត។ ក្រៅពីនោះ ម៉ាស៊ីនបូមដីចំនួនមួយគ្រឿងតម្លៃ ១-៦២០ ០០០ដុល្លារ បានផ្តល់ចំពោះប្រទេសកម្ពុជា ដើម្បីយកទៅបូមដីពីក្នុងទន្លេបម្រើឱ្យការបើកបរនាវាចំណុះ ៣ ៥០០ តោន ទៅកាន់កំពង់ផែក្រុងភ្នំពេញ។ តម្លៃនៃប្រតិបត្តិការបូមដីនេះ គិតជាទឹកប្រាក់ចំនួន៧០ ៦៨៦ ០០០រៀល ដែលសហរដ្ឋអាម៉េរិកជាអ្នកចេញសាឡាងឱ្យពីរគ្រឿង ដែលមួយគ្រឿងៗចំណុះ៤០តោនត្រូវបានផ្តល់ដោយ "យូសូម" (U.S.O.M) ដើម្បីកាត់បន្ថយភាពកកស្ទះនៃការធ្វើដំណើរ

---

[១] The world Book Encyclopaedia, Vol.3, by World Book, Ic, USA 1995, p.72.

[២] The world Book Encyclopaedia, Vol.3, Op.cit., p 23.

[៣] The world Book Encyclopaedia, Vol.3, by World Book, Inc, USA 1995, p.27.

ទៅកាន់ភាគខាងជើងនិងភាគអាគ្នេយ៍របស់ប្រទេស។ ទន្ទឹមនឹងនោះដែរ ក៏មានការផ្តល់ម៉ាស៊ីនភ្លើងសម្រាប់បម្រើការខ្វះខាតអគ្គិសនីនៅតាមបណ្តាខេត្តនានា។ ក្រៅពីនោះព្រលានយន្តហោះជាច្រើនត្រូវបានកែលម្អឡើងវិញ បម្រើឱ្យការហោះហើរក្នុងស្រុកនិងអន្តរជាតិ។ ជាពិសេសទៅទៀត មានការសិក្សាស្រាវជ្រាវធនធានធម្មជាតិ នៅកំពង់ផែក្រុង ព្រះ-សីហនុ ទាក់ទងដល់ប្រព័ន្ធចែកចាយទឹកនិងលទ្ធភាពផ្នែកកសាងវារីអគ្គិសនី[៤]។

អាស្រ័យដោយការអនុវត្តគម្រោងកម្មវិធីជំនួយរបស់សហរដ្ឋអាម៉េរិកលើវិស័យពាណិជ្ជកម្មចាប់ពីឆ្នាំ១៩-៥៤ សាខាក្រុមហ៊ុនជានាវ៉ាប់រងអាម៉េរិកបានកកើតឡើងនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនអាម៉េរិកឈ្មោះ ESSO និង ឈ្មោះ កាល់តិច (CALTEX) បានដើរតួនាទីដ៏សំខាន់មួយក្នុងការលក់ប្រេងដែលនាំចូលមកប្រទេសកម្ពុជា។ ក្រុមហ៊ុនទាំងពីរនេះបានក្លាយទៅជាគូប្រជែងជាមួយក្រុមហ៊ុនរបស់ប្រទេសអង់គ្លេសនិងហូឡង់មួយទៀត គឺក្រុមហ៊ុន (SHELL) ដែលទទួលនាំចូល៦០% នៃប្រេងដែលត្រូវនាំចូលមកក្នុងប្រទេសកម្ពុជា។

រហូតមកដល់ឆ្នាំ១៩៥៩ សហរដ្ឋអាម៉េរិកបានផ្តល់ជំនួយជាទឹកប្រាក់ចំនួន១៣៩ ៨១០ ០០០ដុល្លារ ដល់ប្រទេសកម្ពុជាក្នុងក្របខ័ណ្ឌកម្មវិធីជំនួយរបស់សហរដ្ឋអាម៉េរិកសម្រាប់ទិញផលិតផលនាំចូលនិង១៨ ៣០០ ០០០ ដុល្លារ ទៀតសម្រាប់ឆ្នាំសារពើពន្ធ១៩៦០[៥]។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏កម្រិតជំនួយប្រចាំឆ្នាំលើវិស័យពាណិជ្ជកម្ម បានថយចុះពី៣៥លានដុល្លារ ក្នុងឆ្នាំ១៩៥៥ រហូតដល់១៨លានដុល្លារ ក្នុងឆ្នាំ១៩៦០។ ប្រាក់ជំនួយជាដុល្លារទាំងនោះត្រូវបានផ្តល់តាមរយៈគណកម្មា- ធិការបែងចែករូបិយប័ណ្ណនៃរាជរដ្ឋាភិបាលកម្ពុជានិងយូសូម (U.S.O.M) ប្រចាំនៅប្រទេសកម្ពុជាទៅឱ្យក្រុមហ៊ុនពាណិ-ជ្ជកម្មខ្មែរសម្រាប់ទិញផលិតផលនាំចូល។

សរុបមកក្នុងរយៈពេល៥ឆ្នាំ គិតពីខែមិថុនា ឆ្នាំ១៩៥៤ រហូតដល់ខែមិថុនា ឆ្នាំ១៩៥៩ សហរដ្ឋអាម៉េរិកបានផ្តល់ជំនួយ៖ ៥៤% សម្រាប់សម្ភារៈប្រើប្រាស់ជាមូល-ដ្ឋាន២១% ជាវត្ថុធាតុដើម ២៥% ជាសម្ភារៈបរិក្ខារសម្រាប់ផលិតកម្ម។

ក្នុងចំណោមផលិតផលទាំងនេះ មានក្រណាត់ ប្រេងឥន្ធនៈ ដែក ដែកថែប ស៊ីម៉ងត៍ យានជំនិះ ថ្នាំពេទ្យ និងគ្រឿងអគ្គិសនី។ ក្រុមហ៊ុននាំចូលទាំងអស់ត្រូវទិញផលិ-តផលនាំចូលដោយសេរីពីបណ្តាប្រទេសមូលធន[៦]។

**ខ- ជំនួយផ្នែកសិក្សាធិការ**

បន្ទាប់ពីទទួលបានឯករាជ្យថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានបង្ហាញនូវឆន្ទៈដ៏មុះមុតរបស់ខ្លួនក្នុងការរៀបចំប្រព័ន្ធសិក្សាសាធារណៈឱ្យល្អប្រសើរ ដើម្បីផ្ទេរចំណេះដឹងទៅឱ្យមនុស្សគ្រប់រូបមានជាអាទិ៍ កុមារ យុវជននិងមនុស្សចាស់។ មានបណ្តាប្រទេសនិងអង្គការជាច្រើនបានចូលរួមជួយអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជា មានជាអាទិ៍ សហរដ្ឋអាម៉េរិក ចិន សហភាពសូវៀត មូលនិធិអាស៊ី អង្គ-ការយូណេស្កូ និងអង្គការសុខភាពពិភពលោក។

ដោយឡែកចំពោះសហរដ្ឋអាម៉េរិក ដើម្បីសម្រេចគោលបំណងខាងលើនេះ យូសូម ដែលមានទីស្នាក់ការនៅក្នុងប្រទេសកម្ពុជា បានតម្រង់ទិសឆ្ពោះទៅរកការបណ្តុះ-បណ្តាលគ្រូនិងអភិវឌ្ឍន៍កម្មវិធីសិក្សា។

ចាប់ពីឆ្នាំ១៩៥៥-១៩៥៩ ជំនួយសហរដ្ឋអាម៉េរិកនៅលើវិស័យនេះ បានប្រមូលផ្តុំទៅលើផ្នែកសំខាន់ជាច្រើន ដូចជា ការកសាងប្រព័ន្ធអប់រំនៅបឋមសិក្សា មធ្យមសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន ការអប់រំវិជ្ជាជីវៈនិងបច្ចេក-ទេស ការរៀបចំសៀវភៅសិក្សា ការកសាងសាលាគំរូ ការអភិវឌ្ឍសហគមន៍ និងការអប់រំនៅជនបទជាដើម។ ជាក់ស្តែងក្នុងចន្លោះឆ្នាំ១៩៥៥-១៩៥៩ ទឹកប្រាក់ចំនួន៥ ៨០៣-១៤២ដុល្លារសហរដ្ឋអាម៉េរិក ត្រូវបានផ្តល់ទៅលើវិស័យអប់រំសិក្សាធិការនៅប្រទេសកម្ពុជា។ រហូតមកដល់ឆ្នាំ១៩៥៩ មានគ្រូបង្រៀនចំនួន២៥៩នាក់និងបុគ្គលិករដ្ឋបាលផ្នែកសិក្សាបានទទួលការបណ្តុះបណ្តាលនៅសហរដ្ឋអាម៉េរិកនិងនៅបណ្តាប្រទេសផ្សេងៗទៀត[៧]។

[៤] ibid, p.27.

[៥] The world Book Encyclopaedia, Vol.3,Op.cit., p 20.

[៦] United States Agency for International Development Phnom Penh, Cambodia, 1951-1961, p 15-17.

[៧] The world Book Encyclopaedia, Vol.3, by World Book, Inc, USA 1995, p33.

ជាប់ចេញពីមណ្ឌលគរុវិជ្ជានៅកំពង់កន្ទួត ដែលស្ថិតក្នុងគម្រោងការរួមគ្នារវាងក្រសួងសិក្សាធិការនិងក្រុមបេសកកម្មជំនួយអាម៉េរិក។

តម្រូវការទៅលើជំនួយសហរដ្ឋអាម៉េរិក ជាបឋមបានផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែកអប់រំនៅបឋមសិក្សា។ ដំបូងឡើយសហរដ្ឋអាម៉េរិកបានបង្កើតឱ្យមានជាសាលា "ពិសោធន៍" ចំនួន១៤កន្លែងដើម្បីបំប៉នគ្រូបង្រៀនរយៈពេលខ្លី (ក្នុងវិស្សមកាល) ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ភ្លាមៗផ្នែកគ្រូបង្រៀន។ ម្យ៉ាងទៀត មជ្ឈមណ្ឌលបណ្តុះបណ្តាលគរុកោសល្យរយៈពេលវែងមួយត្រូវបានបង្កើតឡើងនៅកំពង់កន្ទួតតាំងពីឆ្នាំ១៩៥៧ ដែលមានគរុសិស្សចំនួន ១ ០០០នាក់ រៀនសូត្រនិងស្នាក់នៅព្រមទាំងសាលាគំរូ មួយៗក្នុងខេត្តចំនួន១៣។ កម្មវិធីសិក្សាបានផ្តោតសំខាន់ លើការបណ្តុះបណ្តាលគ្រូបឋមសិក្សានៅជនបទ និងបំប៉ន អំពីការប្រតិបត្តិជាក់ស្តែងទាំងឡាយក្នុងសហគមន៍ ដើម្បី ជួយដោះស្រាយបញ្ហាដែលចោទឡើងក្នុងសហគមន៍។

ចំណែកនៅក្នុងកម្រិតមធ្យមសិក្សាវិញ សហរដ្ឋអាម៉េរិកបានជួយបង្កើតឱ្យមានជាសាលាសម្រាប់បណ្តុះបណ្តាលសាស្ត្រាចារ្យទុតិយភូមិ ដោយបញ្ជូនសាស្ត្រាចារ្យចំនួន១៤រូប ទៅបំពេញកម្មសិក្សាដោយផ្ទាល់នៅសហរដ្ឋអាម៉េរិក។ ទន្ទឹមនឹងនោះ តាមសំណើរបស់រាជរដ្ឋាភិបាលសហរដ្ឋអាម៉េរិកបានយកចិត្តទុកដាក់បណ្តុះបណ្តាលភាសាអង់គ្លេសដល់សាស្ត្រាចារ្យ ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលពិសោធន៍និងបណ្តុះបណ្តាលចំនួនពីរកន្លែង សម្រាប់ធ្វើការសិក្សាស្រាវជ្រាវលើផ្នែកភាសានេះ។

ម្យ៉ាងទៀត សហរដ្ឋអាម៉េរិកបានគិតគូរពីការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេសដោយជួយអភិវឌ្ឍទៅលើកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និង ជួយផ្តល់ឧបករណ៍សម្រាប់សាលាសិល្បៈនិងមុខរបរ ព្រមទាំងបញ្ចូលកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និង ជួយផ្តល់ឧបករណ៍សម្រាប់សាលាសិល្បៈ និង មុខរបរ ព្រមទាំងបញ្ចូលកម្មវិធីអប់រំវិជ្ជាជីវៈនិងជំនាញរោងជាងនៅតាមសាលាមធ្យមសិក្សានានា។ ការិយាល័យបច្ចេកទេសមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦២ ដើម្បីទទួលខុសត្រូវក្នុងផ្នែកសិល្បៈនិងមុខរបរ។ បើគេគិតពីសម្ភារៈអប់រំវិញ សហរដ្ឋអាម៉េរិកបានជួយជាសំខាន់ទៅលើផ្នែកនេះ ដោយបែងចែកទៅតាមបណ្តាឆ្នាំនីមួយៗពីឆ្នាំ១៩៥៥ ដល់ ១៩៦២។ ជាក់ស្តែងៈ

ឆ្នាំ១៩៥៥ៈ ៦០០ ០០០ដុល្លារ ឆ្នាំ១៩៥៦ៈ ១. ៥០០ ០០០ដុល្លារ ឆ្នាំ១៩៥៧ៈ ២ ៧០០ ០០០ដុល្លារ ឆ្នាំ១៩៥៨ៈ ១ ៥០០ ០០០ដុល្លារ ឆ្នាំ១៩៥៩ៈ ២ ៤០០-០០០ដុល្លារ ឆ្នាំ១៩៦០ៈ ២ ៦០០ ០០០ដុល្លារ ឆ្នាំ១៩៦១ៈ ៥ ៥០០ ០០០ដុល្លារ ឆ្នាំ១៩៦២ៈ ៦ ៣០០ ០០០-ដុល្លារ[៨]។

ចំពោះប្រាក់ជំនួយដែលគ្រោងទុកសម្រាប់ឆ្នាំ១៩៦១-៦២ មិនទាន់បានចំណាយនៅឡើយ ក្នុងនោះ មានទាំងប្រាក់សម្រាប់ចំណាយស្ថាបនាវិទ្យាស្ថានបច្ចេកទេស សំណង់ស្ថាបនាសាលាជាតិផ្នែកសិល្បៈនិងមុខរបរសម្រាប់មជ្ឈមណ្ឌលថ្មីខាងគរុកោសល្យនៅខេត្តសៀមរាបនិងសម្រាប់អនាគតវិទ្យាល័យមិត្តភាពខ្មែរ-អាម៉េរិកកាំង។ ដោយឡែកចំពោះប្រទេសចិនវិញបានជួយស្ថាបនាសាលាបឋមសិក្សាដែលមានទឹកប្រាក់ទាំងអស់ចំនួន៤២លានរៀល។ ចំណែកសហភាពសូវៀតបានជួយស្ថាបនាវិទ្យាស្ថានបច្ចេកទេស ក្រុមមូលនិធិអាស៊ីបានជួយទិញសៀវភៅ សម្ភារៈសិក្សា និងបញ្ជូននិស្សិតទៅរៀនឯបរទេស សរុបទឹកប្រាក់ចំនួន៦ ៨១០-០០០រៀល (១៩៥៨-៦២)[៩]។

ក្រៅពីនេះនៅមានការឧបត្ថម្ភទៅលើការអប់រំសម្រាប់ជនបទ ដែលផ្សារភ្ជាប់ទៅនឹងកិច្ចអភិវឌ្ឍជនបទ។ មជ្ឈមណ្ឌលរបស់ជាតិមួយ សម្រាប់ការអប់រំមូលដ្ឋាន ត្រូវបានបង្កើតឡើងនៅទន្លេបាទីដោយកិច្ច សហប្រតិបត្តិការពីយូណេស្កូ (UNESCO) អង្គការសុខភាពពិភពលោក (W.H.O.) អង្គការស្បៀងអាហារពិភពលោក (F.A.O.) និងរាជរដ្ឋាភិបាល។ មជ្ឈមណ្ឌលនេះ មានគោលដៅអប់រំទៅលើគោលការណ៍វិធីសាស្ត្រ និង បច្ចេកទេសសម្រាប់ការអភិវឌ្ឍភូមិ ដោយទទួលអប់រំបណ្តុះបណ្តាលគ្រូចំនួន២៥០នាក់ មកពីខេត្តចំនួន១៤ដែលជាក្រុមគ្រូចល័តចុះអប់រំមនុស្សចាស់នៅតាមភូមិនានា តាមបែបផែនជាសាលាបង្ហាញគំរូជាក់ស្តែង។

### គ- ជំនួយផ្នែកសុខាភិបាល

ប្រទេសកម្ពុជា ជាប្រទេសបិតនៅតំបន់ដែលមានជាតុអាកាសក្តៅហើយសើម។ អាស្រ័យដោយលក្ខណៈធាតុ

[៨] The world Book Encyclopaedia ibid, Op.cit, p 25.

[៩] ក្រសួងឃោសនាជាតិកម្ពុជាជួយខ្លួនឯង ខែមិថុនា ឆ្នាំ១០៦៣ ទំព័រ១៥

អាកាសបែបនេះ ប្រទេសកម្ពុជាតែងបានទទួលនូវការរាត ត្បាតពីជំងឺឆ្លងផ្សេងៗ ដែលគេជួបប្រទះក្នុងតំបន់នេះ។

ក្រោយសង្គ្រាមឥណ្ឌូចិន ប្រទេសកម្ពុជាត្រូវប្រឈម មុខដោះស្រាយនឹងភាពក្រខ្សត់ ភាពខ្វះសណ្តាប់ធ្នាប់ និង បញ្ហាសុខភាពប្រជាពលរដ្ឋ។

ពីឆ្នាំ១៩៥៤-១៩៥៤ សហរដ្ឋអាមេរិកបានជួយ ឧបត្ថម្ភជាទឹកប្រាក់ចំនួន២ ២៦៩ ០០០ដុល្លារ និង ៨០-៩៥៤ ០០០រៀល លើវិស័យសុខភាពសាធារណៈ ដែលពីមុននេះជួបការខ្វះខាតខ្លាំងទៅលើឱសថព្យាបាលនិងបរិក្ខារពេទ្យ។ ជាបន្តបន្ទាប់ សហរដ្ឋអាមេរិកបានយកចិត្តទុកដាក់សាងសង់អគារ បំពាក់ឱ្យសាលាភូមិន្ទវិជ្ជាពេទ្យ សាងសង់មន្ទីរពេទ្យព្រះសង្ឃ មន្ទីរពេទ្យកុមារ មន្ទីរសម្ភពក្រុង និង មជ្ឈមណ្ឌលសុខភាពមួយនៅទីកល្អក់[១០]។

សហរដ្ឋអាមេរិកក៏បានយកចិត្តទុកដាក់ផងដែរទៅលើការបំពាក់សម្ភារៈក្នុងមន្ទីរពេទ្យតាខ្មៅដែលក្រោយមកបានក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលបុគ្គលិកបម្រើការផ្នែកសុខភាពសាធារណៈ។

ការផ្គត់ផ្គង់ទឹកស្អាត គឺជាប្រការសំខាន់សម្រាប់លើកកម្ពស់សុខភាពប្រជាពលរដ្ឋ។ ឆ្លើយតបនឹងបញ្ហានេះ សហ-រដ្ឋអាមេរិកបានជួយស្ថាបនាស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុងសំខាន់ៗចំនួន៥ ជួយជីកអណ្តូងស្នប់តាមភូមិនានាចំនួន៦០២កន្លែង សម្រាប់ផ្គត់ផ្គង់ទឹកស្អាត។

ក្រៅពីនេះអង្គការសុខភាពពិភពលោកនិងសហ-រដ្ឋអាមេរិកបានផ្តល់ហិរញ្ញវត្ថុ ដើម្បីបើកយុទ្ធនាការកម្ចាត់ជំងឺគ្រុនចាញ់។ តាមរយៈយុទ្ធនាការនេះគេឃើញមានការបាចកំបោរតាមផ្ទះ ការចែកចាយថ្នាំ ការស្រាវជ្រាវមេរោគគ្រុនចាញ់ ការបង្កើតក្រុមប្រចាំការពិសេសផ្នែកជំងឺគ្រុនចាញ់។ មានបុគ្គលិកសុខាភិបាលកម្ពុជាចំនួន២២នាក់ ត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស។

គួរកត់សម្គាល់ថែមទៀតថា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៥៩ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦០ សហរដ្ឋ-អាមេរិកបានចំណាយអស់ទឹកប្រាក់ចំនួន១៥០ ០០០ដុល្លារលើផ្នែកឯកទេសចាំបាច់សម្រាប់ការពារជំងឺគ្រុនចាញ់ក្នុងប្រទេសកម្ពុជា[១១]។

តទៅទៀតនេះ គឺជាតួលេខដែលបានបញ្ជាក់ឱ្យឃើញពីជំនួយបរទេស រួមមានជំនួយរបស់សហរដ្ឋអាមេរិក ចិន បារាំង សហភាពសូវៀត អង្គការសុខភាពពិភពលោក (W.H.O.) ដែលបានផ្តល់ឱ្យកម្ពុជាដើម្បីអភិវឌ្ឍវិស័យសុខាភិបាល តាំងពីឆ្នាំ១៩៥៥-១៩៦១។

### ឃ- ជំនួយផ្នែករដ្ឋបាលសាធារណៈ

ជំនួយផ្នែករដ្ឋបាលសាធារណៈបានចាប់ដំណើរ-ការពីឆ្នាំ១៩៥៨ ក្នុងលក្ខណៈជាការផ្តល់យោបល់និងអ្នកជំនាញការ។

ប្រាក់ចំណាយទៅលើវិស័យនេះ មានលក្ខណៈតិចតួច បើប្រៀបធៀបទៅនឹងវិស័យដទៃទៀត ពោលគឺក្នុងបរិ-មាណទឹកប្រាក់ត្រឹមតែ៨៦ ០០០ដុល្លារនិង៧៣៥ ០០០រៀលប៉ុណ្ណោះ ដែលក្នុងនោះមានចំណាយជាសំខាន់ទៅលើអ្នកជំនាញការដើម្បីបណ្តុះបណ្តាលកម្មសិក្សាការី១៥ ០០០ដុល្លារ និង១១ ០០០ដុល្លារទៀតសម្រាប់សម្ភារៈការិយាល័យ[១២]។

### ង- ជំនួយផ្នែកមធ្យោបាយឃោសនា

ជំនួយរបស់សហរដ្ឋអាមេរិកលើវិស័យនេះ បានប្រព្រឹត្តទៅតាំងពីឆ្នាំ១៩៥២ ក្នុងគម្រោងជួយរាជរដ្ឋាភិ-បាលកម្ពុជា ដើម្បីពង្រីកមធ្យោបាយទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងទូទាំងប្រទេសតាមរយៈវិទ្យុផ្សាយសំឡេង ការផ្សព្វផ្សាយជាសាធារណៈ សារព័ត៌មាន ខ្សែភាពយន្ត។ល។ ដែលគិតជាទឹកប្រាក់សរុបចំនួន៧៧៣ ០០០ដុល្លារ[១៣]។ ក្នុងបណ្តាឆ្នាំដំបូងនៃកម្មវិធី សហរដ្ឋអាមេរិកបានជួយជាប៉ុស្តិ៍វិទ្យុទទួលសំឡេងចំនួន២៨៥ និង ម៉ាស៊ីនភ្លើងចំនួន២៥០-គ្រឿង ប៉ុស្តិ៍វិទ្យុផ្សាយសំឡេងដែលមានកម្លាំងមួយគីឡូវ៉ាត់ និងក្រុមចល័តបីក្រុម សម្រាប់បម្រើឱ្យមូលដ្ឋាន។

ចាប់ពីឆ្នាំ១៩៥៥-១៩៥៩ សហរដ្ឋអាមេរិកបានជួយពង្រីកមធ្យោបាយឃោសនា ដែលអនុវត្តតាមរយៈក្រសួងឃោសនាការ ដូចជាសាងសង់រោងពុម្ពទំនើប សង់ស្ថានីយ៍វិទ្យុផ្សាយសំឡេងនៅភ្នំពេញ បណ្តុះបណ្តាលបុគ្គ-លិកផ្តល់ជាម៉ាស៊ីនបញ្ចាំងខ្សែភាពយន្តចំនួន៥០គ្រឿង និងបណ្តុះបណ្តាលបុគ្គលិកបម្រើការងារបញ្ចាំងភាពយន្ត ព្រម

[១០] ក្រសួងឃោសនាជាតិ ដ.ឯ.ម. ទំព័រទី១៥។

[១១] ក្រសួងឃោសនាជាតិ ដ.ឯ.ម. ទំព័រទី៣០។

[១២] The American Aid Program in Cambodia, Phnom Penh, Cambodia,1951-1961, p 41- 44.

[១៣] The American Aid Program in Cambodia, Phnom Penh, Cambodia, 1951-1961, p 10-12.

ទាំងកសាងមន្ទីរពិសោធន៍ផ្នែករូបភាពដ៏ទំនើបមួយសម្រាប់ក្រសួងឃោសនាការ។

## ២- ជំនួយផ្នែកយោធានិងមហាផ្ទៃ

ក- ជំនួយផ្នែកយោធា

នៅឆ្នាំ១៩៥៩ សហរដ្ឋអាម៉េរិកបានផ្តល់ជាទឹកប្រាក់ចំនួន១៥៦ ៧០០ ០០០ដុល្លារ ក្នុងក្របខ័ណ្ឌជាជំនួយផ្នែកយោធា ចំពោះកងយោធពលខេមរភូមិន្ទ ដែលបែងចែកទៅតាមបែបបទដូចខាងក្រោម៖

- ៦៩ ៥០០ ០០០ដុល្លារ សម្រាប់សម្ភារៈសឹក
- ៨៧ ៣០០ ០០០ដុល្លារ សម្រាប់ជួយផ្គត់ផ្គង់ប្រាក់បៀវត្សរ៍ និង ប្រាក់ចំណាយរបស់កងទ័ពនិងសម្រាប់សាងសង់បន្ទាយ។ សម្ភារៈក្នុងបរិមាណដ៏ច្រើនបានផ្តល់ចំពោះកងយោធពលខេមរភូមិន្ទក្នុងឆ្នាំ១៩៥៥-១៩៥៦។
- ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ សហរដ្ឋអាម៉េរិកបានផ្តល់ជំនួយផ្នែកយោធាចំពោះប្រទេសកម្ពុជា តាមផ្នែកជាច្រើនដូចជាសម្ភារៈសឹក ប្រាក់បៀវត្សរ៍ ប្រាក់ចំណាយ ស្បៀងហូបចុក និង គ្រាប់រំសេវ។ ចំពោះសម្ភារៈយោធា គឺគិតតាំងពីរថយន្តគ្រប់ប្រភេទ រថពាសដែក កាំភ្លើងដៃ កាំភ្លើងយន្ត សំពៀតស្លាយ មុង ភួយ ជាដើម[១៤]។

ថវិកាយោធាចំនួន៦២% បានផ្តល់ទៅលើប្រាក់បៀវត្សរ៍ ប្រាក់ចំណាយលើប្រាក់បំណាច់ និង របបផ្គត់ផ្គង់សម្រាប់យោធិនម្នាក់ៗ ក្នុងកងយោធពលខេមរភូមិន្ទ។ ក្រៅពីនេះក៏មានកម្មវិធីផ្នែកសំណង់យោធា មានមជ្ឈមណ្ឌលផ្គត់ផ្គង់សម្ភារៈសឹកនៅលង្វែក ឃ្លាំងស្តុបប្រេងសាំងនៅព្រែកព្នៅ បន្ទាយកងវរសេនាធំនៅមោស ខេត្តកំពង់ឆ្នាំង មន្ទីរពេទ្យយោធាតាមតំបន់ចំនួនបី សេនាធិការកងទ័ពជើងទឹក រោងជាងជួសជុល កន្លែងបាញ់វង់ និង ការពង្រីកព្រលានយន្តហោះពោធិ៍ចិនតុង។ ក្រៅពីនោះសហរដ្ឋអាម៉េរិកបានជួយហ្វឹកហ្វឺនដល់នាយទាហាន៩១រូប នៅមូលដ្ឋានយោធាកងទ័ពអាម៉េរិក។

ដូច្នេះតាមស្ថិតិខាងលើឃើញថា ជំនួយយោធារបស់សហរដ្ឋអាម៉េរិកចំពោះប្រទេសកម្ពុជា មានការថយចុះ បើប្រៀបធៀបទៅនឹងឆ្នាំ១៩៥៥។

ខ-ជំនួយផ្នែកមហាផ្ទៃ

សន្តិសុខសណ្តាប់ធ្នាប់សង្គម គឺជាលក្ខខណ្ឌដ៏សំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ បានប្រឈមមុខទល់នឹងបញ្ហាចោរកម្មដែលបង្កឡើងក្នុងសង្គ្រាមលោកលើកទីពីរ ហើយនៅមានសេសសល់រហូតដល់សព្វថ្ងៃ។

ផ្សារភ្ជាប់នឹងបញ្ហានេះ កម្មវិធីជំនួយសម្រាប់ប៉ូលិសស៊ីវិល បានចាប់ដំណើរការពីខែមិថុនា ឆ្នាំ១៩៥៧ រហូតដល់ខែមិថុនា ឆ្នាំ១៩៥៩ ក្នុងបរិមាណទឹកប្រាក់ចំនួន១-០១៣ ៧០០ដុល្លារនិង៩ ៨៣០ ០០០រៀល សម្រាប់ចំណាយទៅលើការទិញសម្ភារៈចាំបាច់ទាំងឡាយ សម្រាប់សំណង់សំខាន់ៗ ការបណ្តុះបណ្តាល និង ជំនាញការអាម៉េរិកដែលបម្រើឱ្យផ្នែកនេះចំនួនប្រាំបីនាក់[១៥]។

ចំពោះប្រទេសមួយ ដែលសំបូរទៅដោយភូមិករមានមនុស្សរស់នៅកុះករ ក៏ដូចជាព្រៃភ្នំច្រើនដូចប្រទេសកម្ពុជា ការចល័តកម្លាំងប៉ូលិស ការបំពាក់បណ្តាញទូរគម-នាគមន៍ទំនើប គឺជាប្រការសំខាន់មិនអាចខ្វះបាន។ ដើម្បីអនុវត្តឱ្យកាន់តែប្រសើរនូវមុខងារនេះ ក្នុងគោលបំណងការពារសន្តិសុខជូនប្រជាពលរដ្ឋ បរិមាណទឹកប្រាក់ចំនួន ៦៥៤ ៤៨០ដុល្លារ ត្រូវបានផ្តល់ទៅលើការទិញរថយន្តហ្ស៊ីប ចំនួន ១៨៣គ្រឿង អូប័រប្រដេញតូចៗចំនួន៣៥គ្រឿង បំពាក់ដែលដោយគ្រឿងបរិក្ខារគ្រប់គ្រាន់ និង រោងជាងជួសជុលរថយន្តនៅភ្នំពេញ។

ក្រៅពីនេះ នៅមានជំនួយឧបត្ថម្ភបង្កើតជាប៉ុស្តិ៍វិទ្យុទាក់ទងចំនួន១៥កន្លែង និង សាខាចំនួន៦៤កន្លែងទៀត ដើម្បីធានាដល់ការបញ្ជូនសារឱ្យប្រព្រឹត្តទៅបានឆាប់រហ័ស។ ទន្ទឹមនឹងនេះ ក៏នៅមានការបំពាក់ជាវិទ្យុទាក់ទងចល័តខ្នាតតូចនិងរោងជាងសម្រាប់ជួសជុលវិទ្យុទាក់ទងផងដែរ។ ទឹកប្រាក់ចំនួន២៧០ ០០០ដុល្លារ ត្រូវបានចំណាយទៅលើផ្នែកនេះរហូតដល់ខែមិថុនា ឆ្នាំ១៩៥៩។ ព្រមជាមួយនោះដែរ ក៏នៅមានទឹកប្រាក់ចំនួន១៨ ០០០ដុល្លារទៀត ត្រូវបាន យកទៅប្រើប្រាស់លើការបង្កើតប្រព័ន្ធទំនើប ផ្នែកត្រួតពិនិត្យ

[១៤] ibid, p 23.

[១៥] The American Aid Program in Cambodia, Op.cit., p.19.

អត្តសញ្ញាណបណ្ណ មន្ទីរពិសោធន៍ ផ្នែករូបភាពនិងវិភាគព័ត៌-មានឱ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាព[១៦]។ ម្យ៉ាងទៀត ការបណ្តុះបណ្តាលកម្លាំងប៉ូលិសមួយនៅខេត្តកំពង់ឆ្នាំងត្រូវបានបង្កើតឡើង។ ជាមួយគ្នានេះដែរ ទឹកប្រាក់ចំនួន៣១០ ០០០ដុល្លារបានវិនិយោគទៅលើការសាងសង់បណ្ឌិត្យសភាដែលបានបើកទ្វារឱ្យដំណើរការនៅឆ្នាំ១៩៦០។ សមិទ្ធផលថ្មីនេះគឺជាសក្ខីភាពនៃកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលមន្ត្រីប៉ូលិសថ្នាក់មធ្យមនិងថ្នាក់ឧត្តមទៅលើមុខវិជ្ជាជំនាញ ដែលពុំធ្លាប់មានតាំងពីយូរមកហើយក្នុងប្រទេសកម្ពុជា។

ក្រៅពីនេះការបង្កើតប្រព័ន្ធបណ្តុះបណ្តាលក្នុងស្រុក សហរដ្ឋអាម៉េរិកក៏បានបញ្ជូននាយប៉ូលិសចំនួន៤៤រូប ទៅធ្វើកម្មសិក្សានៅបរទេស ដែលក្នុងនោះមាន២៧រូប ត្រូវចេញទៅសិក្សាក្នុងឆ្នាំ១៩៦០។

## សន្និដ្ឋាន

ចាប់ពីប្រទេសកម្ពុជាបានឯករាជ្យពីបារាំងមក យើងឃើញថាសហរដ្ឋអាម៉េរិកបានបង្កើតទំនាក់ទំនងជាផ្លូវការជាមួយប្រទេសកម្ពុជា នៅឆ្នាំ១៩៥២ ហើយសហរដ្ឋអាម៉េ-រិកបានផ្តល់ជំនួយសេដ្ឋកិច្ចនិងយោធាមកដល់កម្ពុជា ដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ។ ប៉ុន្តែ ក្រោយមកដោយសារតែមនោគមវិជ្ជានៃសង្គ្រាមត្រជាក់ ទើបសហ-រដ្ឋអាម៉េរិកបានគាបសង្កត់ប្រទេសកម្ពុជាឱ្យដើតាមមនោ-គមវិជ្ជារបស់ខ្លួន តាមរយៈនៃការផ្តល់ជំនួយនេះ។ ដើម្បីឱ្យកម្ពុជាដើរតាមមនោគមវិជ្ជារបស់ខ្លួន សហរដ្ឋអាម៉េរិក បានប្រើប្រាស់សម្ព័ន្ធមិត្តរបស់ខ្លួនដែលមានប្រទេសថៃ និង វៀត-ណាមខាងត្បូងគាបសង្កត់មកលើកម្ពុជាតាមរយៈការខ្ទប់ស្តាត់សេដ្ឋកិច្ចតាមព្រំដែន។ ដោយសារមានការគាបសង្កត់គ្រប់បែបយ៉ាងពីសំណាក់សហរដ្ឋអាម៉េរិកមកលើកម្ពុជា ហេតុដូច្នេះហើយទើបសម្តេចព្រះ នរោត្តម សីហនុ ប្រកាសឈប់ទទួលជំនួយពីសហរដ្ឋអាម៉េរិកនៅឆ្នាំ១៩៦៣ ហើយឈានទៅដល់ការផ្តាច់ទំនាក់ទំនងជាមួយគ្នាទាំងស្រុងនៅឆ្នាំ១៩៦៥។ ពេលនោះជំនួយរបស់សហរដ្ឋអាម៉េរិកត្រូវបានបញ្ឈប់ទាំងអស់រហូតដល់ឆ្នាំ១៩៦៩ ទើបជំនួយរបស់អា-ម៉េរិកចាប់ផ្តើមមានឡើងវិញ។

---

[១៦] The American Aid Program in Cambodia, Op.cit., p.32.

# ជនជាតិដើមភាគតិចនៅខេត្តព្រះវិហារ



លោក **ឡោ សាន**
មន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជា

អន្តោគ្រាមកួយគឺជនជាតិដើមភាគតិចនៅក្នុងអំបូរខ្មែរ-មន និង មានកំណើតតាំងពីយូរយារណាស់មកហើយ។ កួយជាអន្តោគ្រាមមួយចំណោមក្រុមអន្តោគ្រាមជាច្រើនទៀតដែលរស់នៅប្រទេសកម្ពុជា ដូចជា ព្នង សំរែ គ្រឹង ទំពួន ក្រាវែត ស្ទួយ ព្រៅ ប្រាញ។ល។

អន្តោគ្រាមកួយមានច្រើនក្រុមដែលរស់នៅតាមតំបន់ផ្សេងៗ ជាពិសេសនៅបែកខាងជើងនៃប្រទេសកម្ពុជា គឺខេត្តព្រះវិហារ។ បើតាមឯកសាររបស់លោក F. Escoffier ដែលនិយាយអំពី "Les Laos au Cambodge: une cohabitation harmonieuse" លោកបានបង្ហាញថា «ជនអន្តោគ្រាមកួយរស់នៅក្នុងតំបន់មួយចំនួនដូចជា នៅខេត្តកំពង់ធំ គេ ហៅថា កួយរំជ័យ (Kui Rumchey) នៅស្រុកថាឡាបរិវ៉ាត់ នៃខេត្តស្ទឹងត្រែង គេហៅថា កួយហូ (Kui Ho) និងនៅខេត្តព្រះវិហារ គេហៅថា កួយអាន់តេវ (Kui Antey)»។ អន្តោគ្រាមកួយសរុបទូទាំងប្រទេសកម្ពុជាមានប្រមាណ ១៥-៧៧១នាក់ ស្មើ ៥,១០%។ ក្នុងខេត្តព្រះវិហារ អន្តោគ្រាមកួយរស់នៅតាមតំបន់មួយចំនួន ពិសេសប្រមូលផ្តុំក្នុងស្រុកបីគឺស្រុកត្បែងមានជ័យ ក្នុងនោះមានភូមិប៉ាលហាល ឃុំប៉ាលហាល, ភូមិប្រមេរុ ឃុំប្រមេរុ, ភូមិពោធិ៍ ឃុំពោធិ៍, ភូមិក្រាំងដូង ឃុំព្រះឃ្លាំង, ភូមិមហាផល ឃុំឈានមុខ, ស្រុកជ័យសែន ក្នុងនោះមាន២ឃុំ និង ស្រុករវៀង ក្នុងនោះមានភូមិបង្កើនផល ឃុំរមទម, ភូមិដីអោក ឃុំរមណីយ និង ភូមិឃុំ ផ្សេងទៀត។

ក្នុងការស្រាវជ្រាវនេះ យើងបានចុះទៅដល់ភូមិឃុំចំនួនបីក្នុងខេត្តព្រះវិហារ នៅក្នុងចំណោមភូមិ ឃុំមួយចំនួនទៀតដែលមានបងប្អូនកួយរស់នៅ គឺភូមិប៉ាលហាល ឃុំ ប៉ាលហាល ស្រុកត្បែងមានជ័យ ភូមិប្រមេរ ឃុំប្រមេរ ស្រុកត្បែងមានជ័យ និង ភូមិបង្កើនផល ឃុំរមទម ស្រុករវៀង។ ក្រៅពីភូមិឃុំទាំងនេះ យើងបានចុះទៅដល់ភូមិឃុំមួយចំនួនទៀត ដើម្បីសាកសួរព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងខ្លឹមសារនៃគម្រោងស្រាវជ្រាវនេះ ដូចជា ភូមិថ្មល់កោង ឃុំរំដោះ និងភូមិភ្នំដែក ឃុំរម្យណីយ ស្រុករវៀងជាដើម។

អន្តោគ្រាមកួយចែកចេញជាច្រើនពួក ដូចជា កួយ កួយនត្រា កួយដំរី កួយអន្ទរ កួយនលី កួយគ្រេល។ បើតាមការអះអាងរបស់លោក Étienne Aymonier ថា អន្តោគ្រាមកួយមានបីក្រុម គឺ កួយដែក (ចេះជំនាញខាងសិប្បកម្មស្លដែក) កួយកន្តេល (ចេះជំនាញខាងត្បាញកន្ទេល) និងកួយដំរី (ចេះជំនាញខាងថែទាំដំរីឱ្យព្រះរាជា)។ តាមកិច្ចសម្ភាសន៍ជាមួយលោកតា ចាន់ មៀន ជាអាចារ្យរស់នៅភូមិបង្កើនផលបានមានប្រសាសន៍ថា អន្តោគ្រាមកួយមានបី ឬបួនប្រភេទគឺ កួយអន្ទ្រី កួយអន្ទរ កួយអឹក (ឬអក) និងកួយក្លង់។ លោក Étienne Aymonier អះអាងទៀតថា ក្រុមអន្តោគ្រាមកួយច្រើនមានកម្ពស់ទាប មានសម្បុរសណ្តែកបាយ។ កួយប្រុសច្រើនស្លៀកខោខ្លីឬសំពត់ចងក្បិន ពាក់អាវបំពង់ជ្រលក់ពណ៌ខ្មៅ។ ចំណែកឯកួយស្រីវិញស្លៀកសំពត់សំឡុយពាក់អាវបំពង់ ហើយទុកសក់បួងគ្រប់គ្នា។ លក្ខណៈពិសេសនៃកួយនេះ គឺដើរលឿន ពូកែរែកពុន ឬទូល ហើយពូកែអត់ធន់នឹងការហត់នឿយទៀតផង។ កួយមិនចេះខ្លាចសត្វសាហាវទេ។

## ១- របៀបនៃការថែទាំនិងគាំពារកុមារ

ការថែទាំស្ត្រីពេលមានផ្ទៃពោះ មានការចូលរួមពីបងប្អូន ចាស់ទុំ និង ឆ្មបរហូតដល់ស្ត្រីសម្រាលកូនរួច។ ក្នុងការថែទាំនេះ គេមានត្រណមមួយចំនួន ដូចជាហាមធ្វើការងារធ្ងន់ ហាមមិនឱ្យបរិភោគផ្លែត្រប់ពុតលំញង ផ្លែល្ពៅ ត្រយូងចេក ព្រោះគេយល់ថា ជាប្រភេទបន្លែរបស់ព្រាយដែលហូបទៅធ្វើឱ្យស្ត្រីពិបាកក្នុងការសម្រាលកូន។ នៅភូមិខ្លះ គេតមមិនហូបបបរ ព្រោះគេយល់ថា ការហូបបបរនាំឱ្យទារកផៅ (ថ្លោស) ពិបាកសម្រាល។ ក្រោយពេលស្ត្រីសម្រាលកូន គេអាំងភ្លើងក្នុងរយៈពេលពីរបីថ្ងៃទៅមួយសប្តាហ៍និងមានរៀបចំពិធីផ្សេងៗទៅតាមប្រពៃណី ដូចជា ពិធី

ទម្លាក់ជើងក្រាន (ពិធីបង្កក់កូន)ជាដើម។ ក្រៅពីនេះ គេមានថ្នាំរក្សាសុខភាព(រក្សាគភ៌) ដែលផ្សំពីដើមដំបងដំរី ដើមសក់នាង ល្វ និងតាចុកដំរីជាដើម ដែលគេយកមកត្រាំស្រា ឬ ដាំទឹកផឹក។

**២- ការផលិតនិងការរក្សាទុកម្ហូបអាហារ**

អាហារដែលអន្លោគ្រោមកួយបរិភោគមានសត្វឈ្លូស ប្រើស ទន្សាយ ខ្ទីង ជ្រូកព្រៃ មាន់ព្រៃ អណ្តើក ត្រកួត កាំប្រម៉ានិងត្រីជាដើម។ អាហារទាំងនេះត្រូវបានគេយកមកអាំង ឬជុតសម្រាប់បរិភោគ។ ការរុករកអាហារ ច្រើនធ្វើឡើងតាមរយៈការបរបាញ់ ការដាក់អន្ទាក់និងការនេសាទជាដើម។ ដោយឡែក អន្លោគ្រោមកួយមានម្ហូបពីរមុខដែលមានលក្ខណៈពិសេស គឺសម្លកកូរនិងម្ហូបគ្រឿងខ្មៅ។

**៣- ជំនឿ ប្រពៃណី និង ទំនៀមទម្លាប់**

អន្លោគ្រោមកួយមានជំនឿទៅលើ អារក្ស អ្នកតាភ្នំ ដើមឈើធំៗ ថ្ម ដំបូកខ្ពស់ ព្រលឹងជីដូនជីតា ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនាផងដែរ។ ការគោរពជំនឿទាំងនេះ ស្តែងចេញតាមរយៈការបន់ស្រន់ ការសែនព្រេន និងពិធីបុណ្យផ្សេងៗ។ លក្ខណៈពិសេសដែលជាប្រពៃណីរបស់អន្លោគ្រោមកួយ គឺពិធីសំពះពូកខ្នើយនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍, ពិធីបុណ្យផ្កាស្រូវ, ពិធីបុណ្យសព (តាមប្រពៃណីការជ្រើសប្រភេទឈើមកធ្វើមឈូសគឺ ឪពុកដើមស្វាយ ម្តាយដើមគគី ដោយគេលុងធ្វើមឈូសតាមទំហំនៃសព។ សពភាគច្រើនគេយកទៅបញ្ចុះ, ពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធ និង ពិធីបុណ្យផ្សេងៗទៀតមានលក្ខណៈដូចខ្មែរដែរ ដូចជា ពិធីបុណ្យភ្ជុំបិណ្ឌនិងពិធីបុណ្យចូលឆ្នាំជាដើម។

**៤.ចម្រៀង តន្ត្រី និង របាំ**

ចម្រៀងដែលអន្លោគ្រោមច្រៀង មានបទចម្រៀងមួយចំនួនដូចគ្នានឹងបទចម្រៀងខ្មែរដែរ តែក៏មានបទចម្រៀងមួយចំនួនប្លែកពីចម្រៀងរបស់ខ្មែរយើង ដូចជា បទ "តាឡេក" បទចម្រៀងក្នុងពិធីបញ្ជាន់សន្លុង (របាំស្លដែក) ជាដើម។ ចំពោះឧបករណ៍តន្ត្រីភាគច្រើនជាឧបករណ៍តន្ត្រីរបស់ខ្មែរ។ ការប្រគំតន្ត្រីមួយចំនួនក៏ដូចខ្មែរដែរ ប៉ុន្តែមានការខុសប្លែកគ្នាខ្លះនៅក្នុងទំនុកច្រៀង។ លក្ខណៈពិសេសនៃរបាំរបស់អន្លោគ្រោមកួយ គឺរបាំវាយខែល (របាំនេះមានលក្ខណៈជាកីឡាផងដែរ) របាំស្លដែក ឬ របាំជាន់សន្លុង។ ក្រៅពីនេះ គេមានក្បាច់គុណមួយចំនួន ដូចជា ក្បាច់គុណដំបង ក្បាច់គុណដាវ ក្បាច់បោកចម្បាប់ ក្បាច់ទល់អង្រែ ក្បាច់ប្រដាល់ និងក្បាច់វាយខែលជាដើម។ ក្បាច់គុណទាំងនេះ មានលំនាំដូចក្បាច់គុណរបស់ខ្មែរ។

**៥- សំណង់ផ្ទះ**

សំណង់របស់អន្លោគ្រោមកួយពុំមានម៉ូដឬក្បាច់ចម្លាក់អ្វីឡើយ។ ប្រភេទសំណង់ដែលគេសង់ គឺខ្ពស់ពីដីដែលមានសសរពីរឬប្រាំមួយទៅប្រាំបួន ដោយដុំសំបកចេញកយកប់ទៅក្នុងដី។ ផ្ទះមានប្រវែងពីបួនទៅប្រាំម៉ែត្រ កម្ពស់មួយម៉ែត្រពីដី ជញ្ជាំងធ្វើពីសំបកឈើឬកន្ទុំឫស្សី ដំបូលធ្វើពីស្លឹកខ្ទែង(ស្លឹករឹត)។ ក្នុងភូមិប៉ាលហាល គេនិយមសង់ផ្ទះបែរទៅរកទិសខាងជើងឬខាងកើត។ ឯនៅក្នុងភូមិប្រមេរវិញ គេនិយមសង់ផ្ទះដោយដាក់ដំបូងស្របតាមបណ្តោយថ្ងៃ។

**៦- ឱសថ** (ព្យាបាលជំងឺ)

ឱសថសម្រាប់ព្យាបាលជំងឺ គេផ្សំពីឫសឈើ សំបកឈើ ស្លឹកឈើ ដើមឈើ ដោយយកមកត្រាំស្រា ឬ ដាំទឹក ផឹក។ ឱសថទាំងនេះព្យាបាលជំងឺបានច្រើនមុខដូចជា ឈឺពោះ ហើមពោះ ឬ ទល់លាមក (សម្រាប់កុមារ) ក្អួតចង្អោរ គ្រុនអណ្តើក (គ្រុនចាញ់) រក្សាគភ៌ជាដើម។

**៧- មុខរបរ**

អន្លោគ្រោមកួយប្រកបការងារធ្វើស្រែចម្ការ ដួសជ័រ និងសិប្បកម្ម។ សិប្បកម្មៈ តម្បាញសូត្រ តម្បាញអំបោះ ក្រម៉ា ធ្វើរទេះ និង ស្លដែក។ ក្រៅពីនេះ គេចេះធ្វើត្បាល់ក្តឿង ត្បាល់បុក នង្គ័ល រនាស់ជាដើម។

**៨- ការការពារបរិស្ថាន**

អន្លោគ្រោមកួយមានការរក្សាបរិស្ថាន ព្រៃឈើ សត្វព្រៃ បានច្រើននៅសម័យដើម។ គេមានការកាប់ព្រៃនិងដុតព្រៃក្នុងពេលដែលមានតម្រូវការប៉ុណ្ណោះ ដូចជា ការដុតពនព្រៃសម្រាប់ធ្វើស្រែចម្ការនិងការកាប់ឈើមកធ្វើផ្ទះជាដើម។ ដោយឡែក ចំពោះរបៀបរស់នៅវិញពុំមានលក្ខណៈល្អស្អាតប៉ុន្មានទេ ដូចជា ការហូបចុក កង្វះទឹកស្អាត គ្មានបង្គន់អនាម័យ និង សម្លៀកបំពាក់ពុំគ្រប់គ្រាន់ជាដើម។

**៩-ការគ្រប់គ្រងទឹក(ការប្រើប្រាស់និងការរក្សាទឹក)**

ប្រភពទឹកសម្រាប់ប្រើប្រាស់មាន ទឹកស្ទឹង បឹង អូរ ជាដើម។ មធ្យោបាយក្នុងការយកទឹកមករក្សាទុក គឺយកកញ្ចើឬល្អីដែលលាបជ័រដួសយកមករក្សាទុក។ ការរក្សាទឹក

ទុកនេះ បានតែបន្តិចបន្តួចប៉ុណ្ណោះ ដោយពុំមានសម្ភារៈសម្រាប់ផ្ទុកទឹកបានច្រើនឡើយ។

**១០- ការផ្ទេរចំណេះដឹង**

ការផ្ទេរចំណេះដឹង ធ្វើឡើងតាមរយៈការចូលរួមជួយមើលឬសង្កេត និង បង្ហាត់បង្រៀនពីឪពុកទៅកូន ពីបងទៅប្អូន ដូចជាចំណេះដឹងរបស់ឆ្មប ការថែទាំកុមារ ការបរបាញ់ ការផ្សំឱសថ តន្ត្រី របាំ របៀបធ្វើស្រែចម្ការ និង សិប្បកម្មជាដើម។ បច្ចុប្បន្ន ចំណេះដឹងដើមទាំងនេះ បងប្អូនកួយភាគច្រើនពុំមានការចេះចាំបានច្រើនទេ ដោយពុំមានការបង្ហាត់បង្រៀនបន្តជាក្បួនខ្នាតច្បាស់លាស់ដល់ក្មេងជំនាន់ក្រោយឡើយ។

ជារួម យើងឃើញថា លទ្ធផលនៃការស្រាវជ្រាវដែលបានបង្ហាញជូនខាងលើនេះ គឺជាសមិទ្ធផលឬជាទិន្នន័យមួយដែលជាមូលដ្ឋានសម្រាប់ឱ្យជនអន្តោគ្រាមនិងជាតិខ្មែរបានស្គាល់ពីស្ថានភាពពិតពីអតីតកាលរបស់អន្តោគ្រាមកួយនៅខេត្តព្រះវិហារ។ ក្នុងទិន្នន័យដែលយើងទទួលបាននេះ បង្ហាញឱ្យដឹងថា អន្តោគ្រាមកួយមានលក្ខណៈពិសេសជាងអន្តោគ្រាមផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ អ្វីដែលយើងចាត់ទុកថាមានលក្ខណៈពិសេសនោះ បើតាមឯកសារលោកកែប វ៉ាន់ឌី និយាយពីអរិយធម៌ខ្មែរ-មនបានបង្ហាញថា "អន្តោគ្រាមកួយធ្លាប់មានឈ្មោះល្បីល្បាញ ដោយមានវីរបុរសជាតិគេម្នាក់ឈ្មោះ "ពោកំបោរ" ជាមេបដិវត្តិន៍ ប្រឆាំងនឹងពួកអាណានិគមនិយមបារាំងនិងមានកិត្តិសព្ទល្បីរន្ទឺលើផ្នែកបច្ចេកទេសស្លដែក។ ក្រោយមក អន្តោគ្រាមកួយ មានការវិវឌ្ឍមុនគេខាងរបៀបរស់នៅនិងផ្នែកផ្សេងៗទៀត ដូចជាសិល្បៈ ទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនាជាលក្ខណៈខ្មែរទូទៅ។ ការសន្និដ្ឋាននេះ ដោយហេតុថា៖

១-ក្នុងចំណោមបងប្អូនកួយដែលមានអាយុជិត ៧០ឆ្នាំទៅហើយនោះ ពុំធ្លាប់ដឹងឬឮពាក្យថា មានមេកន្ទ្រាញគ្រប់គ្រងភូមិឬសហគមន៍របស់គេនោះឡើយ។ គេធ្លាប់តែឮពាក្យថា មេភូមិ ប្រធានភូមិ មេឃុំ ឬ ជំទប់ប៉ុណ្ណោះ ដែលពាក្យជនជំទប់នេះ ខ្មែរយកមកប្រើតាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ។

២-នៅតំបន់ដែលបងប្អូនកួយរស់នៅមានវត្តអារាមព្រះពុទ្ធសាសនាតាំងពីយូរយារណាស់មកហើយ។

៣.សម្ភារៈដែលគេប្រើប្រាស់ក្នុងការបរបាញ់សត្វ គឺបានប្តូរពីការប្រើស្នាបែបបុរាណមកជាការប្រើកាំភ្លើងជាយូរមកហើយ។

៤. អន្តោគ្រាមកួយចេះត្បាញរវៃនិងប្រើប្រាស់សម្លៀកបំពាក់ ជាពិសេសហូល ផាមួងដូចខ្មែរដែរ។

៥. បច្ចុប្បន្ន យើងស្ទើរតែមិនអាចរកបាននូវសម្ភារៈនានា ដែលអន្តោគ្រាមកួយធ្លាប់ប្រើប្រាស់នៅក្នុងសម័យបុរាណ។ ផ្ទុយទៅវិញ យើងបានឃើញត្រឹមតែសម្ភារៈបែបប្រពៃណីដែលខ្មែរកណ្តាលធ្លាប់ប្រើប្រាស់ប៉ុណ្ណោះ។ ក្រៅពីលក្ខណៈពិសេសនេះ យើងបានរកឃើញនូវអ្វីដែលថ្មី និងគួរឱ្យកត់សម្គាល់គឺ៖

-ព័ត៌មានពិស្តារអំពីរបាំស្លដែកឬរបាំជាន់សន្លុង

-របាំវាយខែលឬកីឡាវាយខែល ដែលកន្លងមកគេធ្លាប់ហៅថា របាំវាយកួយ

-បានដឹងពីអត្ថន័យនៃពាក្យថា ឥន្ទធនូ ឥន្ទ្រើ អ៊ើក (អក) ក្លង់ ដែលមានន័យថា ចាំ បាទ

-មុខម្ហូបមួយចំនួនដែលប្លែកពីមុខម្ហូបរបស់ខ្មែរ ទូទៅដូចជា សម្លកកូរនិងម្ហូបគ្រឿងខ្មៅ។ ក្នុងទិសដៅអភិរក្ស និងអភិវឌ្ឍន៍លើចំណេះដឹងជនអន្តោគ្រាមកួយ យើងសូមលើកនូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងអប់រំ យុវជន និង កីឡា អង្គការក្រៅរដ្ឋាភិបាលនានា ដែលពាក់ព័ន្ធនឹងការអប់រំ និង ការអភិរក្សនូវចំណេះដឹងដើមរបស់មនុស្សជាតិ គួរតែប្រឹងប្រែងបន្ថែមទៀត ក្នុងការផ្តល់លទ្ធភាពចំពោះការស្រាវជ្រាវ ចងក្រងនូវពុទ្ធិទាំងនេះ ដោយបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ជាតិនិងចងក្រងឯកសារស្រាវជ្រាវ។

- ត្រូវបំផុសឱ្យអន្តោគ្រាមកួយ ប្រកបការងារសិប្បកម្មដែកឡើងវិញ
- គួរផ្តល់ឥណទាននិងបច្ចេកវិទ្យាទំនើបដល់អ្នកដែលស្ម័គ្រចិត្តធ្វើសិប្បកម្មស្លដែក
- គួរបន្តសិក្សាស្រាវជ្រាវបន្ថែម ទៅលើរបាំស្លដែក (របាំជាន់សន្លុង) ដើម្បីឈានទៅជំឡើងរបាំ(ក្បាច់រាំ បទភ្លេងនិងទំនុក ច្រៀង ដោយរក្សាអត្តសញ្ញាណអន្តោគ្រាមកួយ

- គួរជំរុញឱ្យមានការបន្តអភិរក្សនិងអភិវឌ្ឍន៍ប្រពៃណីកីឡាវាយខែល (របាំវាយខែល) របាំស្លដែក (របាំជានសន្លុង) និង ពិធីជាប្រពៃណីផ្សេងៗទៀត ដើម្បីរួមចំណែកក្នុងការទាក់ទាញទេសចរ។
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈគួរពិចារណាឡើង វិញអំពីឈ្មោះ "របាំវាយក្អួយ" ពីព្រោះតាមទិន្នន័យនៃការ ស្រាវជ្រាវរបាំនេះ បងប្អូនក្អួយ នៅខេត្តព្រះវិហារ បានហៅ ថា "របាំវាយខែល"។
- បំផុសឱ្យមានការអប់រំបន្ថែមដល់បងប្អូនខ្មែរលើក្អួយនូវចំណេះដឹងទូទៅ និង មុខជំនាញផ្សេងៗទៀត។
- រាជរដ្ឋាភិបាលគួរបង្កើតឱ្យបានឆាប់នូវស្ថានីយទូរទស្សន៍ផ្សាយបន្ត ដើម្បីការរួមចំណែកក្នុងការផ្តល់ពុទ្ធិដល់បងប្អូនខ្មែរក្អួយនិងប្រជាជនខ្មែរក្នុងខេត្តព្រះវិហារ។
- បង្កើតមជ្ឈមណ្ឌលឯកសារ នៅក្នុងតំបន់ដែលមានអន្លោគ្រាមក្អួយរស់នៅច្រើន។

# បញ្ញត្តិស្តីពីសីលធម៌ផ្លូវកណ្តាលក្នុងបរិបទសង្គមខ្មែរ



លោក **ឈត ប៊ុនថង**
បេក្ខជនបណ្ឌិត ផ្នែកទស្សនវិជ្ជា
នៃរាជបណ្ឌិត្យសភាកម្ពុជា

ជាទូទៅនៅក្នុងសង្គមខ្មែរ ប្រជាជនបានដឹងអំពីបញ្ញត្តិផ្លូវកណ្តាលនេះ ជាពិសេសពួកគេបានទទួលឥទ្ធិពលនៃផ្លូវកណ្តាលនេះពីព្រះពុទ្ធសាសនា «កុំធូរពេក (វាមិនពីរោះ) តែកុំតឹងពេក (វាដាច់) ត្រូវរឹតឱ្យតឹងល្មម (ទើបវាពីរោះ)» នេះគឺជាការប្រកាន់គោលជំហរកណ្តាលសម្រាប់ដឹកនាំជីវិតបុគ្គល ជីវិតគ្រួសារនិងជីវិតសង្គមតាមបែបព្រះពុទ្ធសាសនា។ ដោយឈរលើមូលដ្ឋាននេះ ការអប់រំណែនាំកូនចៅរបស់ខ្លួន ចាស់ទុំខ្មែរតែងតែបានលើកឡើងនូវពាក្យប្រៀនប្រដៅមួយចំនួនដូចជា៖

ក)«ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់កុំដើរហោង» មានន័យថា ក្នុងលក្ខខណ្ឌ មនុស្សត្រូវតែដើរតាមផ្លូវត្រង់ មិនកុតកុហក មិនប្រព្រឹត្តអាក្រក់ឬអសីលធម៌ដើម្បីដោះស្រាយបញ្ហា ឬសម្រេចគោលបំណងល្អរបស់ខ្លួនឡើយ។ ប៉ុន្តែក្នុងករណីពិសេសដោយឡែកណាមួយ ដែលចំពោះមុខបុគ្គលឬក្រុមណាមួយត្រូវប្រឈមជាមួយអំពើអសីលធម៌ដោយចៀសមិនរួចនោះ បុគ្គលឬក្រុមនោះ ត្រូវជ្រើសរើសយកអំពើអសីលធម៌ណាមួយដែលឱ្យមានកំហុសខាងសីលធម៌ស្រាលជាងគេបំផុត ដើម្បីដោះស្រាយបញ្ហាឬសម្រេចបំណងល្អនោះ ប៉ុន្តែពួកគេមិនត្រូវគិតថាគេត្រូវតែប្រើវិធីអសីលធម៌នេះដើម្បីដោះស្រាយរាល់បញ្ហានិងគ្រប់ពេលនោះទេ។ ឧទាហរណ៍ ជាទូទៅយើងត្រូវស្មោះត្រង់ចំពោះគ្រួសារអ្នកជិតខាងល្អនិងស្ថាប័នជាតិរបស់យើងដែលត្រឹមត្រូវ ប៉ុន្តែយើងមិនអាចស្មោះត្រង់ឬនិយាយការណ៍ពិតចំពោះមេដឹកនាំសម័យប៉ុល ពត ចំពោះចោរ មនុស្សអាក្រក់ ក្រុមចាប់ជំរិតឬភេរវជននោះទេ។

ខ)«សន្សឹមកុំបំបោល ក្រែងមិនដល់ដូចប្រាថ្នា» មានន័យថា បើធ្វើអ្វីមួយ ត្រូវមើលកាលៈទេសៈ ស្ថានភាព និងត្រូវប្រព្រឹត្តទៅតាមកម្លាំង តាមវ័យ តាមសមត្ថភាពរបស់ខ្លួនកុំលឿនពេកហួសល្បឿនកំណត់ ហួសល្បឿនសុវត្ថិភាព ហួសកម្លាំងនិងហួសសមត្ថភាពនិងលទ្ធភាពដែលយើងអាចធ្វើបាន។ ទីបំផុតយើងអាចមិនបានសម្រេចគោលបំណង ឬអាចទទួលគ្រោះថ្នាក់ឬបរាជ័យ។

គ)«បើចូលស្ទឹងឱ្យតាមបទ» មានន័យថា ក្នុងការធ្វើអ្វីមួយត្រូវពិនិត្យមើលកាលៈទេសៈ ស្ថានភាពនិងត្រូវប្រព្រឹត្តទៅតាមលំនាំនិយាមឬបរិបទជាក់លាក់មួយ។ យើងមិនអាចគិត ធ្វើសេចក្តីសម្រេចចិត្ត ប្រកាន់គោលជំហរនិងប្រព្រឹត្តអំពើណាមួយដោយមិនបានផ្សារភ្ជាប់ឬផ្អែកលើបរិបទជាក់លាក់ណាមួយនោះបានទេ។ បើមិនដូច្នោះទេ នាំឱ្យការគិត ការសម្រេចចិត្ត គោលជំហរនិងការប្រព្រឹត្តរបស់យើងត្រូវជួបឧបសគ្គ គ្រោះថ្នាក់មិនមានការគាំទ្រឬបរាជ័យមិនខានឡើយ។

ឃ)«ចេះឯងឱ្យក្រែងចេះគេ» មានន័យថា ទោះបីជាយើងមានចំណេះដឹង បទពិសោធន៍ វិធី ល្បិច ទេពកោសល្យ កម្លាំងនិងបញ្ញាខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏យើង មិនត្រូវធ្វេសប្រហែសឬប្រមាថដៃគូប្រកួតឬសត្រូវរបស់ យើងដែរ។ ប្រសិនបើយើងប្រមាថចំពោះដៃគូប្រកួតប្រជែង ឬសត្រូវរបស់យើងនោះ យើងអាចចាញ់ល្បិចរបស់គេ និង អាចបរាជ័យជាយថាហេតុ ពីព្រោះ ថាទោះបីជាយើងមានទស្សនវិជ្ជាខ្ពស់ មានចិត្តសាស្ត្រជ្រៅជ្រះ មានការវាយតម្លៃប្រកបដោយគតិបណ្ឌិតក៏ដោយ ក៏យើងមិនអាចព្យាករ និងវាយតម្លៃសមត្ថភាព លទ្ធភាព និង សក្តានុពលរបស់ដៃគូប្រកួតប្រជែងឬសត្រូវរបស់យើងបានគ្រប់ជ្រុងជ្រោយមួយរយភាគរយដែរ។ ហេតុនេះ មានតែការចេះប្រមាណ ចេះក្រែង ចេះប្រយ័ត្នដែលជាផ្លូវកណ្តាលនេះទេ ទើបអាចធ្វើឱ្យយើងទទួលបានជោគជ័យសមតាមសេចក្តីប្រាថ្នារបស់យើងភាគច្រើន។

ង) «បើធ្វើបុណ្យជាមួយព្រះនៅឯវត្ត ចូរកុំភ្លេចធ្វើបុណ្យជាមួយព្រះកន្លោងនៅឯផ្ទះ» គំនិតនេះចាស់ទុំខ្មែរចង់ដាស់តឿនចំពោះមនុស្សខ្លះ ដែលបានប្រព្រឹត្តខុសដោយការ

យល់ច្រឡំថាមានតែការធ្វើបុណ្យជាមួយព្រះសង្ឃនៅឯវត្ត ប៉ុណ្ណោះទេ ទើបបានបុណ្យ ម្ល៉ោះហើយពួកគេបានផ្តោតការយកចិត្តទុកដាក់តែទៅលើការយកចង្ហាន់តង្វាយ គ្រឿងឧបភោគបរិភោគផ្សេងៗទៅប្រគេនតែព្រះសង្ឃដែលគង់នៅឯវត្ត ហើយមិនសូវអើពើចំពោះមាតាបិតា ជីដូនជីតារបស់ខ្លួនដែលជាអ្នកមានគុណនៅឯផ្ទះ ជាព្រះដ៏ធំនិងសំខាន់របស់ខ្លួន។ លើសពីនេះទៀត ពេលខ្លះ ក្រុមមនុស្សខ្លះដែលយល់ច្រឡំនោះមិនគ្រាន់តែមិនបានផ្តល់ម្ហូបអាហារ គ្រឿងឧបភោគបរិភោគផ្សេងៗដល់ឪពុកម្តាយ ជីដូនជីតារបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើសម្តីប្រមាថអ្នកមានគុណរបស់ពួកគេផងដែរ។ ការយល់ខុសនិងទង្វើភាន់ច្រឡំទាំងនេះ គួរចៀសវាងឱ្យបាន តាមពិតស្រែបុណ្យមិនមែនតែព្រះសង្ឃនោះទេ ឪពុក ម្តាយ ជីដូន ជីតា និង ជនងាយរងគ្រោះដទៃទៀត ដូចជា ក្មេងកំព្រា ជនពិការ ជនភៀសសឹក។ល។ ក៏អាចជាស្រែបុណ្យរបស់យើងដែរ។

ច)«កុំកំសាក (ហ៊ាន) តែកុំព្រហើន (ខ្លាចពេក) ពេកគឺត្រូវក្លាហាន»គំនិតនេះចាស់ទុំខ្មែរចង់អប់រំកូនចៅកុំឱ្យខិតទៅរកចុងនីមួយៗនៃភាពដាច់ខាត ទីមួយគឺកំសាក ឬខ្លាចពេករត់ចោលគ្រប់សមរភូមិ គ្រប់បញ្ហាទោះបីតូចក្តីធំក្តី មិនហ៊ានប្រឈម មិនរិះរកវិធីដោះស្រាយ ឱ្យតែមានបញ្ហា គឺពួកគេតែងតែបោះបង់ចោលជានិច្ច ដោយមិនបានវាយតម្លៃពីកម្រិតឧបសគ្គនោះឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តបោះបង់ចោល។ ទីពីរ ចង់ព្រមានកូនខ្មែរកុំឱ្យខិតទៅរកចុងមួយទៀតនៃភាពដាច់ខាត គឺព្រហើន(ហ៊ានពេក) ដោយមិនបានពិនិត្យច្បាស់លាស់អំពីកម្លាំងនិងសមត្ថភាពខ្លួនឯង មិនបានវាយតម្លៃពីស្ថានភាពឬកាលៈទេសៈនៃហេតុការណ៍ កម្រិតនៃឧបសគ្គនិងកម្លាំងរបស់គូប្រជែងឬសត្រូវរបស់ខ្លួនមុនពេលសម្រេចចិត្តប្រឈមឬវាយបក។ បើពុំដូច្នោះទេ ការវាយបកទាំងកម្រោលនេះនឹងបរាជ័យយ៉ាងអាម៉ាស់ឬអាចបាត់បង់ជីវិតក៏សឹងមាន។ ទីបី ចង់អប់រំឱ្យកូនខ្មែរប្រកាន់យកផ្លូវកណ្តាលគឺក្លាហាន មានន័យថា មិនព្រហើន តែក៏មិនកំសាកដែរ គឺត្រូវចេះប្រមាណពីកម្លាំងនិងសមត្ថភាពខ្លួនឯង វាយតម្លៃពីស្ថានភាពឬកាលៈទេសៈនៃហេតុការណ៍កម្រិតនៃឧបសគ្គនិងកម្លាំងរបស់គូប្រជែងឬសត្រូវរបស់ខ្លួនមុនពេលសម្រេចចិត្តថាត្រូវប្រឈមវាយបកឬដកថយ។ ក្លាហាន មានន័យថា ពេលខ្លះត្រូវហ៊ានប្រឈមឬវាយបកវិញ ដើម្បីការពារខ្លួនឬដណ្តើមយកជោគជ័យនៅពេលដែលកម្លាំងនិងលទ្ធភាព សមត្ថភាពរបស់ខ្លួនគ្រប់គ្រាន់។ ប៉ុន្តែពេលខ្លះទៀតត្រូវដកថយជាយុទ្ធសាស្ត្រដើម្បីរៀបចំខ្លួនពង្រឹងសមត្ថភាពនិងយុទ្ធសាស្ត្រឱ្យបានសមល្មម ទើបត្រូវវាយបកជាក្រោយ។ វាជាអំពើអសីលធម៌មួយពេលដែលអ្នកណាម្នាក់ឬក្រុមណាមួយប្រកាសសង្គ្រាមជាមួយមនុស្សម្នាក់ឬក្រុមផ្សេងទៀតនៅពេលដែលគេដឹងយ៉ាងច្បាស់ថា គេមិនអាចយកឈ្នះលើបច្ចាមិត្តរបស់គេ ហើយជាលទ្ធផលគេនឹងខាតបង់ទ្រព្យសម្បត្តិ រងរបួស បាត់បង់ជីវិតឬត្រូវសងការខូចខាតដល់គូសត្រូវរបស់គេទៅតាមច្បាប់សង្គ្រាម។

ឆ)«កុំកំណាញ់តែកុំខ្ជះខ្ជាយគឺត្រូវសប្បុរស» គំនិតនេះ ចាស់ទុំខ្មែរចង់អប់រំប្រជាជនខ្មែរទាក់ទងនឹងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនឱ្យបានត្រឹមត្រូវ។ ប្រសិនបើយើងរកបានលុយ ហើយចូរកុំឱ្យកំណាញ់ហួសហេតុពេករហូតដល់សូម្បីតែការចំណាយសម្រាប់ខ្លួនឯងនិងគ្រួសារលើតម្រូវការមូលដ្ឋានក៏មិនហ៊ានចំណាយ ហាក់ដូចកំពុងធ្វើបាបខ្លួនឯងប៉ុន្តែយើងក៏មិនគួរចំណាយខ្ជះខ្ជាយពេកលើការទិញអ្វីមួយលើសពីតម្រូវការចាំបាច់របស់យើងដែរ។ យ៉ាងណាមិញ យើងគួរប្រើប្រាស់លុយដើម្បីទិញនូវអ្វីដែលគួរទិញសម្រាប់ខ្លួនឯងនិងគ្រួសារ និង ត្រូវមានចិត្តសប្បុរសចែករំលែកធនធានទៅតាមលទ្ធភាពជួយទៅដល់ការអភិវឌ្ឍសហគមន៍ឬជនដែលងាយរងគ្រោះ ដូចជា អ្នកក្រ កុមារកំព្រា ជនពិការ ជនភៀសខ្លួន ជាដើម។

ជ)«គ្រូកាច សិស្សខូច» គំនិតនេះ ចាស់ទុំខ្មែរចង់ដាស់តឿនប្រជាជនខ្មែរឱ្យអប់រំកូនដោយប្រើវិធីកណ្តាលកុំកាចពេក តឹងពេក តែកុំស្លូតពេកដែរ។ ក្នុងការអប់រំកូន ឬសិស្សរបស់ខ្លួន ប្រសិនបើឪពុកម្តាយឬលោកគ្រូអ្នកគ្រូ ប្រើវិធីស្លូតឬធូរលុងពេក កូនឬសិស្សរបស់ខ្លួនមិនស្តាប់បង្គាប់ មិនយកចិត្តទុកដាក់នឹងការរៀនសូត្រឬការងារឡើយ ដែលជាលទ្ធផល កូនឬសិស្សរបស់ពួកគេអាចក្លាយទៅជាមនុស្សមិនមានសីលធម៌ រៀនមិនចេះ ឬ ក្លាយទៅជាមនុស្សដែលមិនសូវមានប្រយោជន៍សម្រាប់សង្គម។ ផ្ទុយទៅវិញ ប្រសិនបើឪពុកម្តាយឬលោកគ្រូអ្នកគ្រូ ប្រើវិធីតឹងតែងពេកដោយមិនគិតពីលក្ខណៈធម្មជាតិរបស់ក្មេងនោះ កូនឬសិស្សរបស់ខ្លួនអាចបាក់ទឹកចិត្ត មានការភិតភ័យ ខ្សោយបញ្ញា មានគំនិតគុំកួនឬចេះប្រើល្បិចកូតករដើម្បីឆ្លើយតបទៅនឹងភាព

តឹងតែងរបស់ឪពុកម្ដាយឬគ្រូរបស់គេទៅវិញ។ ជាលទ្ធផល កូនឬសិស្សរបស់ពួកគេអាចក្លាយទៅជាមនុស្សមិនមាន សីលធម៌ រៀនមិនចេះឬក្លាយទៅជាមនុស្សខិលខូចមិនស្មោះត្រង់ ដែលអាចផ្ដល់ភាពស្មុគស្មាញកាន់តែខ្លាំងដល់គ្រួសារនិងសង្គម។ ដូច្នេះវិធីល្អបំផុតសម្រាប់អប់រំកូនឬសិស្សរបស់គេ គឺត្រូវកាន់យកផ្លូវកណ្ដាលមួយ ពោលគឺត្រូវសំយោគរវាងសេចក្ដីស្រឡាញ់ពិត ហេតុផលនិងវិន័យ មានន័យថា ឪពុកម្ដាយឬគ្រូត្រូវប្រើវិធីទន់ភ្លន់អហិង្សាប្រកបដោយសេចក្ដីស្រឡាញ់ពិត ការយោគយល់អនុគ្រោះនិងពន្យល់ហេតុផលនៅពេលដែលក្មេងមានកំហុស ប៉ុន្តែពួកគេក៏គួរបង្ហាញថាអំពើណាខុស អំពើណាត្រូវ អំពើណាគួរធ្វើនិងអំពើណាមិនគួរធ្វើដែរ។ ពួកគេមិនត្រូវស្រឡាញ់កូនឬសិស្សរបស់ខ្លួនរហូតដល់មិនបានទប់ស្កាត់ឬមិនគិតអំពីត្រូវនិងខុសនោះទេ។ ការធ្វើបែបនេះ មិនមានន័យថាពួកគេ ស្រឡាញ់កូនឬសិស្សរបស់គេនោះទេ ផ្ទុយទៅវិញ គឺពួកគេកំពុងធ្វើបាបកូនឬសិស្សរបស់គេដោយមិនដឹងខ្លួនទៅវិញទេ។

ឈ)«កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់» គំនិតនេះចាស់ទុំខ្មែរចង់ទូន្មានថា ជាធម្មតា ដើម្បីរស់ មនុស្សត្រូវបរិភោគអាហារ ប៉ុន្តែការបរិភោគក៏ត្រូវតែគិតទៅតាមរបបអាហារត្រឹមត្រូវ សមស្របតាមវ័យ សមស្របតាមកម្លាំងដែលយើងបញ្ចេញនិងសមាមាត្រទៅតាមប្រភេទអាហារ ដូចជាអាហារស្ថាបនា(សាងសង់) អាហារថាមពលនិងអាហារការពារ។ ម្យ៉ាងទៀតអាហារដែលយើងចង់បរិភោគមិនមែនសុទ្ធតែជាតម្រូវការរបស់យើងទេ។ ក្រៅពីនេះ យើងត្រូវគិតថាតើប្រភេទអាហារណាដែលត្រូវតមឬជៀសវាងតាមវេជ្ជបញ្ជាក្នុងដំណាក់កាលព្យាបាលជំងឺ ប្រភេទអាហារណាខ្លះដែលគួរបរិភោគឬមិនគួរបរិភោគ ដោយហេតុផលថាតើវាមានប្រយោជន៍ដល់សុខភាពឬអត់ មានជាតិគីមី មានអនាម័យ ឬ មានសុវត្ថិភាពដែរឬអត់។ លើសពីនេះទៀត បើអាហារមានចំនួនតិចក៏យើងមិនត្រូវបរិភោគតែម្នាក់ឯងដែរ យើងត្រូវចេះចែករំលែកចំពោះសមាជិកគ្រួសារឬអ្នករួមដំណើរជាមួយយើងផងដែរ សមដូចពាក្យមួយឃ្លាថា «បើស៊ីកុំតាមឃ្លានត្រូវប្រមាណដល់គ្នីគ្នា»។

ក្រៅពីការយល់ដឹងត្រឹមត្រូវពីខ្លឹមសារនៃបញ្ញត្តិផ្លូវកណ្ដាលដូចដែលបានបង្ហាញជូនខាងលើនេះ ក៏មានមនុស្សមួយចំនួនយល់ច្រឡំអំពីបញ្ញត្តិផ្លូវកណ្ដាលនេះដែរ ដូចជាយល់ថាផ្លូវកណ្ដាលគឺត្រូវធ្វើល្អខ្លះនិងធ្វើអាក្រក់ខ្លះឬត្រូវធ្វើបុណ្យខ្លះនិងធ្វើបាបខ្លះជាដើម។ ដោយសារតែការយល់ច្រឡំបែបនេះហើយ ទើបយើងសង្កេតឃើញមានលេចឡើងនូវបាតុភូតអាក្រក់របស់សង្គមមួយចំនួន ដូចជា មានមនុស្សមួយចំនួននៅពេលខ្លះនៅក្នុងជីវិតរបស់គាត់ គាត់បានប្រព្រឹត្តអាក្រក់ ដូចជា ប្រព្រឹត្តអំពើលួច ប្លន់ ចាប់ជំរិត ស៊ីសំណូក ពុករលួយ ជួញដូរខុសច្បាប់និងសម្លាប់មនុស្ស ជាដើម ហើយនៅពេលខ្លះទៀត គាត់បែរជាទៅធ្វើអំពើល្អវិញ ដូចជាធ្វើអំពើសប្បុរស ធ្វើបុណ្យដាក់ទាន ធ្វើបុណ្យកឋិនទាន ជួយកសាងសហគមន៍និងជួយដល់ជនងាយរងគ្រោះជាដើម ដើម្បីលុបលាងកំហុស ឬ បិទបាំងអំពើអាក្រក់របស់ពួកគេទៅវិញ។ ការគិតនិងការធ្វើបែបនេះគឺជាការយល់ច្រឡំយ៉ាងធំ ប្រសិនមានអ្នកយល់ច្រឡំដូចពួកគេកាន់តែច្រើន នោះសង្គមមនុស្សក៏កាន់តែជួបភាពស្មុគស្មាញចលាចលនិងភាពចម្រូងចម្រាសកាន់តែច្រើនដែរ។

តាមពិត <u>ផ្លូវកណ្ដាលគឺកណ្ដាលនៃផ្លូវត្រូវមិនមែនជាផ្លូវមួយដែលចូលទៅក្នុងផ្លូវខុសខ្លះនិងផ្លូវត្រូវខ្លះនោះទេ។</u> ឧទាហរណ៍៖ ផ្លូវអាក្រក់ឬផ្លូវខុសមានចាប់ពី១ភាគរយទៅ ១០០ភាគរយ ឯផ្លូវល្អឬផ្លូវត្រូវក៏មានចាប់ពី១ភាគរយទៅ ១០០ភាគរយដែរ ក្នុងន័យនេះ ផ្លូវកណ្ដាល គឺ៥០ភាគរយឬជុំវិញ៥០ភាគរយនៃផ្លូវត្រូវ។ ម្យ៉ាងទៀត ផ្លូវកណ្ដាលរវាងការស្រឡាញ់និងការស្អប់បែបអត្តទត្ត គឺការស្រឡាញ់ជាសាកល មិនមែនជាការស្រឡាញ់តែខ្លួនឯងនោះទេ។ ផ្លូវកណ្ដាលរវាងការទទួលយកនិងការបដិសេធបែបជ្រុលនិយម គេរកឃើញនៅក្នុងគតិបណ្ឌិត ការស្គាល់ខុសត្រូវ និង សុភនិច្ឆ័យ។ លើសពីនេះទៀត ផ្លូវកណ្ដាលរវាងការចាប់យកអ្វីមួយដ៏ច្រើនលើសលប់សម្រាប់ខ្លួនឯងនិងការព្រងើយកន្តើយចំពោះការចាប់យកអ្វីមួយសម្រាប់ខ្លួនឯង គេរកឃើញ នៅក្នុងការយល់ដឹងពីសមាមាត្រត្រឹមត្រូវដែលបង្ហាញនៅក្នុងសមត្ថភាពយល់ដឹងជាពិសេសនៅក្នុងសមត្ថភាពនៃការយល់ដឹងពីខ្លួនយើង។ ផ្លូវកណ្ដាលមិនមែនជាផ្លូវមួយក្នុងន័យធម្មតានោះទេ ប៉ុន្តែវាគឺជាផ្លូវនៃជីវិត ជាផ្លូវនៃស្មារតីដែលមាននៅក្នុងខ្លួនរបស់យើង មិនមែននៅខាងក្រៅខ្លួនរបស់យើងទេ។ ដូច្នេះ ចូរយើងប្រកាន់ខ្ជាប់នូវផ្លូវកណ្ដាលរបស់យើង។

## គន្ថនិទ្ទេស

១-កៅ គឹមហួន និង ស-សុកន្តផ័យះ *សន្តិភាពផ្លូវចិត្ត* ភ្នំពេញ, វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព ឆ្នាំ១៩៩៦, ១៦៣ទំព័រ។

២-កៅ គឹមហួន និង សំរាំង កំសាន, *វិធីសាស្ត្រខ្មែរក្នុងការដោះស្រាយទំនាស់* ភ្នំពេញ ឆ្នាំ១៩៩៨; ២២៥ទំព័រ។

៣-ក្រសួងអប់រំ យុវជន និង កីឡា, *ច្បាប់ផ្សេងៗ* បោះពុម្ពលើកទី១ រោងពុម្ពក្រសួងអប់រំ ភ្នំពេញ ឆ្នាំ២០០១, ១៨១ទំព័រ។

៤- ខេមរវិទ្យា (ស៊ិន សំណាង អ្នកបោះពុម្ព)៖ *ចំណេះដឹងអំពីអតីតកាលនិងការរួមវិភាគទានក្នុងការ ស្តារនិងស្ថាបនាប្រទេសកម្ពុជាឡើងវិញ* ភាគ២ ភ្នំពេញ រោងពុម្ពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ភ្នំពេញ ឆ្នាំ១៩៩៨; ៥៨៥ ទំព័រ។

៥-ខ្លូត ធីតា, *មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក* ភ្នំពេញ រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ២០០៩; ៣១៨ទំព័រ។

៦- ខ្លូត ធីតា, *ការស្វែងយល់អំពីការវិវត្តព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ* ភ្នំពេញ រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ឆ្នាំ២០០៩; ៣០៧ទំព័រ។

៧- ខ្លូត ធីតា *ទស្សនៈអហិង្សារបស់ព្រះពុទ្ធសាសនានិងសិទ្ធិមនុស្ស* ភ្នំពេញ រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៩៥។

៨- ខ្លូត ធីតា, *អហិង្សាព្រះពុទ្ធសាសនានិងលទ្ធិប្រជាធិបតេយ្យ* ភ្នំពេញ រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ ១៩៩៦។

៩- ង៉ុយ (អ្នកព្រះភិរម្យ ភាសាអ៊ូ), *ច្បាប់ក្រមង៉ុយ* បោះពុម្ពលើកទី៧ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៧២; ៥៨ទំព័រ។

១០- ង៉ុយ (អ្នកព្រះភិរម្យ ភាសាអ៊ូ), *បណ្តាំក្រមង៉ុយ,* បោះពុម្ពថ្មី ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៩៨; ៩៩ ទំព័រ។

១១- ឆយ យីហ៊ាង, *ការចាំបាច់នៃការប្រើប្រាស់បញ្ញត្តិ «អត់ឱន» នៅក្នុងប្រទេសកម្ពុជា* ភ្នំពេញ ឆ្នាំ ១៩៩៦; ២០ទំព័រ។

១២- ឆយ យីហ៊ាង, *ការស្រុតចុះនៃតម្លៃមនុស្សនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន* ភ្នំពេញ ឆ្នាំ២០០០; ៤៩ទំព័រ។

១៣- Alfredo Panizo, O.P., *Ethics or Moral Philosophy*, Second Printing, PPP, Incorporated Quezon City, 1964, 230p.

១៤- Hans Küng and Karl-Josef Kuschel, *A Global Ethic*: *The Declaration of the Parliament of the World's Religions*, special edition, Continuum, New York, The United States of America and CSM Press, London.

១៥- Kalupahana (David J.), *the Buddha and the Concept of Peace*, First Edition, Sri-Lanka: Sarvodaya, Vishva Lekha Publication, 1999, 233p.

១៦- Peter Schier, Konrad Adenauer Foundation, *World Religions: Universal Peace, Global Ethic.*, First edition, Kuala Lumpur, Malaysia, 2005, 42p.

១៧- Lyons (David), *Ethics and the rule of law*, first published, Cambridge University Press, Cambridge, London, New York, 1984, 229p.

# ទំនាក់ទំនងកម្ពុជា សូវៀត ឆ្នាំ១៩៥៦ ដល់ ១៩៩១




លោក **ចាន់ ថុន្នី**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា


## សេចក្តីសង្ខេប


ក្រោយពីទទួលបានឯករាជ្យពីនឹមអាណានិគមបារាំង ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដែលទើបនឹងទទួលបានឯករាជ្យថ្មីៗដទៃទៀតដែរ ត្រូវប្រឈមមុខនឹងបញ្ហាដែលកើតឡើងថ្មីៗក្នុងអំឡុងសង្គ្រាមត្រជាក់។ ប្រទេសកម្ពុជាបានរងគ្រោះយ៉ាងធ្ងន់ធ្ងរពីឥទ្ធិពលនៃសង្គ្រាមត្រជាក់ ដោយសារតែទំនាស់ខាងមនោគមវិជ្ជា ដែលបំផ្លិចបំផ្លាញប្រទេសកម្ពុជាអស់ជាច្រើនទសវត្សរ៍ក្រោយៗមក។ ដូចជា លោក ម៉ៃខល ឡីហ្វ័រ បានសរសេរថា៖ "ចាប់ពីពេលដួលរលំនៃចក្រភពបុរាណខ្មែរមក *ភូមិសាស្ត្របានផ្សារភ្ជាប់ជាមួយនឹងនយោបាយ ដើម្បីរៀបចំជោគវាសនានៃប្រទេសកម្ពុជា*"។ ដូចគ្នានេះដែរ លោក វីល្លាម ស័រក្រូស ជាអ្នកកាសែតអង់គ្លេស ក៏បានសរសេរថា៖ «ប្រទេសកម្ពុជាជាអ្នករងគ្រោះមួយដោយសារភូមិសាស្ត្រ*និងភាពទន់ខ្សោយខាងនយោបាយរបស់ខ្លួន*»។ ភូមិសាស្ត្រនយោបាយនៃប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៥៣ដល់១៩៩១ សម្គាល់ដោយកត្តាសំខាន់ៗបីគឺ សង្គ្រាមវៀតណាម មត៌កនៃការគ្រប់គ្រងរបស់បារាំង( បារាំងបានបន្សល់ទុកនូវបញ្ហាជម្លោះ ព្រំដែនជាមួយប្រទេសជិតខាង) និង ការប្រកួតប្រជែងនៃមហាអំណាចក្នុងតំបន់ ក៏ដូចជានយោបាយនៃសង្គ្រាម ត្រជាក់។

បើយើងពិនិត្យពិចារណាទៅលើអ្វីដែលជនបរទេសបានសរសេរ យើងឃើញថាក្រោយពីទទួលបានឯករាជ្យពីអាណានិគមបារាំង មេដឹកនាំកម្ពុជាពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រឈមមុខនឹងនយោបាយរបស់ប្រទេសជិតខាង ក៏ដូចជាប្រទេសមហាអំណាចបាននៅឡើយ។ ដូចជានៅឆ្នាំ១៩៥៦ លោក ព្យែរ រ៉ូឡង់ (Pierre Roland) បានសរសេរថា៖ "អ្នកសង្កេតការណ៍បរទេសភាគច្រើនបានយល់ឃើញថា នៅពេលណាដែលប្រទេសអាណាព្យាបាល(បារាំង) លែងគ្រប់គ្រងតទៅទៀត ប្រទេសកម្ពុជាអាចនឹងវិលត្រឡប់ទៅរកផ្លូវនៃការធ្លាក់ចុះ និង ការវិនាសសាបសូន្យវិញ"។

ដូច្នេះ ដើម្បីជៀសវាងគ្រោះថ្នាក់ដោយសារសង្គ្រាម ប្រទេសកម្ពុជាស្វែងរកការគាំទ្រនិងជំនួយពីប្រទេសមហាអំណាចនានា ជាពិសេសមហាអំណាចដែលគួរឱ្យទុកចិត្តនិងអាចពឹងពាក់បាន។ តែប្រទេសមហាអំណាចទាំងឡាយមានតែមហាអំណាចកុម្មុយនីស្តទេ ដែលអាចអូសទាញមេដឹកនាំកម្ពុជាឱ្យដើរតាមគន្លងរបស់ពួកគេ។ ចំណែកឯមហាអំណាចបស្ចិមប្រទេសសុទ្ធសឹងតែជាប្រទេសអាណានិគមដែលប្រទេសតតិយលោកដូចជាកម្ពុជាធ្លាប់ស្គាល់រួចមក ហើយនិងមិនអាចពឹងពាក់បានទៀតផង។ ប្រទេសកម្ពុជាមានជម្រើសរបស់ខ្លួនក្នុងការបង្កើតទំនាក់ទំនងការទូត ហើយបានសម្លឹងឃើញមហាអំណាចកុម្មុយនីស្ត ដូចជា ប្រទេសចិនឬសហភាពសូវៀត។ សម្តេច នរោត្តម សីហនុ បានស្គាល់មេដឹកនាំចិននិងសហភាពសូវៀតក្នុងកំលុងសន្និសីទនៃបណ្តាប្រទេសអាស៊ី-អាហ្វ្រិកនាទីក្រុងបានឌុងឆ្នាំ១៩៥៥មក។ ហេតុនេះហើយបានជាព្រះអង្គបដិសេធមិនចូលរួមក្នុងអង្គការសេអាតូ ដែលមានពួកអាម៉េរិកាំងត្រួតត្រាពីលើឡើយ ហើយព្រះអង្គបានចងភ្ជាប់ប្រទេសទៅនឹងគោលការណ៍បញ្ចសីលា (គោលការណ៍សន្តិសហវិជ្ជមានទាំង៥) ដែលប្រកាសឡើងដោយសន្និសីទនៃបណ្តាប្រទេសអាស៊ី-អាហ្វ្រិកនាទីក្រុងបានឌុង (ប្រទេសឥណ្ឌូនេស៊ី) ឆ្នាំ១៩៥៥វិញ ដែលទ្រង់ក៏ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំទាំងឡាយដែលគេទទួលស្គាល់នោះដែរ។

មុនពេលទទួលបានឯករាជ្យ ប្រទេសកម្ពុជាមិនបានទទួលឥទ្ធិពលនយោបាយពីប្រទេសរុស្ស៊ីទេ ព្រោះកម្ពុជាជារដ្ឋមួយក្នុងសហព័ន្ធឥណ្ឌូចិនបារាំង។ បក្សកុម្មុយនីស្តអន្តរជាតិបានទទួលស្គាល់ថា៖ ឥណ្ឌូចិនជាចំណុចមួយដ៏សំខាន់

ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិនិយមតាំងពីឆ្នាំ១៩១៩ មកម្ល៉េះ។ នៅឆ្នាំ១៩២០ គេបានបញ្ជូនបេសកជនកុម្មុយ-នីស្តមួយក្រុម ពីទីក្រុងវ្ល៉ាឌីវ៉ូស្តុកទៅកាន់ទីក្រុងព្រៃនគរ ដើម្បីរៀបចំបង្កើតបក្សកុម្មុយនីស្តនៅទីនោះ។ គឺទីក្រុងព្រៃ នគរនេះហើយ ដែលគេបានរៀបចំបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិននៅឆ្នាំ១៩៣០។ ចាប់តាំងពីឆ្នាំ១៩៣៥ តំណាងបក្សកុម្មុយនីស្តឥណ្ឌូចិនបានចូលជាសមាជិកគណៈកម្មការប្រតិបត្តិបក្សកុម្មុយនីស្តអន្តរជាតិ (កូមិនទែន)។ ភាពបត់បែននៃនយោបាយកម្ពុជាមិនច្បាស់លាស់ជាមួយប្រទេសមហាអំណាចទាំងពីរ ម្តងជ្រើសរើសយករបបនយោបាយតាមលោកសេរី ម្តងជ្រើសរើសយកនយោបាយអព្យាក្រឹត គាំទ្រកុម្មុយនីស្ត បាននាំឱ្យមានភាពច្របូកច្របល់នៃនយោ-បាយកម្ពុជា ព្រមទាំងរុញច្រានសង្គមជាតិទាំងមូលឱ្យធ្លាក់ក្នុងភ្លើងសង្គ្រាមប្រកបដោយគ្រោះថ្នាក់បំផុត។ បញ្ហាធ្ងន់ធ្ងរទាំងនេះត្រូវបានបញ្ជូនទម្លាក់កំហុសទៅលើសម្តេចនរោត្តម សីហនុ ព្រោះតែព្រះអង្គជាអ្នកដែលមានសិទ្ធិ សម្រេចចិត្តនានានោះ។ នៅពេលដែលពួកវៀតកុងបានចូល មកក្នុងប្រទេសកម្ពុជាប្រមាណជិត២លាននាក់ស្ទើរតែពាស ពេញផ្ទៃប្រទេសហើយនោះ កម្ពុជាមិនអាចគ្រប់គ្រងស្ថាន-ការណ៍បានឡើយ ដោយសារតែប្រទេសចិនបានធ្វើព្រងើយកន្តើយចំពោះមេដឹកនាំកម្ពុជា ព្រោះលែងមានតម្លៃសម្រាប់ចិនទៀតហើយ។ ដូច្នេះ ពេលនោះមេដឹកនាំសូវៀតមិនបានយកចិត្តទុកដាក់ចំពោះព្រះអង្គដូចពេលមុនទៀតហើយ។ នាទសវត្សរ៍ឆ្នាំ១៩៦០ សម្រាប់ហេតុផលផ្ទាល់របស់ពួកគេទាំងសហភាពសូវៀតនិងប្រទេសចិនបានប្រជែងគ្នា ដើម្បីពង្រីកអំណាចនៅប្រទេសកម្ពុជាតាមរយៈការផ្តល់ជំនួយយ៉ាងច្រើន។ វាជាការប្រកួតមួយដែលជនជាតិចិនអស់ពេលជាច្រើនឆ្នាំបានធ្វើល្អជាង ហើយដែលពួកសូវៀតមិនដែលបានយល់ពីទម្លាប់នេះ[១៧]។

ប្រទេសកម្ពុជានិងសហភាពសូវៀត បានចាប់ផ្តើមបង្កើតទំនាក់ទំនងការទូតចាប់ពីឆ្នាំ១៩៥៦មក។ ក្នុងដំណាក់កាលដំបូងនៃទំនាក់ទំនងនេះមានលក្ខណៈវិជ្ជមាននិងអវិជ្ជ-មានជាច្រើន ដោយសារតែមេដឹកនាំនៃប្រទេសទាំងពីរពុំសូវមានការយោគយល់គ្នាទៅវិញទៅមក ព្រោះប្រទេសកម្ពុជាប្រកាន់យករបបរាជានិយម ឯសហភាពសូវៀតជាប្រទេសសង្គមនិយមដ៏ធំបំផុតក្នុងពិភពលោក។ ក្នុងការបង្កើតទំនាក់ទំនងជាមួយសហភាពសូវៀត សម្តេច នរោត្តម សីហនុ បានមានបន្ទូលក្នុងឱកាសព្រះទស្សនកិច្ចនៅទីក្រុងម៉ូស្គូនាឆ្នាំ១៩៥៦ ថា ការសម្រេចចិត្តរបស់កម្ពុជានេះ គឺជាបុព្វនិមិត្តមួយនៃមិត្តភាពដ៏រឹងប៉ឹងរវាងប្រទេសយើងទាំងពីរផងនិងជាចំណងមួយដែលអាចទាញប្រជាជននៃប្រទេសតូចមួយ(កម្ពុជា)ឱ្យខិតទៅជិតបង្កើយនឹងមហាជនសូវៀត។ ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងសហភាពសូវៀតត្រូវបានធ្វើឱ្យប្រសើរឡើង ជាពិសេស ក្រោយពីការបញ្ឈប់ជំនួយសហរដ្ឋអាម៉េរិកនាចុងឆ្នាំ១៩៦៣។ សហភាពសូវៀតបានផ្តល់ជំនួយក្នុងវិស័យសុខាភិបាល ដោយបានជួយកសាងមន្ទីរពេទ្យដ៏ធំមួយនៅក្រុងភ្នំពេញ[១៨]។ ដើម្បីពង្រីកទំនាក់-ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត សហ-ភាពសូវៀតបានផ្តល់អំណោយដ៏មានសារសំខាន់ក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា គឺការស្ថាបនាសាលាបច្ចេកទេសជាន់ខ្ពស់ (តិចណូ) នៅឆ្នាំ១៩៦១[១៩]។ សហភាពសូវៀតបានចាប់ផ្តើមផ្តល់ជំនួយខាងសេដ្ឋកិច្ចនៅឆ្នាំ១៩៦១និងជំនួយយោធានាខែសីហា ឆ្នាំ១៩៦៣ ពេលដែលបានស្នើសុំផ្តល់ជំនួយសាស្ត្រាវុធដោយកំណត់ដល់ប្រទេសកម្ពុជា។ ជំនួយយោធាដំបូងៗ បានផ្តល់ឱ្យកម្ពុជានៅខែកុម្ភៈ ឆ្នាំ១៩៦៤ និងការផ្តល់បន្តទៀតនៅ ខែវិច្ឆិកាឆ្នាំ១៩៦៤។ នៅខែកុម្ភៈ ឆ្នាំ១៩៦៨ កិច្ចព្រមព្រៀងផ្តល់ជំនួយយោធាថ្មីមួយបានចុះហត្ថលេខារវាងប្រទេសកម្ពុជានិងសហភាពសូវៀត។ ចាប់ពីឆ្នាំ១៩៧០មក ចំណងទាក់-ទងរវាងកម្ពុជានិងសហភាពសូវៀត ត្រូវបានចុះខ្សោយជាលំដាប់។ ក្រោយពីរបបកម្ពុជាប្រជាធិតេយ្យដួលរលំនៅ ខែមករា ឆ្នាំ១៩៧៩មក យើងឃើញថា សហភាពសូវៀតបានភ្ជាប់ទំនាក់ទំនងឡើងវិញជាមួយនឹងរដ្ឋាភិបាលថ្មីនៃប្រទេស

[១៧] Osborne Milton, *Sihanouk : Prince of Light and Prince of Darkness*, 1994, p.136.

[១៨] កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពសង្គមនិយមសូវៀតនិងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាស្តីពីការស្ថាបនាមន្ទីរពេទ្យមួយនៅក្រុងភ្នំពេញ ជាអំណោយដល់រដ្ឋាភិបាល និង ប្រជារាស្ត្រកម្ពុជា ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៥៧។

[១៩] កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពសង្គមនិយមសូវៀតនិងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាស្តីពីការស្ថាបនា សាលាបច្ចេកទេសជាន់ខ្ពស់នៅក្រុងភ្នំពេញ ជាអំណោយដល់រដ្ឋាភិបាលនិងប្រជារាស្ត្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦១។

កម្ពុជា។ ការភ្ជាប់ទំនាក់ទំនងជាមួយសហភាពសូវៀតឡើងវិញក្រោយឆ្នាំ១៩៧៩ ជាពេលវេលាមួយដែលមានការប្រណាំងប្រជែងគ្នាយ៉ាងខ្លាំងរវាងប្រទេសមហាអំណាចកុម្មុយនីស្តទាំងពីរគឺប្រទេសចិននិងសហភាពសូវៀត។ ពេលនោះប្រទេសកម្ពុជាក៏បានធ្លាក់ទៅក្នុងប្លុកប្រឈមទាំងពីរ ដែលមិនអាចនឹងងាករេទៅខាងប្លុកណាផ្សេងក្រៅពីប្លុកសូវៀតបានដូចកាលពីទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ឡើយ។ ចាប់ពីពេលនោះមកសហភាពសូវៀតបានផ្តល់ជំនួយដល់រដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកដល់ការស្តារប្រទេសឡើងវិញ។ ចាប់ពីឆ្នាំ១៩៨៧មក ស្ថានភាពនយោបាយនៅកម្ពុជាបានផ្លាស់ប្តូរ ហើយឈានទៅរកការចរចាដើម្បីបញ្ចប់ជម្លោះរវាងភាគីខ្មែរទាំងបួន។ ដំណើរការចរចានេះបានអូសបន្លាយរហូតដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបមានការចុះហត្ថលេខារវាងភាគីទាំងបួនលើកិច្ចព្រមព្រៀងបញ្ចប់ជម្លោះដ៏រ៉ាំរ៉ៃនេះ។

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសមក ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាសកល ក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិនាខែឧសភា ឆ្នាំ១៩៩៣។ ក្នុងពេលបោះឆ្នោតនោះ ប្រទេសរុស្ស៊ីក៏បានបញ្ជូនកងកម្លាំងរបស់ខ្លួនមកចូលរួមផងដែរ។ ជាលទ្ធផល គេបានបង្កើតរាជរដ្ឋាភិបាលចម្រុះមួយដែលមានសមាសភាពមកពីគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និង គណបក្សដទៃទៀត។ ក្រោយពីការបង្កើតរាជរដ្ឋាភិបាលរួចមក កម្ពុជាបានបង្កើនទំនាក់ទំនងអន្តរជាតិនិងការទូតជាមួយបណ្តាប្រទេសនានាលើសកលលោក ជាពិសេស គឺការបង្កើតឡើងនូវទំនាក់ទំនងការទូតជាមួយនឹងសហព័ន្ធរុស្ស៊ី ដែលជាអ្នកស្នងពីសហភាពសូវៀតមក។

យោងតាមស្មារតីនៃកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ-១៩៩១ សហគមន៍អន្តរជាតិក៏ត្រូវមានភារកិច្ចរៀបចំកៀរគររកជំនួយសម្រាប់ការស្តារនិងកសាងប្រទេសកម្ពុជាឡើងវិញផងដែរ។ ដោយមើលឃើញពីទំហំនៃការខូចខាតដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា អង្គការសហប្រជាជាតិរួមជាមួយនឹងប្រទេសមហាអំណាចនានាបានរួមប្រជុំគ្នា ដើម្បីពិចារណាលើការផ្តល់និងប្រើប្រាស់ជំនួយចាប់ពីឆ្នាំ១៩៩១ រហូតមក។ ការផ្តល់ជំនួយផ្តោតជាសំខាន់ទៅលើស្បៀងអាហារ ទីជម្រក សុខភាព ការបណ្តុះបណ្តាល ការអប់រំ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គមផ្សេងៗទៀត។ នៅខែមេសា ឆ្នាំ១៩៩២ អគ្គលេខាធិការនៃអ.ស.ប. បានអំពាវនាវរកជំនួយសង្គ្រោះបន្ទាន់មួយដល់ប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះ អង្គការសហប្រជាជាតិក៏បានយកចិត្តទុកដាក់លើការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនខ្មែរជាច្រើនម៉ឺននាក់ពីព្រំដែនថៃចូលមកក្នុងប្រទេសកម្ពុជាវិញផងដែរ។

ស្នាដៃនេះចែកចេញជាបីជំពូក។ ក្នុងជំពូកទី១ ផ្តោតជាសំខាន់ទៅលើកត្តាដែលនាំឱ្យប្រទេសកម្ពុជានិងសហភាពសូវៀតខិតជិតគ្នា។ ជំពូកទី២នឹងរៀបរាប់ពីដំណាក់កាលទី១នៃទំនាក់ទំនងរវាងប្រទេសកម្ពុជានឹងសហភាពសូវៀតពី ឆ្នាំ១៩៥៦រហូតមកដល់ឆ្នាំ១៩៧៩។ ឯជំពូកទី៣ នឹងរៀបរាប់យ៉ាងពិស្តារអំពីដំណាក់កាលទី២ នៃទំនាក់ទំនងរវាងប្រទេសកម្ពុជានិងសហភាពសូវៀតពីឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ១៩៩១ អំពីដំណើរឆ្ពោះទៅរកសន្តិភាពនៅប្រទេសកម្ពុជា ដែលនឹងលើកយកតួនាទីដ៏សំខាន់របស់សហភាព-សូវៀតនិងសហគមន៍អន្តរជាតិក្នុងការដោះស្រាយជម្លោះនៅប្រទេសកម្ពុជា ក៏ដូចជាការផ្តល់ជំនួយសម្រាប់ការស្តារនិងកសាងប្រទេសកម្ពុជាឡើងវិញផងដែរ។

ចាប់ពីឆ្នាំ១៩៧៩មក សហភាពសូវៀតបានជួយប្រទេសវៀតណាម ដើម្បីរៀបចំធ្វើអន្តរាគមន៍យោធាចូលក្នុងប្រទេសកម្ពុជាផ្តួលរំលំរបបខ្មែរក្រហមនិងបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ចំណែកឯបណ្តាប្រទេសមហាអំណាចនិងអាស៊ានបានជួយឧបត្ថម្ភក្រុមខ្មែរតស៊ូនៅតាមព្រំដែនកម្ពុជា-ថៃ ដើម្បីបន្តការតស៊ូប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ សភាព-ការណ៍ពិភពលោកកាន់តែមានភាពធូរស្រាល ហើយធ្វើឱ្យមានភាពល្អប្រសើរក្នុងទំនាក់ទំនងរវាងចិននិងសូវៀត ក៏ដូចជាសូវៀត-អាម៉េរិកាំងបានបង្កជាឱកាសល្អមួយក្នុងការចរចារកសន្តិភាពនៅកម្ពុជា។

ការចរចារកសន្តិភាពនៅកម្ពុជាបានបញ្ចប់នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នាសន្និសីទទីក្រុងប៉ារីស ប្រទេសបារាំង ដោយតម្រូវឱ្យភាគីជម្លោះទាំងអស់ត្រូវតែបញ្ឈប់ការច្បាំងគ្នាជាស្ថាពរនិងចូលរួមក្នុងការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ដែលនឹងគ្រោងទុកនៅខែឧសភា ឆ្នាំ១៩៩៣ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ (អ៊ុនតាក់)។ ក្រោយការបោះឆ្នោតនេះ រដ្ឋាភិបាលចម្រុះមួយបានបង្កើត

ឡើង គឺរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ប្រទេសកម្ពុជាបានក្លាយជាព្រះរាជាណាចក្រកម្ពុជា ដូចកាលពីទសវត្សរ៍ទី៦នៃស.វ.ទី២០។

ទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជានឹងសហភាពសូវៀត បានចាប់ផ្តើមពីខែឧសភា ឆ្នាំ១៩៥៦។ សហភាពសូវៀតបានប្រឹងប្រែងបញ្ចុះបញ្ចូលប្រទេសកម្ពុជាឱ្យរក្សាអព្យាក្រឹតភាពរបស់ខ្លួន គឺសូវៀតមានបំណងរារាំងមិនឱ្យកម្ពុជាចូលទៅខាងលោកសេរី ដែលប្រឆាំងនឹងសូវៀតនោះទេ។ ហេតុនេះទើបសូវៀតបានផ្តល់និងសន្យាផ្តល់ជំនួយដល់ប្រទេសកម្ពុជា។ ជំនួយដែលសហភាពសូវៀតបានផ្តល់ឱ្យប្រទេសកម្ពុជាមានដូចជា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ (តិចណូ) និងអ្វីដែលសហភាពសូវៀតបានសន្យាផ្តល់មានដូចជា សំណង់វារីអគ្គិសនីនៅភ្នំកំចាយ ខេត្តកំពត ជាដើម ដែលមិនបានទទួលលទ្ធផលដោយសារតែភាគីសូវៀត។ ដូច្នេះ សហភាពសូវៀតជាប្រទេសផ្តល់ជំនួយមួយក្នុងចំណោមប្រទេសដែលបានផ្តល់ជំនួយដល់ប្រទេសកម្ពុជាដែលមាន សហរដ្ឋអាម៉េរិក និងប្រទេសចិន។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ រដ្ឋាភិបាលសូវៀតបានគាំទ្រទាំងរដ្ឋាភិបាល លន់ នល់ និង រដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់សម្តេច នរោត្តម សីហនុ ដែលតាំងនៅក្រុង ប៉េកាំង។ ប៉ុន្តែនៅពេលដែលពួកខ្មែរក្រហមចូលកាន់កាប់ ក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ទំនាក់ទំនងការទូត រវាងប្រទេសកម្ពុជានឹងសហភាពសូវៀតត្រូវបានកាត់ផ្តាច់ទាំងស្រុង ដោយសារតែរដ្ឋាភិបាលខ្មែរក្រហមគាំទ្រដោយប្រទេសចិន។

ដោយសារតែកត្តាខាងក្រៅ បានជំរុញឱ្យប្រទេសកម្ពុជារងគ្រោះជាច្រើន ដូចជាការប្រឈមមុខដាក់គ្នានៃមហាអំណាចធំៗទាំងបី (សហភាពសូវៀត ចិន និង សហរដ្ឋអាម៉េរិក)នៅឥណ្ឌូចិន។ ក្រោយពីអាណានិគមបារាំងបានដកថយ សហរដ្ឋអាម៉េរិកក៏ចូលមកជំនួសប្រទេសបារាំង ហើយបន្ទាប់មកសហភាពសូវៀតបានចូលមកឥណ្ឌូចិននៅក្រោយសង្គ្រាមវៀតណាមបានបញ្ចប់ទៅនៅឆ្នាំ១៩៧៣។

ដូច្នេះ ទាំងប្រទេសចិន សហរដ្ឋអាម៉េរិក ក៏ដូចជាសហភាពសូវៀត បានប្រកួតប្រជែងគ្នាយ៉ាងខ្លាំងក្លាដើម្បីផលប្រយោជន៍របស់ពួកគេតែរៀងៗខ្លួន ដោយមិនគិតពីផលប្រយោជន៍ឬការរងគ្រោះដោយសារតែឥទ្ធិពលរបស់ពួកគេនោះទេ។ ម្ល៉ោះហើយប្រទេសកម្ពុជាក៏មិនអាចពឹងផ្អែកទាំងស្រុងតែទៅលើចិន សហរដ្ឋអាម៉េរិក ក៏ដូចជា សហភាព-សូវៀតខ្លាំងពេកនោះទេ។ ឧទាហរណ៍ ដូចជាការប្រកួតប្រជែងគ្នារវាងមហាអំណាចទាំងបីនៅឥណ្ឌូចិន ក្នុងកំលុងឆ្នាំ១៩៦០និង១៩៧០ ជាដើម។ ដោយសារតែមានភាពធូរស្រាលរវាងចិននិងស.រ.អា. បានធ្វើឱ្យភាពតឹងតឹងក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកត្រូវបានកាត់បន្ថយផងដែរ ដែលបណ្តាប្រទេសក្នុងតំបន់តែងភ័យខ្លាចពីគ្រោះថ្នាក់ដោយសារការគំរាមកំហែងពីប្រទេសចិន។ ដោយសារតែមានសម្ពាធពីប្រទេសមហាអំណាចកុម្មុយនីស្តនិងស្ថានភាពនយោបាយក្នុងប្រទេស បានបង្ខំឱ្យសម្តេច សីហនុ ប្រកាសឈប់ទទួលជំនួយពីអាម៉េរិកាំងនិងរហូតដល់ការផ្តាច់ទំនាក់ទំនងការ-ទូតនៅឆ្នាំ១៩៦៥ទៀតផង។ ការប្រកាសឈប់ទទួលជំនួយពីអាម៉េរិកាំងនាំឱ្យមានវិបត្តិកើតឡើងជាច្រើន ព្រោះពេលនោះ កម្ពុជាកំពុងតែត្រូវការជំនួយបរទេសជាចាំបាច់។ ការបោះឆ្នោតឆ្នាំ១៩៦៦ បានជ្រើសតាំងរដ្ឋសភាមួយដែលប្រឆាំងនឹងសម្តេច សីហនុ បានបង្ហាញឱ្យឃើញថា អនាគតនៃប្រទេសកម្ពុជាអាចនឹងរបូតចេញពីអំណាចរបស់សម្តេច។ ព្រះអង្គត្រូវប្រឈមនឹងពួកស្តាំនិយមដែលប្រឆាំងដាច់ខាតនឹងកុម្មុយនីស្តដែលជាអ្នកទីក្រុងនិងជាអ្នកស្និទ្ធអាម៉េរិក ហើយមិនយូរប៉ុន្មាន ក្រុមឆ្វេងនិយមបាននាំគ្នារត់ចូលព្រៃអស់។ វិបត្តិនយោបាយកាន់តែធ្ងន់ធ្ងររហូតដល់មានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ពីអំណាចនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

សហភាពសូវៀតនិងកម្ពុជា មានលក្ខណៈខុសប្លែកពីគ្នា ដោយសារតែរបបនយោបាយក្នុងកំលុងទសវត្សរ៍ឆ្នាំ១៩៦០ដល់១៩៧០។ ប្រទេសកម្ពុជាមានការផ្លាស់ប្តូររបបនយោបាយច្រើនដែលវាមិនកើតមាននៅសហភាពសូវៀតនោះទេ។ ការផ្លាស់ប្តូរនៅកម្ពុជាមានលក្ខណៈធ្ងន់ធ្ងរដោយ-សារតែការប្រើអាវុធដើម្បីដោះស្រាយជម្លោះ ជាពិសេសគឺ អន្តរាគមន៍ពីបរទេស ដែលក្នុងប្រវត្តិសាស្ត្រកម្ពុជា ធ្លាប់ជួបប្រទះរួចមកហើយកាលពីស.វ.ទី១៨-១៩ និងទី២០ កន្លងមកនោះ។ ការផ្លាស់ប្តូររបបនយោបាយនេះដែរ ដូចជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានខិតខំលុបបំបាត់ឱ្យអស់នូវអ្វីដែលជាកម្មែលចាស់ អ្វីដែលអ្នកមុនៗបានខិតខំកសាង

បង្កើតឱ្យមាននិងបង្កើតអ្វីៗឱ្យថ្មីទាំងអស់ សូម្បីតែមនុស្សក៏ត្រូវតែថ្មីដែរ។

ទំនាក់ទំនងរវាងសហភាពសូវៀតនឹងប្រទេសកម្ពុជាត្រូវបានស្តារឡើងវិញចាប់ពីឆ្នាំ១៩៧៩រហូតមក។ សហភាព-សូវៀតបានផ្តល់ជំនួយជាច្រើន (ទាំងជំនួយសេដ្ឋកិច្ចនិងយោធា) ដល់ប្រទេសកម្ពុជា សម្រាប់ការលុបបំបាត់ភាពអត់ឃ្លាន ការព្យាបាលជំងឺ ការរៀបចំស្តារឡើងវិញនូវហេដ្ឋា-រចនាសម្ព័ន្ធសង្គមជាតិ ដែលត្រូវបំផ្លិចបំផ្លាញដោយរបប-កម្ពុជាប្រជាធិបតេយ្យ។ សហភាពសូវៀត ក៏បានផ្តល់ជំនួយសម្រាប់ការស្តារវិស័យអប់រំផងដែរ ដូចជាបើកឱ្យដំណើរការឡើងវិញនូវវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសកម្ពុជា-សូវៀត (តិចណូ) សាលាកសិកម្ម សាកលវិទ្យាល័យភ្នំពេញ ជាពិសេសបានទទួលយកនិស្សិតកម្ពុជាឱ្យទៅបន្តការសិក្សាជំនាញបច្ចេកទេសកម្រិតមធ្យមនិងកម្រិតឧត្តមសិក្សានៅតាមបណ្តារដ្ឋនានានៃសហភាពសូវៀតផងដែរ។ នៅពេលបច្ចុប្បន្ន ធនធានមនុស្សជាច្រើនពាន់នាក់ដែលបានបណ្តុះ-បណ្តាលនៅសហភាពសូវៀត កំពុងបម្រើការងារយ៉ាងសកម្មនៅតាមស្ថាប័នរដ្ឋនានា។

នៅពេលដែលលោក ហ្គោរបាឆូវ ឡើងកាន់អំណាចជាប្រមុខរដ្ឋនៅសហភាពសូវៀតនាឆ្នាំ១៩៨៥ លោក ហ៊ុន សែន ក៏បានឡើងកាន់អំណាចជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) នៃសាធារណរដ្ឋប្រជាមានិត កម្ពុជាដែរ។ ដោយសារតែនយោបាយកែទម្រង់របស់លោក ហ្គោរបាឆូវ នេះហើយ បានអនុញ្ញាតឱ្យប្រទេសកម្ពុជា មានឱកាសបានជួបចរចាជាមួយក្រុមចលនាតស៊ូខ្មែរនៅតាមព្រំដែនខ្មែរ-ថៃ ចាប់តាំងពីឆ្នាំ១៩៨៧ រហូតដល់មានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១។

សហព័ន្ធរុស្ស៊ីជាប្រទេសមហាអំណាចធំបំផុតមួយ រីឯកម្ពុជាវិញជាប្រទេសតូចមួយក្នុងពិភពលោក ដែលស្វែងរកការគោរពនិងគាំទ្រពីប្រទេសធំជាងខ្លួន ដើម្បីឱ្យមានភាពស្មើគ្នាក្នុងទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ។ ទោះជាមានភាពរកាំ-រកូសខ្លះៗយ៉ាងណាក្តី ក៏ប្រទេសទាំងពីរនៅតែរក្សាភាពជាមិត្តនឹងគ្នារហូតមក ហើយនៅតែបន្តមិត្តភាពនេះទៅថ្ងៃអនាគត។ ប្រជាជនកម្ពុជានៅតែនឹកមិនភ្លេចនូវគុណូបការៈដ៏ធំធេង ដែលប្រជាជននិងរដ្ឋាភិបាលសូវៀតបានផ្តល់ឱ្យតាំងពីទសវត្សរ៍ឆ្នាំ១៩៦០និងក្រោយឆ្នាំ១៩៧៩។ ដើម្បីរក្សាចំណងទាក់ទងនេះឱ្យមានភាពល្អប្រសើរ ប្រទេសទាំងពីរគួរតែស្វែងយល់ពីគ្នាឱ្យបានកាន់តែស៊ីជម្រៅតទៅទៀតក្នុងផលប្រយោជន៍សម្រាប់ប្រជាជាតិនីមួយៗ។

# ការប្រើប្រាស់កិរិយាសកម្មដោយបន្ថែម«នូវ»ពីមុខកម្មបទផ្ទាល់



លោក **ប៊ី សុខគង់**
បេក្ខជនបណ្ឌិត ផ្នែកភាសាវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

តាមវចនានុក្រមខ្មែរ ពាក្យ នូវ មានន័យពីរះ

(ន.) នឹង, ហើយនឹងៈ ព្រះរាជវង្សានុវង្សនិងមន្ត្រីរាជការតូចធំនូវអស់ប្រជាជនទាំងពួង។

(ន.) ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើៈ បុគ្គលធ្វើនូវអំពើល្អ ដោយកាយវាចាចិត្តនឹងបាន «នូវ» ផលល្អ។

នៅក្នុងការសិក្សានេះ យើងលើកយកពាក្យនូវមកបង្ហាញក្នុងកម្រិតជាពាក្យមួយបែបដែលគេប្រើសម្រាប់បន្ថែមនៅពីមុខនាមឬកន្សោមនាមកម្មបទផ្ទាល់ នៅក្នុងល្បះមួយចំនួនដូចជាៈ

(១)-ចូរអ្នកធ្វើនូវពិពណ៌នាអំពីដំណើរដែលអ្នកបានទៅមើលប្រាសាទនគរវត្ត។

(២)-រាជរដ្ឋាភិបាលក៏បានរក្សានូវលំនឹងម៉ាក្រូសេដ្ឋកិច្ចពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងក្របខ័ណ្ឌច្បាប់...។

(៣)-នៅទីបញ្ចប់នេះ ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្ដងទៀត ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

តាមការសង្កេត យើងឃើញថា ការប្រើប្រាស់នូវក្នុងល្បះមានពីរបែបៈ «នូវ» ជាធាតុឥតប្រយោជន៍ និង «នូវ» ជាធាតុមានប្រយោជន៍។

## ១- ការប្រើ នូវ ក្នុងលក្ខណៈសមស្រប

យើងមានល្បះដូចខាងក្រោម ៖

(៤)- សម្ដេចបានផ្ដល់នូវការគាំទ្រដល់ដំណើរការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បណ្ឌិត នៅរាជបណ្ឌិត្យសភាកម្ពុជា[២០]។

(៥)- លោក ហាស់ វ៉ារី ក៏បានពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខផងដែរ ពីសំណាក់សម្ដេច[២១] ...។

(៦)- វត្តព្រែកបារំ ហៅវត្តព្រែកប្រាំង ក្រោមការដឹកនាំរបស់សម្ដេចព្រះឧត្តមបញ្ញា ព្រះភិក្ខុនន្ទិយោ ដួង ផង់ ជាព្រះចៅអធិការវត្តបានខិតខំអភិរក្សនិងថែរក្សានូវសាស្ត្រាស្លឹករឹត ...។

(៧)- សូមលោកនាយកមេត្តាជ្រាបនិងទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

(៨)- បុគ្គលធ្វើនូវអំពើល្អ ដោយកាយ វាចាចិត្តនឹងបាននូវផលល្អ។

ល្បះខាងលើសុទ្ធតែមានពាក្យ«នូវ»នៅក្នុងកន្សោមកិរិយា គឺ «នូវ» ស្ថិតនៅចន្លោះកិរិយាសព្ទនិងកន្សោមនាម ឬថា «នូវ» ជាចំណងតភ្ជាប់កិរិយាសព្ទជាមួយនឹងកន្សោមនាម ដែលធ្វើឱ្យល្បះមានទម្រង់ដូចខាងក្រោមៈ

កន្សោមនាម + កិរិយាសព្ទ + នូវ + កន្សោមនាម

ខាងក្រោមនេះ យើងនឹងសិក្សាពិនិត្យមើលថា តើវត្តមាននៃពាក្យ «នូវ» ក្នុងល្បះខាងលើ ជាភាពចាំបាច់ខាងវេយ្យាករណ៍ និង ភាពចាំបាច់ខាងរចនាបថដែរឬទេ។ យើងសូមវិភាគដោយដក «នូវ» ចេញពីល្បះខាងលើជាបន្តបន្ទាប់តាមលំដាប់ដូចតទៅៈ

(៤ក)- សម្ដេចបានផ្ដល់ការគាំទ្រដល់ដំណើរការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បណ្ឌិតនៅរាជបណ្ឌិត្យសភាកម្ពុជា។

(៥ក)- លោក ហាស់ វ៉ារី ក៏បានពាំនាំការផ្ដាំផ្ញើសាកសួរសុខទុក្ខផងដែរ ពីសំណាក់សម្ដេច ...។

(៦ក)- វត្តព្រែកបារំ ហៅវត្តព្រែកប្រាំង ក្រោមការដឹកនាំរបស់សម្ដេច ព្រះឧត្តមបញ្ញា ព្រះភិក្ខុនន្ទិយោ ដួង ផង់ ជាព្រះចៅអធិការវត្ត បានខិតខំអភិរក្សនិងថែរក្សាសាស្ត្រាស្លឹករឹត ...។

[២០] ស៊ិន សំណាង ៖ សុន្ទរកថា ក្នុងពិធីបើកបវេសនកាលនៃការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បណ្ឌិតនៅថ្ងៃចន្ទ ទី២២ ខែធ្នូ ឆ្នាំ២០០៨។

[២១] សហការី, ចូលរួមពិធីបុណ្យពុទ្ធាភិសេកព្រះអង្គធំវត្តបឹងណាយ, នៅក្នុងៈ កាសែតកោះសន្តិភាព លេខ ៦៣១៤ ថ្ងៃសុក្រ ទី០៥ ខែធ្នូ ឆ្នាំ ២០០៨ ទំព័រ១១។

(៧ក)- សូមលោកនាយកមេត្តាជ្រាបនិងទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

(៨ក)- បុគ្គលធ្វើអំពើល្អ ដោយកាយវាចាចិត្ត នឹងបានផលល្អ។

យើងឃើញថា ល្បះ(៤ក)(៥ក)(៦ក)(៧ក)(៨ក) ដែលទទួលបានខាងលើនេះ ជាល្បះដែលមានវេយ្យាករណភាព។ កិរិយាសព្ទ ផ្ដល់, ពាំនាំ ថែរក្សា ទទួល ធ្វើ បាន សុទ្ធតែបន្តផ្ទាល់ដោយកន្សោមនាម ក្នុងមុខងារជាកម្មបទផ្ទាល់របស់វា គឺ៖

ផ្ដល់ + ការគាំទ្រ (ក្នុងល្បះ (៤ក))

ពាំនាំ + ការផ្ដាំផ្ញើសាកសួរសុខទុក្ខ (ក្នុងល្បះ (៥ក))

ថែរក្សា + សាស្ត្រាស្លឹករឹត (ក្នុងល្បះ (៦ក))

ទទួល + ការគោរពរាប់អាន (ក្នុងល្បះ (៧ក))

ធ្វើ + អំពើល្អ (ក្នុងល្បះ (៨ក))

បាន + ផលល្អ (ក្នុងល្បះ (៨ក))

យើងអាចកំណត់ទម្រង់នៃល្បះដែលទទួលបានថ្មីដូចនេះ៖

កន្សោមនាម + កិរិយាសព្ទ + កន្សោមនាម

ជាងនេះទៅទៀត ល្បះដែលទទួលបានទាំងអស់នេះ សុទ្ធមានន័យគ្រប់គ្រាន់ ងាយស្ដាប់ ងាយយល់ និងមិនទើសត្រចៀកអ្នកស្ដាប់ឡើយ។ យើងអាចនិយាយបានថា ល្បះទាំងពីរក្រុម គឺល្បះ (៤), (៥),(៦), (៧), (៨) និង ល្បះ (៤ក), (៥ក), (៦ក), (៧ក), (៨ក) ថ្វីត្បិតតែមានទម្រង់ផ្ទៃលើផ្សេងគ្នា តែមានទម្រង់ផ្ទៃក្រោមដូចគ្នា។ ការសាកល្បងនេះបង្ហាញឱ្យយើងឃើញថា ពាក្យ «នូវ»ដែលមាននៅក្នុងល្បះ(៤),(៥),(៦),(៧),(៨) ជាធាតុឥតប្រយោជន៍ទាំងផ្នែកវេយ្យាករណ៍និងទាំងផ្នែករចនាបថ ថែមទៀតផង។

## ២- ការប្រើ «នូវ» ក្នុងលក្ខណៈមិនសមស្រប

យើងមានល្បះដូចខាងក្រោម ៖

(៩)- ...ខ្ញុំបានទទួលពីសម្ដេចនាយករដ្ឋមន្ត្រីនូវបេសកកម្មយ៉ាងសំខាន់[២២] ...។

(១០)- សម្ដេច ... បានខិតខំកសាងឡើងនូវសមិទ្ធផលយ៉ាងច្រើនរាប់មិនអស់ ...[២៣]។

(១១)- *ព្រះអង្គបានចំណាយពេលអស់ជាង២ឆ្នាំ (...) ដើម្បីរៀបចំចងក្រងឡើងវិញនូវសាស្ត្រាស្លឹករឹត ដែលជាផ្នែកមួយតំណាងអោយវប្បធម៌ខ្មែរ* សម័យបុរាណ...។

(១២)- ប្អូនៗត្រូវអនុវត្តឱ្យបានល្អនូវពាក្យស្លោកថា សូវបង្ហូរញើសលើទីលានហ្វឹកហាត់ ដើម្បីចៀសវាងការបង្ហូរឈាមនៅលើសមរភូមិប្រយុទ្ធ។

ល្បះខាងលើទាំងនេះ សុទ្ធតែមាន «នូវ» នាំមុខកន្សោមនាមកម្មបទ នៅក្នុងកន្សោមកិរិយា។ តទៅនេះយើងខ្ញុំនឹង សិក្សាពិនិត្យមើលថាតើពាក្យ «នូវ» ជាធាតុមានប្រយោជន៍នៅក្នុងល្បះដែរឬទេ។ យើងខ្ញុំសាកល្បងដក «នូវ» ចេញពីល្បះខាងលើ ជាបន្តបន្ទាប់តាមលំដាប់ យើង ខ្ញុំបានល្បះ៖

(៩ក)- ...ខ្ញុំបានទទួលពីសម្ដេចនាយករដ្ឋមន្ត្រីបេសកកម្មយ៉ាងសំខាន់...។

(១០ក)- សម្ដេច... បានខិតខំកសាងឡើងសមិទ្ធផលយ៉ាងច្រើនរាប់មិនអស់...។

(១១ក)- ព្រះអង្គបានចំណាយពេលអស់ជាង២ឆ្នាំ ដើម្បីរៀបចំចងក្រងឡើងវិញ *សាស្ត្រាស្លឹករឹតដែលជាផ្នែកមួយតំណាងអោយវប្បធម៌ខ្មែរសម័យបុរាណ...។*

(១២ក)- ប្អូនៗត្រូវអនុវត្តឱ្យបានល្អពាក្យស្លោកថា សូវបង្ហូរញើសលើទីលានហ្វឹកហាត់ *ដើម្បីចៀសវាងការបង្ហូរឈាមនៅលើសមរភូមិប្រយុទ្ធ។*

ល្បះ (៩ក), (១០ក), (១១ក), (១២ក) ដែលទទួលបានខាងលើនេះ សុទ្ធតែជាល្បះដែលមានវេយ្យាករណភាព និង មានន័យគ្រប់គ្រាន់។ ថ្វីត្បិតតែល្បះទាំងនេះមានវេយ្យាករណភាពនិងមានន័យគ្រប់គ្រាន់ ប៉ុន្តែវាអាចធ្វើឱ្យអ្នកស្ដាប់ទាស់ត្រចៀក ពិបាកយល់ន័យជាងល្បះដើមដែលមិនទាន់ដក«នូវ»ចេញ។ ការសាកល្បងនេះបង្ហាញឱ្យយើងឃើញថា ពាក្យ «នូវ» ក្នុងល្បះ (៩),(១០), (១១), (១២) មិនមែនជាធាតុចាំបាច់ខាងផ្នែកវេយ្យាករណ៍ទេ តែវាជាធាតុមានប្រយោជន៍ដែលស្ថិតក្រោមឥទ្ធិពលនៃការប្រើប្រាស់រចនាបថរបស់វាទករដើម្បីឱ្យអ្នកស្ដាប់ឬអ្នកអានងាយយល់តែប៉ុណ្ណោះ។ ឥទ្ធិពលនៃរចនាបថដែលជំរុញឱ្យវាទករប្រើ «នូវ» ក្នុងល្បះខាងលើ កើតឡើងពីកត្តាផ្សេងៗ ដូចខាងក្រោម៖

- ក្នុងល្បះ(៩)៖ កិរិយាសព្ទ «ទទួល» ជាកិរិយាសកម្មដែលមានកម្មបទពីរ៖ មួយជាកម្មបទផ្ទាល់ "បេសកកម្មយ៉ាងសំខាន់" និងមួយទៀតជាកម្មបទមិនផ្ទាល់ "ពីសម្ដេចនាយករដ្ឋមន្ត្រី"។ តាមធម្មតា ក្នុងភាសាខ្មែរ កម្មបទផ្ទាល់ត្រូវស្ថិតនៅក្នុងលំដាប់ទី១ជាប់នឹងកិរិយាសព្ទ ឯកម្ម-

[២២] ស៊ន សំណាង ៖ សុន្ទរកថា ក្នុងពិធីបើកបវេសនកាលនៃការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បណ្ឌិត នៅថ្ងៃចន្ទ ទី២ ខែធ្នូ ឆ្នាំ២០០៨។

[២៣] សហការី, ចូលរួមពិធីបុណ្យពុទ្ធាភិសេកព្រះអង្គធំវត្តបឹងណាយ, នៅក្នុង៖ កាសែតកោះសន្តិភាព, លេខ ៦៣១៤ ដ.ឯ.ម. ទំព័រ១១។

បទមិនផ្ទាល់ ត្រូវស្ថិតនៅក្នុងទីតាំងលំដាប់ទី២ បន្ទាប់ពីកម្មបទផ្ទាល់ ដូចល្បះខាងក្រោមនេះ៖

(៩ខ)-...ខ្ញុំបានទទួលបេសកកម្មយ៉ាងសំខាន់ពីសម្តេចនាយករដ្ឋមន្ត្រី...។ ប៉ុន្តែដោយសារតែវាទករប្រើប្រាស់រចនាបថរបស់ខ្លួន ដោយប្តូរទីតាំងកម្មបទមិនផ្ទាល់ មកនៅលំដាប់ទី១ ជាប់នឹងកិរិយាសព្ទ ឯកម្មបទផ្ទាល់ទៅនៅត្រង់ទីតាំងលំដាប់ទី២បន្ទាប់ពីកម្មបទមិនផ្ទាល់វិញ ទើបជំរុញឱ្យវាទករប្រើពាក្យ «នូវ» ពីមុខកន្សោមនាមកម្មបទផ្ទាល់ដូចល្បះ (៩) គឺ៖ *...ខ្ញុំបាន*ទទួលពីសម្តេចនាយករដ្ឋមន្ត្រីនូវបេសកកម្មយ៉ាងសំខាន់...។

- ក្នុងល្បះ(១០)៖ កិរិយាសព្ទ«កសាង» ជាកិរិយាសកម្ម មានន័យឱ្យអ្នកអាន អ្នកស្តាប់យល់បានថា "ស្ថាបនា បង្កើត ឬ បង្កើតឡើង..." គឺកសាងអ្វីមួយ ដូចជា៖

កសាងអគារសិក្សា កសាងសមិទ្ធផលផ្សេងៗ កសាងសង្គម ... ។

វត្តមានរបស់ «នូវ» ក្នុងល្បះ(១០) ស្ថិតក្រោមឥទ្ធិពលនៃការបន្ថែមពាក្យ«ឡើង» ឱ្យកិរិយាសព្ទ «កសាង» ទៅជា «កសាង» ឡើង ដើម្បីសង្កត់ន័យឱ្យកាន់តែខ្លាំង។ ដោយសារតែវាទករប្រើកិរិយាសព្ទ«កសាង»ឡើងនៅក្នុងល្បះរបស់ខ្លួនទើបជំរុញឱ្យគេប្រើ «នូវ» ពីមុខកន្សោមនាមកម្មបទផ្ទាល់។ ផ្ទុយទៅវិញ បើវាទករប្រើត្រឹមតែកិរិយាសព្ទ «កសាង»នោះ វត្តមានរបស់ «នូវ» មិនមែនជាការចាំបាច់ឡើយ គឺប្រើ «នូវ» ក៏បាន មិនប្រើ «នូវ» ក៏បាន៖

(១០ខ)- សម្តេច... បានខិតខំកសាងសមិទ្ធផលយ៉ាងច្រើនរាប់មិនអស់...។ (គ្មាន «នូវ»)

(១០គ)- សម្តេច... បានខិតខំកសាងនូវសមិទ្ធផលយ៉ាងច្រើនរាប់មិនអស់...។ (មាន«នូវ») ការវិភាគនេះបង្ហាញឱ្យឃើញថា ល្បះ(១០), ល្បះ(១០ក), ល្បះ(១០ខ) និង ល្បះ(១០គ) សុទ្ធតែជាល្បះដែលមានវេយ្យាករណភាពនិងមានន័យពេញលេញ មានន័យថា ល្បះទាំង នេះ ថ្វីត្បិតតែមានទម្រង់ផ្ទៃលើផ្សេងគ្នា តែមានទម្រង់ផ្ទៃ ក្រោមតែមួយ។ ក្នុងចំណោមល្បះទាំងនេះ ល្បះ(១០ខ) ជាល្បះវេយ្យាករណ៍សុទ្ធសាធគ្មានប្រើរចនាបថឡើយ, ល្បះ (១០) និង ល្បះ(១០គ)ជាល្បះដែលប្រើប្រាស់រចនាបថ។

(១០ក)ជាល្បះខ្សត់ខ្សោយខាងរចនាបថឬប្រើរចនាបថខុសទំនង ព្រោះមានកិរិយាសព្ទ «កសាងឡើង» តែមិនមាន«នូវ»នៅពីមុខកន្សោមនាមកម្មបទផ្ទាល់ ដែលធ្វើឱ្យអ្នកស្តាប់សម័យបច្ចុប្បន្នទាស់ត្រចៀកបន្តិច។

- ក្នុងល្បះ(១១)៖ យើងឃើញថា វត្តមានរបស់ពាក្យ «នូវ» កើតឡើងដោយសារតែវាទករប្រើកន្សោមពាក្យជាកិរិយាវិសេស«ឡើងវិញ» ជាប់នឹងកិរិយាសកម្ម «ចងក្រង»។ ផ្ទុយទៅវិញ បើគ្មានកន្សោមពាក្យ «ឡើងវិញ» នៅក្នុងល្បះ ឬ ប្តូរទីតាំងកន្សោមពាក្យ «ឡើងវិញ» មកនៅបន្ទាប់ពីកន្សោមនាមកម្មបទផ្ទាល់ សាស្ត្រាស្លឹករឹត ឬ នៅខាងចុងល្បះ នោះវត្តមានរបស់ពាក្យ «នូវ» មិនមែនជាភាពចាំបាច់ទេ។

- គ្មានកន្សោមពាក្យ «ឡើងវិញ» យើងខ្ញុំទទួលបានល្បះ៖

(*១១ខ*)- ព្រះអង្គបានចំណាយពេលអស់ជាង ២ ឆ្នាំ ដើម្បីរៀបចំចងក្រងសាស្ត្រាស្លឹករឹតដែលជាផ្នែកមួយតំណាងអោយវប្បធម៌ខ្មែរសម័យបុរាណ...។

- កន្សោមពាក្យ ឡើងវិញ ស្ថិតនៅជាប់នឹងកម្មបទផ្ទាល់ យើងខ្ញុំទទួលបានល្បះ៖

*(១១គ)*- ព្រះអង្គបានចំណាយពេលអស់ជាង២ឆ្នាំ ដើម្បីរៀបចំចងក្រងសាស្ត្រាស្លឹករឹតឡើងវិញដែលជាផ្នែកមួយតំណាងអោយវប្បធម៌ខ្មែរសម័យបុរាណ...។

-កន្សោមពាក្យឡើងវិញ នៅខាងចុងល្បះ យើងខ្ញុំទទួលបានល្បះ៖

*(១១ឃ)- ព្រះអង្គបានចំណាយពេលអស់ជាង២ឆ្នាំ ដើម្បីរៀបចំចងក្រងសាស្ត្រាស្លឹករឹត ដែលជាផ្នែកមួយតំណាងអោយវប្បធម៌ខ្មែរសម័យបុរាណឡើងវិញ ...។*

ការដកកន្សោមពាក្យ «ឡើងវិញ» ចេញពីកន្សោមកិរិយា ដូចក្នុងល្បះ(១១ខ) ធ្វើឱ្យវាមានការប្រែប្រួលន័យប្លែកពីល្បះ(១១)និងល្បះ(១១ក)បន្តិច ព្រោះពុំមានការបញ្ជាក់ឱ្យអ្នកស្តាប់បានដឹងថាជាការធ្វើឡើងវិញ។ ផ្ទុយទៅវិញ ល្បះ(១១គ)និងល្បះ(១១ឃ)ពុំមានន័យប្លែកពីល្បះ(១១)និងល្បះ(១១ក)ឡើយ ទោះបីវាមានទម្រង់ផ្ទៃក្រោមខុសប្លែកគ្នាក៏ដោយ ក៏ប៉ុន្តែ យើងមើលឃើញថា ល្បះ (១១ក) ជាល្បះដែលពិបាកស្តាប់ជាងគេ។

-ក្នុងល្បះ(១២) ៖ យើងឃើញថា វត្តមានរបស់ពាក្យ «នូវ» មានឡើងដោយសារតែមានកន្សោមពាក្យដែលជាកិរិយាវិសេសន៍ «ឱ្យបានល្អ» នៅជាប់នឹងកិរិយាសព្ទ «អនុវត្ត»។ បើគ្មានកន្សោមពាក្យ «ឱ្យបានល្អ» នៅក្នុងល្បះទេ ពាក្យ «នូវ» ដែលនៅពីមុខកន្សោមនាមកម្មបទ «ពាក្យស្លោក» មិនមែនជាការចាំបាច់ឡើយ៖

(១២ខ)- ប្អូនៗត្រូវអនុវត្តនូវពាក្យស្លោកថា សូវបង្ហូរញើសលើទីលានហ្វឹកហាត់ដើម្បីចៀសវាងការបង្ហូរឈាមនៅលើសមរភូមិប្រយុទ្ធ។ (មាន «នូវ»)

(១២គ)- ប្អូនៗត្រូវអនុវត្តពាក្យស្លោកថាសូវបង្ហូរញើសលើទីលានហ្វឹកហាត់*ដើម្បីចៀសវាងការបង្ហូរឈាមនៅលើសមរភូមិប្រយុទ្ធ។ (គ្មាន «នូវ»)*

ការដកកន្សោមពាក្យ «ឱ្យបានល្អ» ចេញពីឃ្លាៈធ្វើឱ្យពាក្យ «នូវ» ក្លាយជាធាតុមិនចាំបាច់នៅក្នុងឃ្លាៈមានន័យថា វាទករអាចប្រើឬមិនប្រើពាក្យ«នូវ»នៅក្នុងឃ្លាៈរបស់ខ្លួនៈ ឃ្លាៈ(១២ខ) ដែលមាន «នូវ» នៅពីមុខកម្មបទ «ពាក្យស្លោក» គឺជាឃ្លាៈដែលវាទករប្រើរចនាបថតាមចំណូលចិត្តរបស់ខ្លួន, ចំណែកឯឃ្លាៈ(១២គ)វិញ ដែលពុំមាន «នូវ» នៅពីមុខកម្មបទ «ពាក្យស្លោក» គឺជាឃ្លាៈវេយ្យាករណ៍សុទ្ធសាធ ពុំមានប្រើរចនាបថឡើយ។

ថ្វីត្បិតតែការដកកន្សោមពាក្យ «ឱ្យបានល្អ» ចេញពីឃ្លាៈ មិនធ្វើឱ្យខូចរចនាសម្ព័ន្ធឃ្លាៈ និង មិនរំខានដល់ការប្រើប្រាស់ពាក្យ«នូវ» តែវាបានធ្វើឱ្យឃ្លាៈថ្មីបាត់បង់គំនិតខ្លះដែលវាទករចង់សង្កត់លើកិរិយាសព្ទ «អនុវត្ត» គឺវាទករចង់ជំរុញគូសន្ទនារបស់ខ្លួនឱ្យ«អនុវត្តពាក្យស្លោកឱ្យបានល្អ»។ ក្នុងការនិយាយស្តីធម្មតា ដើម្បីប្រាស្រ័យទាក់ទងគ្នាក្នុងជីវភាពប្រចាំថ្ងៃនាពេលបច្ចុប្បន្ននេះ យើងខ្ញុំពុំធ្លាប់ជួបឃ្លាៈដែលមានពាក្យ «នូវ» នាំមុខកម្មបទនៃកិរិយាសកម្មឡើយ។ យើងខ្ញុំសង្កេតឃើញថាឃ្លាៈដែលមានប្រើពាក្យ «នូវ» ជាឃ្លាៈនៃភាសាសម្រិតសម្រាំង ភាគច្រើនជាឃ្លាៈក្នុងអត្ថបទសំណេរ ដូចជា អត្ថបទបកប្រែពីភាសាបរទេស លិខិតរដ្ឋបាល សុន្ទរកថា អត្ថបទកាសែត ទស្សនាវដ្តី ឬ ជាឃ្លាៈរបស់អ្នកដែលទទួលបានឱកាសពិសេសថ្លែងទៅកាន់អ្នកស្តាប់ច្រើននាក់ឬសាធារណជនទូទៅ។ ខាងក្រោមនេះជាឃ្លាៈមួយចំនួនទៀត ដែលមាន «នូវ» នៅខាងមុខកន្សោមនាមកម្មបទផ្ទាល់ៈ

*(១៣)-* តថាគតបានឃើញនូវភូមិភាគគួរជាទីសប្បាយក្នុងសេនានិគមនោះផង នូវដងព្រៃជាទីជ្រះថ្លាផង នូវស្ទឹងដែលមានទឹកហូរ មានទឹកថ្លា មានកំពង់ដ៏ល្អជាទីសប្បាយផងនូវស្រុកជាទីគោចរជិតល្មមផង។

*(១៤)-* ប្អូនៗត្រូវយកចិត្តទុកដាក់ចងចាំកត់ត្រានិងតាមដាន ក្តាប់ជាប់នូវបណ្តាមេរៀន សំដៅបង្កើននូវរាល់ចំណេះដឹងផ្នែកកងទ័ព...។

*(១៥)-* នៅពេលឆាប់ៗខាងមុខនេះ យើងនឹងមានបណ្ណាល័យអេឡិចត្រូនិកមួយ សម្រាប់ផ្តល់នូវភាពងាយស្រួលដល់ការស្រាវជ្រាវឯកសាររបស់និស្សិតថ្នាក់បណ្ឌិត ...។

(១៦)- លោកអ្នកងើបពីព្រលឹម បើកនូវវិទ្យុ*FM 102.5 ...។*

សរុបសេចក្តីមក យើងខ្ញុំយល់ឃើញថា ការប្រើប្រាស់ «នូវ» នៅក្នុងឃ្លាៈនៃកិរិយាសកម្ម ពុំមែនជាកត្តាចាំបាច់ខាងផ្នែកវេយ្យាករណ៍ទេ តែការប្រើប្រាស់ «នូវ» ក្នុងឃ្លាៈសកម្មនេះ ជាការប្រើប្រាស់ក្រោមឥទ្ធិពលនៃចំណូលចិត្ត ឬ ជាកត្តាជំរុញដែលស្ថិតនៅក្រោមឥទ្ធិពលនៃរចនាបទតែប៉ុណ្ណោះ។ ដូច្នេះ យើងអាចនិយាយបានថា ទោះបីជាឃ្លាៈមានពាក្យ «នូវ» នាំមុខកន្សោមនាមកម្មបទក៏ដោយ ក៏កម្មបទនោះនៅតែជាកម្មបទផ្ទាល់ ហើយកិរិយាសព្ទនៅតែជាកិរិយាសកម្មផ្ទាល់ដដែល។

## គន្ថនិទ្ទេស

### ស្នាដៃជាភាសាខ្មែរ


-ក្រសួងអប់រំៈ វេយ្យាករណ៍ថ្នាក់ទី៧, រោងពុម្ពរណសិរ្ស, ភ្នំពេញ, ១៩៨៣។

-ក្រសួងអប់រំៈ វេយ្យាករណ៍ថ្នាក់ទី៨, រោងពុម្ពរណសិរ្ស , ភ្នំពេញ, ១៩៨៦។

-ច័ន្ទ សំណព្វៈ "ជុំវិញបញ្ហានៃបំលាស់ប្តូរបំរើបំរាស់ និង ការបង្កើតពាក្យ ក្នុងភាសាខ្មែរទំនើប", នៅក្នុងៈ ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ, ឆ្នាំ ទី៣៣, លេខ ៤៤, ខែកក្កដា-កញ្ញា ឆ្នាំ២០០៣។

-ច័ន្ទ សំណព្វៈ "វាក្យស័ព្ទនាម", នៅក្នុងៈ ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ, ឆ្នាំទី៣៤, លេខ ៤៦, ខែមករា-មីនា ឆ្នាំ២០០៤។

-ច័ន្ទ សំណព្វៈ "ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរៈ តួនាទីនៃបុរបទ «ការ» និងផ្នត់ដែក [-អំម/ណ-]/[-អំម/ន-]", នៅក្នុងៈ ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ, ឆ្នាំទី៣៧, លេខ៥៩, ខែមេសា-ឧសភា- មិថុនា ឆ្នាំ ២០០៧។

- ព្រុំ ម៉ល់ៈ "លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យក្នុងភាសាខ្មែរ", នៅក្នុងៈ ទស្សនាវដ្តី ***វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា, លេខ០២ មិថុនា ២០០១។***

- នៅ ស៊ុនៈ "ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់ និង ភាសាមិនមែនអ៊ីសូឡង់" នៅក្នុងៈ Sorn Samnang (Ed.) *ខេមរវិទ្យា* volume II, ១៩៩៩។

- ឡុង សៀមៈ បញ្ហាវចនសព្ទវិទ្យាខ្មែរ, ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ ១៩៩៩។

- អៀវ កើស ៖ ភាសាខ្មែរ, បណ្ណាគារ មិត្តសេរី, ភ្នំពេញ ១៩៦៧។

**ស្នាដៃជាភាសាបរទេសៈ**

- Huffman Franklin, *Modern spoken Cambodia*, New Haven & London, Yale University Press, 1970;

- Judith Jacob, *Cambodian linguistics, litterature and history*, School of Oriental and African Studies (London), 1993;

- Khin Sok, *La grammaire du khmer moderne*, You Feng, Paris, 1999 ;

- Lemaréchal Alain, *Les parties du discours*, Presses Universitaires de France, 1989;

- Long Seam, "contacts externes des langues Mon-Khmer ", in : *Bulletin de l'École Française d'Extrême- Orient,* Tome LXX, Paris, 1981;

- Maspéro Georges, *Grammaire de la langue khmère*, École Française d'Extrême Orient, Imprimerie Nationale (Paris), 1915;

- Maurice Grevisse, *Précis de grammaire française*, Duculot , 1995, 30e Edit.;

- Prum Marc , *Linguistique appliquée à l'enseignement* , Université Nationale de Côte d'Ivoire, 1995;

- Prum Marc, *Initiation à la Linguistique*, Université de Toliara (Madagascar), 1990;

-Prum Marc, "Processus sociolinguistique de la transformation du système lexicologique du khmer ", in: *Revue Tétralogiques* , N° 7 - 1989, pp.61-73, UFR du Langage, Presses Universitaires Rennes II, France;

- Prum Marc, "Analyse sommaire des structures du cambodgien", in: *Bulletin de la CommunautéKhmère d'Outre-Mer*, N° 2 – 1962, Paris;

- Vogel Sylvain, " Introduction à une grammaire du secondaire pour le Cambodge", in : *Cahiersd'Etudes franco-cambodgiens*, N°1-1994, Cercle de Linguistique Franco-Khmer de l'Université de Phnom Penh;

# នយោបាយសេដ្ឋកិច្ចនៅកម្ពុជាពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០



លោក **ជូ ច័ន្ទដារី**
បេក្ខជនបណ្ឌិត ឯកទេសប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-ការរៀបចំនយោបាយសេដ្ឋកិច្ចសង្គម

នៅក្នុងកំលុងទសវត្សរ៍ទី៥និងទី៦នៃស.វ.ទី២០ ស្ថានភាពសេដ្ឋកិច្ចក្នុងការធ្វើវិនិយោគពីបរទេស ពុំសូវមានសភាព ខ្លាំងក្លាទេ ដោយនៅកំលុងឆ្នាំ១៩៥៦-១៩៦១ រាជរដ្ឋាភិ-បាលបានទិញភាគហ៊ុនរបស់ក្រុមហ៊ុនបារាំងមួយចំនួន ដូចជាវិស័យសំណង់អគារនិងរោងចក្រជាដើម។ នៅពេលនោះ ដោយសារតែមូលធនជាតិមានទំហំតូច រាជរដ្ឋាភិបាលបាន ដឹកនាំនយោបាយទាក់ទាញការធ្វើវិនិយោគពីបរទេសនៅ ក្នុងសហគ្រាសចម្រុះ តែវឌ្ឍនភាពនៃសហគ្រាសចម្រុះនេះពុំសូវមានការលេចធ្លោប៉ុន្មានទេ ដោយមានទំហំតិចតួចប៉ុណ្ណោះសម្រាប់ទំហំសហគ្រាសទាំងអស់នៅក្នុងប្រទេស។

ការមិនបានយកចិត្តទុកដាក់ពីសំណាក់មូលធនជាតិនិងបរទេសដើម្បីវឌ្ឍនភាពឧស្សាហកម្មនេះ បានធ្វើឱ្យដំណើរការសហគ្រាសឧស្សាហកម្មរដ្ឋពុំសូវមានប្រសិទ្ធភាព ធ្វើឱ្យសហគ្រាសរដ្ឋនៅទ្រឹង ហើយនាំឱ្យមានការកាត់បន្ថយនូវកម្លាំងពលកម្មសង្គម។

នៅក្នុងការរៀបចំនយោបាយសេដ្ឋកិច្ចប្រទេសនាពេលនោះដែរ គឺជាគម្រោងមួយដែលមានលក្ខណៈជារួមនៅក្នុងការកំណត់ទិសដៅវឌ្ឍនភាពសេដ្ឋកិច្ចប្រទេសគឺផែនការពីរឆ្នាំដំបូងដែលបានកំណត់យកពីឆ្នាំ១៩៥៦-១៩៥៨។ នៅក្នុងផែនការនេះមានជាកម្មវិធីសម្រាប់ទិសដៅអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅលើវិស័យកសិកម្មនិងឧស្សាហកម្ម។ ប៉ុន្តែដើម្បីបំពេញគម្រោងខាងលើនេះបាន គឺអាស្រ័យដោយពឹងផ្អែកទៅលើជំនួយពីបរទេស មានសហរដ្ឋអាមេរិក បារាំង និង ប្រទេសចិន ដែលជំនួយនេះមានទំហំដ៏ច្រើន។ ក្នុងនោះសហរដ្ឋអាមេរិកបានផ្តល់ជំនួយឱ្យដល់ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៥៩ដែលមានទឹកប្រាក់សរុបប្រមាណ ២៤៩ ៩០០ ០០០៛ សម្រាប់សេដ្ឋកិច្ចនិងយោធា[២៤]។

សហរដ្ឋអាមេរិកជាប្រទេសទីមួយដែលបានផ្តល់ជំនួយដល់ប្រទេសកម្ពុជា ចាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យ។ ការផ្តល់ជំនួយរបស់សហរដ្ឋអាមេរិកធ្វើឡើងស្របទៅតាមការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយគ្មានលក្ខខណ្ឌណាមួយទាក់ទងនឹងបញ្ហានយោបាយឡើយ ដែលបំណងស្នើសុំនេះសំខាន់ ដើម្បីឱ្យកម្ពុជាអាចមានសមត្ថ-ភាពទ្រទ្រង់ឯករាជ្យជាតិរបស់ខ្លួនបានតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច[២៥]។

**នៅក្នុងទំនាក់ទំនងជាមួយនឹងបារាំង ប្រទេសកម្ពុជាក៏មានការស្នើសុំជំនួយនេះពីប្រទេសបារាំងផងដែរ ដោយ គណៈកម្មការជំនួយសេដ្ឋកិច្ចបារាំងមួយ។ នៅឆ្នាំ១៩៥៥ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្តីពីសហប្រតិបត្តិការខាងពាណិជ្ជកម្មជាមួយនឹងប្រទេសបារាំង[២៦]។**

នៅឆ្នាំ១៩៥៨ ប្រទេសកម្ពុជាបានបង្កើតឡើងនូវចង្វាក់ផលិតកម្មសេដ្ឋកិច្ចមួយហៅថា រាជសហករណ៍ (សហ-ករណ៍យើង)ជាអង្គការមួយរបស់រដ្ឋ ដែលបង្កើតឡើងដោយព្រះមហាក្សត្រ តាមសេចក្តីស្នើសុំនៃសម្តេចព្រះនរោត្តម សីហនុ

---

[២៤] Mission d´ Aide Americaine au Cambodge, le progra-me de laide economique Americaine au Cambodge : 1955-1959, E.K.L.P anciennement A. Portail, Phnom Penh, 1960, p.9

[២៥] ក្រសួងឃោសនាការ៖ សេចក្តីបញ្ជាក់នៃសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ អតីតមហាក្សត្រកម្ពុជា ចំពោះពាក្យឃោសនារបស់គណបក្សប្រជាធិបតេយ្យ, ១៩៦៦ ទំព័រទី៣-៤។

[២៦] យ យ មីហោយេវ ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ៤១៥។

ឧបឃុវរាជ ដោយអង្គការនេះអាចលើកតម្កើងជីវ-ភាពបណ្តារាស្ត្រទូទៅឱ្យបានខ្ពង់ខ្ពស់ឡើង[២៧]។

រាជសហករណ៍មានទិសដៅសំខាន់មួយដែលធ្វើយ៉ាងណា ដើម្បីឱ្យប្រជាកសិករខ្មែរអាចកាត់ផ្តាច់ពីការជិះ-ជាន់របស់ពួកឈ្មួញកណ្តាលដែលបានបង្កើតនូវប្រព័ន្ធទំនាក់ទំនងហិរញ្ញវត្ថុ ដោយយកការប្រាក់យ៉ាងខ្ពស់នៅទីជនបទខ្មែរ។

នៅឆ្នាំ១៩៥៨ រាជសហករណ៍បានធ្វើសកម្មភាពពាសពេញផ្ទៃប្រទេស ដោយបានរៀបចំឱ្យមាននៅតាមបណ្តាឃុំនានាដែលជាសាខានៅទូទាំងខេត្ត ដោយការឧបត្ថម្ភដល់ប្រជាកសិករខ្មែរនូវគ្រឿងឧបភោគបរិភោគផ្សេងៗជាច្រើនមុខ ដោយរក្សាតម្លៃទាបជាងតម្លៃទីផ្សារ និង សម្រាប់ប្រមូលទិញកសិផលពីប្រជាកសិករ។ មិនតែប៉ុណ្ណោះ អ្នកដែលជាសមាជិកនៃរាជសហករណ៍ដែលត្រូវការប្រាក់ អាចខ្ចីប្រាក់យកទៅទិញគ្រឿងសម្ភារៈពង្រីកផលិតកម្មក៏សហ-ករណ៍នឹងមានប្រាក់បម្រុងទុកឱ្យខ្ចីថែមទៀត[២៨]។ សកម្មភាពរបស់រាជសហករណ៍ដែលបានធ្វើការគ្រប់គ្រងទៅលើសកម្មភាពសេដ្ឋកិច្ចកសិកម្មមានចំនួនប្រមាណ៥០ភាគរយ។ តែចាប់ពីក្រោយឆ្នាំ១៩៦៣ មក ចំនួននៃរាជសហករណ៍នេះក៏បានថយចុះទៅវិញរហូតដល់ឆ្នាំ១៩៦៩។

សហករណ៍ជាតិ មិនត្រឹមតែទទួលទិញផលិតផលកសិផលពីប្រជាកសិករនោះទេ ព្រមទាំងមានការដោះដូរជាមួយនឹងកសិករនូវគ្រឿងឧបភោគបរិភោគទៅនឹងឧបករណ៍ដែលជាមធ្យោបាយផលិតកម្ម។ សហករណ៍ជាតិក៏បានធ្វើឱ្យមានការផ្តល់ឥណទានដល់ប្រជាកសិករផងដែរ។ នៅក្នុងដំណើរផលិតកម្មនៃសហករណ៍ជាតិនេះ ជាដំបូង បានទទួលជោគជ័យនៅក្នុងសកម្មភាពសេដ្ឋកិច្ច ដូចជាការប្រមូលទិញស្រូវពីប្រជាកសិករ។

ដោយសារមូលដ្ឋានសម្ភារៈបច្ចេកទេសនិងប្រភពហិរញ្ញវត្ថុរបស់រាជសហករណ៍មានកម្រិតទន់ខ្សោយសម្រាប់ការងារផលិតកម្មខាងលើនិងម្យ៉ាងទៀតដោយប្រាក់ឥណ-ទានដែលរដ្ឋបានប្រគល់ឱ្យត្រូវបានគេយកទៅប្រើមិនចំមុខសញ្ញាព្រមទាំងមានការកេងបន្លំ។ ឥណទានដែលរដ្ឋាភិបាលផ្តល់ឱ្យសហករណ៍ជាតិត្រូវបានគេយកទៅទិញសម្ភារៈដែលមិនមែនជាសេចក្តីត្រូវការចាំបាច់សម្រាប់ការងារផលិតកម្មរបស់ប្រជាកសិករទេ បែរជាទៅទិញអ្វីដែលគេត្រូវការនៅ ឯទីក្រុងទៅវិញ មានដូចជាគ្រឿងលម្អនិងសង្ហារិមជាដើម។

ដោយសារតែស្ថានភាពបែបនេះ ទើបនាំឱ្យសហ-ករណ៍ជាតិ ស្ថិតក្នុងអស្ថិរភាពនិងអសមត្ថភាព ពីព្រោះមិនបានបង្វិលថវិកាឱ្យទៅរដ្ឋាភិបាលវិញឱ្យបានទាន់ពេលវេលាដែលនាំឱ្យកើតមានជាវិបត្តិនៃរាជសហករណ៍នេះ ទីបំផុតស្ថានភាពសេដ្ឋកិច្ចមួយដែលរំពឹងទុកក្នុងការជួយជំរុញចង្វាក់ផលិតកម្មនៃសេដ្ឋកិច្ចជាតិក៏ត្រូវបាត់បង់ទៅវិញ។

## ២-ការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចសង្គម

នៅប្រទេសកម្ពុជារវាងពាក់កណ្តាលទសវត្សរ៍ទី៥ និងដើមទស្សវត្សរ៍ទី៦នៃស.វ.ទី២០ មានការលេចឡើងនូវស្រទាប់ថ្មីៗដែលមានដូចជា បញ្ញវន្តទីក្រុង ផលិតករ កម្មករសម្រាប់សេវាកម្មទូទៅនិងពួកក្រុមមូលធនតូចៗ។ កំណើនពួកក្រុមមូលធននេះ បានបង្កើតជាទ្រង់ទ្រាយមួយថ្មីនៅក្នុងជួរអ្នកដឹកនាំ ក្នុងនោះមានដូចជាមេបញ្ជាការយោធានិងមន្ត្រីរាជការ ដែលមានមុខតំណែងខ្ពស់ៗ ដែលពួកទាំងនេះបានចូលរួមធ្វើសកម្មភាពទំនាក់ទំនងជំនួញក្នុងរូបភាពច្រើនបែបច្រើន យ៉ាង ដោយសារតែពួកគេមានអំណាចនិងដើមទុន។

នៅក្នុងកំលុងទសវត្សទី៦នៃស.វ.ទី២០ ពួកមេដឹកនាំមួយចំនួននៅក្នុងជួររដ្ឋាភិបាលបានចាប់ផ្តើមដាក់ទុនរបស់គេទៅក្នុងវិស័យឧស្សាហកម្ម។ ពេលនោះដំណើររីកចម្រើននៃ ទំនាក់ទំនងមូលធននិយមនៅទីក្រុង មានដំណើរលឿនជាង នៅឯទីប្រជុំជនខេត្តនិងជនបទ ដែលស្ថានភាពបែបនេះនាំឱ្យកើតមានគម្លាតគ្នា នៅក្នុងបែបផែនផលិតកម្ម-កសិកម្ម ហើយធ្វើឱ្យមានភាពស្មុគស្មាញរវាងអ្នកនៅទីក្រុងនិងជនបទ ក៏នាំឱ្យកើតមានទំនាស់ឡើង។

ប្រជាជនមួយចំនួនធំនៅក្នុងទីក្រុងបានប្រកបមុខរបរអាជីវកម្មជំនួញនិងសេវាកម្មទូទៅ តែក្នុងផ្នែកសកម្មភាពឧស្សាហកម្មនៅមានចំនួនតិច ហើយចំនួនមនុស្សនៅទីក្រុងកាន់តែច្រើនឡើងៗ ជាហេតុនាំឱ្យមានការលំបាកក្នុងការស្វែងរកការងារធ្វើ ដែលធ្វើឱ្យជីវភាពសេដ្ឋកិច្ចប្រជាពលរដ្ឋមានការលំបាក។

នៅក្នុងកំលុងទសវត្សរ៍នៃឆ្នាំ៦០ គេឃើញមានការលេចឡើងនូវការខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍផលិតកម្មឧស្សាហកម្មជាតិ ប៉ុន្តែលក្ខណៈនៃដំណើរវិវត្តឧស្សាហកម្ម

[២៧] រាជសហករណ៍និងសហករណ៍សាខា, ឆ្នាំ១៩៥៩ ទំព័រទី១។
[២៨] -ដ- ទំព័រទី៧។

របស់ប្រទេសកម្ពុជានាពេលនោះ ស្ថិតក្នុងទំហំផលិតកម្មខ្នាតតូចច្រើន ដែលស្ថិតក្នុងដែកម្មសិទ្ធិឯកជន។ រាជរដ្ឋាភិបាលមានគោលនយោបាយគាំទ្រដល់ផលិតកម្មឯកជនដោយផ្តល់ភាពអនុគ្រោះលើការបង់ពន្ធដារ មានការផ្តល់ប្រាក់ឥណទានជាតិនិងការធានាចំពោះការធ្វើជាតូបនីយកម្មសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។

នៅពាក់កណ្តាលដើមទសវត្សរ៍ទី៦នៃស.វ.ទី២០នៅប្រទេសកម្ពុជា គេឃើញហាក់ដូចជាមានការកើនឡើងនូវសកម្មភាពនៃឧស្សាហកម្ម ដោយមានការសង់រោងចក្រសហគ្រាសច្រើនកន្លែង ហើយដែលជាដំណាក់កាលមួយធ្វើឱ្យមានកំណើនផលិតកម្មសេដ្ឋកិច្ចរបស់ប្រទេស។ តែបន្ទាប់ពីឆ្នាំ១៩៦៤មក គេក៏ឃើញមានការថយចុះនូវចំនួនសហគ្រាសឯកជនជាតិទៅវិញ ដោយគេឃើញមានសកម្មភាពសហគ្រាសឯកជន ជាជនជាតិចិន។ ជាទូទៅ ជនជាតិចិនបានគ្រប់គ្រងសហគ្រាសឯកជនខ្នាតតូចដែលមានទំហំមូលនិធិដ៏ច្រើន។ នៅដើមទសវត្សរ៍ទី៦នៃស.វ.ទី២០ជាដំណាក់កាលមួយមានការរីកចម្រើននូវសហគ្រាសឯកជន និង មានបម្រែបម្រួលនៅក្នុងប្រាក់វិនិយោគលើវិស័យឧស្សាហកម្ម។ សហគ្រាសថ្មីៗដែល បានបង្កើតឡើងមានដូចជារោងម៉ាស៊ីនកិនស្រូវ រោងចក្រគីមី រោងចក្រសង្កសី រោងចក្រកៅស៊ូ។ល។

រាជរដ្ឋាភិបាលបានចូលប្រឡូកក្នុងវិស័យផលិតកម្មចាប់ពីពាក់កណ្តាលទសវត្សរ៍ទី៦នៃស.វ.ទី២០។ ដំបូងរដ្ឋាភិបាល មានគម្រោងដើម្បីលើកកម្ពស់សហគ្រាសជាតិ តែដោយសហគ្រាសជាតិមានលក្ខណៈទន់ខ្សោយ និង មានទំនោរវិនិយោគទៅលើវិស័យនានាជាប្រពៃណីទំនៀមទម្លាប់។ ស្ថានភាពបែបនេះបង្ហាញឱ្យឃើញនូវអសមត្ថភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើកម្មវិធីដោយមានការឧបត្ថម្ភពីរដ្ឋ។ ដោយសារស្ថានភាពបែបនេះហើយរាជរដ្ឋាភិបាលបានសម្រេចចិត្តបង្កើតសហគ្រាសដោយខ្លួនឯង គឺជាសហគ្រាសរដ្ឋ តែរដ្ឋាភិបាលមិនប្រឆាំងទៅនឹងវិស័យឯកជនឡើយ។ មូលធនឯកជនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់ទុននៅក្នុងគម្រោងសេដ្ឋកិច្ច។ នយោបាយសេដ្ឋកិច្ចមានមូលដ្ឋាននៅលើលំនឹង រវាងសហគ្រាសរដ្ឋនឹងសហគ្រាសឯកជនធ្វើយ៉ាងនេះ គឺ ដើម្បីផ្តល់លទ្ធភាពពេញបរិបូរដល់វឌ្ឍនភាពនិយោជក ឯកជន។

## ៣- បញ្ហាសេដ្ឋកិច្ចក្នុងដំណាក់កាលចុងក្រោយនៃសង្គមរាស្ត្រនិយម

ក្នុងដំណើរវិវត្តនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្រោយពីប្រទេសនេះបានប្រកាន់យកនូវជំហរឯករាជ្យរបស់ខ្លួន ឃើញថាសកម្មភាពសេដ្ឋកិច្ចនៃប្រទេស មានការវិវត្តឈានឡើងបន្តិចម្តងៗ ដែលនេះដោយសារតែជំនួយគាំទ្រពីបណ្តាប្រទេសនានា ដូចជាសហរដ្ឋអាម៉េរិក ចិននិងសហភាពសូវៀត។ ប៉ុន្តែដោយសារតែជំនួយខ្លះមានការគាបសង្កត់ខាងផ្នែកនយោបាយ ប្រទេសកម្ពុជាក៏សុខចិត្តឈប់ទទួលយកជំនួយនោះទៅវិញ ដូចជាការឈប់ទទួលជំនួយពីសហរដ្ឋអាម៉េរិក[២៩]។

នៅក្នុងកំលុងទសវត្សរ៍ទី៦នៃស.វ.ទី២០ ប្រទេសកម្ពុជាមានការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមលើវិស័យនានាជាច្រើន។ តែមកដល់ឆ្នាំ១៩៦៩ ទើបបានដឹងពីការចុះអន់ថយនៃសេដ្ឋកិច្ចប្រទេស គឺជាបរាជ័យនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់សង្គមរាស្ត្រនិយម។ ការកើតមាននូវឱនភាពថវិកាបានកើតមានយ៉ាងខ្លាំងដែលពុំធ្លាប់មានពីមុនមក។ ផលិតផលកសិកម្មលែងមានការរីកចម្រើន ហើយលទ្ធភាពនៃការនាំចេញមានកម្រិតទាបជាងការគ្រោងទុក។

ការគ្រប់គ្រងផ្នែកសេដ្ឋកិច្ច ដែលរដ្ឋបានធ្វើជាតូបនីយកម្ម គឺជាប្រភពមួយនាំកើតមានភាពមិនប្រក្រតី ជាពិសេស អំពើពុករលួយនិងការកិបកេងទ្រព្យសម្បត្តិក៏ដូចជាថវិការដ្ឋ បានកើតមានឡើងយ៉ាងចំហនិងរីករាលដាលដល់ពួកមន្ត្រីធំៗនៅក្នុងជួរអ្នកដឹកនាំប្រទេស។

ដោយសារស្ថានភាពនេះ គេបានចាត់វិធានការមួយជាបន្ទាន់ដើម្បីរៀបចំឡើងវិញខាងផ្នែកហិរញ្ញវត្ថុដោយតម្រូវឱ្យមានការកាត់បន្ថយរាល់ចំណាយដោយឥតគ្រោងទុកនិងរាល់ចំណាយតាមទំនើងចិត្ត។ ក្នុងការរៀបចំដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចឡើងវិញជាចាំបាច់ត្រូវតែស្វែងរកជំនួយពីបរទេស។ បញ្ហានេះក៏តម្រូវឱ្យមានការរៀបចំនិងសម្របសម្រួលខាងផ្នែកនយោបាយ ជាពិសេសទំនាក់ទំនងនយោបាយការបរទេសជាមួយប្រទេសមហាអំណាចនានាមានដូចជាបារាំង

[២៩]-Raoul M. Jennar, Les cles du cambodge. Faits et chiffres, reperes historiques, profiles cambodgiens. Maisonneuve et la rose, 1995, p. 63

ចិន សហភាពសូវៀត និងជាពិសេសជាមួយនឹងសហរដ្ឋ-អាម៉េរិក ។

ស្ថានភាពនៃទំនាក់ទំនងរវាងប្រទេសកម្ពុជាជាមួយនឹងសហភាពសូវៀត បានកើនរឹតតែខ្លាំងឡើងនៅខែមេសា មានគណៈបេសកកម្មមួយបានត្រូវបញ្ជូនទៅកាន់ទីក្រុងមូស្គូ ដើម្បីសុំជំនួយចាំបាច់បំផុតមួយលើផ្នែកសម្ភារៈសឹក រួមផ្សំនឹងការខ្ចីប្រាក់ជាយថាហេតុមួយក្នុងរយៈពេលយូរផង។ ប៉ុន្តែពួកមេដឹកនាំរបស់សូវៀតបានបង្ហាញឱ្យឃើញភាពស្ទាក់ស្ទើរយ៉ាងខ្លាំងនិងភាពមិនច្បាស់លាស់ក្នុងការផ្គត់ផ្គង់អាវុធ និងគ្រាប់រំសេវ ដែលការផ្ដល់នេះអាចឱ្យគេយកមកប្រើប្រាស់ដើម្បីវាយប្រយុទ្ធនឹងពួកអ្នកបះបោរកុម្មុយនីស្តនៅក្នុងប្រទេសទៅវិញ។

នៅទីក្រុងប៉េកាំងឯណោះវិញ គេបានតាមដានប្រកបដោយការយកចិត្តទុកដាក់និងមានការព្រួយបារម្ភអំពីការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា រួមទាំងការតម្រង់ទិសថ្មីនៃនយោបាយរបស់សម្ដេចព្រះបាទ នរោត្ដម សីហនុ។ បេសកកម្មរបស់ពួកអ្នកបច្ចេក-ទេសចិន បានសាកល្បងរៀបចំឱ្យមានសណ្ដាប់ធ្នាប់តិចតួចក្នុងដំណើរប្រព្រឹត្តទៅនឹងការគ្រប់គ្រងរោងចក្រនានារបស់រដ្ឋឡើងវិញ ដែលផ្ដល់ដោយប្រទេសចិននិងបានចាកចេញទៅទាំងបរាជ័យដោយសារការមិនស្ដាប់បង្គាប់និងអសមត្ថ-ភាពរបស់បណ្ដាអគ្គនាយកសហគ្រាសនានាក្នុងប្រទេសកម្ពុជា ដែលពុំមានការទទួលខុសត្រូវ។

ទោះបីយ៉ាងណាក៏ដោយ រដ្ឋាភិបាល ចិនបានរំឭកជាច្រើនលើកច្រើនសាថា ខ្លួនអាចយល់ព្រមផ្ដល់ប្រាក់កម្ចីមួយចំនួនក្នុងរយៈពេលវែង ដោយគ្មានយកការប្រាក់និងគ្មានលក្ខខណ្ឌដល់ប្រទេសកម្ពុជា។ តាមយៈការធ្លាប់ផ្ដល់ជំនួយរបស់ចិនឱ្យដល់កម្ពុជា មានសមិទ្ធផលមួយចំនួនចាប់តាំងពីឆ្នាំ១៩៥៦មកដល់ឆ្នាំ១៩៦៨។ នៅក្នុងចន្លោះឆ្នាំខាងលើនេះ មានការសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានាដូចជារោងចក្រនិងអាកាសយានដ្ឋានសៀមរាបអង្គរជាដើម ដែលនៅក្នុងពិធីសម្ពោធសមិទ្ធផលទាំងនោះ ប្រមុខរដ្ឋនៃប្រទេសម្ពុជាតែងតែលើកឡើងថាមិត្តភាពរវាងប្រជាជនខ្មែរនឹងប្រជាជនចិន គឺជាមិត្តភាពមួយអមតៈគ្មានអ្នកណាអាចបំផ្លាញបាន ហើយគឺជាមិត្តភាពដ៏បិតបេរក្នុងការប្រយុទ្ធ-ប្រឆាំងនឹងចក្រពត្តិអាម៉េរិក[៣០]។

ជាមួយនឹងនោះ រដ្ឋាភិបាលកម្ពុជាក៏បានទៅសុំជំនួយពីរដ្ឋាភិបាលបារាំង រដ្ឋាភិបាលបារាំងក៏បានបញ្ចេញឱ្យដឹងថាខ្លួនអាចយល់ព្រមផ្ដល់នូវប្រាក់កម្ចី ដោយយកការមិនហួសហេតុមួយសម្រាប់ការធ្វើឱ្យសម្រេចពិតប្រាកដនូវកម្មវិធីអភិវឌ្ឍន៍ជាក់លាក់មួយ។ ប៉ុន្តែភាគីបារាំងបានច្រាន-ចោលការយល់ព្រមផ្ដល់ប្រាក់កម្ចីនេះ ដោយយល់ថាភាគីកម្ពុជាពុំបានបង្ហាញអ្វីជាភាពជាក់ស្ដែងណាមួយសោះដើម្បីរៀបចំពិភាក្សាពីទម្រង់បែបបទផ្សេងៗអំពីបញ្ហានេះ។ តាមការពិតគឺទាល់តែមកដល់ខែកុម្ភៈ ឆ្នាំ១៩៧០ ទើបគណៈ-ប្រតិភូមួយរបស់រដ្ឋាភិបាលក្រុងភ្នំពេញធ្វើដំណើរទៅកាន់ទីក្រុងប៉ារីសដើម្បីចាប់ផ្ដើមចរចាពីការខ្ចីប្រាក់នេះ។

បើនិយាយពីក្នុងប្រទេសវិញ សម្ដេចព្រះបាទ នរោ-ត្ដម សីហនុ ប្រហែលជានឹកសង្ឃឹមដល់ការយថយចុះនៃការប្រឆាំងជំទាស់នឹងព្រះអង្គខ្លះ យ៉ាងហោចណាស់ក៏ដោយផ្នែកដែរ ហើយ ព្រមជាមួយគ្នានោះ មានការបំពេញចិត្តអ្នកគាំទ្រព្រះអង្គភាគច្រើន ពួកគហបតីធ្វើជំនួញដែលដាក់ក្ដីសង្ឃឹមទាំងស្រុងរបស់ពួកគេលើជំនួយដ៏សម្បើមមួយរបស់សហរដ្ឋអាម៉េរិក ដែលអមដោយការហូរចូលយ៉ាងច្រើនរបស់វិនិយោគទុនឯកជនផង។ តែទីបំផុតអ្វីៗ មិនអាចជួយស្រោចស្រង់ដល់ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជាបានឡើយ បែរជាធ្វើឱ្យស្ថានភាពធ្លាក់ទៅក្នុងភ្លើងសង្គ្រាមស៊ីវិលមួយគួរឱ្យរន្ធត់។

## សេចក្ដីបញ្ចប់

យើងឃើញថានៅក្នុងការរៀបចំនយោបាយ សេដ្ឋ-កិច្ចប្រទេសក្រោយពីប្រទេសកម្ពុជាបានបង្កើតសង្គមរាស្ត្រ-និយមឡើង ដែលជានយោបាយមួយក្រោមការដឹកនាំដោយសម្ដេចព្រះបាទ នរោត្ដម សីហនុ ហើយដែលសង្គមរាស្ត្រនិយមបានខិតខំយ៉ាងខ្លាំងដើម្បីជាការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដើម្បីក្សោលំនឹងនៃស្ថានភាពនយោបាយរបស់ខ្លួននៅក្នុងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចនេះ សង្គមរាស្ត្រនិយមបានរិះរកគ្រប់មធ្យោបាយ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រនិងកាត់បន្ថយគម្លាតក្នុងជួរប្រជា-ជនរវាងជនបទនិងទីក្រុង ជាពិសេស ការជួយដល់ប្រជា-

---

[៣០] Études Cambodgiennes, No. 14, Avril-Juin 1968, p. 18

កសិករក្នុងការធ្វើចរាចរកសិផល ដោយជំរុញខាងវិស័យកសិកម្មឱ្យកាន់តែឱ្យមានប្រសិទ្ធភាព ដូចជា ការបង្កើត រាជសហករណ៍ដែលមានតួនាទីជួយសម្រួលដល់ការងារផលិត-កម្មកសិកម្មរបស់ប្រជាជន។

ប៉ុន្តែក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិខាងវិស័យឧស្សាហកម្មវិញ សម្រាប់កម្ពុជាខ្លួនឯងពុំទាន់មានអ្វីធំដុំឡើយ សកម្មភាពខាងឧស្សាហកម្ម គឺដោយសារតែជំនួយក្នុងការសាងសង់រោងចក្រពីបណ្តាប្រទេសនានា។ រីឯខាងផ្នែកពាណិជ្ជកម្មក៏ដូចគ្នាដែរ បានក្លាយទៅជាស្ថាប័នមួយផ្តល់ឱកាសដល់ពួកមន្ត្រីធំៗ ឃុបឃិតជាមួយពួកឈ្មួញដើម្បីប្រមូលផលប្រយោជន៍សម្រាប់តែខ្លួនឯងប៉ុណ្ណោះ ដែលការណ៍នេះនាំឱ្យមានភាពអសកម្មនៅក្នុងសង្គម ដែលនាំឱ្យឈានទៅរកភាពឱនថយនៃសេដ្ឋកិច្ចសង្គមបន្តិចម្តងៗ និងនាំឱ្យប្រទេសធ្លាក់ចូលទៅក្នុងវិបត្តិមួយយ៉ាងធ្ងន់ធ្ងរដោះស្រាយលែងរួច។

# ជាតិនិយមតាមរយៈអ្នកនិពន្ធ ឡាំង ប៉េងសៀក ឬ កាណែល



លោក **ហាក់ ម៉ាន់ដារា**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១- ជីវប្រវត្តិនិងស្នាដៃរួមរបស់អ្នកនិពន្ធ ឡាំង ប៉េងសៀក ឬ កាណែល

### ក- ជីវប្រវត្តិ

ចំពោះជីវប្រវត្តិរបស់អ្នកនិពន្ធ ឡាំង ប៉េងសៀក នេះ យើងរកប្រភពដែលអាចឱ្យធ្វើបទសម្ភាសឈានទៅដឹងឮពីលោកឱ្យក្បោះក្បាយនោះពុំបានទេ។ យើងព្យាយាមស្រាវជ្រាវរកប្រភពដែលអាចផ្ដល់ព័ត៌មានពីលោកណាស់ដែរ តែរកពុំឃើញ ដូច្នេះយើងមានសេចក្ដីសោកស្ដាយជាខ្លាំងចំពោះប្រការនេះ អ្វីដែលយើងអាចរកបាននោះ គឺមានតែប្រវត្តិរបស់លោកបន្តិចបន្តួច ដោយយើងគ្រាន់តែបានដឹងថា លោកគឺជាអ្នកនិពន្ធមួយរូបមានឈ្មោះបោះសំឡេងក្នុងស្រទាប់អ្នកអានកាលពីកំលុងទសវត្សរ៍ទី៦នៃស.វ.ទី២០នោះប៉ុណ្ណោះ។ ចំពោះអ្នកនិពន្ធរូបនេះក្រៅពីឈ្មោះ ឡាំង ប៉េងសៀក លោកក៏នៅមានប៉ាកានាមមួយទៀតហៅថា កាណែល[៣១] នោះផងដែរ។

លោក ឡាំង ប៉េងសៀក ឬ កាណែល កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤៦ នៅភូមិកំពង់ថ្ម ស្រុកកំពង់ថ្ម ខេត្តកំពង់ធំ។ កាលពីក្មេងលោកចូលរៀននៅវិទ្យាល័យទីរួមខេត្តកំពង់ធំ ក្រោយមកក៏ផ្លាស់មករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ឯក្រុងភ្នំពេញវិញ។ ក្នុងឆ្នាំ១៩៦៤ លោកបានចូលរៀននៅមហាវិទ្យាល័យច្បាប់ ហើយពីរឆ្នាំក្រោយមកក៏ទទួលបានសញ្ញាបត្រខាងផ្នែកច្បាប់។ នៅឆ្នាំ១៩៦៧ លោកបានជាប់សញ្ញាបត្រខាងក្រឡាបញ្ជីនៅក្នុងតុលាការ។ លោកគឺជាអ្នកដែលតែងតែធ្វើការប្រឆាំងអំពីរបៀបក្នុងការកាត់ទោសរបស់ពួករាជានិយម និង សាធារណរដ្ឋនិយម។

### ខ- ស្នាដៃរួម

ស្នាដៃរបស់លោកដែលយើងបានរកឃើញ គឺមានទាំងអស់ចំនួន១៩ ដែលស្នាដៃទាំង១៩នោះចែកជាពីរគឺ ស្នាដៃឡាំង ប៉េងសៀក មានចំនួន១២និងស្នាដៃកាណែល មានចំនួន៧[៣២]។

ស្នាដៃទាំងឡាយរបស់លោកដែលយើងបានរកឃើញ ភាគច្រើនលោកនិយមជ្រើសរើសយកបញ្ហាជាតិមកធ្វើជាកម្មវត្ថុនៅក្នុងនិមិត្តកម្មរបស់ខ្លួន ប៉ុន្តែបណ្ដាស្នាដៃទាំងនោះ យើងឃើញមានតែស្នាដៃមួយឈ្មោះថា «ទំនួញក្មេងកំព្រា» នោះទេ ដែលមានលក្ខណៈជាតិនិយមស្រួចស្រាល់ជាងគេ ហើយរឿងនេះទៀតសោត ក៏ត្រូវគ្នាទៅនឹងផ្នាំសិក្សាក្នុងពេលនេះផងដែរ។

## ២- សិក្សាលក្ខណៈជាតិនិយមតាមរយៈរឿង "ទំនួញក្មេងកំព្រា"

ដោយសារអ្នកនិពន្ធ ឡាំង ប៉េងសៀក ឬ កាណែល ជាអ្នកដែលតែងតែប្រឆាំងអំពីរបៀបក្នុងការកាត់ទោសរបស់ពួករាជានិយមនិងសាធារណរដ្ឋនិយម ដូច្នេះហើយសបញ្ជាក់ឱ្យឃើញថា លោក ឡាំង ប៉េងសៀក ឬ កាណែល ពុំមែនជាអ្នកនិពន្ធស្រួចស្រាល់ក្នុងការគាំទ្ររបបសាធារណរដ្ឋនិយម ឬក៏រាជានិយមនោះទេ។ តាមរយៈស្នាដៃរបស់លោក យើងឃើញថា លោក ឡាំង ប៉េងសៀក ឬ កាណែលជាអ្នកនិពន្ធមួយរូបដែលចូលចិត្តជ្រើសរើសយកបញ្ហាជាតិមកធ្វើជាកម្មវត្ថុនៅក្នុងនិមិត្តកម្មប្រលោមលោករបស់ខ្លួន តួយ៉ាងដូចជាស្នាដៃមេចោរកំបុតកជាដើម គឺលោកបានលើកយកបញ្ហាប្រវត្តិសាស្ត្រមកប្រឌិតជារឿងមួយឡើងក្នុងគោលបំណងឆ្លុះបញ្ចាំងនូវតថភាពនៃសង្គមខ្មែរពីអតីតកាលដ៏ឈឺចាប់មួយនាអំឡុងសតវត្សរ៍ទី១៨ ខណៈដែលប្រទេសខ្មែរត្រូវបានពុះចែកផែនដីបីចំណែកដាច់ពីគ្នា ជាហេតុនាំឱ្យមានការកើតឡើងនូវបដិវត្តន៍មួយផ្ដួលរំលំរាជបល្ល័ង្ក។ ឯចំណែករឿងទំនួញក្មេងកំព្រាវិញ បានលាតត្រដាងពីទុក្ខវេទនារបស់

---

[៣១] សូមមើលៈ ឡាំង ប៉េងសៀក វីយ៉ូឡុងស្នេហា ការផ្សាយរបស់បណ្ណាគារអមតា ភ្នំពេញ ឆ្នាំ១៩៧២។

[៣២] សូមមើលបញ្ជីរាយស្នាដៃរបស់អ្នកនិពន្ធ កាណែលឬឡាំង ប៉េងសៀក នៅក្នុងឧបសម្ព័ន្ធ។

ប្រជាជន ក្នុងពេលដែលស្រុកទេសមានចម្បាំងរាំងជល់និងបង្ហាញពីភាពខិលខូចរបស់ពួកមន្ត្រីកាន់ការធំៗក្នុងប្រទេសដែលកេងប្រវ័ញ្ចថវិកាជាតិយកទៅធ្វើមានធ្វើបានបុគ្គលនិងក្រុមគ្រួសារខ្លួនឯង ហើយប្រព្រឹត្តអំពើពាលា ឥតសីលធម៌ ឥតក្រែងរអែងនឹងច្បាប់ទម្លាប់ និង មានចរិតអនាថា ប៉ោទ្បៃ ឥតព្រំដែន តែទីបំផុតត្រូវបាបកម្មតាមផ្ដន្ទាឱ្យគ្រួសារនោះស្លាប់បាត់បង់ជីវិតយ៉ាងវេទនាម្ដងម្នាក់ៗរហូតស្ទើរផុតពូជ។ ការលើកយកមកបង្ហាញបែបនេះ គឺក្នុងគោលបំណងលាតត្រដាងពីទស្សនវិស័យរបស់អ្នកនិពន្ធ ឡាំង ប៉េងសៀក ឬ កាណៃល ចំពោះនយោបាយនិងការគ្រប់គ្រងប្រទេសក្រោយពីបដិវត្តរំលំរបបរាជានិយមពីសំណាក់អ្នកសាធារណរដ្ឋនិយម ដើម្បីឱ្យពួកគេយកទៅធ្វើជាគតិនៅក្នុងការត្រិះរិះពិចារណា ដើម្បីយឹតយោងប្រទេសឱ្យចេញផុតពីគ្រោះអាសន្ន រៀបចំប្រទេសនិងគ្រប់គ្រងរបបមួយឱ្យបានល្អប្រសើរ។

**ក- សង្ខេបរឿង**

សូភី ជាជនភៀសសឹកមួយរូបដូចជនភៀសសឹកដទៃទៀតដែរ។ នាងបានចាកចោលផ្ទះសម្បែង ស្រុកកំណើតមករសាត់តែលតោលនៅទីក្រុង។ សព្វថ្ងៃ នាងធ្វើជាស្រីពេ-ស្យាលាក់មុខ ដើម្បីរកកម្រៃចិញ្ចឹមប្អូនៗទាំងពីររបស់នាងដែលបានរត់រសាត់អណ្ដែតមកជាមួយនាងនិងជូនចាស់ម្នាក់ឈ្មោះ យាយឡុង។ នាងមានសង្សារម្នាក់ឈ្មោះ ភូរិន។ ថ្ងៃមួយ ភូរិន បានមកបបួលនាងឱ្យទៅជួបនឹងម្ដាយមីងរបស់គេនៅឯវត្តនិរោធ តែការពិតគឺគេបោកនាងយកមកលក់នៅផ្ទះបនស្រីពេស្យាទៅវិញសោះ។ នាងត្រូវមេបនឃុំឃាំងជាប់នៅក្នុងផ្ទះបនឯវត្តនិរោធនោះ ហើយបង្ខំឱ្យទទួលភ្ញៀវចោលប្អូនទាំងពីរនៅផ្ទះឥតដំណឹង។

ថ្ងៃមួយ មេបនបាននាំនាងមកឱ្យភ្ញៀវម្នាក់ដល់ភូមិគ្រឹះរបស់គេមួយស្ថិតនៅទួលគោក។ ភ្ញៀវនេះធ្លាប់បានយកនាងមកសប្បាយម្ដងជាពីរមកហើយ។ លើកនេះ ពេលសប្បាយអស់ចិត្តអស់ចង់ហើយ ដោយគេហាក់ដូចជាចូលចិត្តនឹងចរិតនាងផង ភ្ញៀវចំណាស់នេះក៏បានដកកាបូបលុយហូតយកប្រាក់មួយរយរៀលឱ្យទៅនាងជារង្វាន់។ ពេលនោះស្រាប់តែនាងក្រឡេកឃើញរូបថតម្ដាយនិងឪពុកបង្កើតរបស់នាងនៅជាប់ក្នុងការបូបរបស់ភ្ញៀវម្នាក់នេះ ហើយនាងក៏បានសួរនាំរកការពិត។ កាលបើបានដឹងថានាង សូភី នេះ គឺជាកូនស្រីបង្កើតរបស់ខ្លួនហើយ ភ្ញៀវចំណាស់នេះមានក្ដីតក់ស្លុតនិងរន្ធត់ចិត្តជាខ្លាំង។ លោកខំទប់អារម្មណ៍ ហើយប្រាប់នាងដោយកុហកថា ម្ចាស់រូបថតទាំងពីរនេះជាមិត្តភ័ក្ត្រជិតស្និទ្ធរបស់ខ្លួនទៅវិញ។ លោកបានសួរពីដំណើរដើមទងដែលនាំឱ្យនាងធ្លាក់ខ្លួនមកដល់ទីនេះ ហើយនាងក៏បានរ៉ាយរ៉ាប់អំពីដំណើររឿងរ៉ាវរបស់នាងឱ្យបុរសចំណាស់នេះស្ដាប់តាំងពីដើមរហូតដល់ចប់។

ឧត្តមមន្ត្រីប្រសើរ ដែលជាភ្ញៀវនិងជាឪពុកបង្កើតរបស់នាងនេះ មានសេចក្ដីខ្មាសអៀននឹងកំហុសឆ្គងដែលបានប្រព្រឹត្តចំពោះកូនស្រីបង្កើតរបស់ខ្លួនបែបនេះ។ លោកបានលោះនាងពីមេបន ហើយយកនាងទៅឱ្យស្នាក់នៅបណ្ដោះអាសន្នជាមួយនឹងប្អូនស្រីលោកម្នាក់នៅឯបឹងត្របែក ដោយលាក់ការពិតពុំឱ្យនាងដឹងនិងបង្គាប់នាងឱ្យហៅលោកថាមាៗ។ លោកបានធានានឹងនាងថាស្វែងរកប្អូនទាំងពីររបស់នាងនោះឱ្យទាល់តែឃើញ។ ថ្ងៃមួយលោកបាននាំនាងទៅហាងថតរូបមួយដើម្បីផ្ដិតរូបប្អូនៗរបស់នាង។ នៅទីនោះនាងបានឃើញរូបភូរិន (អ្នកដែលបោកយកនាងទៅលក់ឯផ្ទះបន) និងភូរី (អ្នកដែលបានចាប់នាងរំលោភនិងបំផ្លាញភាពបរិសុទ្ធរបស់នាងនៅឯពោធិ៍ចិនតុងនោះ) ហើយនាងក៏បានប្រាប់លោក ប្រសើរ អំពីរឿងរ៉ាវទាំងអស់ដែលជនទាំងពីរនេះបានប្រព្រឹត្តចំពោះនាង។ ដំណឹងនេះរឹតតែធ្វើឱ្យលោកប្រសើរក្ដុកក្ដួលទ្វេថែមទៀត ព្រោះមនុស្សទាំងពីរនាក់នេះជាកូនប្រុសរបស់លោក ដែលត្រូវជាបងបង្កើតរបស់នាង តែម្ដង។ លោកបានហៅ ភូរិន មកប្រាប់ឱ្យដឹងការពិតនេះ ហើយចែករំលែកនូវសម្បត្តិទ្រព្យដ៏មហាសាលរបស់លោក មួយចំនួនធំ ព្រមទាំងបានកាត់ឈ្មោះផ្ទះ និង ដីជាច្រើនកន្លែងឱ្យទៅនាង រួចឱ្យនាងរំដួលជាប្អូនស្រីទៅជួយមើលថែទាំនាងសូភីទៀតផង។ ដោយចូលចិត្តចរិតឫកពានាងនិងអំពើកុសលដែលសូភីជាក្មួយបានសាងនោះ មីងរំដួលក៏បានប្រគល់ភូមិគ្រឹះរបស់ខ្លួនមួយនៅចោមចៅឱ្យសូភី ហើយសូភីក៏បានយកភូមិគ្រឹះនោះទៅធ្វើជាទីជម្រកដល់ជនភៀសសឹកទៅ។

នាង សូភី បានយកចំណែកទ្រព្យសម្បត្តិដែលលោកប្រសើរឱ្យនាងទៅទិញរបស់របរផ្សេងៗ ដើម្បីចែកដល់ជនភៀសសឹកទាំងឡាយដែលបានគេចខ្លួនពីចម្បាំង មករស់បណ្ដោះអាសន្ននៅតំបន់ជាយទីក្រុងនេះ។ លោកប្រសើរនិងលោកស្រីរំដួលពេញចិត្តនឹងទង្វើរបស់ សូភី ជាខ្លាំង។

ថ្ងៃមួយ លោក ប្រសើរ បានទទួលដំណឹងថា ភូរិន កូនប្រុសរបស់លោកនោះ ត្រូវគេបាញ់ស្លាប់ ដោយសារគំនុំរឿងបោកយកប្អូនស្រីគេទៅលក់ឱ្យធ្វើជាស្រីពេស្យា ហើយលោក ប្រសើរ បានលាក់ដំណឹងនេះជិតមិនឱ្យ សូភី ដឹងឡើយ។

ថ្ងៃក្រោយមកនៅពេលដែល សូភី កំពុងតែចែកអំណោយឱ្យជនភៀសសឹកនៅពងទឹកនោះ នាងក៏បានជួបនឹងប្អូនៗទាំងពីររបស់ខ្លួន គឺ រ៉ាយ និង ពៅ ដែលបានបែកគ្នាមួយរយៈមកនោះ ហើយនាំពួកគេមកនៅជាមួយនាង ដោយទាំងលោកយាយម្នាក់ដែលព្រាត់កូនចៅ ហើយរើសយកក្មេងទាំងពីរនេះមកចិញ្ចឹមក្នុងកំលុងពេលដែលពួកគេបានបែកពីនាងនោះមកជាមួយទៀតផង។ សូភីបានយកផ្ទះមួយដែលលោក ប្រសើរ ឱ្យទៅនាងនៅចោមចៅនោះ ធ្វើជាជំរំឱ្យជនភៀសសឹកទាំងនោះ និង យកដីមួយកន្លែងទៀត ធ្វើសាលារៀនដើម្បីឱ្យកូនចៅពួកគេបានរៀនសូត្រទៀតផង។

ពេលវេលាកន្លងទៅមួយរយៈ ស្រាប់តែ ភូរី កូនប្រុសរបស់លោក ប្រសើរ ដែលទៅរៀនឯស្រុកបារាំងនោះត្រូវគ្រោះថ្នាក់ចរាចរណ៍ស្លាប់ទៅទៀត លោក ប្រសើរ បានទៅធ្វើបុណ្យឱ្យកូនដល់ស្រុកបារាំង ហើយលោកក៏បានលាក់ដំណឹងនោះមិនឱ្យនាង សូភី ដឹងដដែល។ លុះត្រឡប់មកវិញ ខ្លួនលោកផ្ទាល់ក៏ស្រាប់តែកើតជំងឺហើមភ្នែកមើលមិនជា ជំងឺលោកធ្វើទុក្ខកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយប៉ុន្មានថ្ងៃក្រោយមកស្រាប់ភ្នែកមួយចំហៀងរបស់លោក ត្រូវខ្វាក់ បន្ទាប់មកក៏ស្រាប់កើតជំងឺសរសៃទាញមួយចំហៀងខ្លួនដើរលែងរួចទៀត។ នាង សូភី បានស្វះស្វែងរកពេទ្យចំណានៗមកព្យាបាលជំងឺឱ្យលោក ប្រសើរ គ្រប់ច្រកល្ហកតែគ្មានប្រសិទ្ធភាពឡើយ។ ថ្ងៃមួយ នាងក៏បានដំណឹងពីស្រុក មកថាម្តាយនាងនៅរស់ តែឪពុកចុងនាងត្រូវស្លាប់ដោយគ្រាប់កាំភ្លើងក្នុងពេលដែលលោកប្រយុទ្ធជាមួយក្រុមពាល មុនពេលនាងចាកចេញមកនោះ។ នាងបានចាត់គេឱ្យទៅយកម្តាយនាងមកនៅភ្នំពេញ ហើយនាំដំណឹងនេះទៅប្រាប់លោកប្រសើរៗមានចិត្តត្រេកអរជាខ្លាំងចំពោះដំណឹងនេះ តែដោយអាការៈរោគរបស់លោកកាន់តែធ្វើទុក្ខខ្លាំងឡើងៗពេលនោះ ជីវិតលោកក៏បានរលត់ក្នុងពេលនោះទៅដោយបាននាំយកទៅនូវរឿងដ៏អាថ៌កំបាំងដែលមិនអាចបកស្រាយបង្ហាញ ការពិតនោះទៅជាមួយផង[៣៣]។

**ខ- តថភាពតាមរយៈស្នាដៃ "ទំនួញក្មេងកំព្រា"**

រឿងទំនួញក្មេងកំព្រា គឺជាប្រលោមលោកមួយដែលអ្នកនិពន្ធបានលើកយកកម្មវត្ថុស្តីពីដំណើរជីវិតនៃនារីម្នាក់ដែលទើបនឹងធំពេញវ័យ ហើយត្រូវព្យុះកំណាចបក់បោកញាំញីឱ្យងងឹតសូន្យសុង រស្មីអាប់អួរ អស់ក្តីសង្ឃឹម តែដោយព្រហ្មលិខិតនៅមានក្តីអាណិតអាសូរដល់រូបនាង ទីបំផុតក៏បានជួយលើកស្ទួយវាសនានាងឱ្យងើបផុតពីភក់ជ្រាំនិងពិភពដ៏ខ្មៅងងឹតសូន្យសុងឱ្យមានពន្លឺភ្លឺរុងរោចន៍ឡើងវិញនោះ មកធ្វើជានិមិត្តកម្មស្នាដៃនៃប្រលោមលោកនេះ។ ក្រៅពីនេះ ដំណើររឿងក៏បានពណ៌នាផងដែរអំពីទុក្ខវេទនារបស់ប្រជាជនខ្មែរដែលរស់នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ហើយបានរត់ភៀសខ្លួនចេញពីសង្គ្រាមនៅទីនោះ មកជ្រកកោនដើម្បីរក្សាអាយុជីវិតនៅទីក្រុង ពីដំណើរជីវិតនៃក្រុមគ្រួសារនាង សូភី ជាពិសេស ពីដំណើរជីវិតរបស់នាងផ្ទាល់ដែលត្រូវទទួលរងគ្រោះពីព្យុះព្យោមារនៃវិបត្តិសង្គមនិងសង្គ្រាមតាំងពីគ្រាដែលនាងរស់នៅស្រុកកំណើត ជាមួយក្រុមគ្រួសាររបស់ខ្លួនរហូតដល់ពេលភៀសខ្លួនមកជ្រកកោននៅភ្នំពេញ ដើម្បីរក្សាអាយុជីវិតដែលនៅសេសសល់ តែទីបំផុត ទីក្រុងដែលនាងបាននិរទេសខ្លួនមក ដើម្បីយកជីវិតមកធ្វើប្រាថ្នាសុំសេចក្តីសុខមួយគ្រានោះ ក៏បានជាន់រស្មីនៃជីវិតនាងពន្លិចទៅក្នុងស្បៃអន្ធការទៅវិញ។

ដូច្នេះ តាមរយៈដំណើររឿង ទំនួញក្មេងកំព្រានេះ អ្នកនិពន្ធបានបង្ហាញឱ្យឃើញនូវចំណុចតថភាពបី គឺ តថ-ភាពសកម្មភាព, តថភាពទីកន្លែងនិងតថភាពតួអង្គ ប៉ុន្តែតថភាពសំខាន់ដែលនឹងត្រូវលើកមកបកស្រាយបង្ហាញនោះ គឺ តថភាពសកម្មភាពនិងតថភាពតួអង្គ។

- **តថភាពសកម្មភាព**

បើសម្លឹងមើលទៅលើព្រឹត្តិការណ៍ពិតជាក់ស្តែង គឺថា នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៣ រដ្ឋាភិបាលសហរដ្ឋ-អាម៉េរិកនិងវៀតណាមខាងជើង បានចុះហត្ថលេខាព្រមព្រៀងនៅ ឡា សែលគ្លូ (La Cells St Cloud) បញ្ចប់សង្គ្រាមវៀត-ណាម តែកងទ័ពអាម៉េរិកខ្លាចប្រទេសកម្ពុជាធ្លាក់ក្នុងរបប

[៣៣] សូមមើលៈ កាណែល ទំនួញក្មេងកំព្រា ភ្នំពេញ ការផ្សាយរបស់សារ-ព័ត៌មានអរិយធម៌ ឆ្នាំ១៩៧៣។

កុម្មុយនីស្តនិងទៅជាជម្រកសម្រាប់កងទ័ពវៀតណាម។ ហេតុនេះហើយចាប់ពីថ្ងៃទី៦ កុម្ភៈ ដល់វេលាពាក់កណ្តាលអាធ្រាត្រ ១៥ សីហា ឆ្នាំ១៩៧៣ កងអាកាសបេ៥២ របស់អាម៉េរិកបានទម្លាក់គ្រាប់បែកចំនួន២៥ ៧.០០០តោន លើតំបន់ស្រែចម្ការក្នុងប្រទេសកម្ពុជា ធ្វើឱ្យប្រទេសនេះក្លាយជារណ្តៅគ្រាប់បែក (Carpet Bombing) តែម្តង។ ប្រជាជនរស់នៅភូមិស្រុកជនបទមិនកើត ក៏តាមគ្នា ពពាក់ពពូនមករស់នៅក្នុងក្រុងភ្នំពេញ និង ទីរួមខេត្តបាត់ដំបង។ ក្នុងកំលុងសង្គ្រាម ៥ ឆ្នាំនេះ ទីក្រុងភ្នំពេញដូចជា បន្ទាយមួយដ៏ធំ ដែលខ្មាំងឡោមព័ទ្ធជាប់។ ប្រជាជនក្នុងប្រទេសចំនួនមួយភាគបីភៀសខ្លួនមករស់នៅទីក្រុង ជាហេតុធ្វើឱ្យទីក្រុងមានប្រជាជនច្រើនហួសប្រមាណ។ ប្រជាជនរងទុក្ខលំបាកវេទនា និង កម្សត់ទុគ៌តពេកក្រៃ។ អ្នកស្រែចម្ការ ដែលឃ្លាតចាកពីស្រុកភូមិតែងគ្រាំចច្រប់ដោយគ្មានការងារធ្វើ គ្រួសារបែកបាក់ព្រាត់ប្រាស់អស់។ មានស្ត្រីមេម៉ាយនិងក្មេងកំព្រារាប់ម៉ឺននាក់ អ្នកជំងឺ មនុស្សត្រូវរបួស ឬ កំបុតដៃជើងរាប់ពុំអស់ មានមនុស្សកើតឃ្លង់ចំនួនជាងមួយពាន់នាក់។ល។ កាលពីដើម គេចាត់ទុកក្រុងភ្នំពេញជាឋានសួគ៌ នៅចុងបូព៌ាប្រទេស នៅក្នុងពេលសង្គ្រាម ទីក្រុងនេះបានក្លាយទៅជាទីប្រជុំនៃជនក្រីក្រដ៏ធំមួយ ដែលមានប្រជាជនរស់នៅប្រមាណជាជាងពីរលាននាក់។ ពួកគេតាំងទីលំនៅគ្រប់កន្លែងឱ្យតែគេអាចនៅកើតពេលគឺ នៅជាមួយញាតិមិត្ត នៅតាមវត្ត នៅលើចិញ្ចើមថ្នល់ នៅក្នុងជំរំ និង នៅក្នុងភូមិដែលពួកគេបានកសាងឡើងភ្លាមៗជុំវិញក្រុង។ ជនក្រីក្រទាំងនោះព្រួយបារម្ភ និង តានតឹងក្នុងចិត្តជាប្រចាំ ព្រោះគ្រាប់រ៉ុក្កែត ឬ គ្រាប់កាំភ្លើងធំ ដែលបានផ្លោងយ៉ាងច្រើនសន្ធឹកសន្ធាប់ចូលភ្នំពេញ បណ្តាលឱ្យស្លាប់ និង ហិនហោចវេទនាជាខ្លាំង។ ឧ. យប់ថ្ងៃទី២០ មេសា ឆ្នាំ១៩៧២ មនុស្សបីរយនាក់នៅទួលគោក ត្រូវទទួលមរណភាពដោយគ្រាប់ផ្លោងចូល។ ក្នុងឆ្នាំ១៩៧៤ សង្កាត់មួយទៀតត្រូវភ្លើងឆេះខ្ទេច ដោយត្រូវគ្រាប់កាំភ្លើងធំខ្មែរក្រហមគឺគ្រាប់ដែលគេបានទិញពីពួកទាហានសាធារណរដ្ឋ។ នៅដើមខែកញ្ញា ឆ្នាំ១៩៧២ កងកុម្មុំង់ដូវៀតកុង មកប្លន់យករថក្រោះនៅផ្សារតូចហើយដាក់គ្រាប់បែកកម្ទេចស្ពានជ្រោយចង្វា។

នៅសម័យនោះសេដ្ឋកិច្ចមិនមានសកម្មភាពអ្វីទាំងអស់ ដូច្នេះ ជនភៀសខ្លួនពិបាករកស្បៀងអាហារបរិភោគយ៉ាងខ្លាំង។ រដ្ឋការពុករលួយស៊ីសំណូកនិងធ្វើអ្វីបានតាមចិត្តដូចសុភាសិតថា "អ្នកធំស៊ីធំ អ្នកតូចស៊ីតូច"។ ប្រាក់រៀលចេះតែចុះថ្លៃ រីឯតម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត។ ប្រជាជនរស់រានមានជីវិតទៅបានដោយសារតែស្បៀង ដែលរដ្ឋាភិបាលសហរដ្ឋអាម៉េរិកផ្តល់មកឱ្យតែប៉ុណ្ណោះ។ ជំនួយស្បៀងទាំងនោះដឹកមកតាមកងនាវាដែលឡើងតាមទន្លេមេគង្គ។ ជាញឹកញាប់ខ្មែរក្រហមវាយបិទផ្លូវទន្លេនេះ រួចកងទ័ពសាធារណរដ្ឋខ្មែរត្រូវវាយបកវិញ។

ចាប់តាំងពីខែមករា ឆ្នាំ១៩៧៥មក ការដឹកនាំតាមទន្លេនេះត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងស្រុង។ នៅសល់តែផ្លូវអាកាសពីក្រុងបាងកកប៉ុណ្ណោះសម្រាប់នាំអង្ករមកចិញ្ចឹមមនុស្សជាច្រើនលាននាក់នៅភ្នំពេញ..."[៣៤]។

បើយើងមើលទៅលើដំណើររឿងឯណោះវិញ ឃើញអ្នកនិពន្ធបានពណ៌នាថា ...សង្គ្រាមឆេះរោលរាល... អ្នកស្រុកភៀសខ្លួនរត់គ្រប់ៗគ្នាគ្មានទីដៅ។ ភាពអ៊ូអរក្នុងភូមិនីមួយៗដែលមានពីមុនមកក៏បាត់បង់អស់ ហើយនៅសល់តែភាពស្ងប់ស្ងាត់ រហោស្ថានគួរឱ្យស្រងេះស្រងោច។ ដើមស្វាយដើមចេក ល្ហុង ល្មុត ខ្នុរ ឈរចាំភូមិរហង់។ ម្ចាស់គ្រៀមរត់គេចខ្លួនដោយខ្លាចសង្គ្រាម គេមិនអាចទ្រាំរស់នៅបានទេ ព្រោះគេជាម្ចាស់អំណាច តែគេគ្មានអាវុធការពារ។ ពេលថ្ងៃលិចទឹកមុខគេជាម្ចាស់អំណាចដែលគ្មានអាវុធក៏លិចចុះជាមួយថ្ងៃសល់តែដើមទ្រូងដែលតឹងចិត្តដែលខ្វល់។ គ្រប់គ្នារត់ទាំងអស់គ្នា។ គ្រួសារដែលមានឋានៈគ្រាន់បើ គេនៅមានបាយកន្ទកប្រហុក ត្រីងៀត អំបិលស្ពាយតាមជាប់ជានិច្ច។ រីឯអ្នកក្រគ្មានវត្ថុទាំងនេះ កាលបើរត់ដល់ទីណាហើយ គេនាំគ្នាជីករាវរកដំឡូង មើមឈើ ឬ ឡើងបេះផ្លែឈើស៊ីសម្រន់ការស្រេកឃ្លាន។ គេភៀសខ្លួនដោយសារសង្គ្រាម ប្តីពរកូន ម្តាយទូលកញ្ជើទូលល្អីទីណាត់ទីណែង ទឹកភ្នែកហូរសស្រាក់បណ្តើរ។ សង្គ្រាមធ្វើឱ្យហិនហោចអស់ទ្រព្យធន។ គេលាស្រែចម្ការលាជង្រុកស្រូវតូច លាគោក្របី មាន់ទា ដំណាំដំណោចផ្សេងៗ។ អ្នកចម្ការលាហើយចម្ការឪឡឹក ចម្ការត្រសក់ ពោត ដំឡូងសណ្តែក ថ្នាំ ទុរេន សាវម៉ាវ។ ពេលសង្គ្រាមជាពេលដែលគេព្រាត់ប្រាស់និរាសគ្នា ពេលដែលសង្សារបែកគូ ឪពុកបែកកូនជីដូនបែកចៅ។ ផ្ទះថ្មីគឺក្រោមដើមឈើធំៗឬក្រោមរទេះ

[៣៤] សូមមើល ចំណុចស្តីពីព្រឹត្តិការណ៍សង្គម នេះបន្ថែមនៅក្នុងជំពូកទី១ ត្រង់ចំណុចព្រឹត្តិការណ៍ទូទៅសង្គមពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ទំព័រ៩១ ដល់១០១។

ដែលបិទបាំងបន្តិចបន្តួចការពារកម្តៅថ្ងៃ។ ពិសេស ពេលសង្គ្រាមជាពេលអត់បាយមនុស្សស្គមស្លេកស្លាំង ក្មេងយំ ងើកងាកដោយការឃ្លានចំណី ម្តាយធ្វើពលិកម្មអស្វារូតស៊ូនឹងការឃ្លានដើម្បីបំពេញក្រពះកូន។ ពេលសង្គ្រាមជាពេលមានជំងឺ ពេលដែលមនុស្សឈឺថ្ងូរស្លាប់ដូចសត្វជាតុ គ្មាននរណាអាចជួយនរណាបាន។ ពេលសង្គ្រាមជាពេលដែលចិត្តមនុស្សឡើងសាហាវដូចសត្វ គិតតែពីលួចប្លន់ កាប់សម្លាប់គំរាមកំហែងគ្នា ដើម្បីតែប្រយោជន៍អាត្មាខ្លួនសួនតួ[៣៥]។

ដូច្នេះ តាមរយៈការពិពណ៌នារបស់អ្នកនិពន្ធបែបនេះបង្ហាញថា សកម្មភាពនៅក្នុងផ្ទៃរឿងដែលមនុស្សម្នាមានការភ័យខ្លាច ហើយគ្រាប់កាំភ្លើងបានបំផ្លាញជីវិតមនុស្ស ជាដើមនោះ គឺជាតថភាពមួយដែលឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ជាក់ស្តែងនៅក្នុងសង្គមនាសម័យនោះយ៉ាងពិតប្រាកដ។

**-តថភាពតួអង្គ**

នៅក្នុងសាច់រឿង អ្នកនិពន្ធបានបង្កើតឡើងតួអង្គជាច្រើនដែលតួអង្គនីមួយៗមានបែបផែនខុសគ្នា ប៉ុន្តែគឺសុទ្ធតែជាតួអង្គដែលតំណាងឱ្យមនុស្សពិតៗនៅក្នុងសង្គម នាសម័យនោះ ដូចជា តួអង្គនាង សូភី ជាស្ត្រីក្រមុំជនបទមួយរូបមានក្រុមគ្រួសាររស់នៅប្រកបដោយភាពកក់ក្តៅដូចគេឯងដែរ ប៉ុន្តែដោយសារតែអស្ថិរភាពសង្គមដែលបង្កឡើងពីវិបត្តិសង្គ្រាមនោះ ក៏បានអូសទាញខ្សែជីវិតរបស់នាងឱ្យសោត់អណ្តែតរសាត់អណ្តែតរសាត់តាយ លិចលង់ផុងជំណើរនៅទីក្រុង រហូតធ្លាក់ខ្លួនទៅជាស្ត្រីពេស្យា និរាសព្រាត់ប្រាស់បងប្អូន ឪពុក-ម្តាយជាដើម នោះគឺជាការឆ្លុះបញ្ចាំងនូវតថភាពសង្គមខ្មែរនាកំលុងទសវត្សរ៍១៩៧០ខណៈដែលប្រទេសជាតិត្រូវប្រឈមមុខនឹងវិបត្តិសង្គ្រាមពាសពេញផ្ទៃប្រទេសនិងអស្ថិរ-ភាពនានារបស់សង្គមដែលបង្កឡើងដោយសារតែសង្គ្រាមនោះ។ ពាក្យពេចន៍ដែលអ្នកនិពន្ធបានពណ៌នានៅក្នុងដំណើររឿងអំពីការរត់លួនរបស់នាង សូភី អំពីការភ័យខ្លាចរបស់អ្នកភូមិស្រុកនៅខេត្តតាកែវជាដើម ដូចដែលថា ... ក្នុងពេលដែលស្រុកទេសកើតចម្បាំង ស្រាប់តែលេចមនុស្សមួយក្រុមបានលុកលុយចូលមកស្រុកភូមិខ្ញុំបង្ខំឱ្យខ្ញុំរៀបការជាមួយមេធំរបស់វានៅពេលបីថ្ងៃទៀត។ អាមេធំពួកខិលខូចនោះ ខ្ញុំបានស្គាល់ច្បាស់ណាស់ ព្រោះកាលពីប៉ុន្មានខែមុន ស្រុកកើតកលិយុគវាបានមកស្នើស្តីដណ្តឹងខ្ញុំម្តងរួចទៅហើយ តែត្រូវលោកឪពុកចុងខ្ញុំនោះទាត់ចោលយ៉ាងដាច់ខាត...។ ... វាបានចងគំនុំនឹងគ្រួសារខ្ញុំ...។ ...ថ្ងៃនោះវាបាននាំបក្សពួកវាចំនួនដប់នាក់មកព័ទ្ធចាប់ខ្ញុំ។ ...ពុកខ្ញុំចេញតយុទ្ធនឹងវាពេញទំហឹង ដោយមានតែកាំបិតដងវែងមួយជាអាវុធ... គ្នាវាស្លាប់អស់នៅសល់តែអាចោរកំហូចនោះដែលត្រូវរបួស ហើយរត់ទៅ... មិនយូរប៉ុន្មាន វានាំបក្សពួកវាមួយចំនួនធំមកទៀតមានកាំភ្លើងបាញ់បង្អើលឆោឡោអស់មួយភូមិ។ ...ពេលនោះកើតចលាចលធំសម្បើមណាស់ អ្នកស្រុកផ្អើលជ្រួលច្របល់ ហើយខ្ញុំក៏ពរប្អូនតូចៗទាំងពីរនោះ រត់ជាមួយអ្នកស្រុក... ខ្ញុំគៀសខ្លួនច្របល់ជាមួយគេជាមួយឯង បីដូចដង្គត់ឈើដែលហូរតាមទឹកពុំដឹងទីដៅនៅឯណា។ គៀសខ្លួនមកដល់ភ្នំពេញទីក្រុងធំ... ខ្ញុំវង្វេងវង្វាន់អស់ ព្រោះតាំងពីតូចមក ខ្ញុំបានស្គាល់ភ្នំពេញតែពីរដងគត់ ហើយគ្មានស្គាល់នរណាម្នាក់សោះនៅទីក្រុង។... ខ្ញុំបានទៅសំពះអង្វរគេម្នាក់នៅពាធិ៍ចិនតុងសូមនៅបម្រើគេ សូមធ្វើការឱ្យគេគ្រប់បែប ដោយសុំតែបាយមួយឆ្អែតនឹងសម្រាប់ប្អូនខ្ញុំទាំងពីរប៉ុណ្ណោះ ... ថ្ងៃទីប្រាំបីនៃការរស់នៅផ្ទះពាធិ៍ចិនតុង វេលាព្រឹក ស្រាប់តែមានប្រុសចម្លែកម្នាក់ចូលទៅដល់បន្ទប់ខ្ញុំគេង ...ខ្ញុំភ័យញ័ររន្ធត់ ព្រោះខ្ញុំមិនដែលបានជួបប្រុសនៅទីស្ងាត់តែពីរនាក់ដូច្នេះទេ។ រីឯម្ចាស់ផ្ទះក៏បាត់ស្ងាត់មិនដឹងជាចេញទៅណាអស់... ពុទ្ធោអើយ! ...ប្រុសនោះនិយាយចែចង់ខ្ញុំគ្មានប្រណីមាត់... ប្រុសព្រហើននេះបានចាប់រំលោភខ្ញុំយ៉ាងព្រៃផ្សៃបំផុត។ ឱ! តើមានអ្វីគួរឱ្យស្រីក្រមុំឈឺចាប់ជាងការឱ្យបាត់បង់ក្តីបរិសុទ្ធ ដោយ-សារតែមានមនុស្សថ្លើមខ្មៅមករំលោភទាំងកំពោល?...ក្រោយមក ទើបខ្ញុំដឹងថា គឺម្ចាស់ផ្ទះនេះហើយដែលស៊ុមគ្រលុំជាមួយមនុស្សខូច... ពេលក្រោយបន្តិចមកទៀតទើបខ្ញុំដឹងច្បាស់ថា ម្ចាស់ផ្ទះនេះ គឺជាមេអណ្តើករកប្រពន្ធចុង រកស្រីញីឱ្យថៅកែ ឬ អ្នកណាដែលមានប្រាក់ឱ្យគាត់។ ...ហួសពេលហើយ ក្តីបរិសុទ្ធក៏បាត់បង់ទៅ ខ្ញុំគេងសញ្ជឹងគិតរកផ្លូវចេញពីស្ថានអពមង្គលនេះ តែទីក្រុងធំយ៉ាងនេះ តើខ្ញុំទៅពឹងអ្នកណា? ...ម្ចាស់ផ្ទះយក្ខិនី ដែលស្គាល់តែប្រាក់ បាននាំប្រុសដទៃទៀតឱ្យមករំលោភលើខ្ញុំផ្ទួនៗ ធ្វើឱ្យខ្ញុំរឹតតែធ្លាក់ជ្រៅទៅក្នុងអន្លង់អវចី។ ... ខ្ញុំគិតថា បើបំណាច់នឹងខកខ្លួនទៅហើយត្រូវតែរៀនរស់ដោយខ្លួនឯងវិញ កុំឱ្យអ្នកណាស៊ីខូងពីលើ។ ខ្ញុំក៏មករស់នៅជាមួយមីងមា ហើយប្រកបមុខរបរជាស្រីពេស្យា

[៣៥] សូមមើល៖ កាណែល ទំនួញក្មេងកំព្រា ដ.ឯ.ម. ទំព័រ១៤៥ ដល់ ១៤៦។

លួចលាក់ ដូច្នេះទៅ...ពេលខ្ញុំប្រកបមុខរបរជាស្រីពេស្យាលួចលាក់ ខ្ញុំបានស្គាល់បុរសម្នាក់នៅក្មេង រូបគេស្អាត សមជាអ្នកមានចំណេះខ្ពង់ខ្ពស់។ គេនិយាយសុំក្ដីស្នេហ៍ពីខ្ញុំៗស្មានថា គេស្មោះស្ម័គ្រនឹងខ្ញុំដោយពិតប្រាកដ ខ្ញុំក៏ប្រថុយផ្ញើប្រាណនឹងគេទៅ ហើយគេបោកប្រាសយកខ្ញុំមកលក់នៅទីនេះ...[៣៦]។

នោះ គឺជាព្រឹត្តិការណ៍ដែលបានកើតមានឡើងជាក់ស្ដែងនៅក្នុងសង្គមខ្មែរ នាកំលុងទសវត្សរ៍ឆ្នាំ១៩៧០នោះតែម្ដង។ តួអង្គនាងសូភី គឺជាតួអង្គមួយដែលអ្នកនិពន្ធប្រឌិតឡើងដើម្បីឆ្លុះបញ្ចាំងចំពោះស្ត្រីក្រមុំជនបទទាំងឡាយដែលពេញរូបឆោមហើយ តែត្រូវមកប្រឈមមុខរស់ក្នុងស្ថានភាពបែបនាង សូភី នេះ នាសម័យនោះ ជានិច្ចកាលគឺរមែងតែជួបប្រទះ នឹងរឿងរ៉ាវដូចដែល សូភី ជួបដោយមិនអាចចៀសផុតបានឡើយ។

ឧត្តមមន្ត្រី ប្រសើរ តាមរយៈសាច់រឿងបានបង្ហាញថា ជាអ្នកមានឋានស័ក្តិ និង មុខមាត់ខ្ពង់ខ្ពស់ អ្នកមានសម្បត្តិទ្រព្យស្ដុកស្ដម្ភក្នុងសង្គមនាសម័យនោះ គឺជាតួអង្គមួយដែលអ្នកនិពន្ធប្រឌិតឡើងតំណាងឱ្យឧត្តមមន្ត្រីនានាក្នុងរបបសាធារណរដ្ឋខ្មែរដែលពួកគេបានរស់នៅសប្បាយហ៊ឺហា ក្នុងខណៈដែលប្រជាជនប្រមាណជាជាងពាក់កណ្ដាលប្រទេសត្រូវរស់នៅប្រឈមនឹងភាពភ័យខ្លាច ខ្វះទីជម្រកសម្រាប់ស្នាក់អាស្រ័យ និង សេចក្ដីអត់ឃ្លានជាដើម ហើយភូរិន្ទនិងភូរី ជាកូនប្រុសលោកឧត្តមមន្ត្រី ប្រសើរ ដែលអាងទ្រព្យសម្បត្តិនិងអំណាចរបស់ឪពុក បានដើរបង្កអំពើពាលាអាវ៉ាសែ ដែលសង្គមមនុស្សសែនមហាស្អប់ខ្ពើមដូចជា ចាប់រំលោភសេពសន្ថវៈស្ត្រីភេទ បោកប្រាស់ស្ត្រីភេទយកទៅលក់ឱ្យធ្វើជាស្ត្រីពេស្យាជាដើមនោះ គឺជាតួអង្គតំណាងឱ្យកូនៗរបស់មន្ត្រីធំៗនៅក្នុងរបបសាធារណរដ្ឋខ្មែរនាសម័យនោះដែលពួកគេរមែងតែងអាងអំណាចបុណ្យស័ក្តិ និង ទ្រព្យ-សម្បត្តិរបស់ឪពុកម្ដាយ ហើយចូលចិត្តប្រព្រឹត្តអំពើថោក-ទាបបែបនេះគ្រប់ទីកន្លែង ហើយដែលសកម្មភាពរបៀបនេះក៏មានលើកឡើងមកបង្ហាញឱ្យឃើញផងដែរតាមរយៈតួអង្គភិរម្យ ជានាយទាហានមួយរូបនៃរបបសាធារណរដ្ឋខ្មែរ ក្នុងរឿងពលទោអភ័ព្វរបស់អ្នកនិពន្ធ គង្គ ប៊ុនឈឿន ដែលនិពន្ធឡើងក្នុងឆ្នាំស្របាលគ្នានឹងរឿងទំនួញក្មេងកំព្រារបស់អ្នកនិពន្ធ កាណែល ឬ ឡាំងប៉េងសៀក នេះដែរនោះ។

ដូច្នេះ តាមរយៈតួអង្គនេះ គឺជាការឆ្លុះបញ្ចាំងនូវថេតភាពមួយនៃសង្គមក្នុងរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោក លន់ នល់ នោះថា មនុស្សរស់នៅក្នុងសង្គមនាសម័យនោះមានគម្លាតគ្នាយ៉ាងខ្លាំងពីរវាងអ្នកមានអំណាចបុណ្យស័ក្តិនិងប្រជាជនសាមញ្ញ។ មន្ត្រីធំដុំនិងក្រុមគ្រួសាររបស់គេអាចរកប្រាក់បានយ៉ាងច្រើន ហើយរស់នៅក្នុងប្រណីតភាពហ៊ឺហាចង់ធ្វើអ្វីបានតាមចិត្ត ឯប្រជាជនតូចទាបរស់នៅប្រៀបដូចជាសត្វធាតុ ឬ ដូចជាទាសករនាសម័យទាសភាពដូច្នេះដែរ ហេតុនេះហើយទើបបានជាក្រោយផ្ដួលរំលំរបបសាធារណរដ្ឋខ្មែរឱ្យដួលរលំទៅ ពួកខ្មែរក្រហមបានកាប់សម្លាប់មនុស្សអស់ជាច្រើននាក់ដោយពុំចាំបាច់មានកំហុសអ្វីធំដុំប៉ុន្មានឡើយ ដែលនេះគឺជាលទ្ធផលបង្កឡើងពីសេចក្ដីគុំកួនរបស់ពួកគេ ចំពោះជនស្រទាប់ថ្នាក់លើនៃសង្គមសាធារណរដ្ឋនោះឯងតែម្ដង។

**គ- លក្ខណៈជាតិនិយមតាមរយៈស្នាដៃ "ទំនួញក្មេងកំព្រា"**

ក្រៅពីការឆ្លុះបញ្ចាំងតថភាពក្នុងសង្គមខ្មែរ នៅកំលុងទសវត្សរ៍ឆ្នាំ១៩៧០នោះ រឿងទំនួញក្មេងកំព្រា ក៏បានបង្កប់នូវលក្ខណៈជាតិនិយមរបស់អ្នកនិពន្ធយ៉ាងខ្លាំងក្លានៅក្នុងនោះថែមទៀតផង ដែលលក្ខណៈជាតិនិយមនោះ បានបង្ហាញឱ្យយើងឃើញតាមរយៈសកម្មភាពរបស់តួអង្គនាងសូភីត្រង់កន្លែងដែលនាងពោលថា ...អូយ! ឯងសម្លាប់អញមក តែមុននឹងអញស្លាប់ទៅ អញសូមប្រាប់ឯងឱ្យភ្លឺភ្នែកទៅចុះថា ស្រុកទេសកើតចម្បាំងគេត្រូវការប្រជាពលរដ្ឋដែលមានសុខភាពមាំទាំដូចឯងអ៊ីចឹង។ ឯងមិនខ្មាសគេទេឬអីដែលឯងយករបស់ដែលជាតិត្រូវការជាចាំបាច់នោះសម្រាប់តែគំរាមកំហែងស្រីខ្មែរទៅវិញនោះ?..[៣៧] ឬ ត្រង់កន្លែងដែលថា ... លោកពូឃើញស្រាប់ អ្នកភៀសខ្លួនទាំងអស់វេទនាណាស់ រីឯក្មេងៗកូនអ្នកភៀសខ្លួនទាំងអស់ក៏ហាក់ដូចជាប៉ោឡៃ គ្មានបានរៀនសូត្រអ្វីសោះ។ ក្នុងស្ថានភាពបែបនេះថ្ងៃក្រោយទៅក្មេងៗទាំងនោះ ក្លាយទៅជាក្មេងល្ងង់មិនចេះអ្វីសោះ លោកពូមិនអាណោចអាធម្មចំពោះក្មេងទាំងនោះទេឬ?...លោកពូគិតមើល! ក្មេងៗទាំងនោះសុទ្ធតែក្មេងនៃជនជាតិខ្មែរ គ្មាឥតបានរៀនសូត្រអ្វីទេ មុខជាល្ងង់ប៉ោឡៃ រហូតធំពេញរូបរាងរៀងៗខ្លួន។ បើកូនខ្មែរមួយភាគធំខ្វះសាលា

[៣៦] សូមមើលៈ កាណែល ទំនួញក្មេងកំព្រា ដ.ឯ.ម. ទំព័រ ៦៥ដល់៧៤។

[៣៧] សូមមើលៈ កាណែល ទំនួញក្មេងកំព្រា ដ.ឯ.ម. ទំព័រ៤៣។

រៀន ជួបគ្រោះគ្រប់ពេលយ៉ាងនេះ តើដប់ម្ភៃឆ្នាំទៅមុខទៀត អនាគតវាសនាស្រុកទេសយើងនឹងក្លាយជាអ្វី? លោកពូ អើយ! ខ្ញុំអាណោចអាធម្មណាស់ ក្មួយមុខជាទៅអំពាវនាវរក យុវជនស្ម័គ្រចិត្តឱ្យទៅបង្រៀនកូនជនកៀសខ្លួនដោយក្មួយ សុខចិត្តចេញកម្រៃឱ្យឬពុំដូច្នោះទេ ក្មួយនឹងទៅសុំក្រសួង ខាងលើឱ្យមានគ្រូទៅបង្រៀនដល់បុត្រធីតានៃជនកៀស ខ្លួនផង..[៣៨] និងត្រង់កន្លែងដែលថា...នាងតែងលើកដៃបួង សួងសុំឱ្យកុសលធម៌ដែលនាងបានសាងទាំងប៉ុន្មាន មកនោះ ជួយឱ្យជនជាតិខ្មែរនៅតែរស់ជួយឱ្យប្រពៃណី អរិយធម៌ វប្បធម៌ ទំនៀមទម្លាប់ខ្មែរនៅតែគង់វង្ស ជួយក្មេងកំព្រាទាំង ឡាយរកឃើញផ្លូវដើរមួយនៅក្នុងពេលអនាគត ដើម្បីសាង ជីវភាពរស់នៅឱ្យសមស្របទៅតាមតម្លៃនៃប្រជាជន ដែលធ្លាប់ មានប្រវត្តិសាស្ត្ររុងរឿង[៣៩]។ តាមរយៈចំណុចទាំងប៉ុន្មានខាង លើនេះសបញ្ជាក់ឱ្យឃើញថា អ្នកនិពន្ធ ឡាំង ប៉េងសៀក ហៅ កាណែល មានឧត្តមគតិចង់ជួយជាតិ តាមរយៈការ ជួយបំផុសអ្នកអានឱ្យយកចិត្តទុកដាក់ ជួយយឹតយោងគ្នាលើ ចំណុចមួយចំនួនដូចដែលលោកបានអត្ថាធិប្បាយខាងលើ ក្នុងស្ថានភាពដែលប្រទេសជាតិកំពុងជួបប្រទះនឹងគ្រោះ សង្គ្រាមតាមដែលអាចធ្វើទៅបាន ដើម្បីបន្តនិរន្តរភាពមនុស្ស ពីមួយជំនាន់ទៅមួយជំនាន់កុំឱ្យជួបគ្រោះអាក្រក់រហូតដល់ បាត់បង់អត្តសញ្ញាណជនជាតិខ្មែរទៅនោះ។ ការបង្ហាញសកម្មភាពរបស់នាង សូភី នារីមួយរូបដែលរងគ្រោះពីវិបត្តិសង្គម តែមានវាសនាអាចងើបឈរឡើងវិញបាន ហើយសាងកុសលធម៌ចំពោះមនុស្សទូទៅដែលមានស្ថានភាពដូចនាងដែរនោះ គឺជាការចង់បង្ហាញផ្លូវរបស់និពន្ធទៅដល់មនុស្សទូទៅនៅក្នុង សង្គមដែលមានលទ្ធភាព ឱ្យមានចិត្តអាណិតមេត្តាចំពោះ មនុស្សនានា ដែលកំពុងរងគ្រោះដោយសារសង្គ្រាម ហើយ ត្រូវការការជួយយកអាសាមួយគ្រាពីអ្នកដែលមានឈាមជ័រ ដូចគ្នា ហើយមានលទ្ធភាពអាចជួយគ្នាបាន។ ម្យ៉ាងទៀត តាមរយៈការភ្ញាក់ខ្លួនដឹងកំហុសនិងការចង់កែខ្លួនឡើងរបស់ ឧត្តមមន្ត្រី ប្រសើរ ឪពុក សូភី ជាអតីតមន្ត្រីធំមួយរូបនៅក្នុង រដ្ឋាភិបាលដែលបានកិបកេង យកទ្រព្យសម្បត្តិរដ្ឋជាច្រើនធ្វើ មានបានផ្ទាល់ខ្លួនហើយទីបំផុតមានវិប្បដិសារីក៏បរិច្ចាគទ្រព្យ អស់ទាំងនោះឱ្យទៅ សូភី ជាកូនស្រី ដែលពីមុននាងត្រូវកូន ប្រុសលោកទាំងពីរ និងរូបលោកខ្លួនឯងផ្ទាល់ជាន់ឈ្លីឱ្យងងឹត សូន្យសុងលិចលង់ទៅក្នុងភក់ជ្រាំយកទៅធ្វើកុសលអ្វីតាម តែនាងចង់ធ្វើ និង ដើម្បីជាការស្មោលាទោសកំហុសរបស់ខ្លួន និងកូនប្រុសទាំងពីរដែលជាបងប្រុសបង្កើតរបស់នាង ហើយ បានសាងបាបកម្មយ៉ាងធ្ងន់ធ្ងរចំពោះនាង។ ការសារភាព កំហុសរបស់តួអង្គនេះ គឺបានធ្វើឡើងតាមរយៈការប្រគល់ ទ្រព្យសម្បត្តិដែលខ្លួនមាន ឱ្យទៅនាងសូភីដើម្បីឱ្យនាងយក ទៅចាត់ចែងធ្វើកុសលតាមចិត្តដែលនាងចង់បានផងនិងតាម រយៈការសន្ទនា ដោយតួអង្គឧត្តមមន្ត្រីប្រសើរខ្លួនឯងផ្ទាល់ ជាមួយវរជ្ឈលនោះ ដែលទង្វើនិងការសារភាពនេះគឺជាចេតនា របស់អ្នកនិពន្ធ ចង់បង្ហាញផ្លូវទៅដល់មន្ត្រីទាំងឡាយដែល មានតួនាទីខ្ពង់ខ្ពស់នៅក្នុងរដ្ឋាភិបាលនាសម័យសាធារណរដ្ឋខ្មែរនិងបណ្តាបុគ្គលដែលបានសាងអំពើដ៏អាក្រក់ជួជាតិ ទាំងឡាយ ដូចបណ្តាតួអង្គទាំងបីខាងលើនេះឱ្យមានចិត្ត ភ្ញាក់រឭក ហើយកែប្រែខ្លួនធ្វើអំពើល្អឱ្យបានទាន់ពេលវេលា ទាន់ឱកាសដែលខ្លួននៅមានជីវិតនៅឡើយ ហើយការនិរាស ព្រាត់ប្រាស់ដែលអ្នកនិពន្ធឱ្យគ្រួសារឧត្តមមន្ត្រី ប្រសើរ បាន ទទួលរងទាំងប៉ុន្មាននោះ គឺជាការបង្ហាញផ្លូវឬថាជាបណ្តា សារមួយដែលអ្នកនិពន្ធបានដាក់ចំពោះអ្នកដែលបានប្រព្រឹត្ត អំពើអាក្រក់ជួជាតិផងទាំងពួង ដូចយ៉ាងការប្រព្រឹត្តកន្លងមក របស់គ្រួសារឧត្តមមន្ត្រី ប្រសើរ នោះឱ្យខ្លាចរអា ហើយឈប់ ប្រព្រឹត្តអំពើអាក្រក់តទៅទៀត។

តាមរយៈសកម្មភាពនាង សូភី ដែលបានធ្វើចំពោះ ជនកៀសសឹកនោះ គឺជាការឆ្លុះបញ្ចាំងអំពីទឹកចិត្តរបស់អ្នក និពន្ធផ្ទាល់ចំពោះស្ថានភាពស្រុកទេសដែលកំពុងប្រឈម មុខនឹងចម្បាំងរាំងជល់ និង បញ្ហាអសន្តិសុខគ្រប់បែបយ៉ាង ក្នុងគោលបំណងជួយរួមចំណែកអូសទាញមនុស្សទូទៅឱ្យ សាងកុសលធម៌តាម តែអាចធ្វើទៅបានចំពោះមនុស្សដែល កំពុងតែកម្សត់ទុគត ហើយដែលមានឈាមជ័រជាខ្មែរដូចគ្នា និងដើម្បីយិតយោងគ្នាឱ្យងើបចេញផុតពីគ្រោះមហន្តរាយ នានា ដែលបណ្តាលឡើងដោយសារតែសង្គ្រាម ក្នុងកាលៈទេសៈមួយដែលពួកគេកំពុងដង្ហើយហៅរកការអាណិតអាសូរ និងអ្នកជួយសង្គ្រោះនោះ។ គំនិតដែលអ្នកនិពន្ធស្តែងឡើង តាមរយៈស្នាដៃទំនួញក្មេងកំព្រានេះ គឺជាគំនិតជាតិនិយម ដ៏ថ្លៃថ្លាមួយ ជាគំនិតដែលបំផុសឱ្យមនុស្សទូទៅយកចិត្តទុក

---

[៣៨] សូមមើលៈ កាណែល ទំនួញក្មេងកំព្រា ដ.ឯ.ម. ទំព័រ ១៧០ដល់ ១៧៤-១៧៥។

[៣៩] ដ.ឯ.ម. ទំព័រ ១៧០ដល់១៧០-១៨៥។

ដាក់ជួយអាណិតអាសូរជាតិជ្រោមជ្រែងជួយដល់ជាតិមាតុភូមិរបស់ខ្លួនដែលកំពុងតែប្រឈមមុខនឹងស្ថានភាពធ្លាក់ចុះដុនដាប ធ្វើយ៉ាងណាជួយរួមចំណែកគ្នាស្តារសង្គមមួយដែលកំពុងតែប្រឈមមុខនឹងវិបត្តិគ្រប់បែបយ៉ាង ក្នុងគោលបំណងរំដោះចេញឱ្យបានរួចផុតពីស្ថានភាពដ៏ប្រកបដោយគ្រោះអាសន្នបែបនេះ ដើម្បីបានវិលត្រឡប់ទៅរកប្រក្រតីភាពវិញ។ ដូច្នេះ គំនិតនេះគឺជាគំនិតវិជ្ជមានមួយចំពោះជាតិនិងចំពោះអ្នកដែលមានគំនិតស្រឡាញ់និងអាណិតអាសូរដល់ជាតិ។ ទោះបីជាការពិត គេមិនបានឃើញអ្នកនិពន្ធកាណែល ឬ ឡាំង ប៉េងសៀក បរិច្ចាគទ្រព្យធន ឬ សាច់ឈាមរបស់ខ្លួនទៅដល់ជាតិដោយជាក់ស្តែងមែន ប៉ុន្តែចំពោះអ្នកណាដែលបានអានស្នាដៃទំនួញក្មេងកំព្រានៅក្នុងស្ថានភាពនោះវិញ គឺប្រាកដជាមានចំនួនមិនតិចទេដែលមានអារម្មណ៍រន្ធត់ ក្តុកក្តួល អាណិតអាសូរទៅដល់ខ្សែជីវិតរបស់នាង សូភី និង ប្រជាជនខ្មែររាប់លាននាក់ដែលរស់នៅប្រឈមមុខនឹងភ្លើងសង្គ្រាមជាប្រចាំអស់រយៈពេលរាប់សិបខែថ្ងៃ។ ឆ្លើយតបទៅនឹងការណិតអាសូរ ដែលមាននៅក្នុងចិត្តរបស់ពួកគេនោះហើយ ទើបបានជាគេឃើញមានមនុស្សមួយចំនួនសុខចិត្តបរិច្ចាគនូវភាគចំណែករបស់ខ្លួនខ្លះៗ ដូចជា ទីកន្លែងស្នាក់អាស្រ័យនិងម្ហូបអាហារសម្រាប់ទទួលទានចម្អែតពោះប្រចាំថ្ងៃជាដើម ទៅដល់ជនភៀសសឹកដែលពនេចរពីទីកន្លែងមួយទៅទីកន្លែងមួយដើម្បីភាពរួចរស់ជីវិតពីសង្គ្រាមនិងអសន្តិសុខឱ្យពួកគេបានរស់មួយថ្ងៃៗទៅតាមលទ្ធភាពដែលពួកគេអាចធ្វើបានមួយអន្លើៗនោះដែរ។ លើសពីនេះទៅទៀត គំនិតជាតិនិយមរបស់អ្នកនិពន្ធដែលរំលេចឡើងតាមរយៈស្នាដៃនេះ ពិតជាបាននាំមនុស្សមិនតិចទេឱ្យសុខចិត្តដើរចោលរបបសាធារណរដ្ឋខ្មែរ ឬក៏ហោចណាស់លះបង់ចោលចិត្តគំនិតទុច្ចរិតដែលរបបសាធារណរដ្ឋខ្មែរបានបង្រៀនខ្លួន ហើយវៀរចាកលែងប្រព្រឹត្តអំពើអបាយមុខអស់ទាំងនោះតទៅទៀតដោយស៊ូទ្រាំរស់តាមសមាជីវៈរបស់ខ្លួននោះ។

## ឯកសារពិគ្រោះ


១- កាណែល : វីយ៉ូឡុងស្នេហា, ការផ្សាយរបស់បណ្ណាគារអមតា, ភ្នំពេញ, ឆ្នាំ១៩៧២។

២- ទំនួញក្មេងកំព្រា : ការផ្សាយរបស់សារព័ត៌មានអរិយធម៌ ភ្នំពេញ, ឆ្នាំ១៩៧៣។

៣- ខឹម សំឱ : ប្រវត្តិអក្សរសាស្ត្រខ្មែរ ការផ្សាយរបស់កាសែតសាមគ្គី, បោះពុម្ពផ្សាយលើកទី២ ភ្នំពេញ, ឆ្នាំ១៩៥៦។

៤- ឃីង ហុកឌី : ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, Paris, L'Harmattan, Paris, 1997។

៥- មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០ : បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ, ភ្នំពេញ, ឆ្នាំ២០០៤។

៦- ឃួន សុខម្ភ : បញ្ជីរាយនាមអ្នកនិពន្ធពី ឆ្នាំ១៩០០-១៩៧១ ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៧១។

៧- ឆាំង សុង : រដ្ឋប្រហារទម្លាក់សេនាប្រមុខ លន់-នល់ ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៩?

៨- ដៀប សុផលេ : របបសង្គមរាស្ត្រនិយម ពីមហាជ័យជំនះឈានទៅដល់វិបត្តិនិងការដួលរលំ១៩៥៥-១៩៧០, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ២០០៥។

៩- ឌ. គាម : ការសិក្សាអំពីវិវត្តន៍នៃអក្សរខ្មែរ, ការផ្សាយរបស់បណ្ណាល័យអប្សរា, ភ្នំពេញ, ឆ្នាំ២០០០។

១០- ត្រឹង ងា : អរិយធម៌ខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៧៤។

១១- តាត់ លីហុក : រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៩៣, សមាគមអ្នកសារព័ត៌មានខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៩៦។

១២- ម៉ុញ សារី : សទ្ទានុក្រមអក្សរសិល្ប៍, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៩៩។

១៣- ពៅ សាមី : មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ជំពូក ១, ឯកសារប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់, ភ្នំពេញ, ក្រសួងអប់រំនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ឆ្នាំ១៩៨៧

១៤- លន់ នល់ : ដំណើរខ្មែរថ្មី, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៧៤។

១៥- លាង ហាប់អាន : សិក្សាអត្ថបទ សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ, ភាគ១-២, ភ្នំពេញ, ការផ្សាយរបស់រោងពុម្ពសឹង ហេង, ឆ្នាំ១៩៦៦។

១៦- ប្រវត្តិអក្សរសាស្ត្រខ្មែរ : ភ្នំពេញ, ការផ្សាយរបស់បណ្ណាគារ គិម អេង, ឆ្នាំ១៩៦៧។

១៧- លី ធាមតេង : អក្សរសាស្ត្រខ្មែរ, បោះពុម្ពផ្សាយដោយបណ្ណាគារសេង ងួនហួត, ភ្នំពេញ, ឆ្នាំ១៩៦០។

១៨- អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី : ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ ឆ្នាំ១៩៧២។

១៩- លី ធាមតេង និង ម៉ា ឡាយខេម : វិវត្តន៍នៃអក្សរសាស្ត្រខ្មែរ, បោះពុម្ពផ្សាយដោយគណៈកម្មការស្រាវជ្រាវនៃសមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៧២។

២០- វ៉ាន់ឌី កាអុន : វិភាគទាននៃការសិក្សាអក្សរ-សិល្ប៍ខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៧២?។

២១- អក្សរសិល្ប៍ : វិភាគទានក្នុងការសិក្សាប្រាកដនិយម ប្រលោមនិយម, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៧៣។

២២- សោម សុមុនី : វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០, ឯកសារស្រាវជ្រាវក្រោមការឧបត្ថម្ភពីមូលនិធិ Toy-ota, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ២០០៤។

# និន្នាការខេមរនិយមក្នុងរូបភាពពុទ្ធនិយមតាមរយៈរឿង "កាកី"



លោក **តាន់ សុគន្ធា**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្ដីផ្ដើម

រឿងកាកីជាប្រលោមលោកពាក្យកាព្យ ដែលត្រូវបានតាក់តែងឡើងនៅឆ្នាំ១៨១៥ ដោយព្រះបាទ អង្គឌួង។ តាមការបញ្ជាក់របស់អ្នកនិពន្ធ យើងបានដឹងថា ក្នុងអក្សរសិល្ប៍ថៃ ក៏មានរឿងនេះដែរ គឺមានប្រលោមលោកជាភាសាថៃផង និងគម្ពីរជាភាសាបាលីផង។ តែដំណើររឿងទាំងនោះមិនដូចគ្នាទាំងស្រុងឡើយ ដូចជាក្នុងអក្សរសិល្ប៍ថៃ តួអង្គនាងកាកីបានសោយរាជ្យនៅទីបញ្ចប់រឿង ឯក្នុងអក្សរសិល្ប៍ខ្មែរ តួអង្គកាកីត្រូវទទួលការកាត់ទោសប្រហារជីវិត។

ការបញ្ចប់រឿងកាកីរបស់ព្រះបាទ អង្គឌួង មិនត្រឹមតែបង្ហាញថា រឿងនេះខុសពីកាកីថៃប៉ុណ្ណោះទេ តែថែមទាំងបង្ហាញថា វាមានលក្ខណៈខុសពីលក្ខណៈអក្សរសិល្ប៍ពុទ្ធនិយមសម័យកណ្ដាលទៀតផង។ ជាការពិតណាស់ដែលអ្នកនិពន្ធបានតាក់តែងរឿងនេះ ដោយគោរពទាំងស្រុងតាមគំរូតំណែងនិពន្ធតាមបែបជាតក តែឥទ្ធិពលរឿងកាកីមិនបានអប់រំមនុស្សតាមគន្លងធម៌ព្រះពុទ្ធសាសនាដូចរឿងក្រុងសុភមិត្រឡើយ។ ក្នុងសង្គមខ្មែរ *គេព្រួតគ្នាស្អប់តួអង្គកាកី មិនមែនដោយសារនាងកាកីធ្វើខុសពីដំបូន្មានព្រះទេ តែដោយសារនាងធ្វើខុសពីប្រពៃណីខ្មែរ ដោយក្បត់ប្ដីទៅមានសាហាយ*ពោលគឺ រឿងកាកីមានគំនិតអប់រំមនុស្សតាមគន្លងចរិយាសាស្ត្រខ្មែរដែលឆ្លុះបញ្ចាំងឱ្យឃើញពីចរិតនិងបញ្ហាពិតក្នុងសង្គមគ្រួសារខ្មែរ។ ដូច្នេះ វាជាស្នាដៃមួយដែលមានរូបភាពជាពុទ្ធនិយម ឯខ្លឹមសារជាខេមរនិយម។ ក្នុងការសិក្សារឿងនេះ យើងនឹងសង្កត់ធ្ងន់លើនិន្នាការស្នាដៃ ព្រោះវាជាចំណុចនៃគោលនិយមថ្មីសម័យនោះនិងជាមូលដ្ឋានប្រធានបទរបស់ប្រលោមលោកពាក្យរាយនាដើមសតវត្សរ៍ទី២០។ ដោយនិន្នាការនោះទាក់ទងយ៉ាងសំខាន់ដល់មូលដ្ឋានចរិយាសាស្ត្រខ្មែរ ដែលមានលក្ខណៈហាក់ដូចជាប៉ះពាល់ដល់សិទ្ធិមនុស្សខ្លះផង ទើបក្នុងការសិក្សា យើងនឹងបញ្ចូលការរិះគន់ខ្លះដោយផ្អែកលើគោលការណ៍មនុស្សធម៌ ដើម្បីឱ្យការសិក្សាបានជាប្រយោជន៍ដល់ទ្រឹស្ដីអក្សរសិល្ប៍ផងនិងដល់ទ្រឹស្ដីសង្គមផង ព្រោះអ្នកនិពន្ធមិនអាចផ្ដាច់ខ្លួនចេញពីបញ្ហាសង្គមបានឡើយ។

## ១- អ្នកនិពន្ធ

ព្រះអង្គឌួងជាអតីតមហាក្សត្រខ្មែរក្នុងស.វ.ទី១៩។ ព្រះអង្គឌួងប្រសូតនៅឆ្នាំ១៧៩៦។ ព្រះអង្គជាបុត្ររបស់ស្ដេច អង្គអេង ហើយបានភៀសព្រះអង្គទៅគង់នៅប្រទេសថៃជាងមួយទសវត្សរ៍។ ព្រះអង្គឌួងត្រឡប់មកស្រុកខ្មែរវិញនៅឆ្នាំ១៨៤១ ដែលយើងអាចចាត់ទុកថា ព្រះអង្គសោយរាជ្យសម្បត្តិចាប់តាំងពីពេលនោះមក ពិតមែនតែម្ចាស់ក្សត្រីអង្គម៉ី មិនទាន់ចូលទិវង្គតនៅឡើយ។ ដោយសន្ធិសញ្ញារវាងសៀម និងយួន នៅខែធ្នូ ឆ្នាំ១៨៤៥ បានស្រុះស្រួលប្រគល់រាជបល្ល័ង្ក ខ្មែរមកព្រះអង្គឌួងវិញ។

ព្រះអង្គឌួងបានទទួលរាជាភិសេកនៅឧដុង្គនាថ្ងៃទី៧ ខែមីនា ឆ្នាំ១៨៤៨ ក្នុងជន្មាយុ៥២ព្រះវស្សា ហើយទ្រង់ព្រះនាមាភិធេយ្យ *"ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះស្រីសុរិយោពណ៌បរមសុរេន្ទ្រា មហាចក្រពត្តិធិរាជបរមនាថ.."*។ បន្ទាប់ពីឡើងសោយរាជ្យភ្លាម ព្រះអង្គចាប់ផ្ដើមកសាងប្រទេសឡើងវិញ ដោយថវិកាពីឃ្លាំងរាជវាំង បង្កើតស្ថាប័នផ្នែកសង្គមកិច្ច ពោលគឺប្រជារាស្ត្រក្រីក្រនិងព្រះសង្ឃ អាចមកទទួលអាហារស្រស់ស្រូបនិងឆាន់ប្រចាំថ្ងៃ។ ព្រះអង្គបានបន្ថយពន្ធដារនានា ហើយសុវត្ថិភាពក៏បានកើតឡើងវិញក្នុងប្រទេស ដោយព្រះអង្គបានបង្កើតរចនាសម្ព័ន្ធនានា សម្រាប់បង្ក្រាបចោរកម្មនិងបទឧក្រិដ្ឋផ្សេងៗ។ នៅឆ្នាំ១៨៤៨ ព្រះអង្គឌួងបានបង្កើតតុលាការសាលាឧទ្ធរណ៍ ហើយព្រះអង្គផ្ទាល់ជាអធិបតីលើតុលាការទី២នេះ។ ចាប់ពីឆ្នាំ១៨៥៣ បានចាប់ផ្ដើមពិនិត្យសើរើជាទូទៅនូវមាត្រាច្បាប់នានាដោយព្រះអង្គបានចូលរួមយ៉ាងសកម្ម។

ព្រះអង្គឌួងបានបោះប្រាក់នៅឆ្នាំ១៨៤៨ និងបានកែប្រែរាជកិច្ចជាទូទៅ។ ព្រះអង្គបានចាប់ផ្តើមឱ្យសង់កំពែង និងផ្លូវគមនាគមន៍ ហើយរវាងឆ្នាំ១៨៥០ ព្រះអង្គបញ្ជាឱ្យមន្ត្រីកែនប្រជាជនឱ្យធ្វើកំពែងដីដើម្បីការពារប៉ែកខាងកើតរាជធានី ហើយបានយកថវិកាពីឃ្លាំងរាជវាំងឱ្យកសាងផ្លូវថ្នល់ដើម្បីឱ្យរាស្ត្រស្រែចម្ការដឹកជញ្ជូនភោគផលទៅដល់កំពង់ផែភ្នំពេញ។

ព្រះអង្គឌួងបានកែទម្រង់ព្រះពុទ្ធសាសនាដោយបញ្ជូន គណៈប្រតិភូ មានមន្ត្រីសេនាបតីខ្មែរ២រូប ទៅគាល់ស្តេចសៀមនៅថ្ងៃអង្គារ ទី១២ ខែមេសា ឆ្នាំ១៨៥៣ ដើម្បីសូមឱ្យស្តេចសៀមបញ្ជូនមកស្រុកខ្មែរវិញនូវព្រះសង្ឃមួយអង្គ ដែលមានចំណេះខ្ពង់ខ្ពស់ខាងព្រះពុទ្ធសាសនាព្រះនាមមហាប៉ាន ព្រមទាំងសូមឱ្យយកទាំងគម្ពីរព្រះត្រៃបិដកមកផង បានសេចក្តីថា ពុទ្ធសាសនាគណៈធម្មយុត្តិកនិកាយចូលមកកម្ពុជាចាប់ពីពេលនោះមក។

ជនជាតិបារាំងម្នាក់ឈ្មោះ ហង់រី មូហូត៍ (Henri MOUHOT) បានជួបស្តេចអង្គឌួងរវាងឆ្នាំ១៨៥៨ ហើយបានសរសេរពីរូបសម្បត្តិព្រះអង្គឌួងថា *"ព្រះជន្មប្រមាណ៦០ព្រះវស្សា មានព្រះកាយទាប ជាត់ក្រអាញ ព្រះកេសាខ្លី។ ទឹកព្រះភ័ក្ត្របង្ហាញប្រាជ្ញាញាណវាងវៃនិងមានសមានចិត្ត ល្អ[៤០]"*។

ព្រះអង្គឌួង បានកសាងរាជាណាចក្រឡើងវិញ ទាំងផ្នែកវប្បធម៌ ទាំងផ្នែកសេដ្ឋកិច្ច។ ក្នុងពេលដឹកនាំប្រទេស ព្រះអង្គឌួងបានរៀបចំការងារគ្រប់គ្រងបានយ៉ាងល្អប្រសើរ ម្យ៉ាងទៀតព្រះអង្គបានប្រមូលអ្នកប្រាជ្ញ បណ្ឌិតទាំងឡាយ មកធ្វើការក្បែរព្រះអង្គដើម្បីកសាងប្រទេសជាតិឡើងវិញ។ ព្រះអង្គបានរើបម្រះចេញពីការត្រួតពិនិត្យរបស់សៀម និងយួន ហើយងាកមករកបស្ចិមប្រទេសវិញ។ ព្រះអង្គបានចូលទិវង្គតនៅឆ្នាំ១៨៦០ ដោយបន្សល់ទុកនូវស្នាដៃសំខាន់ពីរគឺ *រឿងកាកី* និង *ច្បាប់ស្រី* (ជាច្បាប់ឧបទេសពាក្យកាព្យ)។ ព្រះអង្គឌួងជារាជបុរសសីលធម៌និងជាពុទ្ធសាសនិកជនយ៉ាងខ្លាំងក្លា។

## ២- សង្ខេបរឿង

នៅនគរពារាណសី មានស្តេចមួយអង្គសោយរាជ្យឈ្មោះព្រហ្មទត្ត។ ព្រះបាទព្រហ្មទត្តជាស្តេចមានអំណាចមានប្រទេស១០១ ជាចំណុះ មានកិលៀងម្នាក់ឈ្មោះគន្ធ័ន ជាមនុស្សមានប្រាជ្ញាវាងវៃ ចេះដេញពិណនិងចេះច្រៀង ដោយបង្កើតពាក្យកាព្យភ្លាមៗយ៉ាងពីរោះ។ ព្រះអង្គមានអគ្គមហេសីយ៉ាងល្អឯកនាមនាងកាកី។ កាកីមានកំណើតពីផ្កា ត្រូវបានឥសីម្នាក់រើសយកទៅចិញ្ចឹមហូតពេញវ័យ ពេលព្រះបាទព្រហ្មទត្តបានជួប ក៏សុំតាឥសីយកមកធ្វើជាអគ្គមហេសី។ ពេលនោះមានស្តេចគ្រុឌមួយនៅនគរសិម្ពលី មានឫទ្ធិអស្ចារ្យ អាចកាឡាខ្លួនជាមនុស្សអាចហោះរំលងសមុទ្រធំៗ។ គ្រុឌតែងហោះមកពារាណសី ហើយកាឡាខ្លួនជាប្រុសកំលោះយ៉ាងស្អាត រួចចូលលេងបាស្កាជាមួយព្រះបាទព្រហ្មទត្តរាល់សប្តាហ៍។ ថ្ងៃមួយពេលបាត់ស្វាមីពីក្នុងបន្ទប់យូរ កាកីបានចេញមកមើលនៅកន្លែងព្រះអង្គលេងបាស្កា។ កាកីបានឃើញកំលោះគ្រុឌស្អាត ក៏បញ្ចេញឫកពាត្រេកត្រអាលដាក់គ្រុឌ ឯគ្រុឌពេលឃើញកាកី ក៏ចាប់ចិត្តស្រឡាញ់ដែរ។ យប់នោះ ពេលបែកពីព្រហ្មទត្ត គ្រុឌបានបង្កើតព្យុះភ្លៀង ធ្វើឱ្យចលាចលក្នុងវាំង ហើយចូលឆក់យកកាកីទៅស្ថានសិម្ពលី។ ពេលបាត់កាកី ព្រហ្មទត្តកើតទុក្ខយ៉ាងខ្លាំង ហើយហៅគន្ធ័នមកសួរ។ គន្ធ័នបានសង្ស័យលើកំលោះគ្រុឌ ហើយប្រាប់ព្រហ្មទត្តថា ត្រូវរង់ចាំរហូតដល់សប្តាហ៍ក្រោយ។ គ្រុឌបានយកកាកីទៅរួមរស់ជាមួយយ៉ាងសុខសាន្ត។ រហូតដល់ពេលដែលត្រូវទៅលេងបាស្កាជាមួយព្រហ្មទត្ត គ្រុឌបានសុំនាងកាកីទៅពារាណសី នាងអង្វរមិនឱ្យគ្រុឌទៅតែគ្រុឌថាខ្លាចគេសង្ស័យហើយនៅតែទៅ។ ក្រោយពេលលេងបាស្កា គ្រុឌបានលាព្រហ្មទត្តត្រឡប់ទៅសិម្ពលីវិញដូចធម្មតា ដោយមិនបានដឹងថាគន្ធ័ន បានកាឡាខ្លួនជាស្រមើលតោងរោមគ្រុឌទៅជាមួយឡើយ។ គន្ធ័នបានទៅដល់សិម្ពលី រួចនៅពេលថ្ងៃពេលដែលគ្រុឌចេញទៅរកចំណី គន្ធ័នបានចេញមកលួងលោមកាកីនិងរួមរក្សជាមួយនាងពេញមួយសប្តាហ៍។ គ្រុឌមិនបានដឹងរឿងនេះ លុះដល់ពេលត្រូវទៅលេងបាស្កាក៏ទៅដូចជាប្រក្រតី ឯគន្ធ័នក៏តោងរោមគ្រុឌត្រឡប់មកវិញដែរ។ គន្ធ័នបានរាយការណ៍ប្រាប់ព្រហ្មទត្តទាំងអស់ ទាំងការដែលខ្លួនរួមរក្សជាមួយកាកី ដោយទម្លាក់កំហុសលើកាកី ដើម្បីឱ្យព្រហ្មទត្តអភ័យទោសឱ្យខ្លួន។ ព្រហ្មទត្តមិនយកទោសគន្ធ័ន ហើយបែរជាស្អប់កាកី រួចប្រាប់គន្ធ័នឱ្យរកល្បិចយកកាកីមកវិញ។ សប្តាហ៍ក្រោយមក ពេលគ្រុឌមកលេងបាស្កា គន្ធ័នបានយកពិណមកលេង រួចច្រៀងរៀបរាប់ពីការដែលខ្លួន

[៤០] យឹង ហុកឌី ***មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី១៩*** ដ.ឯ.ម. ទំព័រ ២២

បានរួមរក្សជាមួយកាកីនៅស្ថានសិម្ពលី។ គ្រុឌបានដឹងថា កាកីមិនស្មោះនឹងខ្លួន ក៏នាំកាកីមកពារាណសីវិញ ទោះបីនាងអង្វរកយ៉ាងណាក៏ដោយ។ ពេលព្រឹក ព្រហ្មទត្តបានឃើញកាកីនៅក្នុងសួន ក៏និយាយជៀលត្មះនាងយ៉ាងខ្លាំង។ កាកីបានប្រកែកដោះសារថា នាងគ្មានកំហុសនិងបានអង្វរសុំអភ័យទោស តែព្រហ្មទត្តនៅតែបញ្ជាឱ្យគេយកនាងទៅបណ្ដែតពោងពាយចោលក្នុងសមុទ្រ។ មួយសប្ដាហ៍ក្រោយមក នាងកាកីក៏បានស្លាប់ដោយរន្ធត់និងយ៉ាងវេទនាក្នុងមហាសាគរ។

## ៣- រូបភាពពុទ្ធនិយម

រឿងកាកី មានចំណងជើងនិងដំណើររឿងដោយឡែករបស់ខ្លួនមិនដូចរឿងណាមួយក្នុងបញ្ញាសជាតកឡើយ។ តែនៅប្រទេសកម្ពុជា គេរាប់បញ្ចូលរឿងនេះ ក្នុងប្រភេទរឿងសាស្ត្រាល្បែង ដែលភាគច្រើនត្រូវបាននិពន្ធតាមលំនាំរឿងក្នុងគម្ពីរបញ្ញាសជាតកនេះ ពីព្រោះអ្នកនិពន្ធ បានយកគំរូតំណែងនិពន្ធបែបជាតកមកអនុវត្តក្នុងតំណែងនិពន្ធស្នាដៃខ្លួន។ ឧទាហរណ៍ៈ

ក្នុងសេចក្ដីផ្ដើម អ្នកនិពន្ធបានបញ្ជាក់ថា រឿងនេះលោកបានបកប្រែពីភាសាសៀម ដែលមានគោលដើមនិយាយថា ជារឿងមាននិទាននៅក្នុងគម្ពីរភាសាបាលី[៤១] ដំណាលពីកាលព្រះពោធិសត្វត្រាច់រង្គាត់ក្នុងវដ្ដសង្សារ។ ការបញ្ជាក់នេះ មានន័យថា អ្នកនិពន្ធថៃ បានសរសេររឿងនេះតាមលំនាំរឿងក្នុងគម្ពីរជាភាសាបាលី ហើយអ្នកនិពន្ធខ្មែរបានប្រែរឿងនេះពីភាសាថៃមកភាសាខ្មែរ[៤២]។

ដូច្នេះ ទោះបីស្នាដៃនេះ ត្រូវបានអ្នកនិពន្ធសរសេរតាមគ្នាច្រើននាក់ក៏ដោយ ក៏វានៅតែបង្ហាញឱ្យយើងឃើញលក្ខណៈផ្ដើមរឿងបែបជាតកដែរ។

ក្នុងពេលបង្ហាញតួអង្គគ្រុឌ អ្នកនិពន្ធបញ្ជាក់ថា គ្រុឌគឺជាពោធិសត្វ ដែលជាតួអង្គសំខាន់មួយរបស់រឿងជាតក។

នៅទីបញ្ចប់ អ្នកនិពន្ធបានបញ្ជាក់ការសេជាតិរបស់តួអង្គទាំងអស់ដូចគ្នានិងការបញ្ចប់រឿងនៃស្នាដៃជាតកទាំងអស់ដូចជាៈ

គ្រុឌ គឺព្រះសម្មាសម្ពុទ្ធ(ព្រះពុទ្ធ) *"ឯគ្រុឌរាជបក្សា គឺព្រះសម្មាសម្ពុទ្ធ ត្រាស់ទ្រង់បរិសុទ្ធ តែងទេសន៍ទូន្មានសព្វសត្វ[៤៣]"*។

ព្រហ្មទត្ត គឺជាព្រះសារីបុត្រ (ជាអគ្គសាវ័កញាណ) *"ឯអង្គព្រះព្រហ្មទត្ត រលីងថ្កាត់មិញមកបាន ជាអគ្គសាវ័កញាណ គឺអង្គព្រះសារីបុត្រ[៤៤]"*។

គន្ធ័ន គឺព្រះមោគ្គល្លាន (ជាអគ្គសាវ័ក) *"រីនាយនាដកូវេន សិល្បសាស្ត្រក្លែនសិទ្ធិស័ក្តិ ចេះរលីងជាអគ្គ-សាវ័កគឺមោគ្គល្លាន[៤៥]"*។

កាកី គឺជានាងចិញ្ចានៅឋាននរក *"ស្លាប់ទៅនៅនរក វេទុក្ខទោសតាមវេរា លុះមកដល់សាសនាព្រះពុទ្ធយើងនេះបានត្រាស់។ ទើបមានបន្ទូលទេសនា ជាគាថាជុំជាតកច្បាស់ ថាកាកីនោះផ្លាស់ ជាតិជានាងចិញ្ចាជាក់"*។

តាមការសិក្សាកន្លងមក យើងឃើញថា មិនមែនតែអ្នកនិពន្ធរឿងកាកីមួយទេ ដែលអនុវត្តតាមគំរូតំណែងនិពន្ធនេះ តែអ្នកនិពន្ធនៃប្រទេសបួននៅឥណ្ឌូចិនគឺ ខ្មែរ ថៃ ឡាវ និងភូមា បានអនុវត្តតាំងពីអំឡុងសតវត្សរ៍ទី១៦មក។ ដោយសារគំរូនេះហើយ ទើបរឿងកាកីនៅតែមានរូបភាពជាស្នាដៃបែបពុទ្ធនិយម ទោះបីខ្លឹមសារវាចាប់ផ្ដើមមានចំណុចខេមរនិយមហើយក៏ដោយ។

## ៤- លក្ខណៈខេមរនិយម

លក្ខណៈដោយឡែករបស់រឿងកាកី ដែលធ្វើឱ្យរឿងនេះ ខុសពីស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមទូទៅស្ថិតត្រង់ការដែលអ្នកនិពន្ធមិនភ្ជាប់ទ្រឹស្ដីសាសនាក្នុងចំណោទនិងសម្រាយបញ្ហារឿង។ ដំណាក់ដំណើររឿងសំខាន់ៗដូចជា ការដែលគ្រុឌចក់នាងកាកីពីស្ដេចព្រហ្មទត្ត ការផិតក្បត់របស់កាកីកំហឹងព្រហ្មទត្តនិងល្បិចកលរបស់គន្ធ័នជាដើមមានលក្ខណៈ

[៤១] តែមិនបានបញ្ជាក់ថាជាគម្ពីរណាទេ។

[៤២] បើតាមការបញ្ជាក់នេះ យើងមិនអាចចាត់ទុកថា រឿងកាកីជាស្នាដៃអក្សរសិល្ប៍ខ្មែរបានឡើយ តែដោយពិនិត្យទៅឃើញថា រឿងកាកីរបស់ព្រះអង្គឌួង មានចំណុចខុសពីរឿងកាកីរបស់ថៃច្រើន ទើបយើងរាប់រឿងនេះចូលក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ យើងយល់ថាការប្រើពាក្យ "បកប្រែ" របស់អ្នកនិពន្ធ នាំឱ្យមានការច្រឡំ ត្រង់នេះគួរបញ្ជាក់ថា "សរសេរតាមលំនាំប្រធានរឿង..." ទើបត្រឹមត្រូវជាង។

[៤៣] ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះបរមកោដ្ឋ អង្គឌួង កាកី ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៦ ឆ្នាំ ១៩៧៤ ទំព័រ៥១។

[៤៤] ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះបរមកោដ្ឋ អង្គឌួង កាកី ដ.ឯ.ម. ទំព័រ៥១។

[៤៥] ដ.ឯ.ម. ទំព័រ៥១។

ដូចគ្នានឹងដំណើរជីវិតពិតប្រាកដក្នុងសង្គមមនុស្ស។ តាមការបង្ហាញរបស់អ្នកនិពន្ធ យើងឃើញថា ដំណើរជីវិតរបស់តួអង្គទាំងអស់ ត្រូវបានកំណត់ដោយសច្ចភាពសង្គម មិនមែនដោយច្បាប់សាសនាទេ ដូចជាតួអង្គកាកីក្នុងអក្សរសិល្ប៍ខ្មែរត្រូវស្លាប់ដោយការកាត់ទោសរបស់ស្តេចព្រហ្មទត្ត គឺស្លាប់ក្រោមអំណាចច្បាប់នៃប្រទេសមួយ ឯតួអង្គកាកីរបស់អ្នកនិពន្ធថៃមិនរងគ្រោះដោយការកាត់ទោសរបៀបនេះទេ ព្រោះថៃមានទម្រង់ច្បាប់ផ្សេងពីនេះ។ ដូច្នេះ ទោះបីរឿងកាកីមានលក្ខណៈអច្ឆរិយៈតាមការពិពណ៌នារូបតួអង្គក្តី ក៏វានៅតែបានឆ្លុះបញ្ចាំងពីជីវភាពពិតប្រាកដក្នុងសង្គម ពិសេសការកាត់ទោសកាកីធ្វើឱ្យយើងឃើញទម្រង់ច្បាប់ចរិយាសាស្ត្រមួយបែបដែលនៅមានអត្ថិភាពនៅឡើយក្នុងសង្គមខ្មែរនិងនៅប្រទេសមួយចំនួនលើពិភពលោក។ ក្នុងការសិក្សាអំពីលក្ខណៈខេមរនិយមក្នុងរឿងកាកីនេះ យើងសូមបង្ហាញអំពីលក្ខណៈជីវភាពក្នុងសង្គមខ្មែរ ដែលទាក់ទងនឹងបញ្ហាផិតក្បត់ ព្រមទាំងបង្ហាញអំពីលក្ខណៈច្បាប់ចរិយាសាស្ត្រខ្មែរដែលដាក់ទោសយ៉ាងធ្ងន់ធ្ងរដល់អំពើផិតក្បត់របស់នារី។

ការឆ្លុះបញ្ចាំងអំពីវិបត្តិកាមគុណក្នុងសង្គមគ្រួសារខ្មែរ បញ្ហាជីវភាពដែលលេចធ្លោក្នុងរឿងកាកី គឺបញ្ហាវិបត្តិក្នុងសង្គមគ្រួសារ ពិសេសគឺបញ្ហាដែលទាក់ទងនឹងការផិតក្បត់។ តាមដំណើររឿងយើងឃើញថា កាកីបានក្បត់ពីព្រហ្មទត្តទៅរួមរស់ជាមួយគ្រុឌ រួចក្បត់គ្រុឌលួចរួមរក្សជាមួយគន្ធ័ន ហើយទីបំផុតត្រូវព្រហ្មទត្ត បញ្ជាឱ្យគេសម្លាប់ដោយបណ្តែតពោងពាយ។ ដំណើររឿងបែបនេះឆ្លុះបញ្ចាំងពីដំណើរជីវិតពិតនៃគ្រួសារជាច្រើនលើពិភពលោក។ ដោយឡែកក្នុងសង្គមខ្មែរលក្ខណៈជីវិតរបៀបនេះមានតាំងពីយូរណាស់មកហើយ ម្យ៉ាងទៀត ក្រៅពីរឿងកាកី យើងឃើញមានរឿងនិទានមួយចំនួនទៀត ក៏បានឆ្លុះបញ្ចាំងតថភាពបែបនេះដែរ ដូចជារឿង ពស់កេងកង រឿងមាយាស្ត្រី...។ តាមការបង្ហាញរឿងរបស់ អ្នកនិពន្ធទាំងនោះ យើងឃើញថា វិបត្តិបែបនេះគ្មានទាក់ទងអ្វីនឹងលទ្ធិសាសនាឡើយ តែវាជាវិបត្តិដែលផ្តើមចេញពីកត្តាជីវសាស្ត្រ ពីសេចក្តីត្រូវការក្នុងរឿងកាមដែលយើងអាច ហៅថាជាវិបត្តិកាមគុណ។ ជាទូទៅយើងឃើញការផិតក្បត់នេះ ច្រើនកើតមានឡើងក្នុងករណីដែលបុរសជាប្តីមិនបានបំពេញកាមកិច្ចជាមួយភរិយាឱ្យបានគ្រប់គ្រាន់ ដូចជាក្នុងករណីបុរសប្រពន្ធច្រើន បុរសមិនរវល់នឹងកាមកិច្ចឬខ្វះបច្ចេកទេសឬឃ្លាតឆ្ងាយពីភរិយា។ រឿងនិទានខ្មែរ ព្រមទាំងរឿងកាកី ក៏បង្ហាញដូច្នេះដែរ៖

ក្នុងរឿងពស់កេងកង អ្នកនិពន្ធបង្ហាញថា ប្រពន្ធបាន ក្បត់ប្តីទៅរួមរក្សជាមួយសត្វពស់កេងកង ព្រោះតែប្តីនោះជាអ្នកជំនួញ ហើយដើរបាត់ពីផ្ទះបួនប្រាំឆ្នាំទើបមកជួបប្រពន្ធម្តង។

ក្នុងរឿងមាយាស្ត្រី ប្រពន្ធក្បត់ប្តី ដោយប្តីនោះជាមនុស្សដែលមិនរវល់សោះក្នុងរឿងកាមគុណ... សូម្បីតែប្រពន្ធមានសាហាយក៏មិនដឹងផង។

ឯការដែលកាកីក្បត់ពីព្រហ្មទត្ត ក៏ស្ថិតលើមូលហេតុមិនខុសពីនេះដែរ។ ជាការពិតណាស់ដែលថា ព្រហ្មទត្តស្រឡាញ់កាកីយ៉ាងខ្លាំង ពេលបាត់កាកី ព្រហ្មទត្តកើតទុក្ខនៅមិនស្ងៀម តែក្នុងទំនាក់ទំនងរស់នៅជាមួយគ្នារាល់ថ្ងៃ យើងឃើញថា ព្រហ្មទត្តពិតជាពុំបានបំពេញកាមកិច្ចឱ្យបានគ្រប់គ្រាន់ដល់កាកីឡើយ។ ទីមួយ ព្រហ្មទត្តជាស្តេចដែលចូលចិត្តលេងល្បែងបាស្កា ដូចជាពេលជួបលេងជាមួយគ្រុឌម្តងៗ ព្រហ្មទត្តលេងដោយស្ទើរតែភ្លេចពេលវេលានិងប្រពន្ធ។ មួយទៀត ព្រហ្មទត្តជាស្តេចដែលមានស្រីស្នំរាប់រយ ពោលគឺមិនមែនមានពេលរួមរក្សតែជាមួយនាងកាកីទេ។

សរុបមក យើងឃើញថា រឿងផិតក្បត់របស់កាកីកើតពីសេចក្តីត្រូវការកាមគុណតាមច្បាប់ធម្មជាតិ។ ជាទូទៅទោះកាកីក្តី ទោះនារីដទៃទៀតក្តី តែងតែត្រូវការបុរសម្នាក់ជាស្វាមីដែលអាចថ្នាក់ថ្នមនាងកើត ហើយដែលអាចបំពេញកាមតណ្ហាឱ្យនាងបានគ្រប់គ្រាន់ ហើយបើពុំនោះទេ វាអាចកើតមានការផិតក្បត់នេះ។ បើគិតតាមច្បាប់ធម្មជាតិបែបនេះ គេមិនត្រូវដាក់ទោសអំពើរបៀបនេះទេ តែក្នុងសង្គមខ្មែរ អ្នកដែលប្រព្រឹត្តបែបនេះ តែងតែទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះ ការកាត់ទោសកាកីគឺជាការឆ្លុះបញ្ចាំងលក្ខណៈច្បាប់ចរិយាសាស្ត្រនៃសង្គមខ្មែរពិតប្រាកដ។

**៥- ចរិយាសាស្ត្រខ្មែរតាមរយៈការកាត់ទោសកាកី**

រឿងកាកីបានបញ្ចប់ដោយរៀបរាប់ពីការរន្ធត់តក់ស្លុតនិងការឈឺចាប់ហួសប្រមាណរបស់នាងកាកីមុនពេលស្លាប់ ដោយត្រូវបានគេបណ្តែតពោងពាយចោលក្នុងសមុទ្រ។ ការរៀបរាប់នេះ គឺជាការបង្ហាញអំពីសោកនាដកម្មនៃជីវិតនារីម្នាក់យ៉ាងពិតប្រាកដ។ តែចំពោះតួអង្គព្រហ្មទត្តដែលជាអ្នកស្រឡាញ់កាកីយ៉ាងខ្លាំង បែរជាសម្រេចធ្វើឱ្យនាងស្លាប់

យ៉ាងវេទនាដោយគ្មានអាណិតនិងសោកស្តាយ។ យើងយល់ថា នេះជាអំពើឃោរឃៅដែលផ្តើមចេញអំពីកំហឹងផ្ទាល់របស់ស្តេចព្រហ្មទត្តចំពោះការផិតក្បត់របស់កាកី។ តែតាមការបង្ហាញរបស់អ្នកនិពន្ធ អំពើនេះមានលក្ខណៈជាការកាត់ទោសតាមច្បាប់ទៅវិញ។ ក្នុងដំណើររឿង អ្នកនិពន្ធបានបង្ហាញពីកំហឹងព្រហ្មទត្តដែរ តែពេលសម្រេចកាត់ទោសកាកីព្រហ្មទត្តបានពោលថា ៖

*"រីខ្លួនមេមួយ កុំបីមេព្រួយ*
*ដោះសារវិលវល់*
*នឹងយកមកទុក ធ្វន់ស្រុកអំពល់*
*នឹងឲ្យដឹងដល់*
*ប្រទេសនានា ។...*
*បើគេដឹងរឿង ដឹងរ៉ាវក្បួនក្បឿង*
*គេនឹងនិន្ទា ...*[៤៦] "។

តាមសម្តីនេះ ការដែលព្រហ្មទត្តសម្រេចកាត់ទោសនេះ មិនមែនដោយសារកាកីមានកំហុសតែចំពោះព្រហ្មទត្តម្នាក់ទេ តែដោយនាងមានកំហុសចំពោះចរិយាសាស្ត្រសង្គមទាំងមូល។ តាមខ្លឹមសាររបស់វា ចរិយាសាស្ត្រនោះ គឺជាច្បាប់មួយដែលទាមទារយ៉ាងខ្លាំងនូវភក្តីភាពរបស់នារីចំពោះបុរសជាស្វាមី។ ក្នុងសង្គមដែលអនុវត្តច្បាប់ចរិយាសាស្ត្រនេះ គេស្អប់ខ្ពើមបំផុតការផិតក្បត់របស់នារី។ ដូច្នេះ ការដែលព្រហ្មទត្តមិនអាចសម្រាលទោសកាកីបាន ព្រោះច្បាប់ចរិយា-សាស្ត្រនោះបានកាត់ទោសនាងរួចទៅហើយ។ ក្នុងសង្គមខ្មែរ យើងអាចនិយាយបានថា ចរិយាសាស្ត្រនេះមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើជីវភាពរស់នៅរាល់ថ្ងៃ លើប្រពៃណីទំនៀមទម្លាប់និងលើច្បាប់សង្គមទៀតផង ជាក់ស្តែង គឺយើងធ្លាប់ឃើញ មានការកាត់ទោសប្រហារជីវិតនារីដែលមានកំហុសដូចនាង កាកីនេះ។ ឧទាហរណ៍៖ ក្នុងប្រវត្តិសាស្ត្រខ្មែរ នាស.វ.ទី១៧ មានម្ចាស់ក្សត្រីម្នាក់ឈ្មោះព្រះម៉ែឃ្លួវត្តី ត្រូវគេចាប់កាត់ក្តី រួចកាត់ទោសប្រហារជីវិត ដោយក្បត់ប្តីជាមហាឧបរាជ ឈ្មោះ ព្រះឧទ័យ ទៅស្រឡាញ់ព្រះរាមព្រះរាជសម្ភារ (១៦២៧-១៦៣២)។ តាមឧទាហរណ៍នេះ យើងឃើញថា រឿងកាកី គឺជាការឆ្លុះបញ្ចាំងចរិយាសាស្ត្រនេះពិតប្រាកដ។ យើងយល់ថាព្រះអង្គឌួង ដែលបាននិពន្ធរឿងនេះ ជាការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះច្បាប់នេះ ព្រោះក្រៅពីរឿងកាកី ទ្រង់បាននិពន្ធច្បាប់ឧបទេសជាពាក្យកាព្យមួយទៀតឈ្មោះថា"ច្បាប់ស្រី" ដែលមានន័យជាដំបូន្មានសម្រាប់នារី។ ដូច្នេះហើយ ទើបលោកនិពន្ធរឿង "កាកី" ដោយយកច្បាប់នោះ ជាកម្មវត្ថុនៃការឆ្លុះបញ្ចាំងដែលធ្វើឱ្យរឿងនេះ មានន័យដូចជាច្បាប់ចរិយាសាស្ត្រសម្រាប់នារីដែរ។ ការបញ្ចប់រឿងដោយបង្ហាញពីមរណភាពយ៉ាងឈឺចាប់ ព្រមទាំងការបង្ហាញពីការសជាតិនាងកាកី ទៅជានាងចិញ្ចានៅស្ថាននរកជាការគំរាមកំហែងស្មារតីនារី មិនឱ្យហ៊ានប្រព្រឹត្តប្រឆាំងនឹងចរិយាសាស្ត្រនោះ។

ដោយហេតុការណ៍កាត់ទោសកាកី វាស្របនឹងចរិយា- សាស្ត្រ ដែលគ្របដណ្តប់លើជីវភាពសង្គមខ្មែរ ដូច្នេះទើបចំពោះខ្មែរ រឿងកាកីគ្មានលក្ខណៈជាសោកនាដកម្មឡើយ។ ដូច្នេះហើយទើបអ្នកអានរឿងកាកី មិនត្រឹមតែមិនអាណិតនាងប៉ុណ្ណោះទេ គឺថែមទាំងស្អប់ខ្ពើមទៀតផង។ សព្វថ្ងៃពាក្យ "កាកី" ក្លាយជាពាក្យជៀលជេរនារីដែលផិតក្បត់។ គេប្រើ ពាក្យនេះ ទាំងក្នុងជីវភាពជាក់ស្តែង ទាំងក្នុងស្នាដៃអក្សរសិល្ប៍ និងក្នុងបទចម្រៀង។ ក្នុងសិល្បៈអក្សរសិល្ប៍ខ្មែរ "កាកី" ជា និមិត្តរូបនៃនារីផិតក្បត់។ ឯក្នុងជីវភាពជាក់ស្តែង ស្ត្រីដែល បានប្រព្រឹត្តដូចនាងកាកី ត្រូវគេរិះគន់ខ្លាំងណាស់ ឯក្រុមនារី ពេស្យា ត្រូវគេចាត់ទុកថាជាមនុស្សដែលគ្មានកិត្តិយសសោះ ក្នុងសង្គម។ និយាយរួម នារីប្រភេទ "កាកី" ក្នុងសង្គមខ្មែរ សព្វថ្ងៃ ទោះបីមិនត្រូវច្បាប់កាត់ទោសដូចនាងកាកី ក៏ត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរខាងផ្លូវស្មារតីដែរ ព្រោះដូចជាត្រូវរស់នៅក្រៅសង្គម។

ការកាត់ទោសព្រះម៉ែឃ្លួវតី ការកាត់ទោសកាកី ព្រមទាំងការឯកោ នារីបែបនោះក្នុងសង្គមខ្មែរបង្ហាញឱ្យឃើញថាខ្មែរជាអ្នកនិយមចរិយាសាស្ត្របែបផ្តាច់ ការអមនុស្សធម៌និងអយុត្តិធម៌។

ជាការពិតណាស់ ក្នុងសង្គមត្រូវមានច្បាប់សម្រាប់អប់រំមនុស្ស ប៉ុន្តែមនុស្សក៏ត្រូវការសេរីភាពដែរ។ ដូច្នេះចរិយាសាស្ត្រដែលមានតួនាទីបណ្តុះបុគ្គលិកលក្ខណៈល្អៗដល់មនុស្សនោះ ក៏ត្រូវតែរក្សាជាដាច់ខាតនូវសេរីភាពរបស់មនុស្សម្នាក់ៗ។ ប៉ុន្តែក្នុងខ្លឹមសារចរិយាសាស្ត្រខ្មែរដែលឆ្លុះបញ្ចាំងតាមរយៈរឿងកាកីរបស់ព្រះបាទអង្គឌួង គេបានលុបចោលទាំងស្រុងនូវសេរីភាពនោះ។ ការទាមទារភក្តីភាពរបស់

[៤៦] ព្រះរាជនិពន្ធព្រះបាទសម្តេចព្រះហរិរក្ខរាមាឥស្សរាធិបតី អង្គឌួង *កាកី* ជ.ឯ.ម. ទំព័រ ៦០។

នារីចំពោះបុរស គឺជាការបង្ខំឱ្យនារីនោះ ត្រូវតែរក្សាសេចក្ដីស្នេហាចំពោះបុរសតែម្នាក់ដោយគ្មានលក្ខខណ្ឌ។ ឧទាហរណ៍ ៖ ទោះបីស្ដេចព្រហ្មទត្តមានស្រីស្នំរាប់រយ ឯគ្រុឌនៅកំលោះ ក៏នាងកាកីគ្មានសិទ្ធិស្រឡាញ់គ្រុឌដែរ ព្រោះនាងបានស្រឡាញ់ ព្រហ្មទត្តម្នាក់រួចទៅហើយ។ ដូច្នេះសេរីភាពក្នុងរឿងស្នេហា ត្រូវបាត់បង់ក្រោយពេលនាងរៀបការ ពោលគឺនាងត្រូវតែ មានស្វាមីភក្ដិចំពោះប្ដី ទោះបីប្ដីនោះយ៉ាងណាក៏ដោយ។

ម្យ៉ាងទៀត ការទាមទារភក្ដីភាពរបស់ច្បាប់នោះ វាមានន័យដូចជាការទាមទារពលិកម្មរបស់មនុស្សម្នាក់ចំពោះអ្នកដទៃ។ ប្រការនេះវាអាចល្អដែរ បើសិនជាពលិកម្មនោះជាពលិកម្មទៅវិញទៅមក តែបើតាមដំណើររឿងដែលថាស្ដេចព្រហ្មទត្តមានស្រីស្នំរាប់រយ ហើយបើយោងតាមសិទ្ធិរបស់បុរសខ្មែរ ក្នុងរបបពហុពន្ធនិយម កាលពីសម័យសក្ដិភូមិកន្លងទៅនោះ យើងឃើញថា ចរិយាសាស្ត្រនេះមានលក្ខណៈអយុត្តិធម៌ណាស់ចំពោះនារី។ វាជាច្បាប់ដែលគាបសង្កត់តែនារី ឯបុរសមានសេរីភាពបរិបូណ៌។ ដូច្នេះ តាមខ្លឹមសាររបស់វាចរិយាសាស្ត្រដែលកាត់ទោសកាកី ជាច្បាប់មួយដែលមានលក្ខណៈផ្ដាច់ការនិងអយុត្តិធម៌។

ឯរូបភាពនៃការកាត់ទោសរបស់ច្បាប់នោះ វាមិនត្រឹមតែប៉ះពាល់ដល់សេរីភាពប៉ុណ្ណោះទេ តែថែមទាំងប៉ះ-ពាល់ដល់គោលការណ៍មនុស្សធម៌ទៀតផង។ ជាទូទៅ ពាក្យថា *"មនុស្ស"* មានន័យខុសពីសត្វ ពោលគឺ មនុស្សមិនមែនមានតែកត្តាសរីរសាស្ត្រនិងជីវសាស្ត្រប៉ុណ្ណោះទេ មនុស្សគឺជាសត្វដែលមានរូបរាង មានជីវិត មានគំនិត មានវិចារណ-ញ្ញាណនិងមានសេចក្ដីប្រាថ្នាគ្រប់បែបយ៉ាង ដែលគេពុំអាចប្រកែកបាន។ ក្នុងន័យនេះ មនុស្សដែលរស់នៅក្នុងសង្គមត្រូវមានសេរីភាពក្នុងផ្លូវគំនិតនិងសេរីភាពនៃការសម្រេចសេចក្ដីប្រាថ្នារបស់គេ។ ពាក្យថា *"មនុស្ស"* ត្រូវតែបានទទួលការគោរពជាទីបំផុត ពីព្រោះមនុស្ស ឬ សុភមង្គលរបស់មនុស្ស ជាតម្លៃតែមួយគត់របស់សង្គមមនុស្ស។ យើងយល់ថា ការប្រហារជីវិតកាកីនិងការដៀលត្មះនារីបែបកាកីក្នុងសង្គមខ្មែរ ជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់តម្លៃមនុស្សដោយយោងខ្លាំងពេកលើតម្លៃចរិយាធម៌។ បើយោងតាមគោល-ការណ៍មនុស្សធម៌ គេពុំត្រូវបង្កើតច្បាប់សម្លាប់មនុស្ស ឬចាត់ទុកមនុស្សថោកទាបជាងច្បាប់ឡើយ ត្រូវគិតថា ***"តម្លៃមនុស្ស ជាតម្លៃដែលខ្ពស់បំផុត"***។

និយាយរួម យើងសន្និដ្ឋានថា ចរិយាសាស្ត្រខ្មែរដែលបង្ហាញតាមរយៈការកាត់ទោសកាកី គ្មានមូលដ្ឋានត្រឹមត្រូវទាល់តែសោះ។ យើងបានឃើញថា ចរិយាធម៌នេះ ត្រូវបានបង្កើតឡើងតាំងពីសម័យសក្ដិភូមិមុនសម័យព្រះបាទអង្គឌួងទៅទៀត តែដោយច្បាប់នេះ វាហុចប្រយោជន៍ដល់មនុស្សមួយចំនួន ទើបមកដល់សព្វថ្ងៃ នៅតែមានអ្នកនិយមនិងការពារច្បាប់នេះនៅកម្ពុជា។ សកម្មភាពនាងកាកីអាចចាត់ទុកជាការបះបោរមួយប្រឆាំងនឹងច្បាប់ចរិយាសាស្ត្រនេះ ជាការបះបោរទាមទារសេរីភាពសមភាព។ តែព្រះអង្គឌួងដែលជាតំណាងសក្ដិភូមិម្នាក់ដែរនោះ មិនព្រមប្រគល់សេរី-ភាពនិងសមភាពនោះឱ្យនាងឡើយ។ ឯបុរសខ្មែរបច្ចុប្បន្នដែលជាអ្នកទទួលផលប្រយោជន៍ពីច្បាប់នោះ ក៏នាំគ្នាដាក់ទោសយ៉ាងរំលោភលើនារីបែប "កាកី" ដោយយកពាក្យ **"ការពារទំនៀមទម្លាប់"** មកធ្វើជារបាំង។ ការពិត បើថាឥរិយាបថកាកីនាំឱ្យខូចសណ្ដាប់ធ្នាប់សង្គម នោះឥរិយាបថរបស់ព្រហ្មទត្ត ក៏ត្រូវតែទទួលការកាត់ទោសដែរ ហើយត្រូវកាត់ទោសឱ្យធ្ងន់ជាងកាកីទៅទៀត ព្រោះកាកីមានប្រុសតែបី ឯព្រហ្ម-ទត្តមានស្រីរាប់រយ។

## ៦- ការឆ្លុះបញ្ចាំងពីអត្តទត្ថភាពរបស់បុរសខ្មែរ

ទោះបីការក្បត់របស់កាកីបណ្ដាលមកពីកំហុសរបស់ព្រហ្មទត្តក្ដីឬមកពីកំហុសផ្ទាល់របស់កាកីក្ដី ក៏ការកាត់ទោសកាកីរបស់ព្រហ្មទត្តនិងការរិះគន់កាកីពីសំណាក់បុរសខ្មែរ សុទ្ធតែបញ្ជាក់ឱ្យឃើញពីអត្តទត្ថភាពរបស់អ្នកទាំងនោះយ៉ាងពិតប្រាកដ។ យើងយល់ថា ទោះបីព្រហ្មទត្តកាត់ទោសកាកី ដោយយោលទៅតាមច្បាប់ចរិយាសាស្ត្រណាមួយនោះក៏ដោយ ក៏ការពិត វាមិនអាចលាក់បាំងកំហឹងផ្ទាល់របស់ទ្រង់ដែលបណ្ដាលមកពីការប្រចណ្ឌយ៉ាងខ្លាំងនោះឡើយ។ ឯការប្រចណ្ឌ វាផ្ដើមចេញពីមនោសញ្ចេតនាស្នេហានោះ វាត្រូវតែភ្ជាប់នឹងព្រហ្មវិហារធម៌ ហើយមិនអាចនឹងមានការកាត់ទោសយ៉ាងព្រៃផ្សៃដូច្នេះទេ។ យើងរកឃើញអត្តទត្ថភាពក្នុងរឿងស្នេហាតាមរយៈការផ្ដន្ទាទោស ដោយការប្រចណ្ឌឬច្រណែនក្នុងរឿងកាមគុណនេះ។ ប្រចណ្ឌ ព្រោះគិតថា គូស្នេហ៍របស់ខ្លួនមិនស្រឡាញ់ឬមិនរួមរក្សតែជាមួយខ្លួនម្នាក់ ការដែលចង់

ឱ្យគេស្រឡាញ់តែខ្លួនឯងម្នាក់នេះហើយ ហៅថា "**អត្តទត្ត-ភាព**"។

ដំណើររឿងកាកី បញ្ជាក់ឱ្យយើងឃើញថា តួអង្គព្រហ្មទត្តជាមនុស្សដែលពោរពេញដោយគំនិតអត្តទត្ត-និយម។ ព្រហ្មទត្តខឹងសម្បានឹងកាកី រួចកាត់ទោសប្រហារជីវិតនាង ព្រោះនាងមិនស្រឡាញ់ស្មោះតែចំពោះទ្រង់ម្នាក់។ យើងអាចថា ការទាមទារភក្ដីភាពពីនាងកាកីជាការសមរម្យខ្លះ បើសិនជាព្រហ្មទត្តស្រឡាញ់ស្មោះតែចំពោះកាកីម្នាក់ តែតាមការអះអាងរបស់ខ្លួន ព្រហ្មទត្តមិនបានចាត់ទុកកាកីជាប្រពន្ធផងទេ គឺចាត់ទុកត្រឹមតែជាស្រីចំណីរាគាម្នាក់ក្នុងចំណោមស្រីស្នំរាប់រយៈ

*"អញជាចមក្សត្រ ឥសូររាស្ត្ររង្ស*
*គ្រប់គ្រងនគរា*
*ខ្សត់អីខ្មោចស្រី ចំណីរាគា*
*ស្រីអញមានជា រាប់រយសេសសល់*[៤៧]"។

បានន័យថា ការទាមទាររបស់ព្រហ្មទត្ត គឺជាការទាមទារឱ្យកាកីធ្វើពលិកម្មដើម្បីបំពេញតែអត្តទត្តបុគ្គលតែប៉ុណ្ណោះ រួចក្នុងកាមអំណាច ព្រហ្មទត្តបានយកច្បាប់ចរិ-យាសាស្ត្រមួយមកប្រើក្នុងការកាត់ទោសកាកី ដើម្បីលាក់-កំបាំងអត្តទត្តភាពដ៏គម្រក់របស់ខ្លួន។ ម្យ៉ាងទៀត ដោយយើងឃើញបុរសខ្មែរភាគច្រើន បានការពារចរិយាសាស្ត្រនោះ យើងអាចនិយាយថា អត្តទត្តភាពបែបនេះ ជាចរិតទូទៅរបស់បុរសខ្មែរ ហើយរឿងកាកីគឺជាស្នាដៃមួយដែលបានឆ្លុះបញ្ចាំងនូវចរិតនោះ។ អត្តទត្តភាពនោះ គឺជាមត៌កនៃការអប់រំរបស់របបសក្តិភូមិ បែបទេវរាជនិយមកន្លងមកហើយបុរសខ្មែរដែលព្យាយាមរក្សាមត៌កនោះ វាមិនខុសពីរូបភាពតួអង្គសក្តិភូមិឡើយ។ ដូច្នេះទាន់ពេលនេះ ប្រទេសយើងកំពុងកែប្រែស្ថាប័ន យើងគួរឈរលើមូលដ្ឋាននៃទស្សនៈជឿនលឿនណាមួយពិចារណាបញ្ហា "កាកី" ក្នុងសង្គមយើងឡើងវិញ ធ្វើយ៉ាងណាឱ្យទំនាក់ទំនងស្នេហាបុរសនារីមានភាពយុត្តិធម៌និងប្រកបដោយគោលការណ៍មនុស្សធម៌។

[៤៧] ព្រះរាជនិពន្ធព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី *កាកី* ដ.ឯ.ម. ទំព័រ៦០។

## សន្និដ្ឋាន

សរុបសេចក្ដីមក យើងឃើញថា ទោះបីរឿងកាកីត្រូវបានសរសេរតាមលំនាំរឿងដែលមានក្នុងអក្សរសិល្ប៍ថៃ និងក្នុងគម្ពីរភាសាបាលី ក៏រឿងនេះបានឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅពីជីវភាពនិងផ្នត់គំនិតមនុស្សក្នុងសង្គមខ្មែរ។ ព្រះបាទអង្គឌួង ជាអ្នកនិពន្ធស្នាដៃនេះ គឺជាអ្នកតំណាងឱ្យសង្គមចរិយាសាស្ត្របែបភក្តីភាពនិយមរបស់ខ្មែរ បានបញ្ចប់រឿងកាកីតាមផ្នត់ចរិយាសាស្ត្រនេះធ្វើឱ្យរឿងកាកីបាត់បង់លក្ខណៈជាស្នាដៃបែបខេមរនិយមទៅវិញ។ ដោយព្រះអង្គឌួង តាក់តែងស្នាដៃនេះតាមគំរូតំណែងនិពន្ធនៃសម័យកាលនោះទើបស្នាដៃនេះនៅមានអត្តរូបជាស្នាដៃពុទ្ធនិយមនៅឡើយ។ តែទោះបីយ៉ាងណាក៏ យើងអាចនិយាយបានថា *«ព្រះអង្គឌួងជាអ្នកបង្កើតបន្ថែមជាតុថ្មីមួយដល់អក្សរសិល្ប៍ខ្មែរសម័យកណ្តាល។ ជាតុថ្មីនោះ គឺការឆ្លុះបញ្ចាំងតថភាពក្នុងសង្គមខ្មែរដែលក្រោយមកក្លាយជាមូលដ្ឋាននៃនិម្មិតកម្មប្រលោមលោកពាក្យរាយ ក្នុងសម័យទំនើបនៃអក្សរសិល្ប៍ខ្មែរ»*។

## គន្ថនិទ្ទេស


១- ក្រុមអ្នកចងក្រង : ***ស្រាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ*** សម្រាប់ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់, ភ្នំពេញ, ឆ្នាំ១៩៨៦។

២- ក្រសួងអប់រំ : ***កំណាព្យខ្មែរ ភាគ២*** , ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំនៃសាធារណរដ្ឋប្រជាមា-និតកម្ពុជា, ភ្នំពេញ, ឆ្នាំ១៩៨៥។

៣- ក្រសួងសិក្សាធិការ : ***ពង្សាវតារនៃប្រទេសកម្ពុជា*** រោងពុម្ពព្រះបរមរាជវាំង, ភ្នំពេញ, ឆ្នាំ១៩៥២។

៤- គឹម សែត : ***ប្រវត្តិអក្សរសាស្ត្រខ្មែរ,*** ភ្នំពេញ, ឆ្នាំ១៩៥៩?។

៥- ឃួន សុខម្ភ : ***បញ្ជីរាយនាមអ្នកនិពន្ធពី ឆ្នាំ ១៩០០-១៩៧១,*** ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៧១។

៦- យឹង ហុកឌី :***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ,*** បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ, ភ្នំពេញ, ឆ្នាំ២០០៣។

៧- យឹង ហុកឌី :***មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី១៩,*** បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ, ភ្នំពេញ, ឆ្នាំ២០០៣។

៨- យឹង ហុកឌី : *មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០,* បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ, ភ្នំពេញ, ឆ្នាំ២០០២។

៩- ដុំ កាណាល់ : *ស្វែងយល់អក្សរសិល្ប៍ខ្មែរ,* ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ឆ្នាំ១៩៩៦។

១០- ឧកញ៉ាមហាមន្ត្រី ញ៉ុក នូវ : *ទំនៀមទំលាប់និងប្រពៃណីខ្មែរ,* បោះពុម្ពលើកទី២, ឆ្នាំ១៩៥៨។

១១- ឌ. គាម : *ការសិក្សាអំពីវិវត្តន៍នៃអក្សរសិល្ប៍ខ្មែរ* ការផ្សាយរបស់បណ្ណាល័យអប្សរា ភ្នំពេញ ឆ្នាំ២០០០។

១២- ត្រឹង ងា : *ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២* បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ឆ្នាំ២០០៣។

១៣- ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី អង្គ ឌួង : *រឿងកាកី,* បោះពុម្ពលើកទី៦, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ១៩៧៤។

១៤- ពៅ សាមី : *ទស្សនៈម៉ាក់ អង់គែល ស្តីពីអក្សរសិល្ប៍-សិល្បៈ,* សាលាគរុវិជ្ជាជាន់ខ្ពស់, ភ្នំពេញ, ឆ្នាំ១៩៨៧។

១៥- ពៅសាមី : *មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ (ជំពូក២),* ប្រើប្រាស់ផ្ទៃក្នុង ស.ភ.ព., ឆ្នាំ១៩៨៨។

១៦- ពៅសាមី : *មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ (ជំពូក១),* ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់, ភ្នំពេញ, ឆ្នាំ១៩៨៧។

១៧- លី ធាមតេង : *អ្នកនិពន្ធដែលមានឈ្មោះល្បី,* សមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៧២។

១៨- លី ធាមតេង និង ម៉ា ឡាយខេម : *វិវត្តន៍អក្សរសាស្ត្រខ្មែរ,* បោះពុម្ពផ្សាយដោយគណៈកម្មការស្រាវជ្រាវនៃសមាគមអ្នកនិពន្ធខ្មែរ, ភ្នំពេញ, ឆ្នាំ១៩៧២។

១៩- លាង ហាប់អាន : *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ សម័យនគរភ្នំដល់សម័យឧដុង្គ (ស.វ.១ ដល់ ១៨៥៩) (ភាគ១)* ការផ្សាយរបស់បណ្ណាគារ គឹម អេង, ភ្នំពេញ, ឆ្នាំ១៩៦៧។

២០- វ៉ាន់ ឌីកាអុន : *វិភាគទានក្នុងការសិក្សាប្រាកដនិយម និង អណ្តែតអណ្តូងនិយម,* ភ្នំពេញ, ឆ្នាំ១៩៧៣។

២១- ហ៊ុន គឹមសៀ : *មូលដ្ឋានយល់ដឹងអក្សរ-សាស្ត្រ*, បោះពុម្ពផ្សាយនៅឆ្នាំ១៩៦៣។

២២- អ្នកស្រី ត្រឹង ងា : *អរិយធម៌ខ្មែរ,* ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៥។

# ឯកសារមហាបុរសខ្មែរជាវិភាគទានដល់ការទ្រទ្រង់វិស័យពុទ្ធចក្រ



លោក **ជួន ជីវិន**
បេក្ខជនបណ្ឌិត ផ្នែកអក្សរសិល្ប៍
នៃរាជបណ្ឌិត្យសភាកម្ពុជា

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវអត្ថបទដែលមានក្នុងឯកសារមហាបុរសខ្មែរ ធ្វើឱ្យយើងកាន់តែយល់ច្បាស់អំពីព្រឹត្តិការណ៍សង្គមអតីតកាល ដែលជាបទពិសោធន៍សម្រាប់គតិក្នុងកិច្ចអភិវឌ្ឍសង្គមនាពេលបច្ចុប្បន្ន។ ឯកសារមហាបុរសខ្មែរបានរួមវិភាគទានតាមរយៈទិដ្ឋភាពអក្សរសិល្ប៍ក្នុង នោះជាប្រភពនៃនិមិត្តកម្មប្រលោមលោក ប្រភពនៃនិមិត្តកម្មនាដ្យកថា ប្រភពនៃនិម្មិតកម្មអក្សរសិល្ប៍ពាក្យកាព្យ និង តាមរយៈខ្លឹមសារស្នាដៃ មានការអភិឌ្ឍវិស័យច្បាប់ ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ការទ្រទ្រង់សង្គម-វប្បធម៌ខ្មែរ ជាអាទិ៍ បដិវត្តន៍ប្រជាធិបតេយ្យ ប្រជាជនលើកកម្ពស់ការចូលរួមចំណែករបស់ស្ត្រីក្នុងសង្គមវិស័យទេសចរណ៍ និងដឹកនាំនយោបាយការទូត និង ការគ្រប់គ្រងរដ្ឋបាលសាធារណៈមាន អំពីងារសម្តេចចៅពញា ចៅពញា ពញា អំពីស្តេចត្រាញ់ អំពីសម្តេចចៅហ្វាទឡ្ហៈនិងសេនាបតី អំពីចៅហ្វាយស្រុក-ខេត្តនិងអំពីមន្ត្រីក្នុងព្រះបរមរាជវាំង។ ក្រៅពីការផ្តល់នូវវិភាគទានទ្រទ្រង់ផ្នែកអាណាចក្រ ឯកសារមហាបុរសខ្មែរបានផ្តល់ជាវិភាគផ្នែកពុទ្ធចក្រ ដូចជា៖

## ១- វិភាគទានក្នុងការកសាងវត្តអារាម

នៅក្នុងជំនឿ ព្រះរាជាខ្មែរចាប់ពីក្រោយសម័យអង្គរមកបានកសាងវត្តអារាមជាច្រើនក្នុងវិស័យព្រះពុទ្ធសាសនាសម្រាប់គោរពបូជា សម្រាប់ជាផលានិសង្សទៅជាតិខាងមុខផងនិងជាទីសក្ការៈដ៏ស័ក្តិសិទ្ធិសម្រាប់ការពារព្រះនគរផង។ នៅក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ទ្រង់តាំងរាជធានីនៅចតុម្មុខ ទ្រង់បានកសាងទីវត្តអារាម ដោយមានតម្កល់អ្នកតា និង បង់បត់ទុកជាទ្វារព្រះនគរ មានសាងរូបទសមុខ៤ និងព្រះឥសូរ ព្រះនារាយណ៍និងយាយទេពច្រើនព្រះអង្គ ទ្រង់ប្រតិស្ឋានទុកនៅភ្នំត្រៀល១ ភ្នំស្រង់១ ទុកជាទ្វារព្រះនគរបង្ការសឹកសង្គ្រាមសៀម លាវពីទិសខាងលិច ខាងជើងប្រតិស្ឋាន នៅវត្តស្លាកែត១ ព្រៃកអំពិល១ ព្រះវិហារសួគ៌១ ទុកជាទ្វារ ព្រះនគរ បង្ការសឹកសត្រូវខាងយួនចាមនៅទិសខាងត្បូងនិង ខាងកើត[៤៨]។

| ល.រ | ឈ្មោះវត្ត/បូជនីយដ្ឋាន | អ្នកកសាង | មូលហេតុ |
|---|---|---|---|
| ១ | ចាប់សាងវត្តភ្នំដូនពេញ | ព្រះបាទពញាយ៉ាត | |
| ២ | វត្តពាមផ្លុង | ព្រះបាទពញាយ៉ាត | |
| ៣ | វត្តភ្នំដូនពេញ | ព្រះនារាយណ៍រាជា | |
| ៤ | ព្រះចេតីយ៍ធំបញ្ចុះព្រះសារីរិកធាតុ | ព្រះនារាយណ៍រាជា | |
| ៥ | សាងព្រះចេតីយ៍នៅលើភ្នំ អាសន្នុកបញ្ចុះព្រះបរមសារីរិកធាតុ មកពីមហានគរ | ព្រះស្រីធម្មរាជា | |
| ៦ | ថ្វាយពលព្រះស្រីរតនត្រ័យ | ព្រះស្រីធម្មរាជា | |
| ៧ | សាងវត្តព្រះវិហារសសរ១០០ នៅព្រៃកឆ្លូងបញ្ចុះអាច័ន | ព្រះស្រីធម្មរាជា | |
| ៨ | ជីកស្រះនៅកៀនភ្នំព្រះរាជ្យទ្រព្យ | ព្រះស្រីធម្មរាជា | |
| ៩ | ចេតីយ៍លើភ្នំសន្ទុក | ព្រះស្រីសុគន្ធបទ | |
| ១០ | សាងប្រាសាទមួយតម្កល់ព្រះរូបក្លាយជាអ្នកតាសុគន្ធបទ ក្នុងកំផែងនគរបានជ័យ បានការ | ព្រះស្រីសុគន្ធបទ | |
| ១១ | វត្តម៉ែបាន ឬ វត្តព្រៃបាំង | ព្រះស្រីសុគន្ធបទ | ជាព្រះអារាមហ្លួងលាបំណន់ |
| ១២ | ដូរឈ្មោះវត្តស្តីធំ ទៅជាវត្តព្រះថ្នល់ | ព្រះស្រីសុគន្ធបទ | |
| ១៣ | សាងព្រះវិហារសីមាជាច្រើន | ព្រះស្តេចកន | |
| ១៤ | កើតដំបូកអ្នកតាឃ្លាំងមឿង | ព្រះស្តេចកន | មានជាមុំបី ដំបូកខាងជើងគឺ ដំបូកអ្នកម្ចាងខៀវ ហៅថាដំបូកកន្ទោងខៀវ ដំបូកខាងត្បូង គឺដំបូកពញាមឿង ហៅថាដំបូកឃ្លាំងមឿង ដំបូកខាងលិច គឺដំបូកកូន ពញាមឿងទាំងពីរ ហៅថា ដំបូកក្រវាញ និងកោះមួយនៅក្នុងស្ទឹង ខេត្តពោធិ៍សាត់ គឺកោះនាងពេញ ហៅថាកន្លែងដូនពេញ។ |
| ១៥ | សាងព្រះវិហារ ធ្វើអារាម ខាងជើងផ្សារបរិបូណ៌ | ព្រះចន្ទរាជា | |
| ១៦ | សាងវត្តព្រែកហ្លួង | ព្រះយសរាជា | ដេញស្តេចកនឆ្លងទន្លេសាប ជួបព្យុះចូលចតក្នុងបឹង |
| ១៧ | សាងវត្តប្រាសាទ ហៅវត្តខ្មៅ ចៅអធិ-ការ ព្រះអរិយញាណ សាគរអាប៉ា | ស្តេចកន | |

[៤៨] អេង សុត ឯកសារមហាបុរសខ្មែរ ភ្នំពេញ ឆ្នាំ១៩៨៥ ទំព័រ៣១២។

| | | | |
|---|---|---|---|
| | មានរបេ័ពល ៥០០នាក់ សម្រាប់វត្ត | | |
| ១៨ | សង់ព្រះអារាមខាងជើងបន្ទាយពិជ័យព្រៃនគរ ឈ្មោះវត្តគរ | អ្នកម្នាងផាលែង | |
| ១៩ | សាងព្រះអារាម ព្រះវិហារ ព្រះ ចេតីយ៍វត្តព្រះធាតុព្រះស្រី តាំង នាមចៅអធិការវត្ត ជាព្រះសិរី ធម្មធាតុ និងជីកអុងម៉ុង ព្រះមហោសថ ទទឹង១២ហត្ថ កម្ពស់១៥ហត្ថ ឆ្ងាយដល់ សមុទ្រ | សម្តេចចៅពញាអរជូន អង្គកែម | តម្កល់ព្រះបរមសារីរិ-កធាតុព្រះអរហន្ត |
| ២០ | វត្តគការនិងជីកស្រះ១ សព្វ ថ្ងៃហៅថា វត្តគការទួលតាហែង | សម្តេចចៅពញា ហែង | ស្តេចកន ដាក់ឈ្មោះ វត្តនេះថា វត្តគការ |
| ២១ | សាងវត្តភូមិរកាព្រះប្រាំ សាង ព្រះពុទ្ធរូបពីដើមរកាប្រាំ ជីក ស្រះ១ ទទឹង ២៥ព្យាម បណ្តោយ ៥០ព្យាម | ស្តេចកន | |
| ២២ | ព្រះចន្ទរាជា ប្រែឈ្មោះភ្នំទ្រៀលមកជាភ្នំចំពិតធ្វើអាស្រមតាំងរូបពញាដែក ហៅថា អ្នកតា ដំបងដែក | ព្រះចន្ទរាជា | |
| ២៣ | ព្រះចន្ទរាជា យកដើមឈើទាល និងថ្មដាប់លើដើម ពីភូមិឈើទាលប្រឌិបព្រះខេត្តសំរោងទងនិងខេត្តលង្វែក ថ្មធ្លាក់ជាព្រះបាទព្រះ ៨ព្រះបាទ ដើមឈើទាលធ្លាក់ធ្វើជាព្រះរូប ព្រះពុទ្ធ អង្គចតុទិសនិងព្រះបាទបែរ ចេញទៅចតុទិស កម្ពស់១៨ហត្ថ ព្រះបិដ្ឋិទល់គ្នា ប្រតិស្ឋានក្នុងព្រះ វិហារហ្លួង ហៅថា ព្រះអារាមត្រឡែងកែងនិងសាងទេព្រក្សឃ្លាំងមឿង | ព្រះចន្ទរាជា | |
| ២៤ | ព្រះចន្ទរាជា តាក់តែងព្រះ ចេតិយព្រះឧណ្ណាលោម ជាព្រះអារាមតាំងចៅអធិការ បញ្ចុះសីមារួចចាត់ឱ្យមាន របេ័ពលសម្រាប់វត្ត | ព្រះចន្ទរាជា | |
| ២៥ | ព្រះចន្ទរាជាសាងព្រះវិហារមួយ នៅក្បែរដើមពោធិ៍ ដែលសុគតយូរ ហើយរស់ឡើងវិញ សាងជាវត្ត បញ្ញត្តិឱ្យ ហៅថាវត្ត ពោធិ៍មានបុណ្យ នៅក្នុង ខេត្តពោធិ៍សាត់ តាំងព្រះចៅអធិការ ងារជាព្រះពោធិវង្ស | ព្រះចន្ទរាជា | |
| ២៦ | ព្រះចន្ទរាជាឱ្យសាងវត្តហ្លួង នៅក្នុងខេត្តក្រគរ ប្រគេនឈ្លើយ ៤០នាក់ជាពលសម្រាប់វត្ត | ព្រះចន្ទរាជា | |
| ២៧ | ព្រះចន្ទរាជា សាងវត្តហ្លួង នៅខេត្តក្រង ប្រគេនឈ្លើយ ៣០នាក់ ជាពលសម្រាប់វត្ត | ព្រះចន្ទរាជា | |
| ២៨ | ព្រះចន្ទរាជាសាងវត្តនៅខេត្ត រលាប្អៀរ ថ្វាយឈ្លើយសៀម ៥០នាក់ជាពលរក្សាព្រះវិហារ | ព្រះចន្ទរាជា | |
| ២៩ | ព្រះចន្ទរាជា គង់នៅជើងភ្នំព្រះរាជទ្រព្យ សាងព្រះពុទ្ធ សេយ្យាសន៍១ព្រះអង្គ សាងព្រះពុទ្ធរូបអង្គធំមួយព្រះអង្គ អំពីថ្មតម្កល់លើភ្នំព្រះរាជទ្រព្យ | ព្រះចន្ទរាជា | |
| ៣០ | ព្រះចន្ទរាជា ជីកស្រះមួយសាងព្រះអារាមមួយ ខាងកើតភ្នំ ព្រះរាជទ្រព្យ តាំងនាមហៅ វត្តបឋមកេ្តិ៍ ស្រះ បឋមកេ្តិ៍ | ព្រះចន្ទរាជា | |
| ៣១ | ព្រះចន្ទរាជា សាងប្រាសាទព្រះរាជមន្ទីរហៅថា ប្រាសាទគោកព្រះរាជមន្ទីរ នៅជើងភ្នំ ជ្រាវ ទីដែលព្រះ | ព្រះចន្ទរាជា | រំឭកជាព្រះកេ្តិ៍បឋមវង្ស |
| | បរមរាជា អង្គជ័យ អង្គសួស ប្រសូត្រ | | |
| ៣២ | វត្តព្រះឥន្ទទេព | សម្តេចព្រះអគ្គមហេសី ស្រីទេពធីតាមហាចក្រពត្តិ | ផែនដីព្រះបរមិន្ទរាជា សាងព្រះវិហារនៅទិសអាគ្នេយ៍ព្រះរាជវាំង តាម សុបិននិមិត្ត សម្តេចព្រះអម្រិន្ទ្រាធិរាជចង្អុលកន្លែងឱ្យសាង |
| ៣៣ | សាងព្រះវិហារមួយនៅទីព្រឹក្សព្រះជ្រៃ តាមពាក្យបំណន់របស់ សម្តេចព្រះ អគ្គមហេសី កាលទៅផ្ចាញ់សៀមនៅ មហានគរ បញ្ញត្តិឱ្យហៅឈ្មោះភ្នំ នោះថា ភ្នំព្រះទេពី ឯកោះដំរីឱ្យហៅថា កោះប្រជុំសំរិទ្ធជ័យ | ព្រះស្រីសុរិយោវង្ស | |
| ៣៤ | វត្តទេពប្រណម្យ | ព្រះបរមិន្ទរាជា | សាងព្រះវិហារមួយ នៅទីតម្កល់ធាតុ សម្តេចចៅហ្វាដុង ជំទាវទេវីនារី សោភ័ណដៃ ជាមាតា បិតាក្មេក |

## ២- វិភាគទានក្នុងការពង្រឹងព្រះពុទ្ធសាសនា

នៅក្នុងផែនដីស្តេចកន នៅពេលដែលព្រះចន្ទរាជាបានដណ្តើមបានទឹកដីមួយផ្នែកដោយជោគជ័យពីស្តេចកន ក៏បានតាំងទីរដ្ឋបាលនៅក្រុងបរិបូណ៌ ពេលនោះព្រះអង្គបានរៀបចំយន្តការគ្រប់គ្រងរដ្ឋបាល ផ្នែកអាណាចក្រនិងពុទ្ធ-ចក្រ។ ផ្នែកពុទ្ធចក្រ គឺបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសង្ឃដោយមានការតែងតាំង ដូចជា ចៅអធិការ *សួស* ជាទីសម្តេចព្រះសុគន្ធាធិបតី សីរីសោធសង្ឃនាយក ចៅអធិការ *ស្រី* ជាទី សម្តេច មង្គលទេពាចារ្យ ចៅអធិការ *សោម* ជាទីសម្តេចព្រះធម្មលិខិត ចៅអធិការ *លាស់* ជាទី សម្តេចព្រះពោធិវង្ស ចៅអធិការ *ទន់* ជាទី សម្តេចព្រះវនរ័ត ចៅអធិការ *សោម* ជាទី សម្តេចព្រះមហាព្រហ្មមុនី និងចៅអធិការ *ជ័យ* ជាទី សម្តេចព្រះមហាវិន័យធម្មជាដើម។

សម័យបច្ចុប្បន្ននេះ ផ្នែកពុទ្ធចក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្កើតរចនាសម្ព័ន្ធសង្ឃយ៉ាងរឹងមាំ ដោយយកតាមលំនាំតាមសម័យដើមជា៤ថ្នាក់គឺ ថ្នាក់ទី១ គណៈ សង្ឃវត្តមាន៣អង្គ[៤៩] ថ្នាក់ទី២ គណៈសង្ឃស្រុក មាន ៥ អង្គ[៥០] ថ្នាក់ទី៣ គណៈសង្ឃខេត្ត មាន៦អង្គ[៥១] និងថ្នាក់ទី

៤៩ ចៅអធិការ គ្រូសូត្រស្តាំ និងគ្រូសូត្រឆ្វេង។

៥០ អនុគណ វិន័យធរអនុគណ ធម្មធរអនុគណ សមុហ៍អនុគណ និងអនុលេខាធិការអនុគណ។

៥១ មេគណ បាឡាត់គណ វិន័យធរគណ ធម្មធរគណ សមុហ៍គណ និងលេខាធិការគណ។

៤ គណៈសង្ឃនាយក[៥២] មានច្រើនអង្គ។ ចំពោះព្រះរាជាគណៈ គឺចែកចេញជា២គឺ ព្រះរាជាគណៈក្នុងតំណែងនិងព្រះរាជា គណៈថ្នាក់កិត្តិយស។ ចំពោះព្រះរាជាគណៈក្នុងតំណែងមាន៤ថ្នាក់គឺ ឯក ទោ ត្រី និង ចត្វា ដោយមានឋានន្តរងារផ្សេងៗគ្នា ប្រកបដោយលក្ខណសម្បត្តិ៤យ៉ាងគឺ វិជ្ជាសម្បត្តិ សីលសម្បត្តិ មានវស្សាភិក្ខុពី២០ឆ្នាំឡើងទៅនិងមានឋានន្តរស័ក្តិទីឋានានុក្រមជាព្រះបាឡាត់ឬព្រះគ្រូ ដោយត្រូវបានស្នើ តែងតាំងតាមលំដាប់ថ្នាក់គឺ ពីថ្នាក់ចត្វាទៅថ្នាក់ត្រី ពីថ្នាក់ ត្រីទៅថ្នាក់ទោ ពីថ្នាក់ទោទៅថ្នាក់ឯក ហើយចំពោះព្រះរាជា គណៈកិត្តិយស ត្រូវបានតែងតាំងប្រគេនចំពោះព្រះថេរៈ ដែលមានគុណបំណាច់ចំពោះជាតិនិងសាសនា។ ចំណែក ឯមន្ត្រីសង្ឃខេត្តនិងស្រុកសុទ្ធតែមានឋានន្តរ គឺងារផ្សេងៗគ្នា ដូចជា ឋានន្តរមន្ត្រីសង្ឃទីមេគណខេត្តក្នុងនោះ រាជធានីភ្នំពេញ ព្រះរាជាគណៈមានងារស្រាប់ ខេត្តកំពង់ចាម ព្រះ នាគមុនី ខេត្តកណ្តាល ព្រះវិមលវេទី ខេត្តបាត់ដំបង ព្រះ សង្ឃកិច្ចកោសល ខេត្តបន្ទាយមានជ័យ ព្រះវិជ័យមុនី ខេត្ត សៀមរាប ព្រះសុមង្គលសីលាចារ្យ ខេត្តឧត្តរមានជ័យ ព្រះ ឧត្តរវាសី ខេត្តប៉ៃលិន ព្រះរតនបជោត្តោ ខេត្តតាកែវ ព្រះ មង្គលទិព្វ លោករង្សី ខេត្តកំពត ព្រះជលធីវាសី ខេត្តកែប ព្រះសមុទ្រវាសិសិរីធម្មា ខេត្តព្រៃវែង ព្រះមុនីកិត្តិវង្សា ខេត្ត ស្វាយរៀង ព្រះវង្សាបតីធម្មធារ ខេត្តកំពង់ស្ពឺ ព្រះមុនីសត្ថា ចារ្យកោសល ខេត្តកំពង់ឆ្នាំង ព្រះធម្មវង្សា ខេត្តពោធិ៍សាត់ ព្រះពោធិវង្សាវិមល ខេត្តកោះកុង ព្រះទីបវ័ក្ខសត្ថាចារ្យ ខេត្ត ព្រះសីហនុ ព្រះវិមលសាគរ ខេត្តកំពង់ធំ ព្រះសត្ថាបារមី ខេត្តព្រះវិហារ ព្រះសីមាវិជិត ខេត្តក្រចេះ ព្រះសុគន្ធសីល- សារ ខេត្តស្ទឹងត្រែង ព្រះធម្មកោសលហ្វ៉កខាំ ខេត្តរតនគីរី ព្រះរតនសោភិត ខេត្តមណ្ឌលគីរី ព្រះមណ្ឌលសោភ័ណ។

## ឯកសារយោង

១- ហ៊ុន សែន *បិទសន្និសីទលើកទី ២០ នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ាន* នៅសាលសន្និសីទចតុមុខ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០២។

២- ហ៊ុន សែន *បិទវេទិកាអប់រំជាតិ ស្តីពីការពិនិត្យឡើងវិញនូវកម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០២-២០០៦* នៅសណ្ឋាគារ អាំងទែ ក្រុងទីណាង់តាល់ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។

៣- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធម្មការនិងកិច្ចការសាសនា *បើកបវេសនកាលពុទ្ធិកសិក្សាឆ្នាំ២០០២-២០០៣* ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២។

៤- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីប្រចាំទីស្តីការគណៈរដ្ឋមន្ត្រី *អនុក្រឹត្យ ឆ្នាំ២០០១ ឆ្នាំ២០០២*។

៥- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល២ ឆ្នាំទី១៣ ឆ្នាំ១៩៤១។

៦- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល១ ឆ្នាំទី១៤ ឆ្នាំ១៩៤២។

៧- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល២ ឆ្នាំទី១៧ ឆ្នាំ១៩៤៥។

៨- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល១ ឆ្នាំទី១៨ ឆ្នាំ១៩៤៦។

៩- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល១ ឆ្នាំទី៣៣ ឆ្នាំ១៩៦១។

១០- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល១ ឆ្នាំទី៣៤ ឆ្នាំ១៩៦២។

១១- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល២ ឆ្នាំទី៣៥ ឆ្នាំ១៩៦៣។

១២- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល៣ ឆ្នាំទី៣៨ ឆ្នាំ១៩៦៦។

១៣- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ក្បាល១ ឆ្នាំទី៤៣ ឆ្នាំ១៩៧១។

១៤- ទស្សនាវដ្តីកម្ពុជសុរិយា ភ្នំពេញ ឆ្នាំទី៤៨ លេខ២ ឆ្នាំ១៩៩៤។

១៥- ទស្សនាវដ្តីរាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ លេខ១ ត្រីមាសទី១ ឆ្នាំ២០០២។

១៦- រាជបណ្ឌិត្យសភាកម្ពុជា សកម្មភាព និងសមិទ្ធផល ឆ្នាំ១៩៩៩-២០០០ ភ្នំពេញ ឆ្នាំ២០០២។

១៧- រាជបណ្ឌិត្យសភាកម្ពុជា សកម្មភាព និងសមិទ្ធផល ឆ្នាំ១៩៩៩-២០០៣ ភ្នំពេញ ឆ្នាំ២០០២។

១៨- ក្រសួងធម្មការ និងសាសនា បញ្ជីឈ្មោះវត្តអារាមក្នុងប្រទេសកម្ពុជា ភ្នំពេញ ឆ្នាំ២០០០។

[៥២] ព្រះសង្ឃនាយក ឬ ព្រះសង្ឃរាជ និង ព្រះរាជាគណៈឋានានុក្រមមួយចំនួនទៀត។

១៩- ក្រសួងសិក្សាធិការ ពង្សាវតារនៃប្រទេសកម្ពុជា ភ្នំពេញ ឆ្នាំ១៩៥២។
២០- ក្រសួងអប់រំ អក្សរសិល្ប៍ខ្មែរថ្នាក់ទី៩ ភ្នំពេញ ឆ្នាំ១៩៨៤។
២១- ក្រុមជុំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ១ ភ្នំពេញ ឆ្នាំ១៩៨៩។
២២- ក្រុមជុំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ២ ភ្នំពេញ ឆ្នាំ១៩៨៩។
២៣- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៣ ភ្នំពេញ ឆ្នាំ១៩៨៩។
២៤- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៤ ភ្នំពេញ ឆ្នាំ១៩៨៩។
២៥- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៥ ភ្នំពេញ ឆ្នាំ១៩៨៩។
២៦- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៦ ភ្នំពេញ ឆ្នាំ១៩៨៩។
២៧- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៧ ភ្នំពេញ ឆ្នាំ១៩៨៩។
២៨- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៨ ភ្នំពេញ ឆ្នាំ១៩៨៩។
២៩- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ប្រជុំរឿងព្រេងខ្មែរ ភាគ៩ ភ្នំពេញ ឆ្នាំ១៩៨៩។
៣០- អេង សុត ឯកសារមហាបុរសខ្មែរ ភ្នំពេញ ឆ្នាំ១៩៨៥។

# វិស័យឯកជននិងការងារ



លោក **សួង ម៉េងឡុង**
បេក្ខជនបណ្ឌិត វិទ្យាសាស្ត្រនយោបាយ
នៃរាជបណ្ឌិត្យសភាកម្ពុជា

រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគនិងកំណើនក្នុងប្រទេស។ តួនាទីរបស់រាជរដ្ឋាភិបាល គឺជំរុញការលើកទឹកចិត្ត ជួយបង្កលក្ខណៈ ជួយសម្របសម្រួលនិងជានិយ័តករ។ កម្រិតដ៏ធំនៃការវិនិយោគ គឺជាតម្រូវការចាំបាច់ដើម្បីថែរក្សានិងបង្កើនល្បឿនសន្ទុះនៃកំណើនសេដ្ឋកិច្ចដែលត្រូវផ្អែកលើមូលដ្ឋានច្រើន។ ផ្នែកឯកជនដែលមានកំណើនដ៏រឹងមាំ បំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ស្រូបយកអ្នកចូលរួមក្នុងកម្លាំងពលកម្មដែលចេះតែកើនឡើងនិងបង្កើតជំនាញផ្សេងៗជាច្រើន។ មុំទាំង៤នៃចតុកោណនេះគឺ (១)ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (មានវិស័យកាត់ដេរសម្លៀកបំពាក់និងទេសចរណ៍) (២)ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករ-និយោជិត (៣)ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និង(៤) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់មន្ត្រីបុគ្គលិក-កម្មករ។ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយចំណាយក្នុង ការធ្វើធុរកិច្ចបានពង្រីកលទ្ធភាពប្រើប្រាស់ទីផ្សារបានកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុក ហើយបានលើកកម្ពស់សុវត្ថិភាពតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដែលជំរុញឱ្យមានផងដែរនូវការបញ្ចូលគ្នារវាងសេដ្ឋ-កិច្ចទីប្រជុំជននិងសេដ្ឋកិច្ចជនបទ។ វឌ្ឍនភាពដែលធ្វើឱ្យកើតមានឡើងមកទល់ពេលនេះ ដើម្បីឈានទៅសម្រេចបានអាទិភាពទាំងនេះ បានចូលរួមចំណែកយ៉ាងធំធេងចំពោះការអភិវឌ្ឍថ្មីៗក្នុងវិស័យជាច្រើនផ្សេងទៀតនិងចំពោះការពង្រឹងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាជនជនបទជាពិសេសអ្នកក្រីក្រ។

ការវិនិយោគក្នុងវិស័យឯកជន បាននិងកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស ដែលអាចពិនិត្យឃើញនៅក្នុងសូចនាករម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុ ដោយតាមរយៈនេះបានបង្កើនការជឿជាក់និងភាពកក់ក្ដៅក្នុងចំណោមអ្នកវិនិ-យោគឯកជនជាតិនិងអន្តរជាតិនានាក្នុងសេដ្ឋកិច្ចកម្ពុជា។ ប្រការនេះ គឺជាភស្តុតាងដ៏ធំនៃជោគជ័យរបស់គោលនយោ-បាយ ដែលជួយជំរុញឱ្យមានលទ្ធផលវិជ្ជមាននិងដែលមានលក្ខណៈជឿនលឿនរបស់រាជរដ្ឋាភិបាលកម្ពុជា (ការធានាឱ្យមានសន្តិភាព ស្ថិរភាពគោលនយោបាយ ច្បាប់ និង សណ្ដាប់ធ្នាប់ ការគ្រប់គ្រងដោយច្បាប់ កំណើនម៉ាក្រូសេដ្ឋ-កិច្ចនិងគោលនយោបាយរូបិយវត្ថុនិងការបង្កើតនូវបរិយាកា-សអំណោយផលមួយសម្រាប់ការអភិវឌ្ឍវិស័យឯកជន។ រាជ- រដ្ឋាភិបាលកម្ពុជាបានជំរុញយុទ្ធសាស្ត្រកំណើនដែលនាំមុខដោយការនាំចេញនិងសម្រាប់គាំទ្រប្រជាជនក្រីក្រ ដោយផ្ដោតលើការធ្វើពិពិធកម្មនិងការពង្រីកឱ្យបានទូលំទូលាយនូវមូលដ្ឋានសេដ្ឋកិច្ច ហើយបានលើកទឹកចិត្តជួយសម្រួល និងផ្ដល់ការគាំទ្រដល់ការវិនិយោគរបស់វិស័យឯកជនក្នុងវិស័យអាទិភាពមួយចំនួន។

វេទិកាពិភាក្សារវាងផ្នែកឯកជននិងរាជរដ្ឋាភិបាលកម្ពុជា ហៅថាវេទិការាជរដ្ឋាភិបាល-វិស័យឯកជន ដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលប្រារព្ធធ្វើឡើងជាទៀងរាល់ ៦ ខែម្ដងនិងការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់និងគណៈកម្មាធិការផ្សេងៗទៀតបានផ្ដល់នូវយុត្តាធិការយ៉ាង

សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការដ៏មានអត្ថន័យនិងការយល់ដឹងគ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជានិង វិស័យឯកជន។ ក្រុមការងារមួយផ្សេងទៀត សម្រាប់ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងនិយោជិតនិងនិយោជកត្រូវបានរៀបចំឡើង។ ការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែនិងការពង្រឹង និង ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្មត្រូវបានបញ្ចូលក្នុងវិស័យអាទិភាពសម្រាប់ពិចារណាផងដែរ។

ដើម្បីកាត់បន្ថយនូវរបាំងក្នុងការស្វែងរកសេចក្តីអនុម័តនានាពីបណ្តាក្រសួងនិងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ រដ្ឋាភិបាលកម្ពុជាបានបង្កើតនូវយន្តការច្រកចេញ-ចូលតែមួយដែលអនុញ្ញាតឱ្យបណ្តាអ្នកវិនិយោគអាចទទួលបានការអនុម័តជាកញ្ចប់ក្នុងការស្នើសុំការវិនិយោគ។ គណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកគ្រប់គ្រងលើការអនុវត្តយន្តការច្រកចេញ-ចូលតែមួយនេះ។ ក្នុងស្មារតីកាត់បន្ថយពេលវេលាសម្រាប់ការអនុម័តលើការស្នើសុំការវិនិយោគនិងបង្កលក្ខណៈឱ្យកាន់តែងាយស្រួលថែមទៀតដល់អ្នកវិនិយោគ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់សិទ្ធិជូនអនុគណៈកម្មការ រាជធានី-ខេត្តពិនិត្យសម្រេចលើគម្រោងវិនិយោគនានា ដែលមានទុនវិនិយោគតិចជាង២លានដុល្លារអាម៉េរិក។

គណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង្កើតនូវយន្តការ "ការយកចិត្តទុកដាក់ចំពោះវិនិយោគិន" និង "ប្រព័ន្ធតាមដាននិងត្រួតពិនិត្យការវិនិយោគ" ដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់វិនិយោគិន និងដើម្បីតាមដានពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនានាដែលទទួលបានការអនុម័តរួចហើយ។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាជានានូវតម្លាភាព គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការផ្តល់នូវសេវាកម្មទាំងឡាយដល់វិនិយោគិន។ ទន្ទឹមនេះដែរ អាទិភាពចម្បងមួយរបស់រដ្ឋាភិបាល គឺបន្តធ្វើឱ្យមានប្រសិទ្ធភាពនិងធ្វើឱ្យប្រសើរឡើងក្នុងការផ្តល់សេវាកម្មដល់វិនិយោគិនតាមរយៈការពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រី ជាពិសេសមន្ត្រីថ្នាក់មធ្យមនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលបានចុះហត្ថលេខាទ្វេភាគី លើកិច្ចព្រមព្រៀងស្តីពីការជំរុញនិងការការពារការវិនិយោគចំនួន ២៤ និងកំពុងបន្តការចរចាជាបន្តបន្ទាប់ទៀត ជាមួយបណ្តាប្រទេសផ្សេងៗក្នុងក្របខ័ណ្ឌអាស៊ានអេប៉ិក សហរដ្ឋអាម៉េរិក អឺរ៉ុបនិងតំបន់មជ្ឈិមបូព៌ា ដើម្បីជំរុញការអភិវឌ្ឍវិស័យ ឯកជនឱ្យបានទូលំទូលាយជាងមុននិងកិច្ចព្រមព្រៀង ចំនួន១៧ ផ្សេងទៀត ជាមួយបណ្តាប្រទេសក្នុងតំបន់មជ្ឈិមបូព៌ា អាស៊ីខាងកើតនិងអឺរ៉ុប។

ក្រសួងពាណិជ្ជកម្មកំពុងបន្តធ្វើការងារ លើការធ្វើឱ្យមានប្រសិទ្ធភាពនូវដំណាក់កាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់ព័ត៌មានទីផ្សារ ការរៀបចំសហគមន៍ ផលិតផល ការអនុវត្តកម្មវិធីរោងចក្រល្អប្រសើរ ការសម្របសម្រួលនិងការជំរុញពាណិជ្ជកម្ម ហើយនិងការពង្រឹងឡើងវិញនូវច្បាប់កម្មសិទ្ធិបញ្ញាទាំងឡាយ។ ដូច្នេះ ដើម្បីសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ ក្រសួងពាណិជ្ជកម្មបានបង្កើតការិយាល័យ ចុះបញ្ជីពាណិជ្ជកម្មនៅតាមសាខា ថ្នាក់ខេត្ត ដូចជា សាខាខេត្តបាត់ដំបងជាដើមសម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្មដល់ខេត្តបាត់ដំបងផ្ទាល់ ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិននិងខេត្តបន្ទាយមានជ័យ។ ទន្ទឹមនេះក្រសួង ពាណិជ្ជកម្ម នៅមានផែនការក្នុងការបើកការិយាល័យចុះបញ្ជី ពាណិជ្ជកម្មបន្ថែមទៀត នៅក្នុងខេត្តមួយចំនួនទៀតដូចជា៖

- ក្នុងឆ្នាំ២០១០ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយនឹងត្រូវបង្កើតក្នុងសាខាខេត្តព្រះសីហនុសម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្ម ក្នុងខេត្តព្រះសីហនុផ្ទាល់ ខេត្តតាកែវ ខេត្តកំពតនិងខេត្តកោះកុង។
- ក្នុងឆ្នាំដដែលនេះដែរ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយនឹងត្រូវបង្កើតក្នុងសាខាខេត្តក្រចេះ សម្របសម្រួលដល់កិច្ចការពាណិជ្ជកម្មខេត្តក្រចេះផ្ទាល់ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរីនិងខេត្តរតនគីរី។
- នៅក្នុងឆ្នាំ២០១២ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយនឹងត្រូវបង្កើតក្នុងសាខាខេត្តសៀមរាបសម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្មដល់ខេត្តសៀមរាបផ្ទាល់និងឧត្តរមានជ័យ។
- ដោយឡែកសម្រាប់ឆ្នាំ២០១៣ ក្រសួងពាណិជ្ជកម្មនឹងរៀបចំប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្តល់ការងាយស្រួលក្នុងការចុះបញ្ជីពាណិជ្ជកម្ម។

រហូតមកដល់ពេលបច្ចុប្បន្ន ក្រសួងពាណិជ្ជកម្មបានផ្តល់ព័ត៌មានទីផ្សារពាណិជ្ជកម្ម តាមរយៈព្រឹត្តិបត្រ និង

ទូរទស្សន៍តែប៉ុណ្ណោះ។ ដូច្នេះ ក្នុងឆ្នាំ២០០៨ ដើម្បីជំរុញការលើកកម្ពស់ព័ត៌មានទីផ្សារពាណិជ្ជកម្ម ក្រសួងបានរៀបចំប្រព័ន្ធទំនាក់ទំនងទីផ្សារអេឡិចត្រូនិក ដែលនឹងសង្ឃឹមថា អាចផ្តល់នូវព័ត៌មានលឿននិងប្រសើរជាងមុន។ គ្រប់ព័ត៌មានដែលមានក្នុងប្រព័ន្ធទំនាក់ទំនងទីផ្សារអេឡិចត្រូនិក អាចទទួលបានតាមរយៈការប្រើប្រាស់ទូរសព្ទចល័តដូចជា ព័ត៌មានអំពីតម្លៃកសិផល ផលិតផលម្ហូបអាហារ អត្រាប្តូរ-ប្រាក់និងតម្រូវការផ្សេងៗរបស់ទីផ្សារ។

ក្រសួងពាណិជ្ជកម្មក៏បានផ្តល់ជំនួយផងដែរ ក្នុងការរៀបចំសមាគមអាជីវកម្ម ដើម្បីលើកកម្ពស់សមត្ថភាពផលិត-កម្មនិងដើម្បីធ្វើសមាហរណកម្មផលិតផលទំនិញចូលទៅក្នុងទីផ្សារក្នុងស្រុក ទីផ្សារផលិតផល ពិសេស ទីផ្សារពិភព-លោក។ ជាក់ស្តែង រវាងឆ្នាំ២០០៧-២០០៩ ក្រសួងបានជួយរៀបចំសមាគមអាជីវកម្ម ក្នុងនោះមានសមាគមអភិវឌ្ឍន៍សម្រេចសមាគមអភិវឌ្ឍន៍ស្ករត្នោត សមាគមអភិវឌ្ឍន៍កសិកម្មតំបន់ពាយព្យនិងសមាគមអភិវឌ្ឍន៍ប្រហុកអប់នៅកំពង់ឃ្លាំង។ បច្ចុប្បន្ននេះ ក្រសួងកំពុងជួយរៀបចំសមាគមអាជីវកម្មស្វាយចន្ទី នៅខេត្តកំពង់ចាមនិងខេត្តកំពង់ធំថែមទៀតផង។ ដូច្នេះការរៀបចំសមាគមអាជីវកម្ម អាចជួយប្រែក្លាយពីការធ្វើពាណិជ្ជកម្មគ្រួសារឱ្យទៅជាការធ្វើពាណិជ្ជកម្មដោយមានយុទ្ធសាស្ត្រសម្រាប់ទីផ្សារដែលមានចីរភាព និងមានសមត្ថភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារពិភពលោក។

ដើម្បីសម្រួលដល់ការជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មបានអនុវត្តយ៉ាងសកម្មនូវអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដែលត្រូវបានអនុម័តក្នុងខែមីនា ឆ្នាំ២០០៦និងអនុវត្តមូលនិធិបើកច្រកទីផ្សារនាំចេញ ដែលគាំទ្រដោយធនាគារពិភពលោក។ ដោយឡែកក្រសួងបានរៀបចំ "ពិពណ៌ពាណិជ្ជកម្ម"និងបានរៀបចំកិច្ចប្រជុំជំនួញពាណិជ្ជកម្មជាច្រើនលើកច្រើនសាជា-មួយដៃគូបរទេស ដើម្បីជំរុញឱ្យអាជីវកម្មក្នុងស្រុក ដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន ក្នុងន័យរកដំណោះស្រាយនៃការរាំងស្ទះផលិតផលនិងសម្រួលដល់លំហូរទំនិញទៅកាន់ទីផ្សារបរទេស។

ដើម្បីពង្រឹងវិស័យឯកជនសម្រាប់ការអភិវឌ្ឍពាណិជ្ជ-កម្មសេដ្ឋកិច្ចនិងការជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក ក្រសួងពាណិជ្ជកម្មបានរៀបចំបង្កើតសភាពាណិជ្ជកម្មខេត្តបានចំនួន១១ ចាប់ពីឆ្នាំ២០០៦ដល់ឆ្នាំ២០០៧ ដែលមានទីតាំងនៅក្នុងខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ បន្ទាយ-មានជ័យ កណ្តាល តាកែវ កំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ និងកំពង់ចាម។ នៅឆ្នាំ២០០៨ សភាពាណិជ្ជកម្មកម្ពុជាមានតួនាទីធ្វើជាតំណាងវិស័យឯកជនកម្ពុជាក្នុងការចរចាអំពីការធ្វើពាណិជ្ជកម្មនិងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា។ ដោយឡែកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលបានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៩៥មក កំពុងមានតួនាទីដ៏ខំខាន់ ជួយដល់ការបណ្តុះបណ្តាល និង ការជួយជ្រោមជ្រែងដល់សភាពាណិជ្ជកម្មខេត្តផ្សេងៗទៀត ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ។

ក្រសួងពាណិជ្ជកម្មក៏បានខិតខំផងដែរ ក្នុងការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីទប់ស្កាត់ការផលិតការនាំចូលនិងការចែកចាយផលិតផលក្លែងក្លាយ។ មន្ត្រីកាំកុងត្រូលបានត្រួតពិនិត្យជាប្រចាំតាមច្រកចេញ-ចូល ដើម្បីទប់ស្កាត់ឱ្យបានទាន់ពេលវេលារាល់ចរាចរណ៍ទិញ-លក់ទំនិញខូចគុណភាពដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកប្រើប្រាស់។

ដើម្បីរក្សាការប្រកួតប្រជែងវិស័យកាត់ដេរសម្លៀកបំពាក់ក្នុងទីផ្សារអន្តរជាតិ ក្រសួងពាណិជ្ជកម្មដោយមានកិច្ចសហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជា-ជីវៈបាននិងកំពុងអនុវត្តកម្មវិធី "រោងចក្រល្អប្រសើរជាងមុន" ដើម្បីជានាលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរជាងមុនស្របតាមស្តង់ដាអន្តរជាតិក៏ដូចជាផ្តល់ការអប់រំបណ្តុះ- បណ្តាលកម្មករនិងសហជីព អំពីច្បាប់ស្តីការងារ ដោយផ្សារភ្ជាប់នឹងលក្ខខណ្ឌពាណិជ្ជកម្ម ហើយលើកទឹកចិត្តឱ្យមានការកែច្នៃម៉ូត ដើម្បីជំរុញការផលិតទំនិញកែច្នៃនៅប្រទេសកម្ពុជា។

ដើម្បីជំរុញការធ្វើសមាហរណកម្មក្នុងតំបន់ក្នុងឆ្នាំ២០០៨ គណៈកម្មការគ្រប់គ្រងផ្សារគំរូព្រំដែនកម្ពុជា-វៀត-ណាម បានរៀបចំអភិវឌ្ឍន៍ប្លង់មេដើម្បីសាងសង់ផ្សារតាមព្រំដែនកម្ពុជា-វៀតណាមនៅមេមត់និងរៀបចំចុះកិច្ច ព្រមព្រៀងអនុគ្រោះពន្ធគយ លើការនាំចេញផលិតផលក-សិផលរបស់កម្ពុជាទៅលើទីផ្សារវៀតណាម។ ក្រសួងពាណិជ្ជកម្មបានកត់សម្គាល់នូវបញ្ហាប្រឈមមួយចំនួនលើការនាំចេញ

កសិផលរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។ បញ្ហាទាំងនោះមានដូចជា៖

- ទំនិញភាគច្រើនមិនអាចឆ្លើយតបបានតាមស្តង់ដារបស់អ្នកបញ្ជាទិញ ដោយហេតុថា ម៉ាស៊ីនកែច្នៃ ជាពិសេស ម៉ាស៊ីនកិនអង្ករភាគច្រើនជាម៉ាស៊ីនចាស់ៗមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ នាពេលបច្ចុប្បន្ន មានម៉ាស៊ីនកែច្នៃអង្ករតាមស្តង់ដាចំនួន២ប៉ុណ្ណោះ ដែលមានសមត្ថភាពអាចកែច្នៃបានពី១២ ០០០តោនទៅ១៥ ០០០តោនក្នុងមួយឆ្នាំ។
- ថ្លៃដើមរបស់ទំនិញខ្ពស់ ដោយបណ្តាលមកពីការចំណាយផ្លូវការនិងក្រៅផ្លូវការខ្ពស់ មានតម្លៃដឹកជញ្ជូនខ្ពស់ ដែលមកពីតម្លៃខ្ពស់របស់ប្រេងនិងថាមពលនិងការចំណាយក្រៅផ្លូវការជាច្រើនដំណាក់។

ច្បាប់ពាណិជ្ជកម្មដូចដែលមានរៀបរាប់ខាងក្រោមត្រូវបានបង្កើតឡើងនិងកំពុងត្រូវបានអនុវត្តដោយក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបាននូវទំនុកចិត្តពីអ្នកវិនិយោគនិងសហគមន៍ពាណិជ្ជកម្ម៖

- ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។
- ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវា។
- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាមនិងអំពើប្រកួតប្រជែងមិនស្មោះត្រង់។
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។
- ច្បាស់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។
- ច្បាប់ស្តីពីក្ស័យធន។

ការវិនិយោគវិស័យឯកជនដែលមានប្រភពមកពីបរទេសនិងក្នុងស្រុក បានក្លាយទៅជាយានដ៏សំខាន់មួយនៃនិរន្តរភាព អត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ច ដែលសម្រេចបាននាចុងទសវត្សរ៍នេះ។ វិស័យសេដ្ឋកិច្ចដែលភាគច្រើនទទួលបានមកពីការវិនិយោគឯកជនទាំងអស់នេះមាន៖ វិស័យទេសចរណ៍ វិស័យកាត់ដេរ វិស័យសំណង់ និង ការរុករកប្រេងឧស្ម័ននិងធនធានរ៉ែ នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ម៉្យាងវិញទៀត វិបត្តិហិរញ្ញវត្ថុសាកលលោកនិងការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបានចាប់ផ្តើមឡើងនៅចុងឆ្នាំ២០០៧ បានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ មិនត្រឹមតែលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសប៉ុណ្ណោះទេ ថែមទាំងការវិនិយោគវិស័យឯកជនក្នុងស្រុកផងដែរ។ រាជរដ្ឋាភិបាលកំពុងអនុវត្តកញ្ចប់ជំរុញសារពើពន្ធមួយ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចពិតក៏ដូចជាការចាត់វិធានការ ដើម្បីជួយសម្រាលដល់ផលប៉ះពាល់អវិជ្ជមាននៃវិបត្តិទាំងឡាយនេះ មកលើប្រជាជនក្រីក្រនិងជនងាយរងគ្រោះ។ រាជរដ្ឋាភិបាលកម្ពុជាបន្តបង្កើតនូវបរិយាកាសមួយដែលជួយជំរុញនិងលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុកនិងការវិនិយោគបរទេសនៅក្នុងគ្រប់ វិស័យអាទិភាពដើម្បីពង្រីកនិងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច។ ការរំលេចឡើងនូវការងារនិងបញ្ហាប្រឈមទាំងឡាយដែលបានកើតមាននៅក្នុងវិស័យអាទិភាពនានា ដែលបានទាក់ទាញការវិនិយោគក្នុងស្រុកនិងបរទេសក្នុងពេលប៉ុន្មានឆ្នាំថ្មីៗ នេះត្រូវបានសង្ខេបដូចខាងក្រោម។

**វិស័យទេសចរណ៍៖** ទេសចរណ៍គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចនិងសង្គមកិច្ច ការបង្កើតឱកាសការងារនិងប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជាពិសេស រួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។ ទេសចរណ៍នៅកម្ពុជាជាទេសចរណ៍ "វប្បធម៌ និងធម្មជាតិ" ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍ ការថែរក្សាការពារនិងការអភិរក្សសម្បត្តិវប្បធម៌-ប្រវត្តិសាស្ត្រនិងធនធានធម្មជាតិក៏ដូចជាការប្រើប្រាស់សក្តានុពលនៃធនធានទាំងនេះប្រកបដោយនិរន្តរភាព។ សមិទ្ធផលសំខាន់ៗមួយចំនួនដែលបានគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍រួមមាន៖

- គោលនយោបាយបើកចំហជើងមេឃរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលនិងជំរុញលើកទឹកចិត្តភ្ញៀវទេសចរឱ្យធ្វើដំណើរតាមផ្លូវអា-

កាសបានជួយជំរុញឱ្យមានការកែលម្អអាកាសយាន-ដ្ឋានឱ្យកាន់តែមានភាពប្រសើរឡើង ហើយបច្ចុប្បន្ននេះអាកាសយានដ្ឋានខេត្តព្រះសីហនុ ត្រូវបានដាក់ឱ្យដំណើរការហោះហើរ។ ក្នុងឆ្នាំ២០០៩ ក្រុមហ៊ុនអាកាសចរណ៍ជាតិមួយត្រូវបានបង្កើតឡើង ហើយបានចាប់ផ្តើមដំណើរការជើងហោះហើររបស់ខ្លួនរវាងទីក្រុងភ្នំពេញនិងខេត្តសៀមរាប។

- ការផ្តល់ទិដ្ឋាការត្រូវបានបង្កឱ្យមានលក្ខណៈងាយស្រួលនៅគ្រប់ច្រកទ្វារអន្តរជាតិទាំងអស់។ ទិដ្ឋាការត្រូវបានផ្តល់ជូនភ្ញៀវទេសចរនៅពេលមកដល់ ជាពិសេស ទិដ្ឋាការអេឡិចត្រូនិកក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ដែរ។ នៅក្នុងក្របខ័ណ្ឌអាស៊ាន រាជរដ្ឋា-ភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយប្រទេសសិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ និងប្រទេសវៀត-ណាម ក្នុងការលើកលែងទិដ្ឋាការចំពោះប្រជាពល-រដ្ឋកម្ពុជានិងប្រជាពលរដ្ឋប្រទេសទាំង៥នេះ។ ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវាឌី-ចាប្រាយ៉ា-មេគង្គ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខា សម្រាប់ការប្រើប្រាស់ទិដ្ឋា-ការទោលសម្រាប់ពលរដ្ឋនៃប្រទេសទី៣ ដែលធ្វើដំណើរមកប្រទេសកម្ពុជានិងទៅប្រទេសថៃ។ បញ្ជរព័ត៌មានទេសចរណ៍ត្រូវបានរៀបចំបង្កើតឡើងនៅរាជធានីនិងខេត្តចំនួន១៣ ជាពិសេសខេត្តដែលមានច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីផ្តល់ព័ត៌មានជូនភ្ញៀវទេសចរ ក៏ដូចជាកាផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍នៅកម្ពុជា។ ក្រសួងទេសចរណ៍បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយរដ្ឋកូវ៉ែត ដើម្បីទាក់ទាញភ្ញៀវទេសចរនិងអ្នកវិនិយោគរបស់រដ្ឋកូវ៉ែត។
- សកម្មភាពប្រឆាំងនឹងទេសចរណ៍ផ្លូវភេទកុមារ កំពុងត្រូវបានតាមដានត្រួតពិនិត្យ ហើយវិធានការជាច្រើនកំពុងត្រូវបានអនុវត្តប្រឆាំងនឹងជនល្មើសដោយគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេស-ចរណ៍របស់ក្រសួងទេសចរណ៍ ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា។ បច្ចុប្បន្ននេះសម្ភារៈផ្សព្វផ្សាយអំពីទេសចរណ៍ជាច្រើនត្រូវបានផលិត វីដេអូខ្លីៗ កម្មវិធីអប់រំតាមវិទ្យុ រូបភាពបិទផ្សព្វផ្សាយ បណ្ណផ្ទត់ផ្ទាំងរូបភាពតូច-ធំ សារព័ត៌មាននិងទស្ស-នាវដ្តី ក្នុងគោលបំណងអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យទេស-ចរណ៍ និងជានាឱ្យមានសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។
- វិស័យទេចរណ៍នៅកម្ពុជាធ្លាប់មានកំណើនខ្ពស់លើសពី២០ភាគរយ នៅចន្លោះពីឆ្នាំ២០០០-២០០៧ និងមានការកើនឡើង ៥,៥ភាគរយនៅឆ្នាំ២០០៨។

ទោះជាយ៉ាងណាក៏ដោយ ក៏ការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ជួបបញ្ហាប្រឈមជាច្រើនដូចជា៖

- កញ្ចប់ទស្សនកិច្ចនៅកម្ពុជាមានថ្លៃខ្ពស់។
- ការប្រកួតប្រជែងក្នុងទីផ្សារសេវាទេសចរណ៍ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ (ឧ.សេវាស្នាក់នៅ មធ្យោបាយធ្វើដំណើរការឃោសនាផ្សព្វផ្សាយទេសចរណ៍ ជាដើម)។
- គុណភាពរបស់រមណីយដ្ឋាន សម្បទានិងសេវាកម្មទេសចរណ៍មួយចំនួន ពុំទាន់មានលក្ខណៈស្តង់ដាសមស្របតាមតម្រូវការនៅឡើយ ដែលទាមទារឱ្យមានការកែលម្អ។
- ការអភិវឌ្ឍទេសចរណ៍ ត្រូវបានផ្តោតការយកចិត្តទុកដាក់តែនៅតំបន់ទីប្រជុំជន ដែលជាហេតុធ្វើឱ្យប្រជាជនក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល ពុំបានទទួលផលប្រយោជន៍ពីការអភិវឌ្ឍនេះ។
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ជាពិសេស ផ្លូវថ្នល់ ការផ្គត់ផ្គង់ អគ្គិសនី ទឹកស្អាតនិងប្រព័ន្ធគ្រប់គ្រងកាក-សំណល់រឹងនិងរាវ) ដែលចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ពុំទាន់មានលក្ខណៈសមស្របនៅឡើយ ដែលទាមទារឱ្យមានការកែលម្អបន្ថែមទៀត។
- ចំណូលដែលទទួលបានពីវិស័យទេសចរណ៍ ពុំបានរួមចំណែកឱ្យបានខ្លាំងក្លាក្នុងការជំរុញឱ្យផលិតកម្មនិងការប្រើប្រាស់ផលិតផលក្នុងស្រុក ដោយហេតុ

ថា ចំណូលមួយភាគធំត្រូវបានចំណាយសម្រាប់ការនាំចូលទំនិញនិងសេវាកម្មពីបរទេស។

- ការអនុវត្តគម្រោងអភិវឌ្ឍវិស័យទេសចរណ៍របស់ក្រុមហ៊ុនវិនិយោគឯកជនមួយចំនួនដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា រួចហើយមានភាពយឺតយ៉ាវ ហើយគម្រោងមួយចំនួនទៀតគ្មានសកម្មភាព។
- កលិយុគហិរញ្ញវត្ថុនិងឱនភាពសេដ្ឋកិច្ចសកល វិបត្តិនយោបាយនៅប្រទេសថៃនិងការរីករាលដាលនៃជំងឺគ្រុនផ្តាសសាយថ្មីបានជះឥទ្ធិពលអវិជ្ជមានមកលើវិស័យទេសចរណ៍នៅកម្ពុជា។
- គុណភាពធនធានមនុស្ស ដែលបម្រើការងារនៅក្នុងវិស័យទេសចរណ៍ ទាំងផ្នែកឯកជននិងផ្នែកសេវាសាធារណៈនៅមានកម្រិតទាបនៅឡើយ។

ការអភិរក្សនិងការជំរុញលើកកម្ពស់នូវមរតកវប្បធម៌ខ្មែរដ៏រុងរឿងនិងទំនៀមទម្លាប់ប្រពៃណី គឺជាអាទិភាពខ្ពស់មួយរបស់រដ្ឋាភិបាល។ ប្រាសាទបុរាណ សារមន្ទីរនិងស្នាដៃដ៏ប៉ិនប្រសប់ផ្សេងៗទៀត មានការបង្ហាញពីរបាំប្រពៃណីខ្មែរ ចម្រៀងនិងគំនូរ បានរួមចំណែកនិងគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានរួម ចំណែកយ៉ាងសកម្មក្នុងការធានាឱ្យបាននូវការការពារតំបន់មរតកវប្បធម៌និងការជំរុញគ្រប់សកម្មភាពដែលគ្របដណ្តប់លើទិដ្ឋភាពខុសៗគ្នានៃវិចិត្រសិល្បៈ។

**វិស័យកាត់ដេរៈ** ជាកត្តាសំខាន់មួយដែលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចនិងភាពមានការងារធ្វើកំពុងបង្ហាញជាសញ្ញានៃការបាត់បង់ភាពប្រកួតប្រជែងរបស់ខ្លួនដោយសារតែប្រាក់ឈ្នួលកម្មករមានកម្រិតខ្ពស់(ត្រូវបានធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ ដោយសារវិបត្តិអតិផរណាក្នុងពេលកន្លងមកថ្មីៗនេះ)ធៀបជាមួយនឹងប្រាក់ឈ្នួលកម្មករក្នុងបណ្តាប្រទេសដែលផលិតផលិតផលដូចគ្នា ហើយថ្លៃដឹកជញ្ជូនខ្ពស់និងការកើនឡើងនៃភាពប្រកួតប្រជែង នៅខណៈពេលដែលតម្រូវការក្នុងទីផ្សារពិភពលោកកំពុងធ្លាក់ចុះ។ ម្យ៉ាងទៀតនៅមានកត្តាជាច្រើន ដែលមានឥទ្ធិពលទៅលើកំណើនជាបន្តទៀតក្នុងវិស័យនេះ ជាឧទាហរណ៍ ភាពមានកម្រិតក្នុងការចូលរួមនៃវិស័យដទៃទៀតទៅក្នុងការប្រែប្រួលអនុក្រមតម្លៃនៃវិស័យកាត់ដេរនិងការកើនឡើងនៃចំនួនសហជីពកម្មករក្នុងរោងចក្រ ដោយសារភាពមិនច្បាស់លាស់នៅក្នុងច្បាប់ស្តីពីការងារ។ ដើម្បីបន្ធូរបន្ថយដល់វិស័យនេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងពន្ធនិងបានចាប់ផ្តើមផ្តល់ប្រាក់ឧបត្ថម្ភធនបន្ថែមពីលើប្រាក់ខែរបស់កម្មករចំនួន៦ដុល្លារអាម៉េរិកក្នុងមួយខែ ចាប់ពីចុងខែមេសា ឆ្នាំ២០០៨មក។

វិស័យសំណង់ជាកត្តាសំខាន់មួយផ្សេងទៀត ដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច ក៏ត្រូវបានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោក ក៏ដូចជាការប្រែប្រួលខ្លាំងនៃតម្លៃសម្ភារៈសំណង់នាំចូលដែរ ដូចជា ស៊ីម៉ងត៍និងដែកជាដើម។ ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនិងឥទ្ធិពលនៃវិបត្តិទាំងនេះ ក៏ដូចជាដើម្បីទាក់ទាញការវិនិយោគលើទីផ្សារសំណង់ រដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញរៀបចំសេចក្តីព្រាងច្បាប់ថ្មី មានច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងពង្រឹងការរៀបចំច្រកចេញចូលតែមួយលើការងារផ្តល់សេវាសុំការអនុញ្ញាតសាងសង់។

ការរុករកប្រេង ឧស្ម័ន និង រ៉ែ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការរុករកប្រេងកាត ឧស្ម័នធម្មជាតិនិងរ៉ែ បានទាក់ទាញចំណាប់អារម្មណ៍អ្នកវិនិយោគបរទេសជាច្រើន។ បច្ចុប្បន្នការងាររុករកប្រេងនិងឧស្ម័នបម្រុងមានដំណើរការវិវត្តបានយ៉ាងល្អ ហើយការងារនេះក៏ត្រូវបានរំពឹងទុកថានឹងឈានទៅដល់ដំណាក់កាលនៃការផលិតមួយ ដែលនឹងបង្កើតជាចំណូលថ្មីសម្រាប់រដ្ឋនាពេលអនាគត។ ការស្វែងរុករករ៉ែដែក មាស បុកស៊ីត ត្បូងថ្ម ត្បូងថ្មមានតម្លៃ។ល។ ដែលនឹងអាចក្លាយជាសក្តានុពលរ៉ែដ៏សំខាន់មួយសម្រាប់អភិវឌ្ឍប្រទេសជាតិ កំពុងតែដំណើរការនៅតាមតំបន់សម្បទានរ៉ែនានា នៅតាមបណ្តាខេត្តដែលស្ថិតនៅក្នុងភាគឧត្តរនិងភាគឦសាន។ ទន្ទឹមនឹងនេះ ការធ្វើអាជីវកម្មរ៉ែថ្មកំបោរសម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើម ក្នុងការផលិតស៊ីម៉ងត៍នៅកម្ពុជាកំពុងតែដំណើរការ និង បានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយការនាំចូលផលិតផលស៊ីម៉ងត៍ពីក្រៅប្រទេស។ បទប្បញ្ញត្តិនិងនីតិវិធីនានាត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាឱ្យមាន

ចីរភាពបរិស្ថានការកែច្នៃនៅក្នុងស្រុកដែលបង្កើតឡើងនូវតម្លៃបន្ថែមនិងការបង្កើនជាអតិបរមានូវចំណូលរដ្ឋ។ រដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញយ៉ាងសកម្មលើការវិនិយោគវិស័យឯកជនសម្រាប់ការពង្រីកនិងការធ្វើពិពិធកម្មនៃកម្មន្តសាលនិងផលិតកម្មឧស្សាហកម្ម ដើម្បីទាញយកប្រយោជន៍ពីធនធានធម្ម-ជាតិក្នុងប្រទេស។ ឧស្សាហកម្មដែលផ្អែកលើធនធានធម្មជាតិជាមូលដ្ឋាន ជាពិសេសឧស្សាហកម្មដែលប្រើប្រាស់វត្ថុធាតុដើមពីរ៉ែអលោហៈ ត្រូវបានពង្រីកនិងអភិវឌ្ឍដើម្បីផលិតមុខទំនិញឧស្សាហកម្មថ្មីៗ ហើយឧស្សាហកម្មដែលមានប្រភពធនធានពីកសិកម្មគឺជាឧស្សាហកម្មដែលមានសក្តា-នុពលខ្ពស់ក្នុងការអភិវឌ្ឍ ដោយជំនួសវិស័យឧស្សាហកម្មផ្សេងទៀតដែលងាយទទួលរងផលប៉ះពាល់។

# វិវាទ កម្ពុជា-ថៃ ក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រ



លោក **យង់ ពៅ**
បេក្ខជនបណ្ឌិត វិទ្យាសាស្ត្រនយោបាយ
នៃរាជបណ្ឌិត្យសភាកម្ពុជា

**ក្រោយរដ្ឋប្រហារយោធាទម្លាក់**លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ នាយករដ្ឋមន្ត្រីថៃចេញពីតំណែងកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦ ទំនាក់ទំនងកម្ពុជា-ថៃ ជួបនូវបញ្ហាប្រឈមកាន់តែខ្លាំង។ ជាក់ស្តែង ក្នុងដំណើរការនៃការចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ចាប់ពីឆ្នាំ២០០៧មក ប្រទេសថៃតែងតែរារាំងប្រឆាំងយ៉ាងដាច់អហង្ការជំទាស់មិនឱ្យកម្ពុជាសម្រេចកិច្ចការនេះទេ ដោយលើកហេតុផលថា បើប្រទេសកម្ពុជាដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកនោះនឹងធ្វើឱ្យល្អក់កករដល់ទំនាក់ទំនងរវាងប្រទេសទាំងពីរជាមិនខាន និង ធ្វើឱ្យខូចផលប្រយោជន៍ប្រទេសថៃ។ ដូច្នេះ ប្រទេសថៃត្រូវតែរ៉ាតាមផ្លូវទូត ហើយព្យាយាមពន្យល់ដល់សហគមន៍អន្តរជាតិថា ប្រទេសថៃព្យាយាមសហការជាមួយប្រទេសកម្ពុជាក្នុងការស្នើសុំចុះបញ្ជីប្រាសាទនេះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករួមគ្នា។ តែរដ្ឋាភិបាលកម្ពុជាបានប្រតិកម្មតបវិញថា ប្រាសាទព្រះវិហារជាកម្មសិទ្ធិស្របច្បាប់របស់កម្ពុជា ដែលជាសិទ្ធិសម្រេចរបស់កម្ពុជាតែមួយគត់ ក្នុងការដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក។ រាជរដ្ឋាភិបាលកម្ពុជានៅតែប្រកាន់គោលជំហរដាក់បញ្ចូលប្រាសាទនេះ ជាបេតិកភណ្ឌពិភពលោករហូតដល់បានសម្រេច បើទោះជារដ្ឋបាលរបស់ក្រុងបាងកកជំទាស់យ៉ាងណាក៏ដោយ។

ចាប់ផ្តើមពីបញ្ហាព្រះវិហារនេះ បានដុតរោលនូវរាល់ទំនាក់ទំនងផ្សេងៗទៀតរវាងកម្ពុជានិងថៃ។ តើទំនាក់ទំនងគ្រោតគ្រាតទាំងនេះ កើតចេញពីបញ្ហាព្រះវិហារឬពីបញ្ហាផ្ទៃក្នុងថៃខ្លួនឯង?

ប្រធានបទស្តីពី ***វិវាទកម្ពុជា-ថៃ*** នឹងបានជាពន្លឺមួយដើម្បីស្រាយនូវចម្ងល់របស់មហាជនទូទៅទៅលើអភិក្រមសន្តិភាពនៅក្នុងតំបន់។ ម្យ៉ាងទៀត នាកាលៈទេសៈនេះ ប្រទេសនីមួយៗដែលស្ថិតនៅក្នុងតំបន់ជាមួយគ្នា ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការគ្នាឱ្យបានល្អ ដើម្បីធានាបាននូវឧត្តមភាពនៃភូមិសាស្ត្រនយោបាយរបស់ខ្លួន។ នាយករដ្ឋមន្ត្រីកម្ពុជាបច្ចុប្បន្នតែងលើកឡើងថា «ទំនាក់ទំនងកម្ពុជា-ថៃប្រៀបដូចអណ្តាតនិងធ្មេញ ដែលត្រូវការគ្នាជាចាំបាច់»។ ផ្ទុយទៅវិញ ប្រទេសទាំងពីរនេះនៅតែមានបញ្ហាប្រឈមគ្នានៅឡើយ។

លទ្ធផលនៃស្នាដៃសិក្សាស្រាវជ្រាវនេះនឹងផ្តល់នូវចំណេះដឹង បទពិសោធន៍សំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងមូលហេតុនាំឱ្យមានជម្លោះនិងយន្តការដោះស្រាយនានា ព្រមទាំងទស្សនៈផ្សេងៗដែលបានមកពីបញ្ញវន្តនិងអ្នកនយោបាយកម្ពុជា ថៃ និង ទស្សនៈអ្នកវិភាគនយោបាយពីបណ្តាប្រទេសផ្សេងៗ រួមនឹងទស្សនៈយល់ឃើញផ្ទាល់ខ្លួនក្នុងនាមស្មេរផងដែរ។ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះ យើងសាកល្បងពិនិត្យមើលបញ្ហាដែលបានកើតមានក្នុងអតីតកាលក្នុងសេចក្តីសង្ខេបដូចខាងក្រោម។

តាមការសិក្សាប្រវត្តិទំនាក់ទំនងកម្ពុជា-ថៃ បានបង្ហាញឱ្យឃើញថា ប្រទេសថៃតែងកេងចំណេញលើទំនាក់ទំនងទ្វេភាគី កម្ពុជា-ថៃ ជាដរាបរៀងមក ពោលគឺចាប់តាំងពីមុនសម័យអាណានិគមមកម្ល៉េះ។ ទង្វើនេះ បានបង្ហាញច្បាស់នៅពេលដែលប្រទេសកម្ពុជាចុះទន់ខ្សោយ ថៃឆ្លៀតឱកាសអនុវត្តនយោបាយពង្រីកទឹកដីរបស់ខ្លួន។ ដូចបានលើកឡើងខាងលើ ក្នុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ឆ្លៀតឱកាសដែលប្រទេសបារាំងចុះខ្សោយក្នុងសង្គ្រាមលោកលើកទី២ ប្រទេសថៃបានចុះហត្ថលេខាសម្ព័ន្ធភាពជាមួយនឹងជប៉ុន ហើយបានទាមទារទឹកដីដែលបាត់បង់ពីមុនទៅឱ្យខ្លួនកាន់កាប់វិញ។ សង្គ្រាមបារាំង-ថៃបានប្រព្រឹត្តទៅនៅចន្លោះខែតុលា ឆ្នាំ១៩៤០និងថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១។ ដោយមានអន្តរាគមន៍ពីជប៉ុន សង្គ្រាមត្រូវបានបញ្ចប់នៅក្នុងខែឧសភា ហើយទាហានថៃបានចូលមកក្នុងទឹកដីនៃប្រទេសកម្ពុជា។ នៅពេលនោះរដ្ឋាភិបាលយោធាថៃ

ដែលដឹកនាំដោយភិបុលសង្គ្រាមបានបដិសេធយ៉ាងដាច់ខាត ចំពោះទឹកដីភាគពាយព្យ ជារបស់ប្រទេសកម្ពុជា គឺចាត់ទុកទឹកដីនេះជារបស់ថៃ។

នៅចុងខែកញ្ញា ឆ្នាំ១៩៤០ ប្រទេសថៃដែលស្ថិតនៅក្រោមការជួយឧបត្ថម្ភពីជប៉ុន បានបង្កើតជម្លោះនៅតាមដង ទន្លេមេគង្គជាញឹកញាប់។ នៅថ្ងៃទី១២ វិច្ឆិកា ១៩៤០ រដ្ឋាភិបាលថៃចេញផ្សាយសៀវភៅមួយរៀបរាប់អំពីដែនដីថៃ ដែលស្ថិតនៅក្នុងកណ្ដាប់ដៃបារាំង ហើយក្នុងចំណោមដែនដីទាំងនោះមានប្រទេសកម្ពុជាទាំងមូល។ សៀវភៅនេះក៏បាននិយាយបញ្ចុះបញ្ចូលមតិសកលលោក ហើយថាជនជាតិខ្មែរនិងជនជាតិថៃ ជាសាសន៍តែមួយគឺ សាសន៍ថៃនេះឯង។ នៅខែមករា ឆ្នាំ១៩៤១ កងទ័ពអាកាសសៀមបានទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្លានៅតាមទីក្រុងនានា ដូចជា សេរីសោភ័ណ មង្គលបុរី ស្ទឹងត្រែង បាត់ដំបងនិងសៀមរាប បណ្ដាលឱ្យរងគ្រោះដល់ជនស៊ីវិលផងដែរ។ ការវាយប្រហារខាងផ្លូវអាកាសដ៏ខ្លាំងក្លានេះ មានការជួយទំនុកបម្រុងអាវុធយុទ្ធភណ្ឌពីសំណាក់ប្រទេសជប៉ុន ជាពិសេសយន្តហោះទម្លាក់គ្រាប់បែកនេះតែម្ដង។

ដោយមានការគាំទ្រពីសម្ព័ន្ធមិត្ត ជប៉ុនដាក់សម្ពាធលើអាណានិគមបារាំងទទួលយកកិច្ចការចរចាបារាំង-សៀម ដែលចាប់ដំណើរការនៅទីក្រុងតូក្យូប្រទេសជប៉ុនចាប់ពីថ្ងៃទី០៧ ខែកុម្ភៈតទៅ។ នៅក្នុងពេលនេះ ប្រទេសកម្ពុជាត្រូវបាត់បង់ទឹកដីអស់ ៦០ ០០០គ.ម.[២] ដែលក្នុងនោះមានៈ ទឹកដីខេត្តបាត់ដំបងទាំងមូល ខេត្តសៀមរាប (មួយភាគធំលើកលែងតែស្រុកពួក សូទ្រនិគម អង្គរ) ទឹកដីភាគខាងជើងនៃខេត្តកំពង់ធំ(ស្រុកជាំក្សាន្តនិងឆែប) និងខេត្តស្ទឹងត្រែងត្រើយខាងឆ្វេងទន្លេមេគង្គទាំងអស់។ ទឹកដីរបស់ខ្មែរទាំងឡាយដែលបានធ្លាក់ក្នុងការគ្រប់គ្រងរបស់ថៃ គេបានផ្លាស់ឈ្មោះសឹងគ្រប់ទីកន្លែងក្នុងបំណងបំភ្លៃប្រវត្តិសាស្ត្រ។

បញ្ហាទឹកដីនេះ បង្កើតទៅជាបញ្ហាស្មុគស្មាញមួយរវាងសៀមនិងមហាអំណាចអាណានិគម ជាពិសេសគឺ បារាំង ហេតុនេះហើយបានជាយើងឃើញមានសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងជាច្រើនដូចជា សន្ធិសញ្ញា បារាំង-សៀម ១៨៦៧ សន្ធិសញ្ញាបារាំង-សៀម ១៨៩៣ ១៩០៤ និង ១៩០៧ អនុសញ្ញាបារាំង-ថៃ ថ្ងៃទី៩ឧសភា ១៩៤១ និងកិច្ចព្រមព្រៀងបារាំង-សៀមថ្ងៃទី១៧ វិច្ឆិកា ១៩៤៦ ជាដើម។

ប្រទេសថៃបានបង្កើតឡើងនូវចលនាជាតិនិយមជាច្រើន ដើម្បីប្រឆាំងពួកអាណានិគម ហើយការប្រឆាំងនេះគេសង្ឃឹមថានឹងអាចទាមទារទឹកដីដែលគេបានអះអាងថាបាត់បង់នោះចូលទៅក្នុងដែនដីរបស់សៀមវិញ។

នៅក្នុងចន្លោះឆ្នាំ១៩៤៦ទៅ១៩៤៩ រដ្ឋាភិបាលថៃបានអនុញ្ញាតឱ្យខ្មែរកុម្មុយនីស្ត (ឥស្សរៈកុម្មុយនីស្ត) ក៏ដូចជាពួកខ្មែរឥស្សរៈសេរី (ស្ដាំនិយម) ទិញសព្វាវុធដោយឆ្លងកាត់ទឹកដីថៃ។ នេះមានន័យថា នយោបាយថៃ លើចលនាខ្មែរឥស្សរៈទាំងពីរ ដែលមាននិន្នាការនយោបាយខុសគ្នា ជំរុញឱ្យធ្វើចលនាបណ្ដេញអាណានិគមបារាំងចេញពីកម្ពុជា ដើម្បីផ្ដល់ឱកាសដល់ប្រទេសថៃបានតាំងខ្លួនជាអ្នកចាត់ចែងជោគវាសនាកម្ពុជាតទៅទៀត។ ចុងក្រោយ ពេលអាណានិគមបារាំងចាកចេញពីតំបន់នេះ ថៃនឹងមានឧត្តមភាពលើតំបន់នេះ។ ដោយប្រទេសថៃតែងយល់ឃើញ ដូចដែលបារាំងបានលើកឡើងដែរថា ប្រទេសកម្ពុជានឹងចុះខ្លាំងជាមិនខាននៅពេលដែលអាណានិគមបារាំងប្រគល់ឯករាជ្យមកឱ្យកម្ពុជានោះ។ ជាងនេះទៅទៀត ថៃយល់ថា មនោគមវិជ្ជានយោបាយនៃចលនានេះមិនមែនប្រឆាំងតែបារាំងទេ ប៉ុន្តែប្រឆាំងខ្មែរគ្នាឯងទៀតផង។ ប្រទេសថៃក៏អាចប្រើប្រាស់ពួកគេដើម្បីដណ្ដើមមកវិញនូវទឹកដីមួយចំនួនដែលថៃអះអាងថាបាត់បង់ដោយសារបារាំងនោះ។ ពាក់ព័ន្ធនឹងបញ្ហាជ្រៀតជ្រែករបស់ប្រទេសថៃសម័យកាលនេះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ថា «...ពីមុនស្ដេចខ្មែរបានពាក់មកុដចេញពីបាងកក ...»។ មានការកត់សម្គាល់ឃើញថា នៅឆ្នាំ១៩៤៩ បើទោះបីជាបារាំងប្រគល់ឯករាជ្យឱ្យខ្មែរមិនទាន់ពេញលេញ ក៏សហរដ្ឋអាម៉េរិកបានទទួលស្គាល់ឯករាជ្យខ្មែរក្នុងថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៥០ ដូចគ្នានឹងប្រទេសថៃបានប្រកាសទទួលស្គាល់ឯករាជ្យនៃប្រទេសកម្ពុជា ហើយបានមកដាក់ទូតនៅកម្ពុជា នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥០។

ក្នុងដំណើរស្វែងរកការគាំទ្រពីប្រទេសថៃ ដើម្បីទាមទារឯករាជ្យនេះ ព្រះមហាក្សត្រសម្ដេចព្រះនរោត្តម សីហនុ បានយាងទៅកាន់ទីក្រុងបាងកក ដោយនឹកសង្ឃឹមទទួលបានការគាំទ្រខ្លះពីអ្នកនយោបាយថៃក្នុងការប្រយុទ្ធតស៊ូរបស់ព្រះអង្គប្រឆាំងនឹងបារាំង និង វៀតណាម ប៉ុន្តែអត់បាន

ទទួលបានផលអ្វីនោះទេ។ លើសពីនោះទៀត សម្តេចព្រះនរោត្តម សីហនុ ទទួលបាននូវភាសាគំរោះគំរើយថែមទៀតផង។

បើយើងពិនិត្យមើលបញ្ហាខាងលើនេះ ថៃមាននយោបាយស្របគ្នាជាមួយសហរដ្ឋអាម៉េរិក ប៉ុន្តែបើយើងមើលឱ្យស៊ីជម្រៅសហរដ្ឋអាម៉េរិកដាក់ទូតនៅកម្ពុជាក្នុងគោលបំណងប្រឆាំងរបបអាណានិគមចាស់ៗដូចជាបារាំងនិងអង់គ្លេសក៏ដូចជាការទប់ស្កាត់ការរីករាលលទ្ធិកុម្មុយនីស្តនៅក្នុងតំបន់ឥណ្ឌូចិនផងដែរ។ រីឯថៃប្រញាប់ប្រញាល់គាំទ្រដោយសារមានបំណងចង់ឱ្យបារាំងចេញពីកម្ពុជាឱ្យបានឆាប់រហ័ស ព្រោះបារាំងធ្លាប់ដេញថៃចេញពីតំបន់នេះតាំងពីឆ្នាំ១៨៦៧ ហើយគេនឹងមានប្រៀបឈ្នះលើប្រទេសកម្ពុជា ពីព្រោះកម្ពុជាមានកម្លាំងទ័ពនិងសេដ្ឋកិច្ចខ្សោយ។

ប្រទេសថៃបានរិះរកគ្រប់មធ្យោបាយ ដើម្បីយកចំណេញលើខ្សែបន្ទាត់ព្រំដែននៃប្រទេសកម្ពុជា ពីព្រោះថាការកំណត់ព្រំដែនឆ្នាំ១៩០៤-១៩០៧ តំបន់មួយចំនួនដែលជាព្រំប្រទល់កម្ពុជា-ថៃ ពុំទាន់បានបោះបង្គោលព្រំដែននៅឡើយ ជាពិសេសពីចំណុចមុំបី (ព្រំដែនកម្ពុជា-ឡាវ-ថៃ) រហូតដល់តំបន់អន្លង់វែងដែលក្នុងចន្លោះនោះមានប្រាសាទព្រះវិហារដែលនៅពេលនោះ ថៃមិនទាន់បានប្រគល់ឱ្យខ្មែរនៅឡើយ។ លើសពីនេះទៀត យើងអាចវាយតម្លៃបានថាប្រទេសថៃបានចិញ្ចឹមចិត្តក្នុងការបំពានបូរណភាពទឹកដីកម្ពុជាជាថ្មីក្នុងខណៈដែលឥទ្ធិពលអាណាគមបារាំងចុះខ្សោយនៅក្នុងតំបន់ឬក៏ការប្រគល់ឯករាជ្យដល់ប្រទេសកម្ពុជា។

ជារួម យើងឆ្លើយនឹងគន្លឹះបញ្ហានៅក្នុងចំណុចដែលចោទថា «ហេតុអ្វីប្រទេសថៃប្រញាប់ប្រញាល់ប្រកាសទទួលស្គាល់ឯករាជ្យនៃប្រទេសកម្ពុជា ហើយបានមកដាក់ទូតនៅកម្ពុជា នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥០ មុនអាណានិគមបារាំងប្រគល់ឱ្យទៅទៀត?» គឺថៃចង់ឃើញប្រទេសកម្ពុជាផុតពីដៃមហាអំណាច និង ធ្លាក់ចុះខ្សោយ។

ក្នុងរបបសាធារណរដ្ឋខ្មែរ ថ្វីត្បិតប្រទេសកម្ពុជាបានងាកទៅភ្ជាប់ទំនាក់ទំនងការទូតសហរដ្ឋអាម៉េរិក ដែលជាមហាអំណាចមានសម្ពន្ធភាពយុទ្ធសាស្ត្រជាមួយប្រទេសថៃ ក៏យើងសង្កេតឃើញថា ទំនាក់ទំនងកម្ពុជា-ថៃមិនអាចឈានទៅរកប្រក្រតីភាពបានដែរ។ ប្រទេសថៃបានមើលឃើញពីភាពមិនចុះសម្រុងផ្ទៃក្នុងនៃសាធារណរដ្ឋខ្មែរ នឹងមិនអាចធ្វើឱ្យប្រទេសនេះរឹងមាំបាន។ ជាងនេះទៅទៀត ថៃធ្លាប់បានជ្រោមជ្រែងចលនាខ្មែរឥស្សរៈ ក្នុងរូបភាពបណ្តេញកុម្មុយនីស្តនិងជួយជ្រោមជ្រែងបណ្តេញអាណានិគម ប៉ុន្តែការពិតក្នុងបំណងចិញ្ចឹមដង្កូវស៊ីរូងផ្ទៃក្នុងខ្មែរទៅវិញទេ។

នាទសវត្សរ៍ឆ្នាំ១៩៨០ នៅក្នុងក្របខ័ណ្ឌនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ប្រទេសថៃមិនត្រឹមតែមិនបានជួយពន្លត់ភ្លើងសង្គ្រាមផ្ទៃក្នុងប្រទេសកម្ពុជា ក្នុងនាមជាប្រទេសជិតខាងប៉ុណ្ណោះទេ ថៃមទាំងបានលោតចូលក្នុងឆាកនយោបាយចិនក្នុងការធ្វើសង្គ្រាមប្រឆាំងជាមួយកម្ពុជានិងឥណ្ឌូចិន ក្នុងខណៈពេលបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់នេះ ជាពិសេសឥណ្ឌូណេស៊ី បានចាត់ទុកចិនជាគ្រោះថ្នាក់ដល់អាស៊ាន។ ទាំងនេះមិនមែនជាកំហុស សម្រាប់តែជុំវិញបញ្ហាកម្ពុជាមួយមុខនោះទេ តែជាកំហុសយុទ្ធសាស្ត្រអភិក្រមសន្តិភាពស្ថិរភាពនៅអាស៊ីអាគ្នេយ៍ផងដែរ។ នៅពេលដែលថៃនិងចិនពិភាក្សាគ្នាអំពីការកសាងឃ្លាំងផ្ទុកអាវុធរបស់ចិននៅប្រទេសថៃ បណ្តាប្រទេសក្នុងសមាគមអាស៊ាន សុទ្ធតែមានការព្រួយបារម្ភក្នុងកម្រិតខុសគ្នា។ នៅក្នុងទសកាលនេះ យើងអាចមើលឃើញទៀតថា បើទោះជាប្រទេសថៃមិនពេញចិត្តនឹងសម្តេចព្រះនរោត្តម សីហនុ យ៉ាងខ្លាំងក្នុងបញ្ហាព្រះវិហារនិងខេត្តមួយចំនួនដែលថៃបង្ខំចិត្តប្រគល់ឱ្យកម្ពុជាក្រោយសង្គ្រាមលោកលើកទី២ តែប្រទេសថៃនៅគាំទ្រចំពោះសម្តេចនរោត្តម សីហនុ ប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញក្នុងបំណងចំណេញយុទ្ធភូមិសាស្ត្រនយោបាយរបស់ខ្លួននិងការកេងចំណេញផលប្រយោជន៍សេដ្ឋកិច្ចដែលប្រទេសនេះបានរកស៊ីជាមួយភាគីប្រឆាំងរដ្ឋាភិបាលភ្នំពេញនាពេលនោះ។ ជាយុទ្ធសាស្ត្ររបស់ថៃ ប្រទេសនេះពុំអនុញ្ញាតឱ្យសម្តេចព្រះនរោត្តម សីហនុ មានកម្លាំងគ្រប់គ្រាន់ដើម្បីត្រួតត្រាអំណាចឡើយ សម្តេចព្រះនរោត្តម សីហនុ បានទទួលស្គាល់ថា *«ប្រៀបធៀបបញ្ជីដែលចិនបានផ្តល់ជំនួយសម្រាប់កងទ័ពរបស់ខ្ញុំ (សម្តេចព្រះនរោត្តម សីហនុ) ខ្ញុំបានទទួលតែ១០%គត់ពីថៃ»* ព្រះអង្គបានបន្តទៀតថា *«ថៃមិនចង់ឱ្យសីហនុ ខ្លាំងទេ គេចង់ឱ្យខ្មែរក្រហមគ្របសង្កត់រដ្ឋាភិបាលចម្រុះថៃស្អប់សីហនុ ថៃមិនចង់បានសីហនុទេ»*។

បើយើងពិនិត្យមើលនៅក្នុងដំណាក់កាលចុងក្រោយនៃចលនាខ្មែរក្រហម ដើមទសវត្សរ៍ឆ្នាំ១៩៩០ បានបង្ហាញថា ភាពរឹងមាំ និង ចុះខ្សោយរហូតដល់ដួលរលំទាំង

ស្រុងរបស់ចលនាខ្មែរក្រហមនាដំណាក់កាលចុងក្រោយ នេះមានការជាប់ពាក់ព័ន្ធនឹងប្រទេសថៃដោយមិនអាចប្រកែក បាន។ ដង្ហើមសេដ្ឋកិច្ចរបស់ តាម៉ុក នៅអន្លង់វែងមានទំនាក់ទំនងជាមួយប្រទេសថៃតែមួយប៉ុណ្ណោះ។

ប្រទេសថៃតែងប្រកាន់គោលជំហរមិននៅកៀកនឹងនិន្នាការកុម្មុយនីស្ត ក៏ប៉ុន្តែយើងចោទសួរវិញថា ទំនាក់ទំនងជិតដិតជាមួយចលនាខ្មែរក្រហមស្ថិតនៅក្នុងគោលការណ៍ណាមួយ? អាចជាគោលការណ៍ផលប្រយោជន៍សេដ្ឋកិច្ចប្រទេសថៃមួយមុខឬអាចជាគោលការណ៍ផលប្រយោជន៍សេដ្ឋកិច្ចប្រទេសថៃ រួមនិងការកកូរកកាយផ្ទៃក្នុងកម្ពុជា។

ទឡ្ហីករណ៍បញ្ជាក់ហេតុផលនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន សម្តេច ហ៊ុន សែន បានលើកឡើងជារឿយៗ នៅកំលុងពេលសភាពការណ៍ព្រំដែនតានតឹងខ្លាំងក្នុងចន្លោះឆ្នាំ២០០៨ដល់ឆ្នាំ២០១១ ក្នុងសេចក្តីថា «ប្រទេសថៃតែងបានពាក់ព័ន្ធនឹងនយោបាយផ្ទៃក្នុងកម្ពុជានាទសវត្សរ៍ឆ្នាំ១៩៨០និង១៩៩០លើករណីខ្មែរក្រហមនេះ»។ លើសពី នោះទៀតនៅក្នុងដំណើរការចរចាស្វែងរកសន្តិភាពឆ្ពោះទៅ រកកិច្ចព្រមព្រៀងប៉ារីស៍ សម្តេច ហ៊ុន សែន បានលើកឡើងពីតួនាទីថៃ ក្នុងការបញ្ចុះបញ្ចូលត្រីភាគី ដើម្បីទទួលយកនូវ គំនិតស្តីពីការបង្កើតក្រុមប្រឹក្សាបង្រួបបង្រួមជាតិ ក៏ដូចជា ការបង្កកទំនាក់ទំនងរវាងថៃនិងខ្មែរក្រហម។

ជារួម ប្រវត្តិវិវាទកម្ពុជា-ថៃ មុនឆ្នាំ២០០៦ បានបង្កើតសញ្ញានូវភាពមិនប្រាដកប្រជានៅក្នុងទំនាក់ទំនងនយោបាយការទូតនៃប្រទេសទាំងពីរ។ នៅក្នុងដំណើរវិវត្តនយោបាយកម្ពុជាមុននិងក្រោយសម័យអាណាគម ប្រទេសកម្ពុជាទទួលរងនូវការរំលោភបំពានពីសំណាក់ប្រទេសថៃជាច្រើនករណីដែលធ្វើឱ្យមានវិវាទបន្តបន្ទាប់ ដូចមានក្នុងពេលបច្ចុប្បន្ននេះ។

## គន្ថនិទ្ទេស


១- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ *សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)*, ភ្នំពេញ, ១៩៨៩។

២- ក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, *សង្គ្រាមឥតប្រកាសមួយប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា*, ឆ្នាំ១៩៨៦។

៣- ជុំ ឈាង, *រឿងក្តីប្រាសាទព្រះវិហារ៖ សាលដីកាអញ្ញត្រកម្មបឋម ឆ្នាំ១៩៦១ និង សាលដីកា អង្គសេចក្តី ឆ្នាំ១៩៦២,* ភ្នំពេញ, ២០១១, ៤២៥ទំព័រ។

៤- ដេវិត វ៉ៃ្រត, *ប្រវត្តិសាស្ត្រថៃ,* ភ្នំពេញ, នគរវត្ត, ២០១១, ៤៤០ទំព័រ។

៥- ជៀប សុផល, *សង្គ្រាមនិងសន្តិភាពនៅកម្ពុជាកត្តាតំបន់និងកត្តាសកល ១៩៤៥-១៩៩១,* ភ្នំពេញ, ២០០៥។

៦- នួន ឃឿន, រដ្ឋប្រហារឆ្នាំ១៩៣២ ពីសៀមទៅថៃ ឡង្គ, ភ្នំពេញ, ឆ្នាំ១៩៧១(?)

៧- ទីស្តីការគណៈរដ្ឋមន្ត្រី, *រឿងក្តីប្រាសាទព្រះវិហារ (កម្ពុជាទល់នឹងថៃ)៖ អង្គសេចក្តី សាលដីកា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២,* ភ្នំពេញ, ឆ្នាំ២០១១។

៨- ប៉ែន នុត "ប្រវត្តិសង្ខេបអំពីទំនាក់ទំនងខ្មែរ-សៀម" ភ្នំពេញ ការផ្សាយរបស់បណ្ណាល័យអប្សរា គ.ស.១៩៩៧។

៩- មជ្ឈមណ្ឌលខេមរសិក្សា៖ *សិក្សាតំបន់អាស៊ី-អាគ្នេយ៍,* ភ្នំពេញ, ២០០៧។

១០- វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា៖ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ភាគ១,* ភ្នំពេញ, ២០១០, ២៨៩ទំព័រ។

១១- វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា៖ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ភាគ២,* ភ្នំពេញ, ២០១០, ៣៤៥ទំព័រ។

១២- វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា៖ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ភាគ៣,* ភ្នំពេញ, ២០១០, ៣១២ទំព័រ។

១៣- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា, *ទំនាស់ព្រំដែនប្រទេសថៃ និង ប្រទេសជិតខាង,* ភ្នំពេញ, ២០១០, ២៨២ទំព័រ។

១៤- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា, *វេទិកាបណ្ឌិតសភាចំហ ស្តីពី «ខួបអនុស្សាវរីយ៍លើកទី១៥ឆ្នាំ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៅកម្ពុជា»* ភ្នំពេញ, ២០០៧, ៤៤០ទំព័រ។

១៥- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា, *ទស្សនាវដ្តីវិទ្យាសាស្ត្រ លេខ២,* ភ្នំពេញ, ២០០៩។

១៦- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា, *ទស្សនាវដ្តីវិទ្យាសាស្ត្រ លេខ១,* ភ្នំពេញ, ២០០៨។

១៧- ហ្សង់ ហ្រ្វង់ស្វ័រតាន់, *ភូមិសាស្ត្រនយោបាយចិន,* បោះពុម្ពលើកទី២, ភ្នំពេញ, ២០១១។

១៨- សុខ ទូច, *តួនាទីអង្គការសហប្រជាជាតិ,* ភ្នំពេញ, សមាគមអ្នកវិទ្យាសាស្ត្រ, ឆ្នាំ២០០៣, ២០១ទំព័រ។

១៩- ហ៊ុន សែន, *១០ឆ្នាំនៃដំណើរកម្ពុជា១៩៧៩-១៩៨៩,* ភ្នំពេញ, ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ឆ្នាំ២០១១, ៣៨៦ទំព័រ។

២០-អេលីហ្សាបែក បេ៊កឃ័រ (Elizabeth Becker), *នៅពេលដែលសង្គ្រាមលេត់ទៅ (When the War Over),* ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៥, ៧១២ទំព័រ។

២២- Charles Meyer, ក្រោយស្នាមញញឹមរបស់ខ្មែរ, បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ Derrière le Sourire Khmer), ឆ្នាំ ?

២៣- Marie A. Martin, *ជំងឺកម្ពុជា,* បកប្រែជាភាសាខ្មែរ ដោយ ទីឃាយុ, (ចំណងជើងដើម៖ Le Mal Cambodgien: Histoire d'une société traditionnelle face à ses leaders politiques 1946-1987), ឆ្នាំ១៩៩៤។

២៤- Nicolus Regaud, *កម្ពុជាក្នុងព្យុះសង្ឃរា,* បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ *La Cambodge dans La tourmente : Le troisième conflict indochinois 1978-1991*), ឆ្នាំ ?

២៥- Norodom Sihanouk, *អ្នកទោសខ្មែរក្រហម,* បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ Norodom Sihanouk: Prisonnier des Khmers Rouges), ឆ្នាំ ?

២៦- Philippe Richer, កម្ពុជា៖ សោកនាដកម្មមួយនៃសម័យយើង, បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ Le Cambodge: une tragésie de notre temps), ឆ្នាំ២០០០។

២៧- Richard Sola, កម្ពុជារបស់សម្តេចសីហនុ សេចក្តីសង្ឃឹម ការភ្ញាក់ខ្លួននិងការតូចចិត្ត, បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ Le Cambodge, Espoir, Désillusions et Amertume), ប៉ារីស៍, ១៩៩១។

២៨- Ros Chantrabot, *សាធារណៈរដ្ឋខ្មែរ,* បកប្រែជាភាសាខ្មែរដោយ ទីឃាយុ, (ចំណងជើងដើម៖ La République Khmère), ឆ្នាំ ? ១៧៩ទំព័រ។

# ផលប៉ះពាល់នៃនយោបាយអព្យាក្រឹតរបស់ព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៧០



លោក **សុខ ស៊ីណា**
បេក្ខជនបណ្ឌិត ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

**សេចក្តីផ្តើម**

ប្រទេសកម្ពុជាបានទទួលឯករាជ្យរបស់ខ្លួនពីរបបអាណាព្យាបាលបារាំងនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ បន្ទាប់ពីទទួលឯករាជ្យនោះមក ថ្នាក់ដឹកនាំកម្ពុជាបានរៀបចំប្រទេសជាតិឱ្យមានសន្តិសុខ សន្តិភាព សុវត្ថិភាពសង្គមនិងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានការរីកចម្រើន។ កត្តាមួយដែលសំខាន់ផងដែរនោះគឺ ការកំណត់នូវមូលដ្ឋានគ្រឹះនៃនយោបាយការបរទេសរបស់កម្ពុជា។ នៅពេលនោះ ពិភពលោកបាន ទទួលរងនូវឥទ្ធិពលនៃមនោគមវិជ្ជាធំៗពីរ គឺប្លុកលោកសេរី ដែលមានសហរដ្ឋអាម៉េរិកជាតំណាងនិងប្លុកសង្គមនិយម មានសហភាពសូវៀតជាតំណាង។ ក្នុងបរិបទនោះប្រទេស ស្ទើរតែទាំងអស់នៅក្នុងសកលលោកសឹងតែមិនអាចគេចផុត ពីឥទ្ធិពលមនោគមវិជ្ជាទាំងពីរខាងលើនេះ ជាពិសេស ប្រទេស ដែលធ្លាប់ស្ថិតនៅក្រោមមហាអំណាចអាណានិគម។

ដោយមើលឃើញនូវការមិនចុះសម្រុងគ្នានៃមហាអំណាចសេរីនិងសង្គមនិយមបែបនេះទើប កម្ពុជាបានកំណត់យកទិសដៅនៃនយោបាយការបរទេសរបស់ខ្លួន គឺការប្រកាន់យកនយោបាយអព្យាក្រឹត។ ការប្រកាន់យកនយោបាយការបរទេសបែបនេះ គឺក្នុងគោលបំណងចង់បាននូវឯករាជ្យ សន្តិភាព ស្ថិរភាពសង្គម អធិបតេយ្យជាតិ ហើយចង់ឱ្យមានការគោរពនិងទទួលស្គាល់បូរណភាពទឹកដីកម្ពុជាពីសំណាក់បរទេស។ ដូច្នេះការប្រកាន់យកនយោបាយអព្យាក្រឹតនៅពេលនោះ តើកម្ពុជាបានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមរបស់ខ្លួន?

**១-នយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជា**

កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៦ ក្នុងសន្និសីទមួយនៅខេត្តកំពត សម្តេចព្រះនរោត្តម សីហនុ បានគូសបញ្ជាក់ពីជំហរនៃការប្រកាន់យកនយោបាយអព្យាក្រឹតនេះថា "ចូរអ្នកកុំភ្លេចការណ៍នេះឱ្យសោះ គឺថានយោបាយអព្យាក្រឹតនេះជានយោបាយដែលប្រជាជាតិទាំងមូលបានត្រាយទុកឱ្យខ្ញុំ ជាពិសេស គឺសមាជជាតិលើកទី២នេះហើយដែលបានតម្រូវឱ្យខ្ញុំកាន់អាកប្បកិរិយាមួយនិងជាដាច់ខាតរវាងបក្សខាងលិចនិងបក្សកុម្មុយនីស្តគឺជាអាកប្បកិរិយាមិត្តភាពមួយជាមួយបក្សទាំងពីរនេះ ដែលយើងតោងតែទទួលជំនួយទាំងអស់ណាដែលមិនធ្វើឱ្យសាបរលាបដល់អធិបតេយ្យរបស់យើង និង អព្យាក្រឹតរបស់យើង"[៥៣]។

ហេតុនេះ ទើបនៅឆ្នាំ១៩៥៧ គេបានចេញព្រះរាជក្រមលេខ ២៣២ន.ស. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ស្តីពីនយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជា ហើយក្នុងមាត្រាទី១ នៃច្បាប់នេះបានចែងថា ព្រះរាជាណាចក្រកម្ពុជាជាប្រទេសអព្យាក្រឹត។ តាមខ្លឹមសារនៃច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះរាជាណាចក្រកម្ពុជាពុំត្រូវការចងសម្ពន្ធមិត្តយោធា ឬ ខាងផ្លូវគំនិតជាមួយនឹងបរទេសទេ ព្រះរាជាណាចក្រកម្ពុជា ពុំបង្កសង្គ្រាមប្រឆាំងនឹងបរទេសណាមួយឡើយ។ នៅក្នុងមាត្រាទី២ បានបញ្ជាក់បន្ថែមទៀតថា ក្នុងករណីដែលបរទេសណាមួយមកបង្កសង្គ្រាមប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជាៗមានសិទ្ធិនឹងការពារខ្លួនដោយអាវុធ អំពាវនាវដល់អង្គការសហប្រជាជាតិ និង ប្រទេសមហាអំណាចណាដែលជាមិត្ត[៥៤]។

**ក- ទំនាក់ទំនងរវាងកម្ពុជា និង សហរដ្ឋអាម៉េរិក**

ក្រោយសង្គ្រាមលោកលើកទី២ សហរដ្ឋអាម៉េរិកបានក្លាយទៅជាមហាអំណាចតែមួយគត់នៅក្នុងប្លុកលោកសេរី។ សហរដ្ឋអាម៉េរិកបានខិតខំបញ្ចេញនូវសកម្មភាព ផ្នែក

---

[៥៣] វិភាគទានបទសន្និសីទនយោបាយរបស់សម្តេចព្រះនរោត្តម សីហនុ នៅកំពត ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៦ ទំព័រ៣-៤។

[៥៤] រាជកិច្ច លេខ២៤ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៧ ទំព័រ ៦៣៣៨។

នយោបាយនិងសេដ្ឋកិច្ចទៅលើប្រទេសនានា នៅភូមិភាគអាស៊ីអាគ្នេយ៍ដោយគេអះអាងថា ជាការចាំបាច់ទប់ស្កាត់ការរាតត្បាតរបស់ចលនាកុម្មុយនីស្ត។ ចំណែកឯចលនាតស៊ូទាមទារឯករាជ្យរបស់បណ្ដាប្រជាជាតិនៅឥណ្ឌូចិនប្រឆាំងនឹងប្រទេសបារាំងក៏កាន់តែមានសភាពខ្លាំងឡើងៗ។ សហរដ្ឋអាម៉េរិកបានមើលឃើញនូវការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ជាពិសេសនៅឥណ្ឌូចិនគឺ ជាការគំរាមកំហែងចំពោះសន្តិសុខរបស់ខ្លួន នោះទើបសហរដ្ឋអាម៉េរិកបានចាប់ផ្ដើមរៀបចំនូវយុទ្ធសាស្ត្រដើម្បីទប់ទល់នឹងការរីករាលដាលនេះ។

### ក១- កម្ពុជាទទួលយកជំនួយសហរដ្ឋអាម៉េរិក

កម្ពុជាបានចាប់ផ្ដើមធ្វើទំនាក់ទំនងជាមួយនឹងសហរដ្ឋអាម៉េរិក តាមរយៈជំនួយសេដ្ឋកិច្ចមកឱ្យកម្ពុជានៅឆ្នាំ១៩៥០ គឺជាពេលមួយដែលប្រទេសកម្ពុជានៅមិនទាន់ទទួលបានឯករាជ្យនៅឡើយ។ នៅឆ្នាំ១៩៥១ កិច្ចព្រមព្រៀងផ្ដល់ជំនួយរបស់សហរដ្ឋអាម៉េរិកត្រូវបានធ្វើឡើង។ ដើម្បីឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងនោះសម្ដេចព្រះនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យលេខ ២០ន.ស. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៥១ ដោយបានបង្កើតគណៈកម្មការចាត់ចែងជំនួយសហរដ្ឋអាម៉េរិក[៥៥]។

ពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៥ រហូតមកដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៥៩ សហរដ្ឋអាម៉េរិកបានផ្ដល់ជំនួយជាទឹកប្រាក់សរុបចំនួន៨ ៧៤៩ ០០០ ០០០រៀល ត្រូវនឹង ២៤៩ ៩០០ ០០០ដុល្លារ នេះជាជំនួយសម្រាប់វិស័យសេដ្ឋកិច្ច និង យោធា[៥៦]។

គួរបញ្ជាក់ថា រដ្ឋាភិបាលសហរដ្ឋអាម៉េរិកបានផ្ដល់ជំនួយនេះដោយផ្ដោតទៅលើវិស័យពីរសំខាន់ គឺវិស័យសេដ្ឋកិច្ចដែលជាការចូលរួមចំណែកមួយយ៉ាងសំខាន់សម្រាប់ជួយអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដែលទើបតែនឹងទទួលបានឯករាជ្យពីប្រទេសបារាំង ហើយវិស័យសំខាន់ មួយទៀតគឺផ្នែកយោធា។ ការជួយដល់ផ្នែកនេះជាវិភាគទានមួយដើម្បីពង្រឹងកងយោពលខេមរភូមិន្ទទាំងផ្នែកសម្ភារៈនិងបៀវត្សរ៍ដែលជាទិសដៅមួយយ៉ាងសំខាន់ក្នុងការធ្វើឱ្យកងទ័ពកម្ពុជាមានសមត្ថភាព មធ្យោបាយនិងលទ្ធភាពគ្រប់គ្រាន់ដើម្បីការពារឯករាជ្យ អធិបតេយ្យនិងបូរណភាពទឹកដីរបស់ខ្លួន។

ជំនួយរបស់សហរដ្ឋអាម៉េរិកដែលបានផ្ដល់មកឱ្យកម្ពុជាបានបែងចែកទៅតាមផ្នែកផ្សេងៗគិត ជាភាគរយចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦០ គឺចំណាយលើការងារសាធារណៈ៤៧.២% វិស័យកសិកម្ម១៧.៥% វិស័យអប់រំ១៣. ៨% សុខភាពសាធារណៈ៨.៧% ផ្នែកនគរបាលស៊ីវិល៤.៥% ផ្នែកសហគ្រាស៣.៥% មធ្យោបាយនៃការធ្វើទំនាក់ ទំនង ២.២% ផ្នែករដ្ឋបាលសាធារណៈ០.៩%និងចំណាយផ្សេងៗ ១.៧ %។

ក្រៅពីនេះសហរដ្ឋអាម៉េរិកបានផ្ដល់ជំនួយដែលមិនមាននៅក្នុងគម្រោងគឺមានចំនួនទឹកប្រាក់សរុប ១៥៨ ២៩៩ដុល្លារ[៥៧]។

### ខ- ទំនាក់ទំនងកម្ពុជា និង សហភាពសូវៀត

គួររំឭកថាកាលពីថ្ងៃទី០២ ដល់ទី០៨ ខែកក្កដា ឆ្នាំ១៩៥៦ សម្ដេចព្រះនរោត្តម សីហនុ បានយាងទៅធ្វើ ព្រះរាជទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត។ នាឱកាសនោះ លោកនាយករដ្ឋមន្ត្រីសហភាពសូវៀត ប៊ុល ហ្គានីន បានថ្លែងគូសបញ្ជាក់អំពីជំហររបស់សូវៀត ក្នុងការគោរពចំពោះគោលការណ៍បញ្ចសីលា និង នយោបាយអព្យាក្រឹតមិនចូលបក្សសម្ព័ន្ធរបស់ប្រទេសកម្ពុជា។ ទន្ទឹមនឹងនោះ លោក គ្លីម៉ង់-វ៉ូរ៉ូជីឡូហ្វ ប្រធានសភាជាន់ខ្ពស់សហភាពសូវៀត បានថ្លែងបញ្ជាក់ថា ឫសគល់មិត្តភាពយ៉ាងមាំរវាងប្រជាជាតិយើង ទាំងពីរដែលបានចាប់បដិសន្ធិមកហើយនោះមិនមែនមានសារប្រយោជន៍ចំពោះតែប្រទេសជាមិត្តទាំងពីរនេះប៉ុណ្ណោះទេ គឺមិត្តភាពនេះអាចបម្រើនូវប្រយោជន៍ទូទៅ ក្នុងការពង្រឹងសន្តិភាពសកលលោកទាំងមូល។ ក្រោយរយៈពេលពីរខែបន្ទាប់ពីការយាងទៅធ្វើទស្សនកិច្ចជាផ្លូវការរបស់សម្ដេចព្រះនរោត្តម សីហនុ នៅសហភាពសូវៀត ប្រទេសកម្ពុជាបានបង្កើតឯកអគ្គរាជទូតរបស់ខ្លួនប្រចាំនៅសហភាពសូវៀតនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៥៦[៥៨]។

[៥៥] រាជកិច្ចលេខ១ ចេញផ្សាយថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៥១ ទំព័រ ២៨-៣២។

[៥៦] *Le Programme de l'aide économique américaine au Cambodge 1955-1959,* Phnom Penh, Cambodge, août 1960, p. 9.

[៥៧] *Ibid.*, p. 21.

[៥៨] រាជកិច្ចលេខ ២៤ ចេញផ្សាយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥៦ ទំព័រ ៥៨៧៣-៥៨៧៥។

បន្ទាប់ពីមានសេចក្តីថ្លែងការណ៍រួមរវាងកម្ពុជា និង សហភាពសូវៀតចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៥៦ នាឱកាសនៃព្រះរាជទស្សនកិច្ចជាផ្លូវការរបស់សម្តេចព្រះនរោត្តម សីហនុ មកសហភាពសូវៀតបានយល់ព្រមជួយស្ថាបនាមន្ទីរពេទ្យមួយនៅទីក្រុងភ្នំពេញ។ មន្ទីរពេទ្យនេះមានគ្រែចំនួន៥០០ ព្រមទាំងកន្លែងពិនិត្យមួយដែលអាចពិនិត្យអ្នកជំងឺបានចំនួន ៥០០នាក់ក្នុងមួយថ្ងៃ។ មន្ទីរពេទ្យនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៦០ ដោយដាក់ឈ្មោះថា "មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត"[៥៩]។ បន្ទាប់មកទៀតបានស្ថាបនាវិទ្យាស្ថានបច្ចេកវិជ្ជាជាន់ខ្ពស់ (សាលាតិចណូ) ដើម្បីបណ្តុះបណ្តាលបច្ចេកទេសដល់និស្សិតកម្ពុជា។ ក្រៅពីនេះ សហភាពសូវៀតបានផ្តល់ជំនួយជាសម្ភារៈយោធាមួយចំនួនទៀត។

**គ-ទំនាក់ទំនងកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន**

ប្រវត្តិសាស្ត្របានបង្ហាញឱ្យយើងដឹងអំពីប្រវត្តិនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ កម្ពុជា និង ចិន ដែលមានតាំងពីយូរលង់ណាស់មកហើយ។ នៅក្នុងប្រវត្តិទំនាក់-ទំនងរវាងកម្ពុជា-ចិន សរុបមានចំនួន១០លើក។ លើកទី១០ នោះគឺទំនាក់ទំនងកម្ពុជា និង ចិនក្នុងរជ្ជកាលព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ឆ្នាំ១៩៥៥[៦០]។

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៥៦ សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គក៏បានយាងទៅធ្វើព្រះរាជទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន។ ព្រះរាជដំណើរទស្សនកិច្ចជាលើកដំបូងនាខែកុម្ភៈ ឆ្នាំ១៩៥៦ ទៅកាន់សាធារណរដ្ឋប្រជាមានិតចិននោះ កម្ពុជានិងចិនបានធ្វើសេចក្តីថ្លែងការណ៍រួមដោយ គ្រាន់តែរៀបចំឱ្យមានមូល-ដ្ឋាននៃកិច្ចសហប្រតិបត្តិការជាមិត្តភាពតែប៉ុណ្ណោះ។ មាន-ន័យថា រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិននឹងយល់ព្រមផ្តល់នូវជំនួយសេដ្ឋកិច្ចដោយឥតលក្ខខណ្ឌមកឱ្យប្រទេសកម្ពុជា។

ផ្តើមចេញពីនេះ ប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួនពីរគឺ កិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្មចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៦ និងកិច្ចព្រមព្រៀង ស្តីពីជំនួយសេដ្ឋកិច្ចដែលបានចុះហត្ថលេខានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៥៦[៦១]។ យោងតាមកិច្ចព្រមព្រៀងឆ្នាំ១៩៥៦ សាធា-រណរដ្ឋប្រជាមានិតចិននឹងផ្តល់ជំនួយសេដ្ឋកិច្ចមកឱ្យប្រទេសកម្ពុជាដោយគិតពីឆ្នាំ១៩៥៦-១៩៦៧ ដែលមានចំនួនទឹកប្រាក់មិនលើសពី៨០០លានរៀល។ នៅពេលនោះ នយោ-បាយផ្ទៃក្នុងរបស់កម្ពុជាបានបង្កឱ្យមានឧបសគ្គខ្លះៗទាក់-ទិននឹងបញ្ហាជំនួយនេះ គឺមានការប្រឆាំងជំទាស់ពីពួកស្តាំនិយមនិងការគាបសង្កត់ពីសំណាក់សហរដ្ឋអាម៉េរិក។ ប៉ុន្តែគណៈបេសកកម្មសេដ្ឋកិច្ចខ្មែរប្រចាំនៅទីក្រុងប៉េកាំងត្រូវបានរដ្ឋាភិបាលកម្ពុជាបញ្ជូនទៅតាមការគ្រោងទុក។ សម្តេចព្រះនរោត្តម សីហនុ បានមានព្រះរាជបន្ទូល នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៥៦ ថា "ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងជម្រាបថា ពិតមែនតែយើងមានឧបសគ្គច្រើនតែខ្ញុំបានបញ្ជូនបេសក-កម្មខាងសេដ្ឋកិច្ចខ្មែរតាមផ្លូវការមួយទៅប៉េកាំង។ លោក ជូ អេនឡាយ បានមានប្រសាសន៍ថា លោកមានសេចក្តីជឿជាក់ថា ប្រទេសចិននិងប្រទេសកម្ពុជានឹងអាចជួយគ្នាទៅវិញទៅមក[៦២]។

នាឱកាសព្រះរាជទស្សនកិច្ចនៅសាធារណរដ្ឋប្រជា-មានិតចិនឆ្នាំ១៩៥៦ សម្តេចព្រះនរោត្តម សីហនុ បានថ្លែងសុន្ទរកថា "ដោយព្រះអង្គបញ្ជាក់ថា ពិតមែនតែលទ្ធិរបស់ចិននិងលទ្ធិរបស់ខ្មែរមិនដូចគ្នា តែនយោបាយនិងឧត្តមគតិរបស់រដ្ឋាភិបាលចិន និង រដ្ឋាភិបាលខ្មែរដូចគ្នា"[៦៣]។

ការយាងទៅធ្វើព្រះរាជទស្សនកិច្ចរបស់សម្តេចព្រះនរោត្តម សីហនុ នៅសាធារណរដ្ឋប្រជាមានិតចិននាំឆ្នាំ១៩៥៦ បានស្ថាបនាមូលដ្ឋានឧស្សាហកម្មមួយនៅក្នុងប្រទេសកម្ពុជាក្រោមជំនួយចិន ដែលមានរោងចក្រធំៗចំនួន ៣ គឺរោងចក្រតម្បាញខេត្តកំពង់ចាម រោងចក្រផលិតក្ដារ

[៥៩] សុន្ទរកថា សហជីវិនរដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាលថ្លែងក្នុងឱកាសពិធីសម្ពោធមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៦០។

[៦០] សូមមើល៖ ព្រះរាជដំណើរព្រះបាទនរោត្តម សីហនុ ឧបយុវរាជ ស្តេចយាងទៅកាន់ប្រទេសចិន សាធារណរដ្ឋប្រជាមានិត ខែកុម្ភៈ ឆ្នាំ១៩៥៦ ទំព័រ២៤-៣៧។

[៦១] សង្កថាលោកស្រី ពុង ប៉េងចេង ជាប្រធានគណៈកម្មាធិការចាត់ចែងការរៀបចំទទួលលោកស្រី ចេន យី និងគណៈតំណាងស្ត្រីនៃសាធារណរដ្ឋចិនប្រជាមានិត ឆ្នាំ១៩៥៨។

[៦២] វិភាគបទសន្និសីទនយោបាយរបស់សម្តេចព្រះនរោត្តម សីហនុ នៅកំពត ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៦។

[៦៣] ដ.ឯ.ម. ទំព័រ៦២។

បន្ទះនៅជីឥដ្ឋខេត្តកណ្ដាល រោងចក្រផលិតក្រដាសនៅឆ្លូង ខេត្តក្រចេះ។ ដើម្បីពង្រឹងនូវចំណងមិត្តភាពឱ្យកាន់តែជិតស្និទ្ធថែមទៀតនោះសម្ដេចព្រះនរោត្តម សីហនុ បានអញ្ជើញលោកនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ មកបំពេញទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា។ ឆ្លើយតបតាមការអញ្ជើញនោះ លោក ជូ អេនឡាយ ក៏បានមកធ្វើទស្សនកិច្ចជាផ្លូវការនៅកម្ពុជានាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៥៧។ នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះលោក ជូ អេនឡាយ បានថ្វាយសម្ដេចព្រះនរោត្តម សីហនុ នូវស្ថានីយ៍វិទ្យុផ្សាយសំឡេងមួយដែលមានកម្លាំង២០គីឡូវ៉ាត់សម្រាប់រលកជាតុអាកាសមធ្យមនិងប៉ុស្ដិ៍វិទ្យុផ្សាយសំឡេងមួយទៀត មានកម្លាំង១៥-គីឡូវ៉ាត់សម្រាប់រលកជាតុអាកាសខ្លី។ បន្ទាប់មកទៀត លោក ជូ អេនឡាយ បានបន្ថែមលើជំនួយនេះនូវប៉ុស្ដិ៍វិទ្យុផ្សាយសំឡេងមួយគ្រឿងទៀតជាគម្រប់៣គ្រឿង វិទ្យុនេះមានកម្លាំងផ្សាយ៥០គីឡូវ៉ាត់។ ស្ថានីយ៍វិទ្យុដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិននេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៦០[៦៤]។ ប្រទេសកម្ពុជាបានបង្កើតស្ថានឯកអគ្គរាជទូតរបស់ខ្លួននៅអមសាធារណរដ្ឋប្រជាមានិតចិននាទីក្រុងប៉េកាំង តាមព្រះរាជក្រមលេខ ២៩៩ ន.ស. ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៩[៦៥] ហើយសាធារណរដ្ឋប្រជាមានិតចិនបានយល់ព្រមផ្ដល់ជំនួយរោងចក្រចំនួនបីបន្ថែមទៀត ក្នុងនោះគឺមានរោងចក្រផលិតស៊ីម៉ងត៍ចក្រីទីងនៅខេត្តកំពត រោងចក្រផលិតកែវនៅស្ទឹងមានជ័យ និង រោងចក្រនៅខេត្តបាត់ដំបង។

សរុបមក យើងឃើញថា សាធារណរដ្ឋប្រជាមានិតចិនបានផ្ដល់ជំនួយសេដ្ឋកិច្ចមកឱ្យប្រទេសកម្ពុជាតាមកិច្ចព្រមព្រៀងចំនួន៣៖ ទី១ កិច្ចព្រមព្រៀងចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៥៦ ដែលមានទឹកប្រាក់ចំនួន៨លានលីវស្ទែរលីង។ ទី២ កិច្ចព្រមព្រៀងចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦០ ដែលមានទឹកប្រាក់ចំនួន៤លានលីវស្ទែរលីង។ ទី៣ កិច្ចព្រមព្រៀងចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលមានទឹកប្រាក់ចំនួន ១.៦លានលីវស្ទែរលីង។ សរុបចំនួនទឹកប្រាក់ទាំងអស់ដែលរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនបានផ្ដល់មកកម្ពុជាគឺ១៣.៦លានលីវស្ទែរលីង[៦៦]។

### ២- កម្ពុជាបដិសេធជំនួយសហរដ្ឋអាម៉េរិក

នៅក្នុងរយៈពេល៩ឆ្នាំ គឺពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៦៣ ប្រទេសកម្ពុជាបានទទួលជំនួយសេដ្ឋកិច្ចនិងយោធាពីសហរដ្ឋអាម៉េរិករាប់រយលានដុល្លារ ជំនួយនេះវាជាការចូលរួមចំណែកមួយយ៉ាងសំខាន់ សម្រាប់ទ្រទ្រង់បន្ទុកថវិកាជាតិរបស់រដ្ឋាភិបាលកម្ពុជា ដែលទើបនឹងទទួលបានឯករាជ្យពីរបបអាណាព្យាបាលបារាំង។ ជំនួយផ្នែកសេដ្ឋកិច្ច យោធា និងបច្ចេកទេសរបស់សហរដ្ឋអាម៉េរិកបានផ្ដល់មកឱ្យកម្ពុជាចាប់តាំងពីឆ្នាំ១៩៥៣ដល់ឆ្នាំ១៩៦៣ ហើយជំនួយនោះចាប់ផ្ដើមពីចំនួនច្រើនមកចំនួនតិច[៦៧]។

គួររំឭកផងដែរថា កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៥៥ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិក ហ្វូស្ទ័រ ឌុល្លេស (Foster Dulles) បានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ ដើម្បីទទួល នូវការដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងអង្គការសេអាតូ ប៉ុន្តែ ត្រូវបានបដិសេធដោយសម្ដេចព្រះនរោត្តម-សីហនុ[៦៨]។

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្ដេចព្រះនរោត្តម សីហនុ បានប្រកាសឈប់ទទួលយកជំនួយរបស់សហរដ្ឋអាម៉េរិក។ បន្ទាប់មកទៀតនៅ ថ្ងៃទី២៩-៣១ ខែធ្នូ ឆ្នាំ ១៩៦៣ ដដែល ក្នុងឱកាសសមាជជាតិលើកទី១៦របស់សង្គមរាស្ត្រនិយមបានឯកភាពទាំងស្រុងលើការបដិសេធនូវជំនួយយោធានិងស៊ីវិលទាំងអស់របស់សហរដ្ឋអាម៉េរិក[៦៩]។

ចាប់ពីមានការបដិសេធនូវជំនួយនេះមក ស្ថានភាពនៃទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤ បាតុកម្មប្រឆាំង

---

[៦៤] ចៅ សេង ៖ សុន្ទរកថា រដ្ឋមន្ត្រីក្រសួងឃោសនាការ ថ្លែងក្នុងឱកាសពិធីសម្ពោធរាជស្ថានីយវិទ្យុផ្សាយសំឡេង នៅស្ទឹងមានជ័យ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៦០។

[៦៥] រាជកិច្ចលេខ៧ ចេញផ្សាយថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៥៩ ទំព័រ៧៦៥-៧៦៧។

[៦៦] Charles Meyer, ក្រោយស្នាមញញឹមរបស់ខ្មែរប្រែសម្រួលដោយ ទី យាយុ ទំព័រ១៩៣ ពីស្នាដៃដើមជាភាសាបារាំងដែលមាន ចំណងជើងថា Derrire le Sourire Khmer, Paris, 1971។

[៦៧] Cf. Le Programme de l’aide économique américaine au Cambodge 1955-1959, op. cit., p. 12.

[៦៨] Raoul M. Jennar, Les clés du Cambodge, Faits et chiffres, repères historiques, profiles cambodgiens, cartes, Maison-neuve et Larousse, p. 58.

[៦៩] Ibid. p. 63.

នឹងស្ថានទូតសហរដ្ឋអាម៉េរិកនិងអង់គ្លេស បានកើតឡើង នៅទីក្រុងភ្នំពេញ[៧០]។ ប្រទេសកម្ពុជាបានកាត់ផ្តាច់ចំណងការទូតជាមួយនឹងសហរដ្ឋអាម៉េរិកនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦៥។ ក្រោយពីការកាត់ផ្តាច់ចំណងការទូតជាមួយគ្នាមួយរយៈមកប្រទេសទាំងពីរក៏បានរៀបចំឱ្យមានទំនាក់-ទំនងគ្នាឡើងវិញនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៦៩[៧១]។ មូលហេតុដែលនាំឱ្យកម្ពុជាបដិសេធជំនួយសហរដ្ឋអាម៉េរិក គឺកម្ពុជាមានបំណងចង់គេចចេញពីសង្គ្រាមវៀតណាម ហើយចង់រក្សាទំនាក់ទំនងល្អជាមួយនឹងសមាជិកប្លុកកុម្មុយនីស្ត[៧២]។

**៣-បញ្ហាចោទនៃទំនាក់ទំនងកម្ពុជា និង ប្រទេសថៃ**

សន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៨៦៣ បានធ្វើឱ្យប្រទេសកម្ពុជារួចផុតពីអំណាចគ្រប់គ្រងរបស់ប្រទេសសៀម[៧៣]។ នៅឆ្នាំ១៩០៧ បារាំងបានចុះសន្ធិ-សញ្ញាជាមួយសៀមនាថ្ងៃទី២៣ ខែមីនា ហើយសន្ធិសញ្ញានេះបានតម្រូវឱ្យសៀមប្រគល់ខេត្តភាគពាយព្យមកឱ្យខ្មែរកាន់កាប់វិញ មានខេត្តបាត់ដំបង សៀមរាបនិងស៊ីសុផុន[៧៤]។ ឆ្លៀតឱកាសដែលប្រទេសជប៉ុនវាយកាន់កាប់អាស៊ីអាគ្នេយ៍នោះ ប្រទេសថៃឆ្លៀតយកឥទ្ធិពលជប៉ុនចូលមកវាយដណ្តើមយកទៅវិញនូវខេត្តបាត់ដំបងទឹកដីមួយផ្នែកនៃខេត្តសៀម-រាប កំពង់ធំ និង ស្ទឹងត្រែងនៅឆ្នាំ១៩៤១។ ប៉ុន្តែ ទឹកដីទាំងនោះត្រូវបានប្រគល់មកឱ្យប្រទេសកម្ពុជាវិញ តាមរយៈសន្ធិ-សញ្ញា ក្រុងវ៉ាស៊ីនតោនថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៦[៧៥]។

ទោះជាយ៉ាងណាក៏ដោយ ថៃមិនបានគោរពសន្ធិ-សញ្ញា ឆ្នាំ១៩៤៦ឡើយ ជាក់ស្តែងនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ កងកម្លាំងប៉ូលិសនិងយោធាថៃបានចូលមកកាន់កាប់ប្រាសាទព្រះវិហារ[៧៦]។ គួររំឭកថា ប្រទេសកម្ពុជាបានបង្កើតស្ថានអគ្គរាជទូតប្រចាំក្រុងបាងកកនៅឆ្នាំ១៩៥៥ ហើយបានដំឡើងទៅជាស្ថានឯកអគ្គរាជទូតតាម ព្រះរាជ-ក្រឹត្យ លេខ៨០ ន.ស. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៥៦[៧៧]។ នៅខែកញ្ញា ឆ្នាំ១៩៥៧ លោកសេនាប្រមុខ សារិត ថាណារ៉ាត់ បានធ្វើរដ្ឋប្រហារប្រឆាំងនឹងសេនាប្រមុខភីបុល សង្គ្រាម ដែលព្រឹត្តិការណ៍នេះបានកំណត់នូវការផ្លាស់ប្តូរយ៉ាងជាក់លាក់មួយរបស់នយោបាយថៃជាមួយនឹងប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៨ ទំនាក់ទំនងរវាងប្រទេសទាំងពីរបានចាប់ផ្តើមមានភាពល្អក់កករ នៅពេលនោះ ប៉ូលិសថៃបានចូលកាន់កាប់ប្រាសាទព្រះវិហារ។ ដោយមិនអាចទ្រាំនឹងការរំលោភបំពាននេះតទៅទៀតបាន កម្ពុជាបានសម្រេចដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជា-ជាតិអំពីការបំពារ បំពានរបស់ថៃ។ រហូតមកដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៨ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ឈប់ទំនាក់ទំនងការទូតរបស់ខ្លួនជាបណ្តោះអាសន្នជាមួយនឹងប្រទេសថៃ[៧៨]។ នៅក្នុងឯកសារជំនួយស្មារតីរបស់រាជរដ្ឋាភិបាលកម្ពុជា នៅ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៩ បានស្នើឡើងនូវដំណោះស្រាយពីរគឺ ១-រឿងក្តីនេះនឹងដាក់ជូនទៅតុលាការអន្តរជាតិទីក្រុងឡាអេ ហើយប្រទេសទាំងពីរនឹងអនុវត្តទៅតាមការវិ-និច្ឆ័យរបស់អង្គការកំពូលមួយនេះ ២-ប្រទេសថៃត្រូវដកកងកម្លាំងរបស់ខ្លួនចេញពីប្រាសាទព្រះវិហារ។ ក្នុងបរិវេណ-ប្រាសាទនិងក្នុងរង្វង់វិជ្ជមាត្រ៥គ.ម. ទុកជាតំបន់គ្មានកង-ទ័ព។ ក្នុងការរក្សានូវសិទ្ធិជាម្ចាស់ទៅលើប្រាសាទកម្ពុជាយកការគ្រប់គ្រងប្រាសាទរួមគ្នា ហើយជានាការចូលទៅទស្សនាដោយសេរីចំពោះភ្ញៀវទេសចរនិងមន្ត្រីរដ្ឋាភិបាល[៧៩]។

ដោយរដ្ឋាភិបាលថៃពុំបានឆ្លើយតបនឹងសំណើនេះ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៩ រដ្ឋាភិបាលកម្ពុជាបានដាក់

---

[៧០] Ibid., p. 64.

[៧១]-Charles Meyer : ក្រោយស្នាមញញឹមរបស់ខ្មែរ ប្រែម្រួល ដោយ ទី យ៉ាយុ ដ.ឯ.ម. ទំព័រ២៦២ ពីស្នាដៃដើមជាភាសាបារាំងដែលមានចំណងជើងថា Derrire le Sourire Khmer, Paris, 1971.

[៧២] ដេវីឌ ឆាណ្ឌល័រ (David Chandler) ប្រវត្តិសាស្ត្រខ្មែរ បកប្រែដោយមជ្ឈមណ្ឌលខេមរសិក្សាចេញផ្សាយ លើកទី២ នៅខែកញ្ញា ឆ្នាំ ២០០៥ ទំព័រ២២០។

[៧៣] បណ្ឌិត ស៊ិន សំណាង ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតវគ្គទី១ នៅរាជបណ្ឌិត្យសភាកម្ពុជា សិក្ខាសាលាពង្រឹងជំនាញទូទៅ(ដោយសាស្ត្រចារ្យ) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៨។

[៧៤] Raoul M. Jennar, Les clés du Cambodge, op. cit., p. 47.

[៧៥] ប៉ែន នុត ប្រវត្តិសាស្ត្រសង្ខេបអំពីទំនាក់ទំនងខ្មែរ សៀម ការ ផ្សាយរបស់បណ្ណាគារអប្សរា ឆ្នាំ១៩៩៧ ទំព័រ២២ -២៤។

[៧៦] Aide mémoire sur les relations Khmero-Thailandaises 1962, p. 1.

[៧៧] រាជកិច្ចលេខ៣ ចេញផ្សាយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៥៦ ទំព័រ ៥០៨។

[៧៨] Aide mémoire sur les relations Khmero-Thailandaises, op. cit., p. 2.

[៧៩] Ibid., p. 27.

ពាក្យបណ្ដឹងទៅតុលាការអន្តរជាតិ (CIJ : la Cour Internationale de Justice)។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ១៩៦២ សវនាការចុងក្រោយបានសម្រេចឱ្យកម្ពុជាទទួលជ័យជម្នះក្នុងរឿងក្ដីនេះ។ ដំបូងប្រទេសថៃបានបដិសេធចំពោះសាលក្រមរបស់តុលាការក្រុងឡាអេ ប៉ុន្តែនៅទីបញ្ចប់ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៦២ លោកសេនាប្រមុខ សារិត ថាណារ៉ាត (Maréchal Sarit Thanarat) បានថ្លែងថា ប្រទេសរបស់លោកលំឱនកាយចំពោះមុខសេចក្ដីសម្រេចរបស់តុលាការអន្តជាតិ ដើម្បីគោរពកិច្ចសន្យារបស់ខ្លួនចំពោះធម្មនុញ្ញសហប្រជាជាតិ[៨០]។ នៅថ្ងៃទី០៥ ខែ មករា ឆ្នាំ១៩៦៣ សម្ដេចព្រះ នរោត្តម សីហនុ បានដឹកនាំប្រតិភូជាន់ខ្ពស់ព្រមទាំងអង្គទូត ព្រះសង្ឃ ប្រជារាស្ត្រទៅបង្ហូតទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជានៅលើប្រាសាទព្រះវិហារយ៉ាងឱឡារិក[៨១]។

សរុបមកឃើញថា នៅសម័យសង្គមរាស្ត្រនិយម ប្រទេសកម្ពុជាបានជួបនូវបញ្ហាចោទជាច្រើន នៅក្នុងការធ្វើទំនាក់ទំនងជាមួយប្រទេសជិតខាងមួយនេះ។ នេះគឺដោយសារការបង្កឡើងរបស់ភាគីថៃនិងក្រោមការគាបសង្កត់ពីសំណាក់សហរដ្ឋអាម៉េរិក ដើម្បីអូសទាញប្រទេសកម្ពុជាឱ្យក្លាយទៅជាសមាជិករបស់សេអាតូ។

### ៤- បញ្ហាចោទនៃទំនាក់ទំនងកម្ពុជា និង ប្រទេសវៀតណាម

បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យនៅឆ្នាំ ១៩៥៣មក កម្ពុជាបានរៀបចំចាត់វិធានការវាយទប់ទល់នឹងចលនាវៀតមិញ។ ជាក់ស្តែង ការធ្វើប្រតិបត្តិការសឹកប្រឆាំងនឹងវត្តមានរបស់ក្រុមនេះនៅក្នុងប្រទេសកម្ពុជា ដែលប្រតិបត្តិការនោះត្រូវបានគេហៅថា "ប្រតិបត្តិការសាមគ្គី"។ ប្រតិបត្តិការសាមគ្គីត្រូវបានចាប់ផ្ដើមធ្វើឡើងពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ១៩៥៣រហូតដល់ខែមេសា ឆ្នាំ១៩៥៤។ ប្រតិបត្តិការនេះបានធ្វើឡើងនៅក្នុងខេត្តបាត់ដំបង ក្រចេះ និងស្ទឹងត្រែង។ នៅក្នុងខេត្តបាត់ដំបង ក្រុមវៀតមិញបានចូលមកតាំងពីឆ្នាំ ១៩៤៩ ហើយបន្ទាប់មកនៅខែមេសា ឆ្នាំ១៩៥៤ ក្រុមវៀតមិញបានចូលមកក្នុងខេត្តក្រចេះនិងខេត្តស្ទឹងត្រែងទៀត។ កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវស្តីពីការបញ្ឈប់សង្គ្រាមនៅឥណ្ឌូចិនបានបញ្ជាក់ថា កងទ័ពបរទេសទាំងអស់ត្រូវដកចេញពីប្រទេសកម្ពុជាក្នុងនោះក៏មានកងកម្លាំងរបស់ក្រុមវៀតមិញផងដែរ។

ការមិនស៊ីចង្វាក់គ្នាដំបូងៗរវាងកម្ពុជានិងវៀតណាម បានកើតមានឡើងនៅខែមេសា ឆ្នាំ១៩៥៤ គឺការបន្លំមកចូលក្នុងទឹកដីកម្ពុជារបស់កងទ័ពវៀតមិញចំនួន២កងវរសេនាតូចដែលត្រូវដកចេញទៅប្រទេសវៀតណាមវិញក្រោយពីការបញ្ចប់សន្និសីទីក្រុងហ្សឺណែវ[៨២]។

ការផ្ដើមធ្វើទំនាក់ទំនងរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសវៀតណាមគឺមានការលំបាក ព្រោះថា សន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ប្រទេសវៀតណាមត្រូវបានគេសម្រេចបែងចែកជាពីរដោយមានខ្សែបន្ទាត់កាត់ជាបណ្ដោះអាសន្នរហូតដល់មានការបោះឆ្នោតនៅខែកក្កដា ឆ្នាំ ១៩៥៦[៨៣]។ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៥៦ សម្ដេចព្រះនរោត្តម សីហនុ មានព្រះរាជបន្ទូលថា ការលំបាកនោះ គឺស្ថិតត្រង់ចំណុចដែលមិនដឹងជាត្រូវនិយាយជាមួយនឹងវៀតណាមមួយណា[៨៤]។

នៅខែកុម្ភៈ ឆ្នាំ១៩៥៦ លោក ង៉ោ ឌិញយៀម បានសម្រេចចិត្តភ្ជាប់ទំនាក់ទំនងការទូតជាមួយនឹងប្រទេសកម្ពុជា។ រយៈពេល៣ខែក្រោយមកភាគីកម្ពុជាបានបន្ធូនឥរិយាបថនិងបានយល់ព្រមឱ្យមានស្ថានអគ្គកុងស៊ុល មួយរបស់វៀតណាមតាំងនៅទីក្រុងភ្នំពេញ ហើយប្រទេសកម្ពុជាបានបង្កើតស្ថានតំណាងរបស់ខ្លួននៅអមរដ្ឋាភិបាលវៀតណាមខាងត្បូងតាមព្រះរាជក្រមលេខ ១៤៦ន.ស. ចុះថ្ងៃទី

---

[៨០] វិទ្យាស្ថានអ៊ីនធឺរដេ ព្រឹត្តិបត្របចាំខែ លេខ១ ចេញផ្សាយខែកញ្ញា ឆ្នាំ ២០០៨ ទំព័រ៣១។

[៨១] ស្នាដៃសង្គមរាស្ត្រនិយម តុល្យការពីខែធ្នូ ឆ្នាំ១៩៦២ ដល់ខែ មិថុនា ឆ្នាំ១៩៦៣ (ពីសមាជជាតិលើកទី១៤ ដល់សមាជជាតិ លើកទី១៥) ទំព័រ២០៧ដល់២០៨។

[៨២] Charles Meyer, ក្រោយស្នាមញញឹមរបស់ខ្មែរ ប្រែសម្រួល ដោយ ទី យាយុ ដ.ឯ.ម. ទំព័រ២៣៦ ពីស្នាដៃដើមជាភាសាបារាំង ដែលមានចំណងជើងថា Derrière le Sourire Khmer, Paris, 1971..

[៨៣] Accord sur la cessation des hostilités en indochine, Genève 20 juillet 1954, imprimerie 20 janvier 1965, p. 2.

[៨៤] សេចក្ដីថ្លែងការណ៍ សម្ដេចព្រះឧបរាជកាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ១៩៥៦ ក្នុងឱកាសដែលទ្រង់នាំសមាជិករដ្ឋាភិបាលទី៣ទៅសុំសេចក្ដីទុកចិត្តអំពីរដ្ឋសភា ទំព័រ៤១។

២៥ ខែធ្នូ ឆ្នាំ១៩៥៦[៨៥]។ ដោយមិនអាចគាបសង្កត់ប្រទេសកម្ពុជាឱ្យលះបង់នូវនយោបាយអព្យាក្រឹតនិងបង្ខំឱ្យចូលរួមក្នុងអង្គការសេអាតូបាននោះ វៀតណាមខាងត្បូងកាន់តែទន្ទ្រានចូលមកក្នុងទឹកដីកម្ពុជាជាបន្តបន្ទាប់។ នៅខែមិថុនា ឆ្នាំ១៩៥៨ កងទ័ពវៀតណាមខាងត្បូងបានវាយចូលមកក្នុងតំបន់ភាគឦសាននៃខេត្តស្ទឹងត្រែង[៨៦]។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ព្រះមហាក្សត្រខ្មែរ ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹត បានបញ្ជូនព្រះសារលិខិតមួយច្បាប់អំពាវនាវទៅសហរដ្ឋអាម៉េរិកឱ្យចាត់វិធានការគ្រប់បែបយ៉ាងក្នុងការបញ្ឈប់ការទន្ទ្រានចូលទឹកដីខេត្តស្ទឹងត្រែងដោយខុសច្បាប់ពីសំណាក់កងទ័ពវៀតណាមខាងត្បូង[៨៧]។ នៅពេលនោះ រដ្ឋាភិបាលសហរដ្ឋអាម៉េរិកបានឆ្លើយតបមកវិញថា ខ្លួនមិនអាចធ្វើអន្តរាគមន៍ក្នុងរឿងនេះបានទេ ប៉ុន្តែក៏មិនបណ្តោយឱ្យកម្ពុជាយកគ្រឿងសព្វាវុធដែលជាជំនួយសហរដ្ឋអាម៉េរិកទៅប្រើប្រាស់ប្រឆាំងនឹងកងទ័ពវៀតណាមខាងត្បូងដែលជាសម្ព័ន្ធមិត្ររបស់ខ្លួនដែរ[៨៨]។ ដោយមានភាពតានតឹងកាន់តែខ្លាំងឡើង ប្រទេសកម្ពុជាបានសម្រេចកាត់ផ្តាច់ចំណងការទូតជាមួយនឹងវៀតណាមខាងត្បូងនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៦៣[៨៩]។

នៅឆ្នាំ១៩៦៤ ស្ថានភាពបានវិវត្តជាគុណប្រយោជន៍សម្រាប់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង (វៀតកុង) ដែលពង្រីកការត្រួតត្រារបស់ខ្លួននៅតាមព្រំដែនកម្ពុជាវៀតណាម។ រណសិរ្សរំដោះជាតិវៀតណាមខាងត្បូងបានយល់ព្រមទទួលស្គាល់ព្រំដែនកម្ពុជានិងវៀតណាមនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៦៧ ហើយរដ្ឋាភិបាលទីក្រុងហាណូយបានប្រកាសទទួលស្គាល់នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៦៧[៩០]។ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៦៩ ស្ថានតំណាងទូតរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ត្រូវបានដំឡើងឋានៈទៅជាស្ថានទូត ចំណែកឯរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងទទួលបានស្ថានតំណាងអចិន្ត្រៃយ៍មួយនៅទីក្រុងភ្នំពេញ។ ការរីករាលដាលកាន់តែខ្លាំងឡើងៗរបស់ពួកចលនាតស៊ូវៀតកុងនិងកងទ័ពវៀតណាមខាងជើងបានធ្វើឱ្យទំនាក់ទំនងរវាងកម្ពុជានិងវៀតណាមបានជួបប្រទះនូវបញ្ហាកាន់តែខ្លាំង ឡើងៗ។

## សន្និដ្ឋាន

សរុបមក យើងឃើញថា ក្រោយពីកម្ពុជាទទួល ឯករាជ្យនៅឆ្នាំ១៩៥៣មក ទិសដៅចម្បងគឺការរៀបចំឱ្យមានសុខសន្តិភាពនៅក្នុងផ្ទៃប្រទេស ការអភិវឌ្ឍសេដ្ឋកិច្ចនិងការធ្វើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ នៅសម័យសង្គមរាស្ត្រនិយម កម្ពុជាបានប្រកាន់យកនយោបាយការបរទេសរបស់ខ្លួនគឺនយោបាយអព្យាក្រឹត។ ការប្រកាន់យកនយោបាយនេះក្នុងគោលបំណងរក្សានូវសុខសន្តិភាព ឯករាជ្យភាពនិងការគោរពបូរណភាពទឹកដីពីសំណាក់បរទេស។ ក្រោយពីទទួលបានឯករាជ្យ កម្ពុជាត្រូវស្វែងរកជំនួយផ្នែកសេដ្ឋកិច្ចជាបន្ទាន់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យមានការរីកចម្រើន។

កម្ពុជាបានធ្វើទំនាក់ទំនងជាមួយប្រទេសមហាអំណាចធំៗដូចជា សហរដ្ឋអាម៉េរិក សហភាពសូវៀត និងសាធារណរដ្ឋប្រជាមានិតចិន។ ជាក់ស្តែង ពេលនោះប្រទេសមហាអំណាចតែងបានផ្តល់ជំនួយជាទឹកប្រាក់ សម្ភារៈមន្ទីរពេទ្យ អគារសិក្សានិងរោងចក្រជាច្រើនដល់ប្រទេសកម្ពុជា ដែលជំនួយទាំងនោះបានឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដើម្បីអភិវឌ្ឍប្រទេសជាតិ។ ការប្រកាន់យកនយោបាយអព្យាក្រឹតអាចជំរុញកិច្ចសហប្រតិបត្តិការរវាងកម្ពុជាជាមួយនឹងប្រទេសដែលស្ថិតនៅក្នុងប្លុកសេរីនិងក្នុងប្លុកសង្គមនិយមដើម្បីចៀសវាងនូវការប្រឈមមុខដាក់គ្នានៃមនោគមវិជ្ជាទាំងពីរនេះ។ ប្រការនេះបានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាពនិងការអភិវឌ្ឍមួយរយៈពេលគឺចន្លោះពីឆ្នាំ

---

[៨៥] រាជកិច្ចលេខ២២៤ ចេញផ្សាយថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៦ ទំព័រ ៧៤៤៣-៧៤៤៥។

[៨៦] Norodom Sihanouk, La c.i.a contre le Cambodge, François Maspéro pour l'édition française, Paris,
1973, p. 86.

[៨៧] ព្រះបរមរាជឱង្ការនៃព្រះករុណាព្រះបាទនរោត្តម សុរាម្រឹត ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ទំព័រ ៥-៦។

[៨៨] *Charles Meyer,* ក្រោយស្នាមញញឹមរបស់ខ្មែរ ប្រែសម្រួល ដោយ ទី យាយុ ដ.ឯ.ម. ទំព័រ២១០ ពីស្នាដៃដើមជាភាសាបារាំងដែលមានចំណងជើងថា Derrière le Sourire Khmer, Paris, 1971.

[៨៩] Marie Alexandrine Martin, ***Le Mal cambodgien, Histoire d'une Société Traditionnelle Face à ses Leaders Politiques 1946-1987, Histoire des gens,*** Hachette, 1989, p. 99.

[៩០] *Charles Meyer,* ក្រោយស្នាមញញឹមរបស់ខ្មែរ ប្រែសម្រួលដោយ ទី យាយុ ដ.ឯ.ម. ទំព័រ២៤៤ ពីស្នាដៃដើមជាភាសាបារាំង ដែលមានចំណងជើងថា *Derrière le Sourire Khmer, Paris, 1971.*

១៩៥៥ដល់ឆ្នាំ១៩៧០។ បន្ទាប់ពីសន្និសីទហ្សឺណែវ សង្គ្រាមនៅឥណ្ឌូចិនត្រូវបានបញ្ចប់ ខែកក្កដា ឆ្នាំ១៩៥៤ សហរដ្ឋអាម៉េរិកបានផ្តួចផ្តើមបង្កើតអង្គការសេអាតូនៅខែកញ្ញា ឆ្នាំ១៩៥៤។ ការបង្កើតអង្គការនេះឡើង គឺមាគោលបំណងទប់ទល់នឹងការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ហើយសហរដ្ឋអាម៉េរិកបានមកបញ្ចុះបញ្ចូលប្រទេសកម្ពុជាឱ្យចូលជាសមាជិករបស់អង្គការមួយនេះ។ តែសំណើរបស់សហរដ្ឋអាម៉េរិកត្រូវបានកម្ពុជាបដិ-សេធចោល។ ក្រោយពីការបញ្ចប់សន្និសីទហ្សឺណែវនេះដែរ សហរដ្ឋអាម៉េរិកបានចូលមកឥណ្ឌូចិន តាមរយៈការធ្វើសម្ពន្ធ មិត្តជាមួយវៀតណាមខាងត្បូង។ ទំនាក់ទំនងរវាងប្រទេស ទាំងពីរនេះ សហរដ្ឋអាម៉េរិកបានក្លាយទៅជាអ្នកបង្កសង្គ្រាមឥណ្ឌូចិនឡើងវិញ។ ពេលនោះ សង្គ្រាមនៅវៀតណាមបានផ្ទុះឡើង ហើយបានរីករាលដាលចូលមកក្នុងប្រទេសកម្ពុជា។ ការរីករាលដាលនៃសង្គ្រាមនេះបានធ្វើឱ្យប្រទេសកម្ពុជាកើតមានសង្គ្រាមអូសបន្លាយចាប់តាំងពីឆ្នាំ១៩៧០រៀងមក។ ការកើតមានសង្គ្រាមនៅកម្ពុជា បានធ្វើឱ្យអន្តរាយដល់ហេដ្ឋារចនាសម្ពន្ធសេដ្ឋកិច្ចសង្គម ជាពិសេសការបាត់បង់អាយុជីវិតប្រជាជនខ្មែរអស់យ៉ាងច្រើន។ ហេតុនេះ សហរដ្ឋអាម៉េ-រិកក៏ត្រូវចូលរួមក្នុងការទទួលខុសត្រូវចំពោះការបង្កសង្គ្រាមនៅឥណ្ឌូចិនពិសេសគឺនៅប្រទេសកម្ពុជាផងដែរ។

## គន្ថនិទ្ទេស


**-ភាសាខ្មែរ**

១-រាជកិច្ចលេខ១ ចេញផ្សាយថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៥១។

២-រាជកិច្ចលេខ៣ ចេញផ្សាយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៥៦។

៣-រាជកិច្ចលេខ៧ ចេញផ្សាយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥៦។

៤-រាជកិច្ចលេខ២៤ ចេញផ្សាយថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៦។

៥-រាជកិច្ចលេខ២១ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៧។

៦- រាជកិច្ចលេខ៧ ចេញផ្សាយថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៥៩។

៧-ព្រះរាជដំណើរព្រះបាទ នរោត្តម សីហនុ ឧប-យុវរាជ ស្តេចយាងទៅកាន់ប្រទេសចិនសាធារណរដ្ឋប្រជា-មានិត ខែកុម្ភៈ ឆ្នាំ១៩៥៦ ។

៨-សេចក្តីថ្លែងការណ៍សម្តេចព្រះឧបរាជ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៥៦ ក្នុងឱកាសដែលទ្រង់នាំសមាជិករដ្ឋាភិបាលទី៣ ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។

៩-វិភាគបទសន្និសីទរបស់សម្តេចព្រះ នរោត្តម សីហនុ នៅកំពត ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៦។

១០-សង្កថារបស់លោកស្រី ពុង ប៉េងចេង ជាប្រធានគណៈកម្មាធិការចាត់ចែងការរៀបចំទទួលលោកស្រីចេន យី និង គណៈតំណាងស្ត្រីនៃសាធារណរដ្ឋចិនប្រជាមានិត ឆ្នាំ១៩៥៨។

១១-សុន្ទរកថា លោក ចៅ សេង រដ្ឋមន្ត្រីក្រសួងឃោសនា ការថ្លែងក្នុងឱកាសពិធីសម្ពោធរាជស្ថានីយវិទ្យុ-ផ្សាយសំឡេង នៅស្ទឹងមានជ័យ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៦០។

១២-សុន្ទរកថា សហជីវិនរដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល ថ្លែងក្នុងឱកាសពិធីសម្ពោធមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៦០។

១៣- នរោត្តម សីហនុ អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់ (បកប្រែដោយ ន. រណរង្គ) ឆ្នាំ១៩៩៣។

១៤- សម្តេចព្រះនរោត្តម សីហនុ និង ប៊ែរណាដ៍ គ្រីស័រ សម្តេចព្រះនរោត្តម សីហនុ រំឭកប្រវត្តិរឿងដើម *ជាមួយថ្នាក់ដឹកនាំខ្លះនៅលើពិភពលោក* Yohan Publication, Japan, ឆ្នាំ១៩៩០។

១៥-ខៀវ ថារិកា ប្រវត្តិសាស្ត្រនៃទំនាក់ទំនងអន្តរជាតិពីឆ្នាំ១៩៤៥ មកទល់បច្ចុប្បន្ន និង បញ្ហា *សង្គ្រាមត្រជាក់* ឧបត្ថម្ភបោះពុម្ពដោយសម្តេច ហ៊ុន សែន ភ្នំពេញ ឆ្នាំ១៩៩៧។

**-ភាសាបរទេស**

1- Bekaert Jacques, *Cambodia Diary, Tales of a Divided Nation 1983-1986,* White Lotus, Thailand, 1997.

2- Bekaert Jacques, *Cambodia Diary, A Long Road to Peace 1987-1993* , White Lotus, Thailand 1998.

3- Chandler David P., *Pol Pot: Brother Number One,* Published in 1992 in the United States of America by Westview Press.

4- Hamel Bernard, *Sihanouk et le Drame cambodgien,* Editions L'Harmattan, 1993.

5- J. M. Lambin, Ch. Bouvet, *Histoire Géographie initiation économique,* Hachette, imprimé en France, 1995.

6- Ministère de l´Information, *Les cahiers du Sangkum. Revue des Réalisations du Sangkum Reastr Niyum,* Phnom Penh, Avril 1958-Mai 1962.

7- Ministère de l´Information, *Khmero-Indonesian friendship and solidarity,* Phnom Penh, Août 1962.

8- M. Jennar Raoul, *Les clés du Cambodge, Faits et chiffres, repères historiques, profiles cambod-giens, cartes,* Maisonneuve et Larousse, 1995.

9- Martin Marie Alexandrine, *Le Mal cambodgien,* Histoire d'une Société Tradi-tionnelle Face à ses Leaders Politiques 1946-1987, Histoire des gens, Hachette, 1989.

10- Morris J. Stephen, *Why Vietnam invaded Cambodia, Political culture and the causes of war,* Stanford University Press, Stanford, California, 1999.

11- Norodom Sihanouk, *L'Indochine vue de Pékin,* Entretiens avec Jean Lacouture, Paris, Edition du Seuil, 1972.

12- Norodom Sihanouk, *La c.i.a contre le Cambodge,* François Maspéro pour l'édition française, Paris, 1973.

13- Le Programme de l´aide économique américaine au Cambodge 1955-1959, Phnom Penh, Cambodge, août 1960.

14- Regaud Nicolas, *Peuples et Stratégies, Le Cambodge dans la tourmente, le troisième conflit indochinois 1978-1991,* L'Harmattan, 1991.

15- Revue de Presse Economique et Financière, *Marché Officiel des Changes,* N$^{o}$ 96, 7$^{e}$ année, Vendredi 30 juin 1961.

16-Revue de Presse Economique et Financière, *Marché Officiel des Changes,* No 81, 8$^{e}$ année, Vendredi juin 1962.

17- Richer Philippe, *le Cambodge une tragédie de notre temps,* imprimé en France, août 2001.

18- Shawcross, William. *Sideshow:* Kissinger Nixon and the Destruction of Cambodia, London, The Hoharth Press, 1993

# ការអភិវឌ្ឍកម្មវិធីសិក្សា



លោក **ភង ឌិម**
បេក្ខជនបណ្ឌិត ផ្នែកវិទ្យាសាស្ត្រអប់រំ
នៃរាជបណ្ឌិត្យសភាកម្ពុជា

## កម្មវិធីសិក្សាជាអ្វី ?

*កម្មវិធីសិក្សា* ជាមុខវិជ្ជាសិក្សាទាំងឡាយដែលបានផ្ដល់ឱ្យដោយស្ថាប័នអប់រំណាមួយ ( curriculum is all the courses of study offered by an educational institution )

*កម្មវិធីសិក្សា* ជាមុខវិជ្ជាសិក្សាពេញលេញមួយដែលបានផ្ដល់ឱ្យដោយសាលា ចំណែកឯមុខវិជ្ជាសិក្សាវិញជាកម្មវិធីពេញលេញតាមមុខវិជ្ជាមួយ( a curriculum is a complete course of study offered by a school, a syllabus is the outline of a single course )
http//www.thefreedictionary.com/curriculum

កម្មវិធីសិក្សាមកពីពាក្យឡាតាំង "Currere" ដែលមានន័យថា «រថ»។ ។ ដូច្នេះហើយបានជាពាក្យនេះសព្វថ្ងៃគេហៅ ភាសាអង់គ្លេសថា"Course of study" ដែលភាសាខ្មែរ យើងហៅថាមុខវិជ្ជាសម្រាប់សិក្សា។ សព្វថ្ងៃនេះ ពាក្យ "Course of study" ឬ "Curriculum" នេះមានន័យប្រែប្រួលមិនដូចពីមុនទៀតទេ។

លោក JESUS C. PALMA បានបំភ្លឺឱ្យយើងយល់ច្បាស់ថា "Curriculum" មិនមែនមានន័យត្រឹមតែបញ្ជីមុខវិជ្ជាឬខ្លឹមសារមេរៀនឬសេចក្ដីណែនាំសង្ខេបអំពីមេរៀនដែលត្រូវបង្រៀនឬខ្លឹមសារ ដែលមាននៅក្នុងសៀវភៅនោះទេ។ កម្មវិធីសិក្សាជាការរួមបញ្ចូលគ្នារវាងខ្លឹមសារដែលត្រូវរៀន បទពិសោធន៍និងធនធានដែលជ្រើសរើស រៀបចំនិងអនុវត្តយ៉ាងហ្មត់ចត់ ដើម្បីនាំនិស្សិតទៅដល់ផលសម្រេចក្លាយជាអ្វីមួយ ក្នុងរយៈកាលកំណត់តាមរយៈសកម្មភាពបង្រៀន រៀនស្រាវជ្រាវនិងការអភិវឌ្ឍធនធានមនុស្ស។ ដូច្នេះ តាមមតិរបស់លោក JESUS C. PALMA "Curriculum" ត្រូវរាប់បញ្ចូលទាំង «ខ្លឹមសារអ្វីខ្លះ» ព្រមទាំង «ការអប់រំមនុស្សដោយរបៀបណា» ពោលគឺទាំងពីរនេះបញ្ចូលគ្នាតែម្ដង។

## ការអភិវឌ្ឍកម្មវិធីសិក្សាមានន័យដូចម្ដេច ?

តាមលោក Jesus ការអភិវឌ្ឍមិនមែនមានន័យថាការប្រែប្រួលទេ ព្រោះថាមានតែការប្រែប្រួលវិជ្ជមានទេ ទើបមានន័យថាការអភិវឌ្ឍ។ ដើម្បីចាត់ទុកថាមានការប្រែប្រួលវិជ្ជមាន បានលុះត្រាតែការប្រែប្រួលនោះមានលក្ខណៈបីយ៉ាង៖

- ការប្រែប្រួលទៅរកអ្វីដែលយើងចង់បាន ( purposeful )
- ការប្រែប្រួលទៅតាមផែនការដែលបានគ្រោងទុក ( planned )
- ការប្រែប្រួលទៅរកវឌ្ឍនភាព ( progressive )

តាមលោក Parkey កម្មវិធីសិក្សាជាមុខវិជ្ជានានាដែលបានគ្រោងឡើងដោយគ្រឹះស្ថានសិក្សាណាមួយដើម្បីអនុវត្តសកម្មភាពបង្រៀននិងរៀន។ សៀវភៅណែនាំបង្ហាញអំពីមុខវិជ្ជានៃការសិក្សាដែលមានលក្ខណៈពេញលេញ បំពេញឱ្យដំណើរការការសិក្សាប្រព្រឹត្តទៅប្រកបដោយជោគជ័យដើម្បីឆ្ពោះទៅទទួលសញ្ញាបត្រជំនាញណាមួយ។ មុខវិជ្ជាសិក្សានីមួយៗត្រូវមានការបញ្ជាក់ទៅតាមចំនួនក្រេឌីតដែលគិតទៅតាមម៉ោងនៃការសិក្សាតាមមុខវិជ្ជាក្នុងសប្ដាហ៍។

លោក Parkey បានសរសេរថា៖ កម្មវិធីសិក្សាជា" បទពិសោធន៍ទាំងអស់ដែលនិស្សិតម្នាក់ៗទទួលបានពីកម្មវិធីអប់រំក្នុងនោះមានគោលបំណងត្រឹមត្រូវចំគោលដៅ " ដើម្បីសម្រេចគោលបំណងចង់បាននិងវត្ថុបំណងជាក់លាក់មួយចំនួនដែលពាក់ព័ន្ធព្រមទាំងត្រូវបានរៀបចំផែនការមួយតាមរយៈបណ្ដាញទ្រឹស្ដីនៃការស្រាវជ្រាវនិងការប្រតិបត្តិវិជ្ជាជីវៈកន្លងមកនិងបច្ចុប្បន្ន។ នៅក្នុងនិយមន័យនេះ ពាក្យកម្មវិធីអប់រំមានអត្ថន័យជាចម្បង "ជាបណ្ដុំចំណេះដឹង បំណិនឥរិយាបថដែលគ្រោងឡើងដោយគ្រូនិងអ្នកជំនាញវិជ្ជាជីវៈដទៃទៀត"។

ដូច្នេះហើយបានជាគេតម្រូវឱ្យអ្នកធ្វើការអភិវឌ្ឍកម្ម-

វិធីសិក្សាត្រូវគិតទៅដល់មូលដ្ឋានសំខាន់ៗដូចតទៅ៖

- គោលបំណង៖ រាប់បញ្ចូលទាំងគោលដៅទីបញ្ចប់ និងទិសដៅដែលស្ថាប័នចង់បាន។

- មធ្យោបាយ៖ ធនធានបទពិសោធន៍ជ្រើសរើស សម្រាំងរៀបចំហ្មត់ចត់និងអនុវត្តដើម្បីធ្វើដំណើរការរត់ទៅគោលបំណង។

- ការវាយតម្លៃសមិទ្ធផល៖ តាមរយៈមធ្យោបាយប្រកបទៅដោយប្រសិទ្ធភាពគួរឱ្យជឿបាន តើអង្គភាពបានសម្រេចគោលដៅឬមិនបានសម្រេចគោលដៅ ហើយតើអង្គភាពបានសម្រេចគោលដៅឬមិនបានសម្រេចគោលដៅដល់កម្រិតណា?




គំនូសតា )ង៖ បង្ហាញអំពីមូលដ្ឋាននៃការអភិវឌ្ឍកម្មវិធីសិក្សា(

កម្មវិធីសិក្សាមិនមែនជាអ្វីដែលនឹងថ្កល់ទេ ពោលឱ្យងាយស្តាប់ វាជាអ្វីមួយដែលដកស្រង់បទពិសោធន៍និងកែលម្អ ដើម្បីនាំទៅរកប្រសិទ្ធភាពខ្ពស់នៃការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់តម្រូវការនៃការអភិវឌ្ឍសង្គមជាតិ។ ដូច្នេះ យើងមិនអាចនិយាយបានថា យើងបានកម្មវិធីសិក្សាមួយដ៏ល្អហើយនោះទេ ព្រោះសង្គមប្រែប្រួលឥតឈប់ឈរដែរ។ គេតែងតែពោលថា "Curriculum is always tentative" បានន័យថា កម្មវិធីសិក្សា គឺបណ្តោះអាសន្ន ជានិច្ចតាមលំនាំមួយ ដែលនាំមកនូវកម្រិតខ្ពស់នៃប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។ នៅក្នុងការអនុវត្តអភិវឌ្ឍកម្មវិធីសិក្សានេះ យើងត្រូវធ្វើជាបន្តនូវផែនការកម្មវិធី ការអនុវត្តផែនការឱ្យបានហ្មត់ចត់ ការវាយតម្លៃនិងការពិនិត្យឡើងវិញ ដើម្បីកែលម្អ។ នេះជាសកម្មភាពប្រព្រឹត្តទៅជានិច្ចគ្មានទីបញ្ចប់ ដោយផ្អែកទៅលើលទ្ធផលស្រាវជ្រាវអំពីតម្រូវការរបស់អ្នកសិក្សា តម្រូវការរបស់អ្នកឧបត្ថម្ភជំនួយ បំណងប្រាថ្នារបស់សង្គម បំណងប្រាថ្នារបស់អ្នកប្រើប្រាស់និងតម្រូវការសម្របសម្រួលទៅនឹងសាកលភាវូបនីយកម្ម។ នៅក្នុងដ្យាក្រាមខាងលើនេះ សញ្ញាព្រួញទាំងពីរនេះបញ្ជាក់នូវឥទ្ធិពលទៅវិញទៅមកនិងទំនាក់ទំនងចាំបាច់បំផុតត្រូវតែមាន ដើម្បីបង្កើតបានជាប្រព័ន្ធមួយឱ្យប្រព្រឹត្តទៅបានល្អ។

## យុទ្ធសាស្ត្រនៃការរៀបចំកម្មវិធីសិក្សា

ការតាក់តែងកម្មវិធីសិក្សាជាជំហានមួយសំខាន់បំផុតដែលអង្គភាពបណ្តុះបណ្តាលនីមួយៗ ក៏ដូចជាសាកលវិទ្យាល័យ វិទ្យាស្ថានត្រូវយកចិត្តទុកដាក់រៀបចំឱ្យបានល្អជាទីបំផុតស្របទៅនឹងការប្រមើលមើលនៃតម្រូវការរបស់ប្រទេសជាតិ របស់សង្គមជាតិ និង របស់ពលរដ្ឋសម្រាប់អនាគត។ កម្មវិធីសិក្សានេះត្រូវតែឆ្លើយតបទៅនឹងសំណួរ តើគ្រូបង្រៀនអ្វីខ្លះដល់និស្សិត? បំណិនប្រសប់អ្វីខ្លះដែលនិស្សិតត្រូវចេះ? សមត្ថភាពប្រតិបត្តិអ្វីខ្លះ (Skill Performance) ដែលត្រូវយកចិត្តទុកដាក់អភិវឌ្ឍដល់និស្សិត អ្នកជំនាញខាងកម្មវិធីសិក្សាបានបញ្ចេញមតិជាច្រើនលើបញ្ហានេះ លោក Jeanette Colby និង Miske Witt បាននិយាយថា កម្មវិធីសិក្សាគឺអ្វីដែលសាលារៀនមានចិត្តចង់បង្រៀនដល់និស្សិត ហើយកម្មវិធីសិក្សានោះត្រូវតែបញ្ជាក់យ៉ាងច្បាស់ពីគោលដៅជាក់លាក់អាចវាស់បានដែលកំណត់ដោយវត្ថុបំណង ចំណុចចាប់ផ្តើមនៃការអភិវឌ្ឍនិងសកម្មភាពប្រតិបត្តិកម្មវិធីសិក្សានោះ។ លោកបណ្ឌិត King Jordan ប្រធានសាកលវិទ្យាល័យ Gallader បានសរសេរថា ខ្លឹមសារមេរៀនដែលបង្រៀនទៅ" ដល់សិស្ស ឬ តម្រូវឱ្យនិស្សិតរៀន គេហៅថា កម្មវិធីសិក្សា"។

## លក្ខណៈឯកភាពគ្នា

លក្ខណៈស្រុះគ្នានេះមានឥទ្ធិពលធំធេងណាស់។ ស្ថាប័នឧត្តមសិក្សាមួយប្រៀបបាននឹងវង់តន្ត្រីមួយមានមនុស្សច្រើននាក់កាន់ឧបករណ៍ផ្សេងៗគ្នា ហើយអ្នកទាំងនោះត្រូវតែបំពេញភារកិច្ចរៀងៗខ្លួន ប៉ុន្តែត្រូវតែស៊ីចង្វាក់គ្នាព្រមៗគ្នាទៅតាមការបញ្ជារបស់អ្នកឱ្យសញ្ញាដែលជាប្រធានកំណត់ទិសដៅនោះ ទើបវង់ភ្លេងនោះបង្កើតបាននូវសមិទ្ធផលមួយដែលជាសូរសៀងដ៏ពីរោះរណ្តំជាទីចូលចិត្តរបស់អ្នកស្តាប់។ យ៉ាងណាមិញ ស្ថាប័នមួយត្រូវតែមានបុគ្គលិកមន្ត្រីគ្រប់គ្រង គណៈគ្រប់គ្រង ហើយត្រូវតែខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានស្រុះគ្នាទៅតាមបេសកកម្មចក្ខុវិស័យគោលដៅរបស់អង្គភាពក្រោមការដឹកនាំរបស់ប្រធានអង្គភាព។

## លក្ខណៈនិរន្តរភាព

ត្រូវតែបង្កើតក្រុមការងារមួយ ដែលមានសមាស

ភាពការងារនេះត្រូវតែធ្វើជាបន្ត កែលម្អបន្តផ្អែកទៅលើលទ្ធ-ផលស្រាវជ្រាវអំពីការតាមដានភាពពេញចិត្តរបស់អតិថិជន និងការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត។ ត្រូវបង្កើតកម្មវិធីសិក្សាថ្មី ផ្អែកលើមូលដ្ឋាននៃកម្មវិធីសិក្សាចាស់ដែលមាន។

## លក្ខណៈប្រកបដោយគុណភាព

សព្វថ្ងៃនេះគេតែងនិយាយអំពីគុណភាពអប់រំ និងការប្រឡងប្រណាំងប្រជែងអង្គភាព។ យើងមិនអាចរកបានទេប្រសិនបើយើងខ្វះក្រុមការងារដែលចាត់តាំងត្រឹមត្រូវទៅនឹងការត្រួតពិនិត្យ។ ដូច្នេះ យើងត្រូវធ្វើផែនការអភិវឌ្ឍនិងត្រួត-ពិនិត្យទើបយើងទទួលបានគុណភាព ពោលគឺធនធានមនុស្សដែលយើងបណ្តុះបណ្តាល (Human Product) ស្ថិតនៅក្នុងកម្រិតណាបើប្រៀបធៀបជាមួយគេ។

## យុទ្ធសាស្ត្រកម្មវិធីសិក្សាតាមប្រព័ន្ធម៉ោង

ប្រព័ន្ធម៉ោងជាប្រភេទនៃកម្មវិធីសិក្សាដែលប្រទេសមួយចំនួននៅមានប្រើ ដោយសារតែប្រព័ន្ធម៉ោងរៀបចំតាមមុខវិជ្ជានីមួយៗនោះ មានកំណត់ចំនួនម៉ោងសរុបរបស់មុខវិជ្ជានោះ ដោយបែងចែកទៅតាមឆមាសនៃឆ្នាំសិក្សា។

គុណសម្បត្តិនៃប្រព័ន្ធម៉ោង៖ គ្រូនិងនិស្សិតបង្រៀននិងរៀនទៅតាមចំនួនម៉ោងកំណត់របស់កម្មវិធី ដើម្បីទៅដល់ស្តង់ដាមួយដែលបានកំណត់ទុកដោយក្រសួងអប់រំឬសាកលវិទ្យាល័យ។

គុណវិបត្តិ៖ ក្នុងករណីដែលនិស្សិតប្រឡងមិនជាប់មធ្យមភាគប្រចាំឆ្នាំ និស្សិតត្រូវតែរៀនសាឡើងវិញជាថ្មីទាំងអស់ដោយត្រួតថ្នាក់។ កម្មវិធីបែបនេះមិនបានលើកទឹកចិត្តចំពោះនិស្សិតពូកែឬសម្របទៅតាមចំណង់ចំណូលចិត្តសម្រាប់និស្សិតជ្រើសរើសមេរៀនជំនាញ ដែលសមស្របទៅនឹងសមត្ថ-ភាពខ្លួនឡើយ។

## ការអភិវឌ្ឍកម្មវិធីសិក្សាផ្សារភ្ជាប់នឹងផល-ប្រយោជន៍សង្គម

ការអភិវឌ្ឍកម្មវិធីសិក្សាមានគោលបំណងមួយ គឺដើម្បីរៀបចំនិស្សិតសម្រាប់ពេលអនាគត ហើយប្រការនេះពិបាកនឹងរកការឯកភាពគ្នាបំផុតអំពីថាតើចំណេះដឹងនិងបំណិនបែបណានឹងត្រូវការនាពេលអនាគត។ គ្មានអ្នកណាម្នាក់អាចដឹងច្បាស់ថាគោលការណ៍អ្វីដែលត្រូវប្រើ អ្វីដែលមានអត្ថប្រយោជន៍ពិតប្រាកដនៅក្នុងជីវិតអនាគត បទ-ពិសោធន៍បែបណាឬចំណេះដឹងខ្ពស់បែបណា ដើម្បីជាគោលបំណងនៃការបណ្តុះបណ្តាលរបស់យើងនោះទេ។ បញ្ហាទាំងអស់នេះគួរតែលើកយកមកពិនិត្យនិងពិភាក្សាគ្នា ហើយក្រុមស្រាវជ្រាវមានតួនាទីធំធេងណាស់ក្នុងវិស័យនេះ។

## មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្ស




## ការអភិវឌ្ឍកម្មវិធីសិក្សាបច្ចុប្បន្ន

ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលនៅឧត្តម-សិក្សាឱ្យឆ្លើយតបតាមតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការពិនិត្យកែសម្រួលនិងអភិវឌ្ឍន៍កម្មវិធីសិក្សា គឺជាបញ្ហាមួយចាំបាច់។ ដោយឡែក ប្រព័ន្ធកម្មវិធីសិក្សាតាមរបៀបគិតចំនួនម៉ោងក្នុងឆមាសនិងឆ្នាំដែលគ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានសិក្សាឯកទេសនៅកម្ពុជាបានអនុវត្តដ៏យូរលង់មកនោះ គួរតែត្រូវសើរើពិនិត្យឡើងវិញដោយយកប្រព័ន្ធកម្មវិធីសិក្សា តាមរបៀបក្រេឌីតមកប្រៀបធៀប ដើម្បីស្រង់យកចំណុចល្អ និងចំណុចដែលមិនជឿនលឿនមកពិនិត្យសម្រេចចិត្ត ដើម្បីកែលម្អនិងផ្លាស់ប្តូរ។ ដើម្បីសម្រេចបាននូវទិសដៅនេះ ចំណុចមួយចំនួននៃដំណើរការបណ្តុះបណ្តាលតាមប្រព័ន្ធទាំងពីរ ដូចជាការរៀបចំកម្មវិធីសិក្សា ការប្រឡងឆមាស និងការប្រឡងបញ្ចប់ការសិក្សា និង ភាពអាចផ្ទេរការសិក្សាបានត្រូវលើកយកមកពិនិត្យ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សា។

## កម្មវិធីសិក្សាសម័យទំនើប

កម្មវិធីសិក្សាតាមC (ប្រព័ន្ធក្រេឌីត) មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងប្រព័ន្ធម៉ោងដែរ។ មុខវិជ្ជានីមួយៗក្នុងប្រព័ន្ធក្រេឌីតត្រូវសិក្សារយៈពេលមួយឆមាសពី១៤ទៅ១៦សប្តាហ៍ដូចគ្នា។ មុខវិជ្ជាណាដែលសិក្សាក្នុងថ្នាក់មួយម៉ោងក្នុងមួយសប្តាហ៍រយៈពេល១៤ទៅ១៦សប្តាហ៍ ពេលប្រឡងជាប់គេនិយាយថា និស្សិតទទួលបានមួយក្រេឌីត។ មុខវិជ្ជាណាដែលសិក្សាទ្រឹស្តី២ម៉ោងក្នុងមួយសប្តាហ៍ រយៈ-

ពេលពី១៤ទៅ១៦សប្តាហ៍ ហៅថា២ក្រេឌីត។ ៣ម៉ោងក្នុងសប្តាហ៍ហៅថា ៣ក្រេឌីត ៤ម៉ោងក្នុងមួយសប្តាហ៍ហៅថា ៤ក្រេឌីត។ មុខវិជ្ជាណាដែលសិក្សាបីម៉ោងក្នុងមួយសប្តាហ៍ពេញមួយឆមាសទី១និងបន្ត៣ម៉ោង ក្នុងមួយសប្តាហ៍ពេញមួយឆមាសទី២ទៀតហៅថា៦ក្រេឌីត។ ប្រព័ន្ធក្រេឌីតបានចែកមុខវិជ្ជានៅក្នុងកម្មវិធីសិក្សាជាបីផ្នែកគឺ៖

១- មុខវិជ្ជាសិក្សាមូលដ្ឋាន (Foundation course)

២- មុខវិជ្ជាដែលតម្រូវឱ្យនិស្សិតត្រូវតែសិក្សា (Major course)

៣-មុខវិជ្ជាដែលអនុញ្ញាតឱ្យនិស្សិតជ្រើសរើស (Elective course)

## កម្មវិធីសិក្សានិងការអនុវត្ត

មនុស្សយើងភាគច្រើនតែងតែមានគំនិតមិនចង់ធ្វើការផ្លាស់ប្តូរ។ ដូច្នេះ ដើម្បីទប់ទល់នឹងគំនិតប្រឆាំងមិនព្រមប្រែប្រួល អ្នកអភិវឌ្ឍកម្មវិធីត្រូវតែប្រើប្រាស់យុទ្ធវិធីមួយដែលហៅថាលំនាំចូលរួមទាំងអស់គ្នា (a participatory process) តាមលោក Omstein និងលោក Hunkin ព្រោះថា តាមរយៈការចូលរួមពិភាក្សាស្វែងយល់ និងសរសេរ ធ្វើឱ្យយើងកាត់បន្ថយបានមួយចំនួននូវគំនិតដែលប្រឆាំងនឹងការផ្លាស់ប្តូរខ្លឹមសារឬវិធីសាស្ត្របង្រៀន។

នៅក្នុងលំនាំអភិវឌ្ឍកម្មវិធីសិក្សា ស្ថាប័នឧត្តមសិក្សានីមួយៗត្រូវតែរៀបចំឱ្យមានសិក្ខាសាលា ដើម្បីប្រមូលផ្តុំគំនិតយុទ្ធសាស្ត្រក្នុងការតាក់តែងខ្លឹមសារតាក់តែងកិច្ចតែងការ និងការបង្រៀនសាកល្បងក្នុងក្រុមជាការចាំបាច់ ដើម្បីរួមចំណែកកែលម្អគ្នាទៅវិញទៅមកក៏ដូចជាផ្តល់បទពិសោធន៍ឱ្យគ្នាទៅវិញទៅមកដែរ។ ដូច្នេះ ការអភិវឌ្ឍកម្មវិធីសិក្សាទាមទារនូវថវិកាដើម្បីគាំទ្រដល់ការរៀបចំសិក្ខាសាលាក៏ដូចជាទាក់ទាញឱ្យគ្រូមកចូលរួមសិក្ខាសាលាផងដែរ ហើយតាមរយៈការចូលរួមនេះ គំនិតប្រឆាំងនឹងការប្រែប្រួលកម្មវិធីសិក្សាថ្មីក៏ត្រូវបានកាត់បន្ថយផងដែរ។

កម្មវិធីសិក្សាថ្មីតែងតែបញ្ចូលមេរៀនជំនាញថ្មី ដើម្បីតម្រូវទៅតាមការអភិវឌ្ឍរបស់សង្គម។ ដូច្នេះ ការរិះរកថវិកាដើម្បីបញ្ជូនសាស្ត្រាចារ្យទៅរៀននៅបរទេសជាការចាំបាច់ដើម្បីបង្កើនសមត្ថភាពបង្រៀនជំនាញថ្មី។

## វាយតម្លៃកម្មវិធីសិក្សា

អ្នកគ្រប់គ្រងសាកលវិទ្យាល័យ មហាវិទ្យាល័យត្រូវស្វែងយល់ឱ្យបានច្បាស់ថា ការបណ្តុះបណ្តាលរបស់ខ្លួនមានប្រសិទ្ធភាពកម្រិតណា។ ដូច្នេះ ការវាយតម្លៃកម្មវិធីសិក្សាជាចាំបាច់ត្រូវតែធ្វើ។ ដើម្បីវាយតម្លៃកម្មវិធី យើងត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១- ការសម្រេចគោលដៅ៖ តើនិស្សិតមានបំណិនជំនាញពិតប្រាកដឬទេ? តើនិស្សិតមានមូលដ្ឋានជំនាញអាចបន្តសិក្សាក្នុងជីវិតរបស់គេឬទេ? តើនិស្សិតយកចំណេះដឹងនិងបំណិនដែលរៀនទៅប្រើប្រាស់ក្នុងវិជ្ជាជីវៈរបស់គេឬទេ?

២- ភាពទន់ភ្លន់នៃកម្មវិធី៖ តើខ្លឹមសារកម្មវិធីឆ្លើយតបទៅនឹងតម្រូវការរបស់សង្គមរបស់អ្នករៀនដែរឬទេ?

៣- ផលចំណេញ៖

- តើនិស្សិតប្រឡងជាប់បានទទួលសញ្ញាបត្របានផលចំណេញអ្វីខ្លះសម្រាប់ខ្លួនគេ?(ចិញ្ចឹមជីវិតពិតប្រាកដ)

- តើសង្គមបានទទួលផលចំណេញអ្វីខ្លះពីនិស្សិតដែលទទួលបានសញ្ញាបត្រនេះ (ស្នាដៃសម្រាប់សង្គម)។

លទ្ធផលនៃការវាយតម្លៃជាមូលដ្ឋានគ្រឹះនៃគំនិតសម្រាប់យើងសិក្សាទុកនិងសម្រេចចិត្តទុកផ្នែកណានឹងត្រូវកែលម្អផ្នែកណា។ ដូច្នេះ ការវាយតម្លៃកម្មវិធីសិក្សាត្រូវតែធ្វើជាបន្ត។

## ការអភិវឌ្ឍកម្មវិធីសិក្សាតាមទស្សនៈគរុវិទូ

ការអភិវឌ្ឍកម្មវិធីសិក្សានិងការផ្លាស់ប្តូរកម្មវិធីសិក្សាគឺជាការងារមួយដ៏សំខាន់ស្របទៅនឹងគោលបំណងណែនាំនៃការអប់រំនិងការសិក្សាតាមរយៈដំណើរការនៃការបង្កើតកម្មវិធីសិក្សាដោយកម្មវិធីសិក្សានោះមានលក្ខណៈជាផ្លូវការនិងគ្រោងទុកយ៉ាងច្បាស់លាស់។ កម្មវិធីសិក្សាតែងតែមានការបង្កប់ ដែលមិនបានប្រាប់ឱ្យដឹងក្នុងកម្មវិធីសិក្សា (ទាំងគ្រូទាំងសិស្សមិនបានដឹងថាមានកម្មវិធីនោះទេ) និងកម្មវិធីសិក្សាទូទៅ យ៉ាងតិចក៏ត្រូវមានបួនចំណុចដែរគឺគោលបំណងខ្លឹមសារ វិធីសាស្ត្របង្រៀននិងការវាយតម្លៃដោយឆ្លងកាត់តាមការត្រួតពិនិត្យតាមដាននិងប្រឡងយ៉ាងត្រឹមត្រូវ។

លោកស្រី Hildar Taba បានពន្យល់អំពីជំហាននីមួយៗរបស់លោក Tyler ដែលដាក់ឈ្មោះថា (Taba model) នៃការអភិវឌ្ឍកម្មវិធីសិក្សារបស់គាត់ចែកជាប្រាំពីរជំហានដូចខាងក្រោម៖

- ជំហានទី១៖ ការវិនិច្ឆ័យនៃសេចក្តីត្រូវការ

- ជំហានទី២៖ ការរៀបចំវត្ថុបំណង

- ជំហានទី៣៖ ការជ្រើសរើសខ្លឹមសារ

- ជំហានទី៤៖ ការរៀបចំខ្លឹមសារ

- ជំហានទី៥៖ ការជ្រើសរើសបទពិសោធន៍សិក្សា

- ជំហានទី៦៖ ការរៀបចំបទពិសោធន៍សិក្សា

-ជំហានទី៧៖ ការសម្រេចចិត្តលើអ្វីមួយដើម្បីវាយតម្លៃលើវិធីសាស្ត្រនិងមធ្យោបាយនៃការធ្វើអ្វីមួយនោះ។

ទស្សនៈអភិវឌ្ឍកម្មវិធីសិក្សារបស់ Viviane de Lansheer។ ចំពោះលំនាំអភិវឌ្ឍកម្មវិធីសិក្សាត្រូវពិភាក្សាឱ្យមានមតិឯកភាពគ្នារវាងសៀវភៅសិក្សាការអប់រំនិងការបណ្តុះ- បណ្តាល។ គំរូអភិវឌ្ឍកម្មវិធីសិក្សានេះ គឺ ស្រាវជ្រាវផែនការកម្មវិធីពិសោធន៍សាកល្បងផ្សព្វផ្សាយវាយតម្លៃកែលម្អ។ ជាទូទៅដំណើរប្រព្រឹត្តទៅមានដូចខាងក្រោមនេះ៖

- ការកំណត់យកគោលនយោបាយអប់រំ។ គោល-បំណងកម្មវិធីសិក្សាតែងចេញពីគោលនយោបាយអប់រំជាប្រចាំ។

- ធ្វើវាយតម្លៃតម្រូវការនិងភាពទុកចិត្តបានទៅលើកម្មវិធីសិក្សា។

-ធ្វើការកំណត់គោលបំណងនិងវត្ថុបំណងនៃកម្មវិធីសិក្សា។

- ធ្វើផែនការកម្ម ផែនការបង្រៀនឱ្យបានល្អ ដើម្បីអនុវត្តកម្មវិធីសិក្សា។

-គោលដៅជាកត្តាកំណត់ឱ្យយើងពិចារណាអំពីខ្លឹម - សារសម្រាប់បង្រៀន វិធីសាស្ត្របង្រៀននិងឧបករណ៍ចាំបាច់ដែលត្រូវយកមកប្រើអំពីមធ្យោបាយវាយតម្លៃ។ ទិដ្ឋភាពទាំងនេះត្រូវមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ព្រមទាំងជួយកែលម្អគ្នាទៀតផង។

-តម្រូវការសម្រាប់ការបង្កើតការសិក្សាត្រូវពិភាក្សានិងស្រុះស្រួលគ្នា។

-តាក់តែងរចនាសម្ពន្ធកម្មវិធីរួមនិងកម្មវិធីលម្អិតលើកទី១។

-សាកល្បងក្នុងស្ថានភាពពិសោធន៍មួយចំនួនជាមួយនិស្សិតនិងគ្រូតិចតួច ពេលខ្លះសាកល្បងដោយចៃដន្យ និងពេលខ្លះទៀតសាកល្បងជាមួយក្រុមជំនាញណាមួយមិន ត្រឡប់របស់អ្នកចូលរួមនីមួយៗ ជាកម្មវត្ថុសម្រាប់វិភាគ ដើម្បីកែលម្អកម្មវិធីសិក្សាឱ្យបានកាន់តែប្រសើរឡើងជាលំដាប់។

បណ្ឌិត សម្តេច សែនផុន ប្រសើរ សិរិ ជាអ្នកឯក-ទេសអប់រំនៅអង្គការយូណេស្កូប្រចាំកម្ពុជា មានយោបល់ថាចង់បើរក្សាការពារអភិវឌ្ឍដោយចីរភាព សូមយកតម្រាប់តាមសត្វអង្រ្កង។ អង្រ្កងយកស្លឹកឈើខ្ចីៗមកធ្វើសំបុក ដែលអាចនៅជាប់បានយូរ។ រយៈពេលមួយនៅរដូវប្រាំង ដើមឈើត្រូវជ្រុះស្លឹកអស់ ប៉ុន្តែអង្រ្កងមានវិធីរក្សាស្លឹកឈើជាសំបុករបស់ខ្លួននោះឱ្យនៅគង់វង្សបាន។ ដល់ពេលមានស្លឹកខ្ចីពួកវាក៏ធ្វើសំបុកបន្តទៅទៀត នេះជាលក្ខណៈនិរន្តភាពដ៏ប្រសើរមួយបែបដែលអ្នកអភិវឌ្ឍកម្មវិធីសិក្សាគួរតែពិចារណា។

## ការអភិវឌ្ឍកម្មវិធីសិក្សានៅប្រទេសអភិវឌ្ឍ

ដោយសហរដ្ឋអាម៉េរិកជាប្រទេសជឿនលឿននៅលើពិភពលោកនេះសម្បូរទៅដោយអ្នកប្រាជ្ញនិងបច្ចេកវិទ្យាទំនើប ការរៀបចំកម្មវិធីសិក្សាដើម្បីឱ្យធនធានមនុស្សគេបានយកចិត្តទុកដាក់អប់រំមនុស្សឱ្យប្រកបដោយសមត្ថភាពគ្រប់វិស័យ។ ហេតុនេះហើយបានជាសហរដ្ឋអាម៉េរិកបានរៀបចំយ៉ាងល្អិតល្អន់ទៅលើកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សនេះជាពិសេសកម្មវិធីសិក្សាតាំងពីកម្រិតទាបបំផុតរហូតដល់កម្មវិធីសិក្សាថ្នាក់ខ្ពស់បំផុតរបស់គេដោយផ្អែកលើគំនិតដ៏ខ្ពង់ខ្ពស់បំផុតមួយ គឺចង់បាននូវមនុស្សដែលខ្លាំងជាងគេគ្រប់ផ្នែកលើសកលលោក។

នេះជាចំណុចសំខាន់របស់ស.រ.អ. ក្នុងការបង្កើតកម្មវិធីសិក្សាដើម្បីបណ្តុះបណ្តាលធនធានមនុស្ស។ សហ-រដ្ឋអាម៉េរិកគិតដល់បញ្ហាអភិវឌ្ឍកម្មវិធីសិក្សាតាមបែបប្រព័ន្ធក្រេឌីត ដែលក្នុងនោះនឹងកំពុងអនុវត្តដោយមានភាពទូទៅនិងងាយស្រួល រៀបចំទៅតាមដំណើរការខ្លះៗដែលមានមូល-ដ្ឋានដូចខាងក្រោម៖

ក្រេឌីតជាកត្តាតម្លៃមួយសម្រាប់សម្តែងអំពីបរិមា-ណនៃខ្លឹមសាររបស់មុខវិជ្ជាណាមួយដែលត្រូវបង្រៀន និងរៀនឬពិន្ទុក្រេឌីត ដែលនិស្សិតសន្សំបានប្រាប់ពីប្រឡងប្រចាំឆមាសបានជោគជ័យលើការសិក្សាមុខវិជ្ជាទាំងឡាយដោយសន្សំក្រេឌីតដើម្បីឱ្យបានចំនួនសរុបទៅតាមចំនួនកំណត់របស់ស្ថាប័នណាមួយនឹងទទួលបានវិញ្ញាបនបត្រ ឬ សញ្ញា-បត្រផ្នែកជំនាញអ្វីមួយ។

## ការអភិវឌ្ឍកម្មវិធីសិក្សាប្រទេសអាស៊ាន

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រនៃប្រទេសអាស៊ានជាទូទៅតែងតែមានសមាសភាគផ្សំបីយ៉ាងគឺ ការអប់រំទូទៅ

ការអប់រំវិជ្ជាជីវៈនិងមុខវិជ្ជាឱ្យជ្រើសរើស។ មុខវិជ្ជានៅក្នុងការអប់រំទូទៅសម្រាប់បរិញ្ញាបត្រក្នុងរយៈពេលបួនឆ្នាំមានពី ២៥ទៅ៤០% អាស្រ័យទៅតាមប្រភេទនីមួយៗ។ ចំពោះមុខវិជ្ជានៅក្នុងការអប់រំវិជ្ជាជីវៈវិញ មានប្រមាណពី៥០-៦០% សម្រាប់បរិញ្ញាបត្ររយៈពេលបួនឆ្នាំ។ ចំណែកឯមុខវិជ្ជាឱ្យជ្រើសរើសវិញ គឺផ្ដល់ឱ្យនិស្សិតជ្រើសរើសនូវមុខវិជ្ជាដែលគេចូលចិត្តដោយខ្លួនឯងតាមលទ្ធភាពផ្ដល់ឱ្យសាកលវិទ្យាល័យ សមាសភាគនៃមុខវិជ្ជាដែលដាក់ឱ្យជ្រើសរើសនោះ អាស្រ័យទៅតាមសមត្ថភាពដែលអាចផ្ដល់បានរបស់គ្រឹះស្ថានឧត្ដមសិក្សានីមួយៗឬសាកលវិទ្យាល័យ។ ម៉្យាងវិញទៀត នៅមានគ្រឹះស្ថានមួយចំនួនទៀតក្រៅពីនេះ តម្រូវឱ្យនិស្សិតរៀបចំគម្រោងស្រាវជ្រាវឬនិក្ខេបបទបញ្ចប់ការសិក្សា។ ភាគរយនៃមុខវិជ្ជាឱ្យជ្រើសរើសនិងរៀបចំគម្រោងស្រាវជ្រាវឬភាគរយដែលនៅសល់ពីសមាសភាគផ្សំទាំងពីរដំបូងខាងលើ គឺការអប់រំទូទៅនិងការអប់រំវិជ្ជាជីវៈ។

## កត្តាមានឥទ្ធិពលលើកម្មវិធីសិក្សា

បណ្ដាកត្តាទាក់ទងដល់ការបង្កើតអភិវឌ្ឍកម្មវិធីសិក្សានិងអ្នកអភិវឌ្ឍកម្មវិធីសិក្សាត្រូវគិតទៅដល់ផ្នែកលើលក្ខណៈពិសេសទាំងឡាយដូចមានបញ្ជាក់នៅក្នុងតារាងគំនូសបំព្រួញខាងក្រោម៖




កម្រិតនៃកម្លាំងសង្គមដែលមានឥទ្ធិពលលើកម្មវិធីសិក្សា

(Parkey, F.W., 2000)

## គន្ថនិទ្ទេស


- ក្រសួងអប់រំ យុវជន និងកីឡា សេចក្ដីណែនាំអំពីការរៀបចំកម្មវិធីសិក្សាប្រតិបត្តិគរុកោសល្យឱ្យដល់គរុនិស្សិតមធ្យមសិក្សាទុតិយភូមិបណ្ដុះបណ្ដាលនៅមហាវិទ្យាល័យគរុកោសល្យគរុនិស្សិត ជាអតីតនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ៦២១ អយក។ ចុះថ្ងៃទី៣០ មករា ២០០២។
- ក្រសួងអប់រំ យុវជន និងកីឡា សន្និបាតបូកសរុបការងារអប់រំយុវជននិងកីឡា ឆ្នាំ២០១០-២០១១។
- ក្រសួងអប់រំយុវជននិងកីឡាកម្មវិធីសិក្សាវិទ្យាសាស្ត្រ កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្មវិធីសិក្សានិងសៀវភៅសិក្សាឆ្នាំ១៩៩៩។
- **ខ្លូត ធីតា** ព្រះពុទ្ធសាសនានិងការអភិវឌ្ឍ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៨។
- **ចាន់ រដ្ឋសុផា** ការបំផុសគំនិតនិស្សិតឱ្យចង់រៀនមហាវិទ្យាល័យគរុកោសល្យ ឆ្នាំ២០០០។
- **នូ ចាន់សុភី** ឪដាក់ទិកនិងកម្មវិធីសិក្សានៅរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២។
- **នេត បារ៉ុម** កម្មវិធីសិក្សានៃបណ្ដាប្រទេសអាស៊ានករណីអប់រំព្រះពុទ្ធសាសនា នៅកម្រិតឧត្ដមសិក្សានៅក្នុងសិក្ខាសាលា ស្ដីពីការអភិវឌ្ឍកម្មវិធីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ថ្ងៃទី០៦-០៧ កុម្ភៈ ឆ្នាំ២០០២។
- **អ៊ឹម កុច** ទ្រឹស្ដីរបស់ចិត្តវិទូមនុស្សនិយមនិងគោលវិធីសាស្ត្រនិស្សិតមជ្ឈមណ្ឌលមហាវិទ្យាល័យគរុកោសល្យ ឆ្នាំ២០០១។
- **អ៊ឹម កុច** ការអប់រំនិងការអភិវឌ្ឍកម្មវិធីសិក្សាវិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០០៩។
- **អ៊ឹម កុច** ការអភិវឌ្ឍកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការធានាគុណភាពអប់រំនៅឧត្ដមសិក្សា មហាវិទ្យាល័យគរុកោសល្យ ២០០៨។
- MoEYS, The Curriculum Structure, RUPP, 2001
- Sloper (David) Higher Education in Cambodia, UNESCO, 1999
- Richard (D. Kellough)/Noreen (G. Kellough), A Guide to Methods and Resource

Planning for Competence, 1999

- Braydy (Laurie) Curriculum Development, 1992
- Lansheer (Viviane De), L´éducation et la Formation, Paris, Presses Universitaires de France, 1992

© ២០១២ រាជបណ្ឌិត្យសភាកម្ពុជា
ចំនួន ១០០០ ច្បាប់
រក្សាសិទ្ធិ គ្មានផ្នែកណាមួយនឹងត្រូវបានបោះពុម្ពឡើងវិញដោយគ្មានការអនុញ្ញាតិ
ជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ

---

© 2012 Royal Academy of Cambodia
No. 1000 copies
All rights reserved. No part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.



ប្រាសាទ អង្គរវត្ត


**Royal Academy of Cambodia Review**

Russian Federation Blvd

P.O Box: 531, Phnom Penh

Kingdom of Cambodia

Tel: (855) 23 640 66 22

Fax: (855) 23 890 180

E-mail: magazinerac@yahoo.com

Website: www.rac-academy.edu.com

**រាជបណ្ឌិត្យសភាកម្ពុជា**

មហាវិថីសហព័ន្ធរុស្ស៊ី

ប្រអប់សំបុត្រលេខ: ៥៣១ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៤០ ៦៦ ២២

ទូរសារលេខ: (៨៥៥) ២៣ ៨៩០ ១៨០

អ៊ីម៉ែល / សារអេឡិចត្រូនិច: magazinerac@yahoo.com

គេហទំព័រ: www.rac-academy.edu.com